# ព្រះរាជក្រម

នស/រកម/០១០២/០០៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល-កម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូមស្តីពី តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យ ប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូម
# ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

មាត្រា ១.-

អនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលធ្វើនៅទីក្រុងរ៉ូមប្រទេសអ៊ីតាលី នាថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលក្ខន្តិកៈទីក្រុងរ៉ូមនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករាឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

នស. ០១.០២.០០០៦

ជា ស៊ីម

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា

សុខ អាន

លេខ : ០៩ ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

- លក្ខន្តិកៈនៃក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ
- Rome Statute of the International Criminal Court
- Statut de Rome de la Cour Pénale Internationale

# ច្បាប់លក្ខន្តិកៈនៃក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

## បុព្វកថា

ដោយមានមនសិការថា មនុស្សទាំងអស់បានរួបរួមគ្នាជាធ្លុងមួយ វប្បធម៌របស់មនុស្សបានចូលរួមផ្សំគ្នានៅក្នុងកេរ្តិ៍ដំណែលរួម និងដោយមានការព្រួយបារម្ភថា បណ្តុំនៃរូបគំនូរតូចៗដែលមិនមានលក្ខណៈមាំមួននេះ អាចនឹងត្រូវបានបំបែកចេញពីគ្នានៅពេលណាមួយ ។

ដោយយកចិត្តទុកដាក់ថា ក្នុងកំឡុងពេលនៃសតវត្សនេះ កុមារ ស្ត្រី និង បុរស រាប់លាននាក់បានរងគ្រោះ ដោយសារអំពើឃោរឃៅដែលមិនអាចស្មានដល់ ដែលធ្វើឱ្យមនសិការរបស់មនុស្សជាតិមានការតក់ស្លុតយ៉ាងខ្លាំង ។

ដោយទទួលស្គាល់ថា បទល្មើសព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរទាំងឡាយគំរាមកំហែងដល់សន្តិភាព សន្តិសុខ និងសុខមាលភាពពិភពលោក ។

ដោយមានការអះអាងថា បទល្មើសព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរបំផុតធ្វើឱ្យមានការព្រួយបារម្ភដល់សហគមអន្តរជាតិទាំងមូល មិនត្រូវរួចផុតពីការដាក់ទណ្ឌកម្ម និង ត្រូវតែធ្វើឱ្យប្រាកដថាមានការនាំយកមកជំនុំជំរះដែលមានប្រសិទ្ធភាព តាមរយៈការចាត់វិធានការនៅថ្នាក់ជាតិ និង តាមរយៈការធ្វើឱ្យកិច្ចសហប្រតិបត្តិការអន្តរជាតិ កាន់តែបានប្រសើរឡើង ។

ដោយមានការប្តេជ្ញាចិត្ត បញ្ចប់និរទណ្ឌភាពចំពោះជនដៃដល់ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទាំងនោះ ហើយដូច្នេះ រួមចំណែកទប់ស្កាត់នូវបទល្មើសព្រហ្មទណ្ឌទាំងនេះ ។

ដោយចងចាំថា នេះជាភារកិច្ចរបស់រដ្ឋនីមួយៗក្នុងការអនុវត្តន៍យុត្តាធិការព្រហ្មទណ្ឌរបស់ខ្លួនលើអ្នកទាំងឡាយដែលទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌអន្តរជាតិទាំងនោះ ។

ដោយមានការបញ្ជាក់អះអាងឡើងវិញពីគោលបំណង និង គោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និង ជាពិសេស រដ្ឋទាំងអស់ត្រូវទប់ខ្លួនពីការធ្វើការគំរាមកំហែង ឬពីការប្រើប្រាស់កម្លាំងប្រឆាំងទល់នឹងបូរណភាពដែនដី ឬ ឯករាជ្យភាពខាងនយោបាយរបស់រដ្ឋណាមួយ ឬក្នុងកិរិយាបទណាផ្សេងទៀត ដែលមិនស្របទៅ នឹងគោលបំណងរបស់អង្គការសហប្រជាជាតិ ។

ដោយការសង្កត់ធ្ងន់ក្នុងទំនាក់ទំនងនេះថា គ្មានអ្វីមួយនៅក្នុងច្បាប់លក្ខន្តិកៈនេះ ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យរដ្ឋភាគីណាមួយចូលទៅធ្វើអន្តរាគមក្នុងជម្លោះប្រដាប់អាវុធ នៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋណាមួយឡើយ ។

ដោយមានការប្តេជ្ញាចិត្តបញ្ចប់អំពើទាំងនេះ និង សម្រាប់ជាគុណប្រយោជន៍ដល់ជនតាបច្ចុប្បន្ន និង អនាគត បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ឯករាជ្យមួយ ដែលមានទំនាក់ទំនងជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ ដែលមានយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុត ដែលសហគមអន្តរជាតិទាំងមូលមានការព្រួយបារម្ភ ។ ដោយមានការសង្កត់ធ្ងន់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានបង្កើតឡើងតាមច្បាប់លក្ខន្តិកៈនេះ ត្រូវជាការបន្ថែមលើ យុត្តាធិការព្រហ្មទណ្ឌជាតិ។ បានសម្រេចចិត្តធានាការគោរពជារៀងរហូតតាមការដាក់ឱ្យអនុវត្តន៍នូវយុត្តិធម៌អន្តរជាតិ ។

បានព្រមព្រៀងគ្នាដូចតទៅនេះ :

## **ភាគទី ១ : ការបង្កើតតុលាការ**

### មាត្រា ១ : អំពីតុលាការ

តុលាការព្រហ្មទណ្ឌអន្តរជាតិ("**តុលាការ**") ត្រូវបានបង្កើតឡើងតាមរយៈច្បាប់លក្ខន្តិកៈនេះ។ តុលាការនេះ ជាស្ថាប័នអចិន្ត្រៃយ៍ ហើយត្រូវមានអំណាចអនុវត្តយុត្តាធិការរបស់ខ្លួនលើជនទាំងឡាយដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុតដែលជាការព្រួយបារម្ភរបស់អន្តរជាតិ ដូចមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ និង ត្រូវជាការបន្ថែមលើយុត្តាធិការព្រហ្មទណ្ឌជាតិ។ យុត្តាធិការ និង ការប្រព្រឹត្តទៅរបស់តុលាការត្រូវគ្រប់គ្រងដោយបទបញ្ញត្តិទាំងឡាយនៃ ច្បាប់លក្ខន្តិកៈនេះ ។

### មាត្រា ២ : អំពីទំនាក់ទំនងរបស់តុលាការជាមួយនឹងអង្គការសហប្រជាជាតិ

តុលាការត្រូវមានទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិ តាមរយៈកិច្ចព្រមព្រៀងដែលត្រូវអនុម័តយល់ព្រម ដោយសន្និបាតនៃរដ្ឋភាគីទាំងឡាយនៃច្បាប់លក្ខន្តិកៈនេះ ហើយបន្ទាប់មកត្រូវចាត់ចែងដោយប្រធានតុលាការក្នុងនាមតុលាការ ។

### មាត្រា ៣ : អំពីអាសនៈតុលាការ

១. អាសនៈតុលាការត្រូវបង្កើតនៅទីក្រុងហាក នៅក្នុងប្រទេសហូឡង់ (រដ្ឋម្ចាស់ផ្ទះ) ។

២. តុលាការត្រូវធ្វើកិច្ចព្រមព្រៀងទីបញ្ជាការ ជាមួយរដ្ឋម្ចាស់ផ្ទះ ដើម្បីបានទទួលការអនុម័តយល់ព្រម ពីសន្និបាតនៃរដ្ឋភាគីទាំងឡាយ ហើយបន្ទាប់មក ត្រូវចាត់ចែងដោយប្រធានតុលាការក្នុងនាមតុលាការ ។

៣. តុលាការអាចប្រព្រឹត្តទៅនៅកន្លែងផ្សេងទៀតបាន នៅពេលណាខ្លួនពិចារណាឃើញថា វាជាការប្រាថ្នាចង់បាន ដូចដែលមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ ។

### មាត្រា ៤ : អំពីឋានៈ និង អំណាចផ្លូវច្បាប់របស់តុលាការ

១. តុលាការ ត្រូវមានចរិកលក្ខណៈនីតិបុគ្គលភាពអន្តរជាតិ។ តុលាការ ក៏ត្រូវមានសមត្ថភាពផ្លូវច្បាប់ តាមការចាំបាច់សម្រាប់ការអនុវត្តន៍មុខងាររបស់ខ្លួន និង ការបំពេញគោលបំណងរបស់ខ្លួនផងដែរ ។

២. តុលាការអាចអនុវត្តមុខងារ និង អំណាចរបស់ខ្លួន ដូចមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ នៅលើដែនដីនៃរដ្ឋភាគីណាមួយ ហើយតាមរយៈកិច្ចព្រមព្រៀងពិសេស នៅលើដែនដីនៃរដ្ឋដទៃទៀតបាន ។

## ភាគទី ២ : យុត្តាធិការ ភាពអាចទទួលយកបាន និង ច្បាប់ដែលយកមកអនុវត្ត

### មាត្រា ៥ : អំពីបទល្មើសព្រហ្មទណ្ឌស្ថិតក្នុងយុត្តាធិការតុលាការ

១. យុត្តាធិការតុលាការត្រូវបានកំរិតដែនកំណត់ចំពោះបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុតដែលធ្វើឱ្យមានការព្រួយបារម្ភដល់សហគមអន្តរជាតិទាំងមូល។ តុលាការមានយុត្តាធិការអនុលោមតាមច្បាប់លក្ខន្តិកៈនេះ ចំពោះ បទល្មើសព្រហ្មទណ្ឌ ដូចតទៅនេះ :

(ក) បទល្មើសព្រហ្មទណ្ឌប្រល័យពូជសាសន៍

(ខ) បទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងមនុស្សជាតិ

(គ) បទល្មើសព្រហ្មទណ្ឌសង្គ្រាម

(ឃ) បទល្មើសព្រហ្មទណ្ឌនៃការឈ្លានពាន

២. តុលាការត្រូវអនុវត្តយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌនៃការឈ្លានពាន បន្ទាប់ពីបទបញ្ញត្តិមួយត្រូវបានអនុម័តឡើង អនុលោមទៅតាមមាត្រា ១២១ និង ១២៣ ដែលកំណត់និយមន័យបទល្មើសព្រហ្មទណ្ឌ

នោះនិងបានដាក់ចេញនូវលក្ខខ័ណ្ឌដែលតុលាការត្រូវតែអនុវត្តយុត្តាធិការចំពោះបទល្មើសព្រហ្មទណ្ឌនេះ ។ បទបញ្ញត្តិនេះត្រូវស្របជាមួយនឹងបទបញ្ញត្តិពាក់ព័ន្ធដទៃទៀតនៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។

## មាត្រា ៦ : អំពីការប្រល័យពូជសាសន៍

សម្រាប់គោលបំណងនៃច្បាប់លក្ខន្តិកៈនេះ ពាក្យ "ប្រល័យពូជសាសន៍" មានន័យថា អំពើណាមួយដូចខាងក្រោមនេះ ដែលបានប្រព្រឹត្តឡើងដោយមានចេតនាបំផ្លិចបំផ្លាញ ទោះបីទាំងមូលក្តីឬផ្នែកខ្លះក្តី នូវក្រុមជាតិសាសន៍ ក្រុមជាតិពន្ធ ក្រុមពូជសាសន៍ ឬក្រុមសាសនាជាអាទិ៍ :

(ក) ការសម្លាប់សមាជិកទាំងឡាយនៃក្រុមនោះ

(ខ) ការបង្ករឱ្យមានការរងគ្រោះថ្នាក់ដល់រូបកាយ ឬ ដល់បញ្ញាស្មារតីយ៉ាងធ្ងន់ធ្ងរចំពោះសមាជិកទាំងឡាយនៃក្រុមនោះ

(គ) ការដាក់ដោយផ្ចិតផ្ចង់នូវលក្ខខ័ណ្ឌជីវិតដល់ក្រុមនោះ ក្នុងគំរិតមួយដែលប្រុងនឹងនាំដល់ការបំផ្លិចបំផ្លាញជាក់ស្តែងនូវក្រុមនោះ ទោះបីទាំងមូលក្តី ឬផ្នែកខ្លះក្តី

(ឃ) ការដាក់ចេញវិធានការដោយមានចេតនាទប់ស្កាត់ការចាប់កំណើតនៅក្នុងក្រុមនោះ

(ង) ការផ្លាស់ទីកុមារពីក្រុមមួយទៅក្រុមមួយទៀតដោយបង្ខិតបង្ខំ

## មាត្រា ៧ : អំពីបទល្មើសព្រហ្មទណ្ឌប្រឆាំងមនុស្សជាតិ

១. សម្រាប់គោលបំណងនៃច្បាប់លក្ខន្តិកៈនេះ ពាក្យ "បទល្មើសប្រឆាំងមនុស្សជាតិ" មានន័យថា អំពើណាមួយដូចតទៅនេះ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារដ៏សុះសាយឬដែលមានលក្ខណៈជាប្រព័ន្ធមួយ ដោយផ្ទាល់ប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាម្នាក់ ដោយមានការដឹងពីការវាយប្រហារនោះ :

(ក) ឃាតកម្ម

(ខ) ការធ្វើឱ្យសាបសូន្យ

(គ) ការដាក់មនុស្សឱ្យធ្វើជាទាសករ

(ឃ) ការនិរទេស ឬ ការផ្លាស់ទីប្រជាពលរដ្ឋដោយបង្ខិតបង្ខំ

(ង) ការដាក់ពន្ធនាគារ ឬ ការដកហូតសេរីភាពខាងរូបកាយ ដែលជាការបំពានលើវិធានជាមូលដ្ឋាននៃច្បាប់អន្តរជាតិ

(ច) ការធ្វើទារុណកម្ម

(ឆ) ការចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយការដាក់បង្ខំ ការមានគភ៌ដោយបង្ខំ វណ្ណកម្មដោយដាក់បង្ខំ ឬការបំពានផ្លូវភេទក្នុងទ្រង់ទ្រាយផ្សេងទៀត ដែលមានភាពធ្ងន់ធ្ងរប្រហែលគ្នានេះ ។

(ជ) ការធ្វើទុកបុកម្នេញលើក្រុម ឬលើសមូហភាពជាក់លាក់ណាមួយ លើមូលដ្ឋាននយោបាយ ពូជសាសន៍ ជាតិសាសន៍ ជាតិពន្ធ វប្បធម៌ សាសនា ភេទ ដូចបានកំណត់និយមន័យក្នុងកថាខ័ណ្ឌទី០៣ ឬ លើមូលដ្ឋានផ្សេងទៀត ដែលត្រូវបានទទួលស្គាល់ជាសាកលថា មិនអាចអនុញ្ញាតឱ្យធ្វើបានឡើយតាមច្បាប់អន្តរជាតិនៅក្នុងទំនាក់ទំនងជាមួយអំពើណាមួយដែលបានចែងក្នុងកថាខ័ណ្ឌនេះ ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលស្ថិតក្នុងយុត្តាធិការតុលាការ ។

(ឈ) ការបាត់ខ្លួនមនុស្សដោយដាក់បង្ខំ ។

(ញ) បទល្មើសព្រហ្មទណ្ឌអាប៉ាថេដ ។

(ដ) អំពើអមនុស្សធម៌ដែលមានលក្ខណៈជាអន្តរជាតិស្រដៀងគ្នាដទៃទៀត ដែលមានចេតនាបង្កឱ្យមានការរងគ្រោះដ៏ធំធេង ឬគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់រូបកាយ ឬដល់សុខភាពខាងបញ្ញាស្មារតី ឬសុខភាពខាងរូបកាយ។

២. សម្រាប់គោលបំណងនៃកថាខ័ណ្ឌទី ១

(ក) "ការវាយប្រហារប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាម្នាក់" មានន័យថា ដំណើរការនៃការប្រព្រឹត្តមួយពាក់ព័ន្ធ នឹងការប្រព្រឹត្តអំពើជាច្រើនដូចមានចែងក្នុងកថាខ័ណ្ឌទី១ ប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាម្នាក់ស្របតាម ឬ ស្ថិតក្នុង ការធ្វើឱ្យជឿនលឿនទៅមុខរបស់រដ្ឋមួយ ឬ គោលនយោបាយចាត់តាំងដើម្បីប្រព្រឹត្តការវាយប្រហារបែបនេះ ។

(ខ) "ការធ្វើឱ្យសាបសូន្យ" រួមបញ្ចូលទាំងការដាក់លក្ខខ័ណ្ឌលើជីវិតដោយចេតនា ដែលក្នុងចំណោមនោះមាន ការដកហូតសិទ្ធិទទួលបានអាហារ និង ថ្នាំពេទ្យ ក្នុងគំរិតមួយដែលប្រុងនឹងនាំដល់មានការបំផ្លិចបំផ្លាញផ្នែកមួយនៃ ប្រជាពលរដ្ឋ ។

(គ) "ការដាក់មនុស្សឱ្យធ្វើជាទាសករ" មានន័យថា ការប្រើអំណាចណាមួយ ឬអំណាចទាំងអស់ដែលមានជាប់នឹងសិទ្ធិកម្មសិទ្ធិទៅលើជនម្នាក់ និង រួមទាំងការប្រើសិទ្ធិនេះក្នុងដំណើរការជួញដូរមនុស្ស ជាពិសេស ស្ត្រី និង កុមារ ។

(ឃ) "ការនិរទេស ឬការផ្លាស់ទីពលរដ្ឋដោយបង្ខិតបង្ខំ" មានន័យថា ការផ្លាស់ទីកន្លែងរបស់ជនដែលពាក់ព័ន ដោយបង្ខំដោយការបណ្តេញ ឬដោយអំពើបង្ខិតបង្ខំផ្សេងទៀត ចេញពីតំបន់ដែលពួកគេមានវត្តមាននៅដោយស្របច្បាប់ ដោយគ្មានមូលដ្ឋានដូចបានអនុញ្ញាតក្នុងច្បាប់អន្តរជាតិ ។

(ង) "ទារុណកម្ម" មានន័យថា ការធ្វើឱ្យមានការចុកចាប់ ឬការរងគ្រោះជាទំងន់ដោយចេតនា ទោះជាដល់រូបកាយក្តី ឬដល់បញ្ញាស្មារតីក្តី ទៅលើជនដែលនៅក្នុងការឃុំឃាំង ឬក្រោមការត្រួតត្រារបស់ជនជាប់ចោទ លើកលែងតែចំពោះករណីទារុណកម្ម គេមិនត្រូវរាប់បញ្ចូលការចុកចាប់ ឬការរងគ្រោះដែលកើតចេញតែពីការដាក់ទណ្ឌកម្មស្របច្បាប់ដែលមានជាប់នឹងអំពើនោះ ឬដែលមានជាយថាហេតុទេ ។

(ច) "ការមានគភ៌ដោយបង្ខំ" មានន័យថា ការបង្ខាំងដោយខុសច្បាប់នូវស្ត្រីដែលត្រូវធ្វើឱ្យមានគភ៌ដោយបង្ខំ ដោយមានចេតនាចង់ឱ្យមានការប៉ះពាល់ដល់សមាសភាពជាតិពន្ធនៃពលរដ្ឋណាមួយ ឬការអនុវត្តនូវការបំពានដ៏ធ្ងន់ធ្ងរ ដទៃទៀតលើច្បាប់អន្តរជាតិ ។ ក្នុងករណីណាក៏ដោយ មិនត្រូវយកនិយមន័យនេះ ទៅបកស្រាយឱ្យមានឥទ្ធិពលលើច្បាប់ជាតិពាក់ព័ន្ធនឹងដំណើរការមានគភ៌ឡើយ ។

(ឆ) "ការធ្វើទុក្ខបុកម្នេញ" មានន័យថា ការដកហូតសិទ្ធិជាមូលដ្ឋានដោយចេតនា និង យ៉ាងធ្ងន់ធ្ងរដែលផ្ទុយនឹងច្បាប់អន្តរជាតិ ដោយមូលហេតុនៃអត្តសញ្ញាណ នៃក្រុម ឬ សមូហភាព ។

(ជ) "បទល្មើសព្រហ្មទណ្ឌអាផាថេដ" មានន័យថា អំពើអមនុស្សធម៌ដែលមានចរិតលក្ខណៈស្រដៀងគ្នាទៅនឹង អំពើទាំងឡាយដែលពោលនៅក្នុងកថាខ័ណ្ឌទី ១ ដែលបានប្រព្រឹត្តក្នុងបរិបទនៃរបបគ្រប់គ្រងជាស្ថាប័ននៃការសង្កត់សង្កិនជាលក្ខណៈប្រព័ន្ធ និង ការគ្របសង្កត់របស់ក្រុមពូជសាសន៍មួយ ទៅលើក្រុមពូជសាសន៍មួយ ឬច្រើនដទៃទៀត ហើយ ដែលបានប្រព្រឹត្តក្នុងចេតនារក្សាទុករបបនោះ ។

(ឈ) "ការបាត់ខ្លួនមនុស្សដោយបង្ខំ" មានន័យថា ការចាប់ខ្លួន ការឃុំឃាំង ឬ ការចាប់ពង្រត់មនុស្សដោយមានការអនុញ្ញាត ការគាំទ្រ ឬ ការយល់ព្រមរបស់រដ្ឋ ឬ អង្គការនយោបាយ បន្ទាប់មកមានការបដិសេធ មិនទទួលដឹងឮពីការដកហូតសេរីភាពនោះ ឬមិនផ្តល់ពត៌មានអំពីជោគវាសនា ឬទីសំចតនៃជនទាំងនោះ ដោយមានចេតនាដកពួកគេចេញពីការការពារតាមផ្លូវច្បាប់ក្នុងរយៈពេលពន្យាយូរមួយ ។

៣. សម្រាប់គោលបំណងនៃច្បាប់លក្ខន្តិកៈនេះ ពាក្យ "ជែនឌ័រ" ត្រូវបានយល់ថា សំដៅលើភេទទាំងពីរ បុរស និង ស្ត្រី នៅក្នុងបរិបទនៃសង្គម ។ ពាក្យ "ជែនឌ័រ" មិនបានបង្ហាញអត្ថន័យណាមួយផ្សេងពីខាងដើមនេះទេ។

## មាត្រា ៨ : អំពីបទល្មើសព្រហ្មទណ្ឌសង្គ្រាម

១. តុលាការត្រូវមានយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌសង្គ្រាម ជាពិសេស នៅពេលដែលអំពើនោះបានប្រព្រឹត្តឡើង ជាផ្នែកមួយនៃផែនការ ឬនយោបាយ ឬជាផ្នែកមួយនៃការប្រព្រឹត្តក្នុងទំហំដ៏ធំធេងនៃបទល្មើសព្រហ្មទណ្ឌបែបនេះ ។

២. សម្រាប់គោលបំណងនៃច្បាប់លក្ខន្តិកៈនេះ "បទល្មើសព្រហ្មទណ្ឌសង្គ្រាម" មានន័យថា :

(ក) ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងស៊ីណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ នូវអំពើប្រឆាំងនឹងមនុស្ស ឬ ទ្រព្យសម្បត្តិដែលត្រូវការពារតាមបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញាទីក្រុងស៊ីណែវដែលទាក់ទង ដែលមានរាយឈ្មោះដូចតទៅនេះ :

(i) ការសម្លាប់ដោយចេតនា

(ii) ទារុណកម្ម ឬការប្រព្រឹត្តអំពើអមនុស្សធម៌ រួមទាំងការពិសោធន៍ជីវសាស្ត្រ

(iii) ការបង្កការរងគ្រោះយ៉ាងធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ដល់រូបកាយឬសុខភាពយ៉ាងធ្ងន់ធ្ងរដោយចេតនា

(iv) ការបំផ្លិចបំផ្លាញ និង ការដកហូតយកទ្រព្យសម្បត្តិដ៏ធំធេងដែលមិនមែនធ្វើឡើងដោយមកពីមានមូលហេតុនៃភាពចាំបាច់ខាងយោធា និង ធ្វើឡើងដោយខុសច្បាប់ និងដោយព្រៃផ្សៃ

(v) ការបង្ខំអ្នកទោសឈ្លើយសង្គ្រាម ឬជនដែលត្រូវការពារដទៃទៀត ឱ្យបំរើការក្នុងកងកម្លាំងរបស់សត្រូវ

(vi) ការដកហូតសិទ្ធិរបស់អ្នកទោសឈ្លើយសង្គ្រាម និង ជនដែលត្រូវការពារដទៃទៀតដោយចេតនា ពីការជំនុំជំរះទោសត្រឹមត្រូវ និង តាមប្រក្រតី

(vii) ការនិរទេសដោយខុសច្បាប់ ឬ ការបញ្ជូនផ្លាស់ទីដោយខុសច្បាប់ ឬការបង្ខាំងមនុស្សដោយខុសច្បាប់

(viii) ការចាប់មនុស្សធ្វើជាចំណាប់ខ្មាំង

(ខ) ការបំពានលើច្បាប់និងទំនៀមទម្លាប់ដ៏ធ្ងន់ធ្ងរដទៃទៀត ដែលអាចអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ នៅក្នុងគំរោងដែលបានបង្កើតឡើងតាមច្បាប់អន្តរជាតិនូវអំពើណាមួយដូចមានរាយឈ្មោះតទៅនេះ :

(i) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិល ឬប្រឆាំងនឹងឯកត្តជនស៊ីវិលដែលមិនចូលរួមដោយផ្ទាល់នៅក្នុងការប្រទូសរាយគ្នានោះទេ ។

(ii) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងវត្ថុស៊ីវិល ដែលនោះជាវត្ថុដែលមិនមែនជាចំណុចគោលដៅខាងយោធាទេ ។

(iii) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹង មន្ត្រី បុគ្គលិកទីតាំង សម្ភារៈ អង្គភាព ឬយានជំនិះ ពាក់ព័ន្ធនឹងជំនួយមនុស្សធម៌ ឬបេសកកម្មរក្សាសន្តិភាព អនុលោមតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ដរាបណាពួកគេមានសិទ្ធិចំពោះការការពារដែលផ្តល់ឱ្យដល់ជនស៊ីវិល ឬ ដល់វត្ថុស៊ីវិលតាមច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធ ។

(iv) ការបើកការវាយប្រហារដោយចេតនា ដោយដឹងថាការវាយប្រហារនេះនឹងបង្កឱ្យបាត់បង់អាយុជីវិត ឬគ្រោះថ្នាក់ដល់ជនស៊ីវិល ឬធ្វើឱ្យខូចខាតវត្ថុស៊ីវិលជាយថាហេតុ ឬការខូចខាតដ៏សុះសាយរយៈពេលវែងឆ្ងាយ និង ដ៏ធំធេងចំពោះបរិស្ថានធម្មជាតិដែលពិតជាមានលក្ខណៈហួសហេតុក្នុងទំនាក់ទំនង ទៅនឹងប្រយោជន៍យោធាទាំងមូលដោយផ្ទាល់ និង ដោយច្បាស់លាស់ ។

(v) ការវាយប្រហារ ឬ ការទម្លាក់គ្រាប់បែកតាមមធ្យោបាយណាក៏ដោយ ទៅលើទីក្រុង ភូមិ លំនៅដ្ឋាន ឬអាគារ ដែលមិនត្រូវបានការការពារ និង ដែលមិនមែនជាចំណុចគោលដៅយោធា ។

(vi) ការសម្លាប់ ឬការធ្វើឱ្យរបួសដល់យុទ្ធជនដែលបានទម្លាក់អាវុធរបស់ខ្លួនចុះ ឬ ជនដែលគ្មានមធ្យោបាយការពារខ្លួនតទៅទៀត ដែលបានចុះចាញ់ព្រមតាមខ្លួន ។

(vii) ធ្វើការប្រើប្រាស់មិនសមស្របនូវទង់ផ្ទាកសង្គ្រាម ទង់ជាតិ សញ្ញាសំគាល់យោធា និងឯកសណ្ឋានសត្រូវ ឬ ឯកសណ្ឋានរបស់អង្គការសហប្រជាជាតិ ក៏ដូចជានិមិត្តសញ្ញាដោយឡែកៗនៃអនុសញ្ញាទីក្រុងសឺណែវ ដែលបណ្តាលឱ្យមានការស្លាប់ ឬ គ្រោះថ្នាក់ដល់មនុស្សយ៉ាងធ្ងន់ធ្ងរ ។

(viii) ការបញ្ជូនផ្លាស់ទីកន្លែងដោយផ្ទាល់ ឬដោយប្រយោល នូវកម្លាំងដែលកំពុងកាន់កាប់ ផ្នែកខ្លះនៃពលរដ្ឋស៊ីវិលរបស់ខ្លួនផ្ទាល់ ចូលទៅក្នុងទឹកដីដែលខ្លួនចូលកាន់កាប់ ឬការនិរទេស ឬការបញ្ជូនផ្លាស់ទីពលរដ្ឋខ្លះ ឬទាំងអស់នៃទឹកដីដែលបានចូលកាន់កាប់ទៅក្នុងទឹកដីនោះ ឬ ចេញក្រៅទឹកដីនោះ ។

(ix) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអាគារ ដែលបានសង់ឡើង សម្រាប់គោលបំណងសាសនា ការអប់រំ សិល្បៈ វិទ្យាសាស្ត្រ ឬគោលបំណងសប្បុរសធម៌ វិមានប្រវត្តិសាស្ត្រ មន្ទីរពេទ្យ និង ទីកន្លែងទាំងឡាយដែលអ្នកជំងឺ និង អ្នករងរបួសប្រមូលផ្តុំនៅ ដោយកន្លែងទាំងនេះមិនមែនជាចំណុចគោលដៅយោធាទេ ។

(x) ការដាក់ជនទាំងឡាយដែលឋិតក្នុងអំណាចរបស់គូបដិបក្សឱ្យរងការធ្វើកាយវិកលកម្ម ឬ ការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬខាងវិទ្យាសាស្ត្រប្រភេទណាមួយ ដែលមិនធ្វើយុត្តិកម្មដោយការព្យាបាលខាងវេជ្ជសាស្ត្រ ទន្តសាស្ត្រ ឬការដេកពេទ្យ ដល់ជនពាក់ព័ន្ធនោះទេ ឬដែលមិន ធ្វើឡើងដើម្បីជាប្រយោជន៍របស់ជននោះ និង ដែលបណ្តាលឱ្យជននោះស្លាប់ ឬធ្វើឱ្យជននោះ រងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់សុខភាព ។

(xi) ការសម្លាប់ ឬ ការធ្វើឱ្យរបួសដោយចិត្តក្បត់ដល់ជនទាំងឡាយដែលជាមនុស្សរបស់ប្រទេស ឬរបស់យោធាបច្ចាមិត្ត ។

(xii) ការប្រកាសថានឹងមិនផ្តល់ការត្រាប្រណីណាមួយឡើយ ។

(xiii) ការបំផ្លាញ ឬ ការរឹបអូសយកទ្រព្យសម្បត្តិរបស់សត្រូវ លើកលែងតែការបំផ្លាញនោះ ឬ ការរឹបអូសយកនោះត្រូវទាមទារបញ្ជាឱ្យធ្វើដោយសារភាពចាំបាច់នៃសង្គ្រាម ។

(xiv) ការប្រកាសលុបចោល ពន្យា ឬ មិនទទួលយកនៅក្នុងតុលាការនៃច្បាប់ (court of law)នូវសិទ្ធិ និង សកម្មភាពទាំងឡាយរបស់ពលរដ្ឋនៃភាគីបច្ចាមិត្ត ។

(xv) ការបង្ខំឱ្យពលរដ្ឋនៃភាគីបច្ចាមិត្តចូលរួមក្នុងប្រតិបត្តិការសឹកសង្គ្រាមដឹកនាំធ្វើឡើងប្រឆាំងនឹងប្រទេសរបស់ពួកគេផ្ទាល់ ទោះបីជាពួកគេបានបំរើការប្រទូសរាយ មុនការចាប់ផ្តើមសង្គ្រាមក៏ដោយ ។

(xvi) ការចូលលួចប្លន់ទីក្រុង ឬ ទីកន្លែងណាមួយ ទោះបីធ្វើឡើងដោយការវាយតប់ក៏ដោយ

(xvii) ការប្រើប្រាស់ជាតិពុល ឬ អាវុធជាតិពុល ។

(xviii) ការប្រើប្រាស់ឧស្ម័នស្ទះដង្ហើម ឧស្ម័នពុល ឬ ឧស្ម័នដទៃទៀត និង ថ្នាំទឹក ឧបករណ៍ ឬ គ្រឿងស្រដៀងគ្នានេះដទៃទៀត ។

(xix) ការប្រើប្រាស់គ្រាប់កាំភ្លើងដែលអាចរីក ឬ ផ្ទុះបែកនៅក្នុងខ្លួនមនុស្សបានយ៉ាងងាយ ដូចជា គ្រាប់កាំភ្លើងដែលមានស្រទាប់ស្រោបពីក្រៅយ៉ាងរឹងមាំតែមិនមានស្រោបគ្រង់បណ្តូលវាទាំងមូលទេ ឬដែលមានច្រៀកដោយស្នាមវះ ។

(xx) ការប្រើប្រាស់អាវុធ កាំភ្លើងផ្លោង ព្រមទាំងឧបករណ៍ និង វិធីសាស្ត្រធ្វើសង្គ្រាមសឹកដែលមានលក្ខណៈបណ្តាលឱ្យរងគ្រោះថ្នាក់ដ៏លើសលប់ ឬគ្រោះថ្នាក់ដែលមិនចាំបាច់ ឬ ដែលមិនរើសមុខ យ៉ាងជាប់នៅក្នុងការបំពានច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធដោយលក្ខខ័ណ្ឌថា អាវុធ កាំភ្លើងផ្លោង ព្រមទាំងឧបករណ៍ និងវិធីសាស្ត្រធ្វើសង្គ្រាមសឹកនោះ គឺជាកម្មវត្ថុនៃការហាមឃាត់ដ៏ទូលំទូលាយមួយ ហើយត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធនៃច្បាប់លក្ខន្តិកៈនេះដោយការធ្វើវិសោធនកម្ម អនុលោមតាមបទបញ្ញត្តិពាក់ព័ន្ធដូចមានចែងក្នុងមាត្រា១២១ និង ១២៣ ។

(xxi) ការប្រព្រឹត្តអំពើយង់ឃ្នងខ្លាំងលើសេចក្តីថ្លៃថ្នូររបស់បុគ្គល ជាពិសេស ការប្រព្រឹត្តដែលធ្វើឱ្យអាម៉ាស និង បាត់បង់តម្លៃមនុស្ស ។

(xxii) ការប្រព្រឹត្តអំពើចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយដាក់បង្ខំ ការមានគភ៌ដោយបង្ខំ ដូចមានកំណត់និយមន័យនៅ កថាខ័ណ្ឌទី ២(ច) នៃមាត្រា ៧ វណ្ណកម្មដោយដាក់បង្ខំ ឬការបំពានផ្លូវភេទក្នុងទម្រង់ទ្រាយផ្សេងៗទៀត ក៏បង្កើតជាការបំពានយ៉ាងធ្ងន់ធ្ងរលើ អនុសញ្ញាទីក្រុងសឺណែវដែរ ។

(xxiii) ការប្រើប្រាស់វត្តមាននៃជនស៊ីវិល ឬជនដែលត្រូវការការពារដទៃទៀត ដើម្បីទទួលបានអភ័យឯកសិទ្ធិលើតំបន់ ឬលើកម្លាំងយោធាជាក់លាក់ដើម្បីឱ្យរួចផុតពីប្រតិបត្តិការសឹក

(xxiv) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអាគារ ឧបករណ៍ សម្ភារៈសុខាភិបាល ឧបករណ៍ដឹកជញ្ជូនវិជ្ជសាសស្ត្រ បុគ្គលិកពេទ្យ ដោយការប្រើប្រាស់និមិត្តសញ្ញាដោយឡែកៗនៃអនុសញ្ញាទីក្រុងសឺណែវ ស្របតាមច្បាប់អន្តរជាតិ ។

(xxv) ការប្រើប្រាស់ការបង្អត់អាហារឱ្យស្លាប់ដោយចេតនាដល់ជនស៊ីវិល ធ្វើជាមធ្យោបាយសឹកសង្គ្រាម ដោយការដកហូតយកពីពួកគេនូវវត្ថុដែលមានចាំបាច់សម្រាប់ការរស់នៅរបស់ពួកគេ រួមទាំងការរារាំងបង្អាក់ដោយឆន្ទៈនូវការផ្គត់ផ្គង់ជំនួយសង្គ្រោះ ដូចមានចែងក្នុងអនុសញ្ញា ទីក្រុងស៊ីណែវ ។

(xxvi) ការកេណ្ឌ ឬ ការបញ្ចូលកុមារក្រោមអាយុដប់ប្រាំឆ្នាំឱ្យចូលបំរើកងទ័ពជាតិ ឬ ប្រើប្រាស់ពួកគេឱ្យចូលរួមយ៉ាងសកម្មក្នុងការប្រទូសរាយគ្នា ។

(គ) ក្នុងករណីជម្លោះយោធាដែលមិនមានចរិកលក្ខណៈជាអន្តរជាតិមិនមានការបំពានដ៏ធ្ងន់ធ្ងរលើមាត្រាពរួមនៃអនុសញ្ញាទីក្រុងស៊ីណែវទាំងបួនចុះថ្ងៃទី១២ ខែ សីហា ឆ្នាំ ១៩៤៩ សកម្មភាពណាមួយដូចមានរាយឈ្មោះខាងក្រោមនេះ ដែលបានប្រព្រឹត្តិឡើងប្រឆាំងនឹងជនទាំងឡាយ ដែលមិនបានចូលរួមសកម្មក្នុងការប្រទូសរាយទេ រួមទាំង សមាជិកនៃពលទាហានដែលបានទម្លាក់អាវុធរបស់ខ្លួនចុះ និងអ្នកដែលឋិតនៅក្នុងទីលានប្រយុទ្ធ (Those placed hers de contract) ដោយមានជំងឺដោយមានរបួស ដោយការឃុំឃាំង ឬ ដោយមូលហេតុ ដទៃទៀត :

(i) អំពើហឹង្សាដល់ជីវិត ឬមនុស្ស ជាពិសេសអំពើមនុស្សឃាតគ្រប់ប្រភេទទាំងអស់ ការធ្វើកាយវិកល ការប្រព្រឹត្តឃោរឃៅ និង អំពើទារុណកម្ម

(ii) ការប្រព្រឹត្តអំពើយង់ឃ្នងខ្លាំងទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គល ជាពិសេស ការប្រព្រឹត្តអំពើដែលនាំឱ្យមានភាពអាម៉ាស់ និង អស់តម្លៃមនុស្ស ។

(iii) ការចាប់ធ្វើជាចំណាប់ខ្មាំង ។

(iv) ការកាត់ទោស និង ការអនុវត្តន៍ការកាត់ទោសដោយគ្មានសាលក្រមកាត់ទោស ចេញដោយតុលាការ ដែលត្រូវបានបង្កើតឡើងជាប្រក្រតីដែលផ្តល់ការធានាខាងតុលាការដែលជាទូទៅត្រូវបានទទួលស្គាល់ថា មានភាពសំខាន់ខានមិនបាន ។

(ឃ) កថាខ័ណ្ឌទី២(គ) អនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ ដូច្នេះហើយមិនអនុវត្តលើស្ថានភាពនៃការវឹកវរ និងភាពតានតឹងផ្ទៃក្នុង ដូចជាកុប្បកម្ម អំពើហឹង្សាមិនទៀងទាត់និងដាច់ឯកកោពីគេ ឬសកម្មភាពដទៃទៀត ដែលមានលក្ខណៈស្រដៀងគ្នានេះទេ ។

(ង) ការបំពានដ៏ធ្ងន់ធ្ងរដទៃទៀតលើច្បាប់ និង ទំនៀមទម្លាប់ ដែលយកមកអនុវត្តចំពោះជម្លោះប្រដាប់អាវុធ ដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់អន្តរជាតិ នូវអំពើដូចមានរាយឈ្មោះតទៅនេះ :

(i) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិលទូទៅ ឬប្រឆាំងនឹងពលរដ្ឋស៊ីវិលឯកត្តជនដែលមិនចូលរួមដោយផ្ទាល់ក្នុងការប្រទុសរាយ ។

(ii) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអាគារ ឧបករណ៍ សម្ភារៈសុខាភិបាល និង ឧបករណ៍ដឹកជញ្ជូនវេជ្ជសាស្ត្រ ព្រមទាំងបុគ្គលិកពេទ្យ ដោយប្រើប្រាស់និមិត្តសញ្ញាដោយឡែក១នៃអនុសញ្ញាទីក្រុងស៊ីណែវ តាមច្បាប់អន្តរជាតិ ។

(iii) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងមន្ត្រី ប៉ុស្តិ៍ទីតាំង ឧបករណ៍សម្ភារៈ ឬ យានជំនិះពាក់ព័ន្ធនឹងជំនួយមនុស្សធម៌ ឬបេសកកម្មរក្សាសន្តិភាព ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ដរាបណាពួកគេមានសិទ្ធិទទួលបានការការពារ ដែលមានឱ្យដល់ពលរដ្ឋស៊ីវិល ឬ វត្ថុស៊ីវិល តាមច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ ។

(iv) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអាគារ ដែលប្រើ ប្រាស់សម្រាប់គោលបំណងសាសនា ការអប់រំ សិល្បៈ វិទ្យាសាស្ត្រ ឬគោលបំណងសសប្បុ រសធម៌ វិមានប្រវត្តិសាស្ត្រ មន្ទីរពេទ្យ និង ទីកន្លែងដែលមានអ្នកជំងឺ និង អ្នករបួស ប្រមូលផ្តុំដោយទីកន្លែងនេះមិនមែនជាចំណុចគោលដៅយោធាទេ ។

(v) ការចូលលួចប្លន់ទីក្រុង ឬកន្លែងណាមួយ ទោះបីជាធ្វើឡើងដោយការវាយតប់ក៏ដោយ ។

(vi) ការប្រព្រឹត្តការចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយដាក់ បង្ខំការមានគភ៌ដោយបង្ខំ ដូចកំណត់និយមន័យនេ.ក្នុងមាត្រា៧ កថាខ័ណ្ឌទី ២(ច) វណ្ណកម្មដោយដាក់បង្ខំ និង អំពើបំពានផ្លូវភេទក្នុងទ្រង់ទ្រាយណាផ្សេងទៀត ក៏បង្កើតបាន ជាការបំពានដ៏ធ្ងន់ធ្ងរលើមាត្រា ៣រួមនៃអនុសញ្ញាទីក្រុងសឺណែវទាំងបួនដែរ ។

(vii) ការកេណ្ឌ និង បញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំ ឱ្យចូលក្នុងកម្លាំង ប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងការប្រទូសរាយ ។

(viii) ការដាក់បញ្ជាឱ្យពលរដ្ឋស៊ីវិលផ្លាស់ទីលំនៅ ដោយសាមូលហេតុពាក់ព័ន្ធនឹងជម្លោះនោះ លើកលែងតែមានការពាក់ព័ន្ធនឹងសុវត្ថិភាពនៃពលរដ្ឋស៊ីវិល ឬ មានមូលហេតុមកពីភាពចាំបាច់ខាងយោធាតម្រូវឱ្យធ្វើដូច្នោះ ។

(ix) ការសម្លាប់ ឬ ការធ្វើឱ្យរងរបួសដល់ពលទាហានដែលក្បត់ ។

(x) ការប្រកាសថា នឹងមិនផ្តល់ការត្រាប្រណីណាមួយឡើយ ។

(xi) ការដាក់ជនដែលស្ថិតនៅក្នុងអំណាចនៃភាគីមួយទៀតនៃជម្លោះឱ្យរងការធ្វើកាយវិកល ឬ ការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬ ខាងវិទ្យាសាស្ត្រប្រភេទណាមួយ ដែលមិនត្រូវធ្វើយុត្តិកម្មដោយការព្យាបាលវេជ្ជសាស្ត្រ ទន្តសាស្ត្រ ឬការដេកពេទ្យ ដល់ជនពាក់ព័ន្ធនោះទេ ដែលមិនធ្វើឡើងក្នុងប្រយោជន៍របស់ជននោះ និង ដែលបណ្តាលឱ្យជននោះស្លាប់ ឬ ធ្វើឱ្យជននោះរងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់សុខភាព ។

(xii) ការបំផ្លាញ ឬការរឹបអូសយកទ្រព្យសម្បត្តិរបស់បច្ចាមិត្ត លើកលែងតែការបំផ្លាញ ឬ ការរឹបអូសយកនោះ ត្រូវទាមទារបញ្ជាឱ្យ ធ្វើដោយសារភាពចាំបាច់នៃ ជម្លោះនោះ ។

(ច) កថាខ័ណ្ឌទី ២(ង) អនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ ដូច្នេះហើយ មិន អនុវត្តចំពោះស្ថានភាពនៃការរំខាននិងភាពតានតឹងផ្ទៃក្នុង ដូចជាកុប្បកម្ម អំពើហិង្សាម្តងម្កាលនិងដាច់ឯកកោពីគេ ឬ អំពើដទៃទៀតដែលមានលក្ខណៈស្រដៀងគ្នានេះទេ។ វាអនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលកើតឡើងក្នុងទឹកដីនៃរដ្ឋមួយ នៅពេលមានជម្លោះប្រដាប់អាវុធដែលមានការបែងចែករវាងអាជ្ញាធររដ្ឋាភិបាល និង ក្រុមប្រដាប់អាវុធដែលត្រូវបានរៀបចំឡើង ឬ រវាងក្រុមដាប់អាវុធ និង ក្រុមប្រដាប់អាវុធនានានោះ ។

៣. គ្មានអ្វីមួយក្នុងកថាខ័ណ្ឌទី២(គ)និង(ឃ) ត្រូវមានឥទ្ធិពលលើការទទួលខុសត្រូវរបស់រដ្ឋាភិបាលដើម្បីរក្សា ឬបង្កើតច្បាប់ និងសណ្តាប់ធ្នាប់នៅក្នុងរដ្ឋនោះឡើងវិញ ឬដើម្បីការពារឯកភាពជាតិ និងបូរណភាពដែនដីនៃរដ្ឋនោះ ដោយមធ្យោបាយស្របច្បាប់ទាំងអស់ឡើយ ។

## មាត្រា ៩ : អំពីធាតុនៃបទល្មើសព្រហ្មទណ្ឌ

១. ធាតុនៃបទល្មើសព្រហ្មទណ្ឌត្រូវជួយតុលាការក្នុងការបកស្រាយ និង ការអនុវត្តន៍មាត្រា ៦, ៧ និង ៨។ ធាតុទាំងនេះត្រូវអនុម័តដោយមតិភាគច្រើន២/៣នៃសមាជិកទាំងឡាយរបស់សន្និបាតនៃរដ្ឋភាគី។

២. ការធ្វើវិសោធនកម្មលើធាតុនៃបទល្មើសព្រហ្មទណ្ឌអាចស្នើឡើងដោយ :

(ក) រដ្ឋភាគីណាមួយ

(ខ) ចៅក្រមទាំងឡាយធ្វើឡើងដោយមតិភាគច្រើនដាច់ខាត

(គ) ព្រះរាជអាជ្ញា

ការធ្វើវិសោធនកម្មទាំងនោះ ត្រូវអនុម័តឡើងដោយមតិភាគច្រើនពីរភាគបីនៃសមាជិកទាំងឡាយរបស់សន្និបាតនៃរដ្ឋភាគី ។

៣. ធាតុនៃបទល្មើសព្រហ្មទណ្ឌ និង ការធ្វើវិសោធនកម្ម នៅពេលនោះត្រូវស្របនឹងច្បាប់លក្ខន្តិកៈនេះ ។

## មាត្រា ១០

គ្មានអ្វីមួយក្នុងភាគនេះត្រូវយកទៅបកស្រាយដើម្បីដាក់កំរិត ឬធ្វើឱ្យមានអគតិធម៌តាមវិធីណាមួយ ចំពោះវិធាននៃច្បាប់អន្តរជាតិដែលអាចមានជាធរមាន ឬ ដែលកំពុងអភិវឌ្ឍឡើងក្នុងគោលបំណងណាក្រៅពីច្បាប់លក្ខន្តិកៈនេះឡើយ ។

## មាត្រា ១១ : អំពីយុត្តាធិការអនាគត (Ratione Temporis)

១. តុលាការមានយុត្តាធិការតែចំពោះបទល្មើសព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តក្រោយច្បាប់លក្ខន្តិកៈនេះចូលជាធរមាន តែប៉ុណ្ណោះ ។

៣. បើរដ្ឋមួយចូលជាភាគីនៃច្បាប់លក្ខន្តិកៈនេះ បន្ទាប់ច្បាប់នេះចូលជាធរមាន ប្រទេសនោះអាចអនុវត្តយុត្តាធិការរបស់ខ្លួនតែចំពោះបទល្មើសព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តក្រោយច្បាប់លក្ខន្តិកៈនេះចូលជាធរមាន សម្រាប់រដ្ឋនោះប៉ុណ្ណោះ លើកលែងតែរដ្ឋនោះបានធ្វើសេចក្តីប្រកាសតាមកថាខ័ណ្ឌទី៣នៃមាត្រា ១២ ។

## មាត្រា ១២ : អំពីការដាក់លក្ខខ័ណ្ឌទុកជាមុនចំពោះការអនុវត្តន៍យុត្តាធិការ

១. តាមរយៈនេះ រដ្ឋដែលក្លាយជាភាគីនៃច្បាប់លក្ខន្តិកៈនេះ ទទួលយកយុត្តាធិការតុលាការចំពោះបទល្មើសព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា ៥ ។

២. ករណីដូចមានក្នុង កថាខ័ណ្ឌ(ក)ឬ(គ)នៃមាត្រា១៣ តុលាការអាចអនុវត្តយុត្តាធិការរបស់ខ្លួន បើរដ្ឋមួយ ឬច្រើន ដូចតទៅនេះជាភាគីចំពោះច្បាប់លក្ខន្តិកៈនេះ ឬបានទទួលយកយុត្តាធិការនៃតុលាការនេះ ស្របតាមកថាខ័ណ្ឌទី៣ :

(ក) រដ្ឋនៃដែនដីដែលអំពើឋិតក្នុងចំណោទបញ្ហានោះបានកើតឡើង ឬ បើបទល្មើសព្រហ្មទណ្ឌនោះបានប្រព្រឹត្តនៅលើនាវា ឬ លើយន្តហោះ នោះត្រូវជារដ្ឋដែលបានចុះបញ្ជីនាវា ឬ យន្តហោះនោះ ។

(ខ) រដ្ឋដែលជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌនោះមានសញ្ជាតិខ្លួន ។

៣. បើការទទួលយករបស់រដ្ឋមួយដែលមិនមែនជាភាគីនៃច្បាប់លក្ខន្តិកៈនេះ ដែលតម្រូវតាមកថាខ័ណ្ឌទី២ តាមរយៈ សេចក្តីប្រកាសដែលចុះបញ្ជីជាមួយនឹងក្រឡាបញ្ជី រដ្ឋនោះអាចទទួលយកការអនុវត្តន៍យុត្តាធិការដោយតុលាការចំពោះបទល្មើសព្រហ្មទណ្ឌដែលស្ថិតក្នុងចំណោទបញ្ហានោះ ។រដ្ឋដែលទទួលយកនោះត្រូវសហការជាមួយតុលាការដោយគ្មាន ការពន្យាពេល ឬគ្មានករណីលើកលែង ស្របតាមភាគទី៩ ។

## មាត្រា ១៣ : អំពីការអនុវត្តន៍យុត្តាធិការ

តុលាការ អាចអនុវត្តយុត្តាធិការរបស់ខ្លួនចំពោះបទល្មើសព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៥ អនុលោមតាម បទប្បញ្ញត្តិទាំងឡាយនៃច្បាប់លក្ខន្តិកៈនេះបើ :

(ក) ស្ថានភាពដែលបទល្មើសព្រហ្មទណ្ឌមួយឬច្រើនបង្ហាញថាត្រូវបានប្រព្រឹត្តឡើង ត្រូវបានដាក់ជូនទៅព្រះរាជអាជ្ញា ដោយរដ្ឋភាគីមួយ អនុលោមតាមមាត្រា ១៤ ។

(ខ) ស្ថានភាពដែលបទល្មើសព្រហ្មទណ្ឌមួយឬច្រើនបង្ហាញថាត្រូវបានប្រព្រឹត្តិឡើង ត្រូវបានដាក់ជូនទៅព្រះរាជអាជ្ញា ដោយក្រុមប្រឹក្សាសន្តិសុខ តាមជំពូក VII នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ឬ

(គ) ព្រះរាជអាជ្ញា បានផ្តួចផ្តើមការស៊ើបអង្កេតមួយពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌនេះ អនុលោមតាមមាត្រា ១៥ ។

## មាត្រា ១៤ : ការដាក់ជូននូវស្ថានភាពដោយរដ្ឋភាគី

១. រដ្ឋភាគីអាចដាក់ជូនព្រះរាជអាជ្ញានូវស្ថានភាពនៃបទល្មើសព្រហ្មទណ្ឌមួយឬច្រើនក្នុងដែនយុត្តាធិការតុលាការដែលបង្ហាញថាត្រូវបានប្រព្រឹត្តឡើងដើម្បីស្នើព្រះរាជអាជ្ញាឱ្យធ្វើការស៊ើបអង្កេតស្ថានភាពនោះក្នុងគោលបំណងកំណត់ថាតើជនជាក់លាក់ម្នាក់ ឬច្រើននាក់នោះ គួរត្រូវចោទប្រកាន់ពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នោះឬទេ ។

២. ការដាក់ជូននេះ ត្រូវបញ្ជាក់ស្ថានភាពពាក់ព័ន្ធទាំងឡាយឱ្យបានជាក់លាក់ តាមលទ្ធភាពដែលអាចធ្វើបាន ហើយមានភ្ជាប់ជាមួយនូវឯកសារសំអាងគាំទ្រ តាមដែលរដ្ឋដែលដាក់ជូនស្ថានភាពនោះមាន ។

## មាត្រា ១៥ : អំពីព្រះរាជអាជ្ញា

១. ព្រះរាជអាជ្ញាអាចផ្តួចផ្តើមការស៊ើបអង្កេតដោយអំណាចរបស់ខ្លួនផ្ទាល់(Proprio motu)យោងលើមូលដ្ឋាននៃពត៌មានអំពីបទល្មើសព្រហ្មទណ្ឌ ដែលស្ថិតក្នុងដែនយុត្តាធិការរបស់តុលាការ ។

២. ព្រះរាជអាជ្ញាត្រូវវិភាគលើភាពហ្មត់ចត់នៃពតិមានដែលទទួលបាន។ ក្នុងគោលបំណង នេះព្រះរាជអាជ្ញានោះ អាចស្វែងរកពតិមានបន្ថែមពីរដ្ឋនានា អង្គការចាត់តាំងទាំងឡាយនៃអង្គការសហប្រជាជាតិ អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ឬប្រភពដែលគួរឱ្យជឿបានដទៃទៀតដែលខ្លួនយល់ថាសមស្រប ហើយអាចទទួលសក្ខីកម្ម ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់នៅក្នុងអាសនៈតុលាការ ។

៣. បើព្រះរាជអាជ្ញាសន្និដ្ឋានថា មានមូលដ្ឋានសមហេតុផលដើម្បីបន្តការស៊ើបអង្កេត ខ្លួនត្រូវដាក់ជូនទៅសភាមុនការជំនុំជំរះនូវសំណើសុំធ្វើការស៊ើបអង្កេត ភ្ជាប់ជាមួយនឹងឯកសារសំអាងគាំទ្រទាំងឡាយដែលប្រមូលបាន។ ជនរងគ្រោះ អាចដាក់ជូនសេចក្តីថ្លែងការណ៍ជូនសភាមុនការជំនុំជំរះ អនុលោមតាមវិធាននៃនីតិវិធីនិងភស្តុតាង ។

៤. បើសភាមុនការជំនុំជំរះ ពេលពិនិត្យសំណើនិងឯកសារសំអាងគាំទ្រទាំងឡាយ ពិចារណាឃើញថា មានមូលដ្ឋានសមហេតុផលដើម្បីបន្តធ្វើការស៊ើបអង្កេត ហើយថាករណីនោះស្ថិតក្នុងយុត្តាធិការតុលាការនោះ ខ្លួនត្រូវអនុញ្ញាតឱ្យចាប់ផ្តើមធ្វើការស៊ើបអង្កេត ដោយគ្មានអគតិចមិចំពោះការកំណត់ជាបន្ទាប់ទៀតដោយតុលាការអំពីយុត្តាធិការ និង ភាពអាចទទួលយកបាននៃករណី ។

៥. ការបដិសេធរបស់សភាមុនការជំនុំជំរះ មិនអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត មិនត្រូវប្រានចោលជាមុននូវការដាក់បង្ហាញសំណើបន្តបន្ទាប់ទៀតដោយព្រះរាជអាជ្ញា យោងលើអង្គហេតុ ឬភស្តុតាងថ្មីចំពោះស្ថានភាពដដែលនោះឡើយ ។

៩. បើបន្ទាប់ពីការត្រួតពិនិត្យជាបឋម ដូចពោលក្នុងកថាខ័ណ្ឌទី១ និងទី២ ព្រះរាជអាជ្ញាសន្និដ្ឋានថាពតិមានដែលបានផ្តល់ឱ្យមិនបង្កើតជាមូលដ្ឋានសមហេតុផលសម្រាប់ធ្វើការស៊ើបអង្កេតទេ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់អ្នកដែលបានផ្តល់ពតិមាននោះវិញ។ ការនេះមិនត្រូវប្រានចោលជាមុនចំពោះព្រះរាជអាជ្ញាពីការពិចារណាពតិមានបន្ថែមទៀតដែលបានដាក់ជូន គាត់ទាក់ទងនឹងស្ថានភាពដដែលនូវអង្គហេតុ ឬ ភស្តុតាងថ្មីឡើយ ។

## មាត្រា ១៦ : អំពីការទុកឱ្យការស៊ើបអង្កេត ឬការនាំយកមកជំនុំជំរះ

គ្មានការស៊ើបអង្កេត ឬការនាំយកមកជំនុំជំរះណាមួយអាចចាប់ផ្តើម ឬបន្តតាមច្បាប់លក្ខន្តិកៈនេះក្នុងរយៈពេល ១២ ខែ បន្ទាប់ពីក្រុមប្រឹក្សាសន្តិសុខបានស្នើសុំឱ្យតុលាការចាត់ការដូចមានចែងក្នុងសេចក្តីសម្រេចអនុម័តឡើងតាមជំពូក VII នៃធម្មនុញ្ញអង្គការសហប្រជាជាតិបានឡើយ។ សំណើនេះអាចបន្តឡើងសាជាថ្មីដោយក្រុមប្រឹក្សានេះ តាមលក្ខខ័ណ្ឌ ដូចគ្នានេះ ។

## មាត្រា ១៧ : អំពីបញ្ហានៃភាពអាចទទួលយកបាន

១. យោងតាមកថាខ័ណ្ឌទី១០នៃបុព្វកថា និង មាត្រា១ តុលាការត្រូវកំណត់ថា ករណីមួយមិនអាចទទួលយកបាន ទេបើ :

(ក) ករណីនេះត្រូវបានស៊ើបអង្កេត ឬនាំយកមកជំនុំជំរះដោយរដ្ឋដែលមានយុត្តាធិការលើករណីនោះរួចហើយ លើកលែងតែរដ្ឋនោះគ្មានឆន្ទៈ ឬគ្មានលទ្ធភាពអនុវត្តការស៊ើបអង្កេត ឬការនាំយកមកជំនុំជំរះដោយពិតប្រាកដ ។

(ខ) ករណីនេះត្រូវបានស៊ើបអង្កេតដោយរដ្ឋដែលមានយុត្តាធិការលើករណីនោះហើយ ហើយរដ្ឋនេះបានសម្រេចមិននាំយកជនពាក់ពន្ធ័នោះមកជំនុំជំរះទេ លើកលែងតែ សេចក្តីសំរេចនោះកើតចេញពីលទ្ធផលនៃភាពគ្មានឆន្ទៈ ឬ អលទ្ធភាពរបស់រដ្ឋនោះក្នុងការនាំយកមកជំនុំជំរះដោយពិតប្រាកដ ។

(គ) ជនពាក់ព័ន្ធត្រូវបានជំនុំជំរះចំពោះអំពើដែលជាកម្មវត្ថុនៃពាក្យបណ្តឹងនោះរួចហើយ ហើយការជំនុំជំរះដោយតុលាការមិនត្រូវបានអនុញ្ញាតឱ្យតាម កថាខ័ណ្ឌទី៣នៃមាត្រា ២០ ទេ ។

(ឃ) ករណីនោះមិនធ្ងន់ធ្ងរគ្រប់គ្រាន់ល្មមសម្រាប់ធ្វើយុត្តិកម្មសកម្មភាពបន្តទៀតដោយតុលាការឡើយ។

២. ដើម្បីកំណត់អំពីភាពគ្មានឆន្ទៈក្នុងករណីជាក់លាក់មួយ តុលាការត្រូវពិចារណាដោយសំអាងលើគោលការណ៍នៃដំណើរការសមរម្យដែលបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ថាតើចំណុចមួយឬច្រើន ដូចតទៅនេះ កើតមានដើម្បីអាចអនុវត្តបាន ឬទេ :

(ក) ករណីទាំងនោះបាន ឬកំពុងយកមកដំណើរការ ឬសេចក្ដីសម្រេចថ្នាក់ជាតិបានធ្វើឡើងក្នុងគោលបំណង បិទបាំងជនពាក់ព័ន្ធពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសព្រហ្មទណ្ឌដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៥ ។

(ខ) មានការពន្យាពេលមិនសមហេតុផលក្នុងករណីរឿងក្ដីនោះ ដែលក្នុងស្ថានភាពនោះមិនស្របនឹងចេតនានាំយកជនពាក់ព័ន្ធមករកយុត្តិធម៌ ។

(គ) ករណីទាំងនោះមិនបានដំណើរការដោយឯករាជ្យ ឬមិនលំអៀង ហើយករណីរឿងក្ដីទាំងនោះបាន ឬ កំពុងដំណើរការក្នុងរបៀបមួយដែលក្នុងស្ថានភាពនោះមិនស្របនឹងចេតនានៃការនាំយកជនពាក់ព័ន្ធមករកយុត្តិធម៌ ។

២. ដើម្បីកំណត់អលទ្ធភាពក្នុងករណីជាក់លាក់មួយ តុលាការត្រូវពិចារណាថា ដោយយោងលើការដួលរលំទាំងស្រុងឬ ជាសារវ័ន្ត ឬអលទ្ធភាពនៃប្រព័ន្ធតុលាការជាតិរបស់រដ្ឋនោះ តើរដ្ឋនោះគ្មានលទ្ធភាពទទួលបានជនជាប់ចោទ ឬគ្មានភស្តុតាង និង សក្ខីកម្មចាំបាច់ ឬបើមិនដូច្នេះទេ គ្មានលទ្ធភាពដំណើរការជំរះករណីរឿងក្ដីរបស់ខ្លួនបាន ឬ ទេ ។

### មាត្រា ១៨ : អំពីសេចក្ដីសំរេចបឋមអំពីភាពអាចទទួលយកបាន

១. នៅពេលដែលស្ថានភាពមួយត្រូវបានដាក់ជូនទៅតុលាការស្របតាមមាត្រា១៣(ក) ហើយព្រះរាជអាជ្ញាបានកំណត់ថា មានមូលដ្ឋានសមហេតុផលដើម្បីចាប់ផ្ដើមការស៊ើបអង្កេត ឬក៏ព្រះរាជអាជ្ញាផ្ដើមគំនិតធ្វើការស៊ើបអង្កេតស្របតាមមាត្រា១៣(គ) និងមាត្រា១៥ ពេលនោះព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅគ្រប់រដ្ឋភាគីទាំងអស់ និងទៅរដ្ឋទាំងឡាយណាដែលយកចិត្តទុកដាក់ចំពោះពត៌មានដែលមាននោះ ជាធម្មតាអាចអនុវត្តយុត្តាធិការរបស់ខ្លួន លើបទល្មើសព្រហ្មទណ្ឌនោះ។ ព្រះរាជអាជ្ញាអាចជូនដំណឹងទៅរដ្ឋទាំងនោះបាន ដោយឈរលើមូលដ្ឋានជាសំងាត់ និង បើព្រះរាជអាជ្ញាជឿថា វាចាំបាច់ដើម្បីការពារជនទាំងនោះ ដើម្បីទប់ស្កាត់ការបំផ្លាញចោលនូវភស្តុតាង ឬ ដើម្បីទប់ស្កាត់ការគេខ្លួនរបស់ជនទាំងនោះ ព្រះរាជអាជ្ញាអាចដាក់កំរិតដែនកំណត់នូវវិសាលភាពនៃពត៌មានដែលត្រូវផ្ដល់ ទៅឱ្យរដ្ឋទាំងឡាយ។

២. នៅក្នុងរយៈពេលមួយខែ បន្ទាប់ពីទទួលបានសេចក្ដីជូនដំណឹងនោះ រដ្ឋអាចជំរាបជូនទៅតុលាការថាខ្លួនកំពុងធ្វើការស៊ើបអង្កេត ឬ បានស៊ើបអង្កេតលើពលរដ្ឋរបស់ខ្លួន ឬ អ្នកផ្សេងទៀតដែលឋិតនៅក្នុង

យុត្តាធិការរបស់ខ្លួនទាក់ទងនឹងអំពើល្មើសព្រហ្មទណ្ឌ ដែលអាចបង្កើតជាបទល្មើសព្រហ្មទណ្ឌដែលចែង នៅក្នុងមាត្រា៥ ហើយដែលទាក់ទងទៅនឹងពត៌មានដែលបានផ្តល់ឱ្យនៅក្នុងសេចក្តីជូនដំណឹងផ្ញើទៅរដ្ឋទាំងឡាយ។ តាមការស្នើសុំរបស់រដ្ឋនោះ ព្រះរាជអាជ្ញ ត្រូវទុកការស៊ើបអង្កេតលើជនទាំងឡាយឱ្យរដ្ឋដែលស្នើសុំនោះជាអ្នកធ្វើការស៊ើបអង្កេត លើកលែងតែ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា សភាមុនការជំនុំជំរះ (Pre-Trial Chamber)សំរេចអនុញ្ញាតឱ្យព្រះរាជអាជ្ញាធ្វើការស៊ើបអង្កេត។

៣. ការទុកឱ្យ(differal)របស់ព្រះរាជអាជ្ញាចំពោះការស៊ើបអង្កេតរបស់រដ្ឋ ត្រូវបើកឱ្យត្រួតពិនិត្យមើលដោយព្រះរាជអាជ្ញា ក្នុងរយៈពេល០៦ខែបន្ទាប់ពីកាលបរិច្ឆេទនៃការទុកឱ្យ ឬ នៅពេលណាមានការផ្លាស់ប្តូរកាលៈទេសៈធំៗ ដោយផ្អែកទៅលើភាពគ្មានឆន្ទៈឬភាពគ្មានលទ្ធភាពរបស់រដ្ឋ ក្នុងការធ្វើការស៊ើបអង្កេត។

៤. រដ្ឋដែលទាក់ទង ឬ ព្រះរាជាអាជ្ញា អាចប្តឹងឧទ្ធរណ៍ទៅ សភាឧទ្ធរណ៍ (Appeals Chamber)ប្រឆាំងទៅនឹងសេចក្តីសំរេចរបស់សភាមុនការជំនុំជំរះ ស្របតាមកថាខ័ណ្ឌទី០២នៃមាត្រា៨២។ បណ្តឹងឧទ្ធរណ៍ អាចត្រូវធ្វើសវនាការផ្អែកលើមូលដ្ឋានល្បឿនរហ័ស។

៥. នៅពេល ព្រះរាជអាជ្ញាបានទុកឱ្យការស៊ើបអង្កេតស្របតាមកថាខ័ណ្ឌទី០២ ព្រះរាជអាជ្ញា អាចស្នើសុំឱ្យរដ្ឋដែលទាក់ទងជំរាបជូនពត៌មានមួយរយៈម្តង១ដល់ព្រះរាជអាជ្ញា នូវការវិវត្តន៍នៃការស៊ើបអង្កេតរបស់ខ្លួន និងនូវរាល់ការនាំយកមកជំនុំជំរះណា (subsequent prosecution)ដែលបានធ្វើឡើងនាពេលបន្ទាប់។ រដ្ឋភាគី ត្រូវឆ្លើយតបទៅនឹងសំណើរទាំងនោះ ដោយគ្មានការពន្យាពេលមិនសមហេតុផល។

៦. ការព្យួរសេចក្តីសំរេចដោយ សភាមុនការជំនុំជំរះ ឬ នៅពេលណាដែលព្រះរាជអាជ្ញា បានទុកឱ្យការស៊ើបអង្កេត អនុលោមតាមមាត្រានេះ នៅលើមូលដ្ឋានពិសេស ព្រះរាជាអាជ្ញាអាចស្វែងរកការអនុញ្ញាតពីសភាមុនការជំនុំជំរះ ដើម្បីបន្តជំហ៊ានស៊ើបអង្កេតសំខាន់ សំរាប់គោលបំណងរក្សាការពារភស្តុតាង បើកាលណាខ្លួនយល់ឃើញថាមាន ឱកាសតែមួយគត់ក្នុងការទទួលបាននូវភស្តុតាងសំខាន់ ឬ មានការប្រថុយដ៏ធំមួយដែលភស្តុតាងនោះអាចមិនមាន នៅពេលបន្ទាប់ទៅទៀតទេ។

៧. រដ្ឋដែលបានប្រជែងជំទាស់នឹងសេចក្តីសំរេចរបស់ សភាមុនការជំនុំជំរះ អនុលោមតាមមាត្រានេះ អាចប្រជែងតវ៉ាពីភាពអាចទទួលយកបាននៃករណីស្របតាមមាត្រា១៩ លើមូលដ្ឋាននៃការមានអង្គហេតុសំខាន់បន្ថែមទៀត ឬ មានការផ្លាស់ប្តូរកាលៈទេសៈសំខាន់។

មាត្រា ១៩ : អំពីការប្រជែងតវ៉ាលើយុត្តាធិការតុលាការ ឬ ភាពអាចទទួលយកបាននៃករណីរឿងក្តី

១. តុលាការត្រូវធ្វើឱ្យខ្លួនឯងពេញចិត្តថា ខ្លួនមានយុត្តាធិការលើករណីដែលបានប្តឹងមកខ្លួន។ តាមសេចក្តីស្នើរបស់ខ្លួន តុលាការអាចកំណត់អំពីភាពអាចទទួលយកបាននៃករណីរឿងក្តី ស្របតាមមាត្រា១៧។

២. ការប្រជែងតវ៉ាទៅនឹងភាពអាចទទួលយកបាននៃករណីរឿងក្តី ផ្អែកលើមូលហេតុដែលបានចែងនៅក្នុងមាត្រា ១៧ ឬ ការប្រជែងតវ៉ាទៅនឹងយុត្តាធិការរបស់តុលាការអាចធ្វើបានដោយ :

(ក). ជនជាប់ចោទ ឬ ជនដែលត្រូវបានចេញដីកាឱ្យចាប់ខ្លួន ឬ ដីកាកោះហៅឱ្យចូលខ្លួនមកតុលាការ អនុលោមតាមមាត្រា ៥៨។

(ខ). រដ្ឋដែលមានយុត្តាធិការលើករណីរឿងក្តី ដោយមានមូលហេតុថា ខ្លួនកំពុងតែធ្វើការស៊ើបអង្កេត ឬ កំពុងតែធ្វើនាំយកមកជំនុំជំរះនូវករណីរឿងក្តីនោះ ឬ បានធ្វើការស៊ើបអង្កេតហើយ ឬ បានធ្វើការនាំយកមកជំនុំជំរះហើយ។ ឬ

(គ). រដ្ឋដែលតម្រូវឱ្យមានការទទួលយកយុត្តាធិការ អនុលោមតាមមាត្រា១២។

៣. ព្រះរាជអាជ្ញា អាចស្វែងរកសេចក្តីសំរេចពីតុលាការទាក់ទងទៅនឹងចំណោទបញ្ហាអំពីយុត្តាធិការ ឬ ភាពអាចទទួលយកបាន។ នៅក្នុងដំណើរជំរះរឿងក្តីទាក់ទងទៅនឹងយុត្តាធិការ ឬ ភាពអាចទទួលយកបាន អ្នកដែលបានដាក់ស្ថានភាពនោះ អនុលោមតាមមាត្រា១៣ ព្រមទាំងជនរងគ្រោះ អាចដាក់ជូនការកត់សំគាល់របស់ខ្លួនទៅតុលាការបាន។

៤. ភាពអាចទទួលយកបាននៃករណីរឿងក្តី ឬ យុត្តាធិការតុលាការ អាចនឹងត្រូវប្រជែងតវ៉ាបានតែម្តងគត់ ដោយជន ឬ រដ្ឋណាមួយដែលពោលនៅក្នុងកថាខ័ណ្ឌទី២។ ការប្រជែងតវ៉ា អាចធ្វើឡើងនៅមុនពេល ឬ នៅ ពេលចាប់ផ្តើមការជំនុំជំរះ។ នៅក្នុងកាលៈទេសៈពិសេស តុលាការ អាចផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រជែងតវ៉ាលើសពីមួយដង ឬ ឱ្យធ្វើការប្រជែងតវ៉ានៅពេលក្រោយពីការចាប់ផ្តើមការជំនុំជំរះបាន។ ការប្រជែងតវ៉ាទៅនឹងភាពអាចទទួលយកបាននៃករណីរឿងក្តីនៅពេលចាប់ផ្តើមការជំនុំជំរះ ឬ នៅពេលបន្ទាប់ដោយមានការអនុញ្ញាតពីតុលាការ អាចគ្រាន់តែផ្អែកលើមាត្រា ១៧។

៥. រដ្ឋដែលបានពោលនៅក្នុងកថាខ័ណ្ឌទី២(ខ)និង(គ) ត្រូវប្រជែងតវ៉ានៅក្នុងឱកាសដែលឆាប់បំផុត ។

៦. មុនមានការបញ្ជាក់ច្បាស់ពីការនាំយកមកជំនុំជំរះ ការប្រជែងតវ៉ាទៅនឹងភាពអាចទទួលយកបាននៃករណីរឿងក្តី ឬ ការប្រជែងទៅនឹងយុត្តាធិការតុលាការ ត្រូវដាក់ជូនទៅ សភាមុនការជំនុំជំរះ។ ក្រោយពេលមានការបញ្ជាក់ច្បាស់ ពីការនាំយកមកជំនុំជំរះ ការប្រជែងតវ៉ា ត្រូវដាក់ជូនទៅសភាជំនុំជំរះ។ សេចក្តីសំរេចទាក់ទងទៅនឹងយុត្តាធិការ ឬ ភាពអាចទទួលយកបាន អាចប្តឹងឧទ្ធរណ៍ទៅសភាឧទ្ធរណ៍ស្របតាមមាត្រា៨២បាន។

៧. បើសិន ការប្រជែងតវ៉ាត្រូវបានធ្វើដោយរដ្ឋដែលបានពោលនៅក្នុងកថាខ័ណ្ឌទី២(ខ)ឬ(គ) ព្រះរាជអាជ្ញា ត្រូវព្យួរការស៊ើបអង្កេតសិនរហូតដល់ពេលតុលាការធ្វើការសំរេច ស្របតាមមាត្រា១៧។

៨. ចំពោះសេចក្តីសំរេចដែលព្យួរទុកដោយតុលាការ ព្រះរាជអាជ្ញាអាចស្វែងរកការអនុញ្ញាតពីតុលាការ :

(ក). ដើម្បីបន្តជំហ៊ានស៊ើបអង្កេតចាំបាច់ ដែលបានពោលនៅក្នុង កថាខ័ណ្ឌទី៦នៃមាត្រា ១៨។

(ខ). ដើម្បីប្រមូលយកសេចក្តីថ្លែង ឬ សក្ខីកម្ម ពីសាក្សី ឬ ដើម្បីបង្ហើយការប្រមូលនិង ការពិនិត្យភស្តុតាង ដែលបានចាប់ផ្តើមធ្វើមុនពេលមានការប្រជែងតវ៉ា។ និង

(គ). ក្នុងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋដែលពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការគេចខ្លួនរបស់ជនដែលព្រះរាជអាជ្ញា បានស្នើសុំដីកាចាប់ខ្លួន អនុលោមតាមមាត្រា ៥៨ រួចទៅហើយ។

៩. ការធ្វើការប្រជែងជំទាស់ នឹងមិនមានឥទ្ធិពលលើសុពលភាពនៃអំពើដែលបានធ្វើដោយព្រះរាជអាជ្ញា ឬលើបញ្ជា ឬ ដីកា ដែលត្រូវបានចេញដោយតុលាការមុនពេលមានការប្រជែងតវ៉ាទេ។

១០. បើសិនតុលាការបានសំរេចថាករណីរឿងក្តីនោះមិនអាចទទួលយកបានអនុលោមតាមមាត្រា១៧ព្រះរាជអាជ្ញាអាចដាក់ស្នើរការសើរើសេចក្តីសំរេចនោះបាន ប្រសិនបើ ខ្លួនប្រាកដក្នុងចិត្តយ៉ាងពេញលេញថាអង្គហេតុថ្មីបានកើតឡើង ដែលធ្វើអវិជ្ជមានកម្ម(ដែលប្រឆាំងនឹង)មូលដ្ឋានដែលករណីនោះបានផ្អែកលើពីមុនមកមិនអាចទទួលយកបាន អនុលោមតាមមាត្រា ១៧។

១១. ទាក់ទងទៅនឹងបញ្ហាដែលបានពោលនៅក្នុងមាត្រា១៧ បើសិន ព្រះរាជអាជ្ញា ទុកឱ្យការស៊ើបអង្កេតព្រះរាជអាជ្ញា អាចស្នើរឱ្យរដ្ឋដែលពាក់ព័ន្ធឱ្យមានពត៌មានស្តីពីដំណើរការជំរះរឿងក្តីដល់ព្រះរាជអាជ្ញាបាន ។ តាមការស្នើរបស់រដ្ឋដែលពាក់ព័ន្ធ ពត៌មាននោះត្រូវទុកជាសំងាត់។ បើសិនជាបន្ទាប់មក ព្រះរាជអាជ្ញា សំរេចបន្តធ្វើការស៊ើបអង្កេត ខ្លួនត្រូវជូនដំណឹងដល់រដ្ឋនោះទាក់ទងទៅនឹងដំណើរការដែលមានការទុកឱ្យការស៊ើបអង្កេតនោះ។

## មាត្រា ២០ : អំពីការជំនុំជំរះតែមួយលើក (Ne bis in idem)

១. លើកលែងតែមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ គ្មានជនណាម្នាក់ត្រូវបានជំនុំជំរះដោយតុលាការទាក់ទងលើការប្រព្រឹត្តដែលបានបង្កើតជាមូលដ្ឋាននៃបទល្មើសព្រហ្មទណ្ឌដែលជននោះត្រូវបានតុលាការសំរេចឱ្យមានពិរុទ្ធភាព( ឱ្យមានទោស) ឬ សំរេចឱ្យរួចខ្លួន( គ្មានទោស) ម្តងរួចទៅហើយនោះទេ។

២. គ្មានជនណាម្នាក់ត្រូវជំនុំជំរះនៅក្នុងតុលាការមួយទៀត ចំពោះបទល្មើសព្រហ្មទណ្ឌដែលបានចែងនៅក្នុងមាត្រា៥ ដោយជននោះត្រូវបានតុលាការសំរេចឱ្យមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរួចទៅហើយនោះទេ។

៣. គ្មានជនណាម្នាក់ ដែលត្រូវបានជំនុំជំរះដោយតុលាការមួយផ្សេងទៀតចំពោះការប្រព្រឹត្តដែលបានពណ៌នាផងដែរនៅក្នុងមាត្រា៦, ៧ ឬ ៨ ត្រូវជំនុំជំរះដោយតុលាការទាក់ទងទៅលើការប្រព្រឹត្តដូចគ្នាតែមួយទេ លើកលែងតែដំណើរការទាំងឡាយនៅក្នុងតុលាការមួយផ្សេងទៀតនោះ :

(ក).ត្រូវបានធ្វើឡើងសំរាប់គោលបំណងលាក់បាំងជនដែលពាក់ព័ន្ធ ពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ សំរាប់បទល្មើសដែលឋិតនៅក្នុងយុត្តាធិការនៃតុលាការនោះ។ ឬ

(ខ). បើមិនអញ្ចឹងទេ ត្រូវបានធ្វើឡើងដោយគ្មានឯករាជ្យ ឬ ដោយគ្មានភាពឥតលំអៀង ស្របតាមបទដ្ឋាននៃដំណើរការត្រឹមត្រូវតាមច្បាប់ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយត្រូវបានធ្វើឡើងតាមរបៀបមួយដែល ក្នុងកាលៈទេសៈនានា មិនស្របតាមចេតនានាំខ្លួនជនដែលពាក់ព័ន្ធ នោះមករកយុត្តិធម៌។

## មាត្រា ២១ : អំពីច្បាប់ដែលត្រូវយកមកអនុវត្ត

១. តុលាការត្រូវអនុវត្ត :

(ក). ទីមួយ ច្បាប់លក្ខន្តិកៈនេះ ធាតុនៃបទល្មើសព្រហ្មទណ្ឌ និង វិធាននៃនិតិវិធីនិងភស្តុតាង របស់តុលាការ។

(ខ). ទីពីរ តាមការសមស្រប សិទ្ធិសញ្ញា និង គោលការណ៍ និងវិធាននៃច្បាប់អន្តរជាតិ ដែលអាចយកមកអនុវត្តបាន រួមបញ្ចូលទាំងគោលការណ៍នៃច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធដែលត្រូវបានបង្កើតឡើង។

(គ).បើខាងលើនេះប្រើការមិនបាន គោលការណ៍ទូទៅនៃច្បាប់ដែលទាញយកប្រើដោយតុលាការចេញពីច្បាប់ជាតិរបស់ប្រព័ន្ធច្បាប់ទាំងឡាយរបស់ពិភពលោក ដែលរួមទាំង តាមការសមស្រប ច្បាប់ជាតិទាំងឡាយរបស់រដ្ឋដែលគួរជាធម្មតាអនុវត្តយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌនោះ ក្នុងលក្ខខ័ណ្ឌថាគោលការណ៍ទាំងនោះមិនផ្ទុយទៅនឹងច្បាប់លក្ខន្តិកៈនេះ ហើយមិនផ្ទុយទៅនឹងច្បាប់អន្តរជាតិ និង បទដ្ឋាននិងស្តង់ដារ ដែលទទួលស្គាល់ជាអន្តរជាតិ។

២. តុលាការអាចអនុវត្តគោលការណ៍ និង វិធានទាំងឡាយនៃច្បាប់ តាមខ្លឹមសារដូចដែលត្រូវបានបកស្រាយ នៅក្នុងសេចក្តីសំរេចកាលពីមុនរបស់ខ្លួន។

៣. ការអនុវត្តន៍ និង ការបកស្រាយច្បាប់ អនុលោមតាមមាត្រានេះ ត្រូវតែស្របគ្នាជាមួយនឹងសិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ហើយមិនត្រូវមានភាពខុសប្លែកដែលប្រឆាំងគ្នាផ្អែកលើមូលដ្ឋាន ដូចជា ភេទដូចបានកំណត់ពន្យល់នៅក្នុង កថាខ័ណ្ឌទី៣នៃមាត្រា៧ អាយុ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ឬ ជំនឿ ទស្សនៈនយោបាយ ឬ ទស្សនៈផ្សេងៗទៀត ដើមកំណើតជាតិ ជាតិពន្ធុ ឬ ដើមកំណើតសង្គម ទ្រព្យសម្បត្តិ កំណើត ឬ ឋានៈសង្គម ឡើយ។

## ភាគទី ០៣ ៈ គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ

### មាត្រា ២២ : អំពីការគ្មានបទល្មើសព្រហ្មទណ្ឌបើសិនគ្មានច្បាប់ (Nullum crimen sine lege)

១. អនុលោមតាមច្បាប់លក្ខន្តិកៈនេះ គ្មានជនណាម្នាក់ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ លើកលែងតែ ការប្រព្រឹត្តនោះបង្កបង្កើតនៅពេលកើតឡើងនូវបទល្មើសព្រហ្មទណ្ឌដែលឋិតក្នុងយុត្តាធិការតុលាការ។

២. និយមន័យនៃបទល្មើសព្រហ្មទណ្ឌ ត្រូវតែបកស្រាយអធិប្បាយឱ្យល្អិត ហើយមិនត្រូវពង្រីកវិសាលភាព ដោយការពន្យល់ប្រៀបធៀប(analogy)ឡើយ។ នៅក្នុងករណីមានវិមតិសង្ស័យ ការកំណត់និយមន័យនោះ ត្រូវបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងត្រូវរងការធ្វើការស៊ើបអង្កេត ត្រូវនាំយកមកជំនុំជំរះ ឬ ត្រូវបានសំរេចឱ្យមានពិរុទ្ធភាព។

៣. មាត្រានេះ មិនត្រូវប៉ះពាល់ដល់ការស្វែងចរិកលក្ខណៈនៃការប្រព្រឹត្តណាមួយ ដែលមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ ឯករាជ្យពីច្បាប់លក្ខន្តិកៈនេះឡើយ។

### មាត្រា ២៣ : អំពីការគ្មានទោសបើគ្មានច្បាប់កំណត់ (Nulla poena sine lege)

ជនដែលត្រូវតុលាការសំរេចឱ្យមានពិរុទ្ធភាព អាចត្រូវដាក់ទណ្ឌកម្ម ស្របតាមច្បាប់លក្ខន្តិកៈនេះតែប៉ុណ្ណោះ។

### មាត្រា ២៤ : អំពីការគ្មានលក្ខណៈប្រតិសកម្ម (Non-retroactivity ratione personae)

១. គ្មានជនណាម្នាក់ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ក្រោមច្បាប់លក្ខន្តិកៈនេះ ចំពោះការប្រព្រឹត្តធ្វើឡើង មុនពេលដែលច្បាប់លក្ខន្តិកៈនេះចូលជាធរមានឡើយ។

២. ក្នុងករណីមានការកែប្រែផ្លាស់ប្តូរនៅក្នុងច្បាប់ដែលអាចយកមកអនុវត្តបាន ចំពោះករណីមួយមុនមានសាលក្រមស្ថាពរ ត្រូវអនុវត្តច្បាប់ដែលមានលក្ខណៈជាប្រយោជន៍ដល់ជនដែលកំពុងត្រូវបានស៊ើបអង្កេត ត្រូវបាននាំយកមកជំនុំជំរះ ឬ ត្រូវបានសំរេចឱ្យមានពិរុទ្ធភាព ។

## មាត្រា ២៥ : អំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

១. តុលាការត្រូវមានយុត្តាធិការលើរូបវន្តបុគ្គល អនុលោមតាមច្បាប់លក្ខន្តិកៈនេះ។

២. ជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនៅក្នុងយុត្តាធិការតុលាការ ត្រូវទទួលខុសត្រូវ និង ទទួលទណ្ឌកម្មជាលក្ខណៈបុគ្គល ស្របតាមច្បាប់លក្ខន្តិកៈនេះ។

៣. ស្របតាមច្បាប់លក្ខន្តិកៈនេះ ជនម្នាក់ត្រូវទទួលខុសត្រូវ និង ទទួលទណ្ឌកម្មជាលក្ខណៈបុគ្គល ចំពោះបទល្មើសព្រហ្មទណ្ឌដែលឋិតនៅក្នុងយុត្តាធិការតុលាការ ប្រសិនបើជននោះ :

(ក). ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ទោះជាក្នុងរូបភាពជាឯកត្តជន ក្នុងរូបភាពរួមជាមួយអ្នកផ្សេងទៀត ឬតាមរយៈជនដទៃទៀត ដោយមិនគិតថាជនដទៃទៀតនោះទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬអត់នោះទេ។

(ខ). បញ្ជា អន្ទងចិត្ត ឬ ជំរុញចិត្តឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ ដែលតាមពិត កើតមានឡើង ឬ ត្រូវបានប៉ុនប៉ងធ្វើឡើង។

(គ). សំរាប់គោលបំណងសំរួលដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ ទំនុកបំរុង កំដរ ឬក៏ ជួយក្នុងការប្រព្រឹត្ត ឬ ការប៉ុនប៉ងប្រព្រឹត្ត រួមទាំងការផ្តល់មធ្យោបាយសំរាប់ការប្រព្រឹត្តផងដែរ។

(ឃ). តាមមធ្យោបាយណាមួយផ្សេងទៀត រួមចំនែកនៅក្នុងការប្រព្រឹត្ត ឬ ការប៉ុនប៉ងប្រព្រឹត្ត នូវបទល្មើសព្រហ្មទណ្ឌនោះ ដោយជនមួយក្រុមដែលធ្វើអំពើនោះឡើងក្នុងគោលបំណងរួមតែមួយ។ ការរួមចំណែកនេះត្រូវមានលក្ខណៈជាចេតនា ហើយត្រូវ :

(i). បានធ្វើឡើងដោយមានបំណងបន្តសកម្មភាពព្រហ្មទណ្ឌ ឬ គោលបំណងព្រហ្មទណ្ឌរបស់ក្រុមដែលសកម្មភាព ឬ គោលបំណងទាំងនោះពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នៅក្នុងយុត្តាធិការតុលាការ, ឬ

(ii). បានធ្វើឡើងដោយមានការដឹងអំពីចេតនារបស់ក្រុមចង់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

(ង). ទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌនៃអំពើប្រល័យពូជសាសន៍ ញុះញង់អ្នកដទៃដោយផ្ទាល់និងជាសាធារណៈ ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍

(ច).ការប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ ដោយការធ្វើសកម្មភាពដែលចាប់ផ្តើមការអនុវត្តន៍ដោយជំហ៊ានជាសារវន្ត ប៉ុន្តែបទល្មើសព្រហ្មទណ្ឌមិនបានកើតមានឡើងដោយសារតែកាលៈទេសៈឯករាជ្យពីចេតនារបស់ជននោះ។ ទោះបីជាយ៉ាងណាក៏ដោយ ជនដែលបោះបង់ចោលនូវកិច្ចខិតខំប្រឹងប្រែងដើម្បីប្រព្រឹត្តបទល្មើសនោះ ឬក៏ ទប់ស្កាត់នូវការសំរេចការប្រព្រឹត្តិបទល្មើសនោះ មិនត្រូវទទួលទណ្ឌកម្ម ក្រោមច្បាប់លក្ខន្តិកៈនេះ ចំពោះការប៉ងប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌនោះទេ បើសិនជា ជននោះបានបោះបង់ចោលដោយស្ម័គ្រចិត្តនិងដោយពេញលេញនូវគោលបំណងព្រហ្មទណ្ឌនោះ។

៤. គ្មានបទបញ្ញត្តិណាមួយនៃច្បាប់លក្ខន្តិកៈនេះ ដែលទាក់ទងទៅនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ត្រូវប៉ះពាល់ដល់ការទទួលខុសត្រូវរបស់រដ្ឋ ក្រោមច្បាប់អន្តរជាតិឡើយ។

## មាត្រា ២៦ : អំពីការមិនបញ្ចូលក្នុងយុត្តាធិការចំពោះជនដែលមានអាយុក្រោម១៨ឆ្នាំ

តុលាការនឹងមិនមានយុត្តាធិការលើជនណាដែលមានអាយុក្រោម១៨ឆ្នាំ នៅពេលនៃការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌដែលត្រូវចោទនោះ ឡើយ។

## មាត្រា ២៧ : អំពីភាពមិនទាក់ទងនៃសម្បទាផ្លូវការ

១. ច្បាប់លក្ខន្តិកៈនេះ ត្រូវអនុវត្តដោយស្មើគ្នាលើជនគ្រប់រូប ដោយគ្មានការខុសប្លែកគ្នាអ្វីផ្អែកលើសម្បទាផ្លូវការឡើយ។ ជាពិសេស សម្បទា ជាប្រមុខរដ្ឋឬរដ្ឋាភិបាល ជាសមាជិករដ្ឋាភិបាល ឬ សមាជិករដ្ឋសភា ជាអ្នកតំណាងដែលបានជាប់ឆ្នោត ឬ ជាមន្ត្រីរដ្ឋាភិបាល នឹងគ្មានករណីលើកលែងឱ្យជនណាម្នាក់រួចពីការទទួលខុសត្រូវក្រោមច្បាប់លក្ខន្តិកៈនេះ ឬ នៅក្នុងសម្បទាឬនៃសម្បទាផ្ទាល់នេះ មិនត្រូវបង្កបង្កើតជាមូលដ្ឋានសំរាប់ការបន្ធូរបន្ថយទោសឡើយ។

២. អភ័យឯកសិទ្ធិ ឬ វិធាននៃនីតិវិធីពិសេស ដែលអាចមានជាប់នឹងសម្បទាផ្លូវការរបស់ជនម្នាក់ មិនថានៅក្រោមច្បាប់អន្តរជាតិ ឬ ច្បាប់ជាតិទេ មិនត្រូវជាឧបសគ្គរារាំងតុលាការពីការប្រើប្រាស់យុត្តាធិការរបស់ខ្លួនលើជននោះឡើយ។

## មាត្រា ២៨ : អំពីការទទួលខុសត្រូវរបស់មេបញ្ជាការ និង ថ្នាក់លើផ្សេងៗទៀត

លើសពីមូលដ្ឋានផ្សេងៗទៀតនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ក្រោមច្បាប់លក្ខន្តិកៈនេះ ចំពោះបទល្មើសព្រហ្មទណ្ឌឋិតក្នុងយុត្តាធិការតុលាការ :

១. មេបញ្ជាការកងទ័ព ឬ ជនដែលដើរតួរដោយមានប្រសិទ្ធភាពជាមេបញ្ជាការកងទ័ព ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះបទល្មើសព្រហ្មទណ្ឌឋិតក្នុងយុត្តាធិការតុលាការ ដែលបានប្រព្រឹត្តដោយកងកម្លាំងដែលឋិតនៅក្រោមបញ្ជានិងការត្រួតត្រាមានប្រសិទ្ធភាពរបស់ខ្លួន ឬ អំណាចនិងការត្រួតត្រាមានប្រសិទ្ធភាព តាមករណីជាក់ស្តែង ជាលទ្ធផលនៃការខកខានមិនបានត្រួតត្រាត្រឹមត្រូវរបស់ខ្លួនលើកងកម្លាំងទាំងនោះ បើសិនជា :

(ក). មេបញ្ជាការកងទ័ពនោះ ឬ ជននោះ ទោះជាបានដឹង ឬ អាស្រ័យលើកាលៈទេសៈនៅពេលនោះគួរបានដឹងថា កងកម្លាំងកំពុងតែប្រព្រឹត្ត ឬ ប្រុងនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ, និង

(ខ). មេបញ្ជាការកងទ័ព ឬ ជននោះ ខកខានមិនបានចាត់វិធានការចាំបាច់និងសមហេតុផល នៅក្នុងក្របខ័ណ្ឌនៃអំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ ឬ បង្ក្រាបការប្រព្រឹត្តរបស់កងកម្លាំងទាំងនោះ ឬ ដើម្បីប្រគល់បញ្ហានោះទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេត និង នាំយកមកជំនុំជំរះ ។

២. ទាក់ទងទៅនឹងទំនាក់ទំនងរវាងថ្នាក់លើ(មេ)និងថ្នាក់ក្រោម(កូនចៅ)ដែលមិនបានពណ៌នានៅក្នុងកថាខ័ណ្ឌទី១ ថ្នាក់លើត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះបទល្មើសព្រហ្មទណ្ឌឋិតនៅក្នុងយុត្តាធិការតុលាការ ដែលត្រូវបានប្រព្រឹត្តឡើងដោយថ្នាក់ក្រោមដែលឋិតនៅក្រោមអំណាចនិងការត្រួតត្រាមានប្រសិទ្ធភាពរបស់ខ្លួន ជាលទ្ធផលនៃការខកខានរបស់ខ្លួនក្នុងការធ្វើការត្រួតត្រាត្រឹមត្រូវលើថ្នាក់ក្រោម បើ :

(ក). ថ្នាក់លើបានដឹង ឬ បានធ្វើមិនអើពើដោយដឹងខ្លួនចំពោះពត៌មានដែល បង្ហាញយ៉ាងច្បាស់ថាថ្នាក់ក្រោមកំពុងតែប្រព្រឹត្ត ឬ ប្រុងនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ

(ខ). បទល្មើសព្រហ្មទណ្ឌដែលទាក់ទងនឹងសកម្មភាពទាំងឡាយដែលឋិតនៅក្នុងការទទួលខុសត្រូវ និងការត្រួតត្រាថ្នាក់ក្រោមមានប្រសិទ្ធភាព, និង

(គ). ថ្នាក់លើខកខានមិនបានចាត់វិធានការចាំបាច់និងសមហេតុផលនៅក្នុងក្របខ័ណ្ឌអំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ ឬ បង្ក្រាបការប្រព្រឹត្តរបស់ថ្នាក់ក្រោម ឬ ដើម្បីដាក់បញ្ហាទៅអាជ្ញាធរមានសមត្ថកិច្ចសំរាប់ធ្វើការស៊ើបអង្កេត និង នាំយកមកជំនុំជំរះ ។

## មាត្រា ២៩ : អំពីការមិនអនុវត្តនូវអាជ្ញាយុកាល

បទល្មើសឋិតនៅក្នុងយុត្តាធិការតុលាការ មិនត្រូវជាកម្មវត្ថុនៃអាជ្ញាយុកាលឡើយ ។

## មាត្រា ៣០ : អំពីធាតុខាងបញ្ញាស្មារតី(Mental Element)

១. លើកលែងតែមានចែងផ្ទុយពីនេះ ជនម្នាក់ត្រូវទទួលខុសត្រូវ និង ទទួលទណ្ឌកម្មខាងព្រហ្មទណ្ឌ ចំពោះបទល្មើសព្រហ្មទណ្ឌឋិតនៅក្នុងយុត្តាធិការតុលាការ តែក្នុងករណីដែលធាតុជាសំខាន់ៗត្រូវបានប្រព្រឹត្តដោយមានចេតនា និង ដោយមានការដឹង (knowledge)។

២. សំរាប់គោលបំណងនៃមាត្រានេះ ជនម្នាក់ត្រូវចាត់ទុកថាមានចេតនា បើ :

(ក).នៅក្នុងការទាក់ទងទៅនឹងការប្រព្រឹត្តិ មានន័យថា ជននោះភ្ជាប់ការចូលរួម(engage)នៅក្នុងការប្រព្រឹត្តិនោះ

(ខ). នៅក្នុងការទាក់ទងទៅនឹងផលវិបាក មានន័យថា ជននោះបង្កឱ្យកើតផលវិបាកនោះ ឬ ជននោះមានសតិដឹងថា វានឹងកើតមាននៅក្នុងដំណើរដែលកើតមានឡើងជាធម្មតានៃព្រឹត្តិការណ៍។

៣. សំរាប់គោលបំណងនៃមាត្រានេះ ពាក្យ"ការដឹង = knowledge" មានន័យថា ការមានសតិដឹង (awareness) ថាកាលៈទេសៈមួយកំពុងមានវត្តមាន ឬ ផលវិបាកមួយនឹងកើតមាននៅក្នុងដំណើរកើតមានឡើងធម្មតានៃព្រឹត្តិការណ៍។ ពាក្យ"ដឹង =know" និង"ដោយដឹងខ្លួន =knowingly" ត្រូវបកស្រាយអធិប្បាយឱ្យស្របតាមគ្នា។

## មាត្រា ៣១ : អំពីមូលហេតុសំរាប់ការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ

១. លើសពីមូលហេតុផ្សេងៗទៀតសំរាប់ការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ ជនម្នាក់មិនត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ បើសិនជា នៅពេលដែលជននោះប្រព្រឹត្តិ :

(ក). ជននោះមានជំងឺវិបត្តិស្មារតី ឬ អនិបុណភាព(defect)ដែលបំផ្លាញសម្បទារបស់ជននោះក្នុងការយល់ដឹងពីភាពខុសច្បាប់ ឬ ប្រភេទនៃការប្រព្រឹត្តរបស់ខ្លួន ឬ សម្បទាក្នុងការគ្រប់គ្រងការប្រព្រឹត្តរបស់ខ្លួនឱ្យស្របតាម ការតម្រូវនៃច្បាប់។

(ខ). ជននោះឋិតក្នុងសភាពស្រវឹងដែលការស្រវឹងបំផ្លាញសម្បទារបស់ជននោះលើការយល់ដឹងភាពខុសច្បាប់ ឬ ប្រភេទនៃការប្រព្រឹត្តរបស់ខ្លួន លើកលែងតែជននោះស្រវឹងដោយស្ម័គ្រចិត្តនៅក្នុងកាលៈទេសៈដែលជននោះបានដឹង ឬ បានមិនអើពើចំពោះការប្រថុយ( ហានិភ័យ = risk ) ដែលជាលទ្ធផលនៃការស្រវឹងនោះ ជននោះ ទំនងជាភ្ជាប់ការចូលរួមនៅក្នុងការប្រព្រឹត្តដែលបង្កបង្កើតឡើងនូវបទល្មើសព្រហ្មទណ្ឌឋិតនៅក្នុងយុត្តាធិការតុលាការ។

(គ). ជនដែលធ្វើអំពើសមហេតុផលដើម្បីការពារខ្លួន ឬ ការពារជនម្នាក់ទៀត ឬ នៅក្នុងករណីបទល្មើសសង្គ្រាម ការពារទ្រព្យដែលសំខាន់ចាំបាច់សំរាប់ការចិញ្ចឹមជីវិតរបស់ជននោះ ឬ របស់ជនដទៃទៀត ឬ ទ្រព្យដែលសំខាន់ចាំបាច់សំរាប់បំពេញបេសកម្មយោធា ទល់នឹងការប្រើប្រាស់កម្លាំងដោយខុសច្បាប់ដែលប្រុងនឹងកើតមានឡើង តាមរបៀបមួយសមាមាត្រទៅនឹងកំរិតនៃគ្រោះថ្នាក់ចំពោះជននោះ ឬ ចំពោះជនដទៃទៀត ឬ ចំពោះទ្រព្យដែលត្រូវបានការពារនោះ។ ហេតុដែលជននោះពាក់ព័ន្ធនៅក្នុងប្រតិបត្តិការការពារ(defensive operation)ធ្វើឡើងដោយបង្ខំ មិនត្រូវដោយខ្លួនវាផ្ទាល់ បង្កបង្កើតមូលហេតុ សំរាប់ការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ក្រោមអនុកថាខ័ណ្ឌនេះទេ។

(ឃ). ការប្រព្រឹត្តដែលត្រូវបានចោទថាបង្កបង្កើតនូវបទល្មើសព្រហ្មទណ្ឌឋិតនៅក្នុងយុត្តាធិការតុលាការ បានត្រូវធ្វើឡើងដោយមានការបង្ខិតបង្ខំដែលជាលទ្ធផលមកពីការគំរាមកំហែងចំពោះក្ស័យមរណៈដែលប្រុងនឹងកើតមានឡើង ឬ នូវការឈឺចាប់ផ្នែករូបកាយដែលកំពុងមានឬដែលប្រុងនឹងកើតមានឡើង ចំពោះជននោះ ឬ ចំពោះជនដទៃទៀត ហើយជននោះ ធ្វើអំពើត្រឹមកំរិតចាំបាច់និងសមហេតុផលដើម្បីបញ្ចៀសការគំរាមកំហែងនេះ ក្នុងលក្ខខ័ណ្ឌថាជននោះមិនមានចេតនាបង្កឱ្យមានការឈឺចាប់ធំជាងទំហំនៃការឈឺចាប់ដែលត្រូវបានពុះពារជៀសវាង។ ការគំរាមកំហែងនោះអាចជា :

(i). បានធ្វើឡើងដោយជនម្នាក់ផ្សេងទៀត

(ii).បានបង្កបង្កើតឡើងដោយកាលៈទេសៈផ្សេងៗទៀត ដែលហួសពីលទ្ធភាពគ្រប់គ្រងរបស់ជននោះ។

២. តុលាការត្រូវកំណត់ពីភាពអាចអនុវត្តបាននៃមូលហេតុសំរាប់ការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចែងនៅក្នុងច្បាប់លក្ខន្តិកៈនេះ ចំពោះករណីដែលដាក់ឱ្យតុលាការសំរេច។

៣. នៅពេលជំនុំជំរះ តុលាការអាចពិចារណាមូលហេតុសំរាប់ការឱ្យរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ក្រៅពីមូលហេតុទាំងឡាយដែលបានពោលនៅក្នុងកថាខ័ណ្ឌទី០១ ដែលមូលហេតុនោះត្រូវបានទាញយកចេញមកពីច្បាប់ដែលអាចយកមកអនុវត្តបាន ដូចដែលមានចែងនៅក្នុងមាត្រា២១។ នីតិវិធីទាក់ទងទៅនឹងការពិចារណាលើមូលហេតុនោះ ត្រូវចែងនៅក្នុងវិធាននៃនីតិវិធីនិងភស្តុតាង។

## មាត្រា ៣២ : អំពីការច្រឡំអំពីអង្គហេតុ ឬ ការច្រឡំអំពីអង្គច្បាប់

១. ការច្រឡំអំពីអង្គហេតុអាចជាមូលហេតុមួយសំរាប់ការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ តែក្នុងករណីវាធ្វើអវិជ្ជមានកម្ម(ប្រឆាំង)ទៅនឹងធាតុបញ្ញាស្មារតី (mental element) ដែលត្រូវតម្រូវដោយបទល្មើសព្រហ្មទណ្ឌនោះ ។

២. ការច្រឡំអំពីអង្គច្បាប់ ជាតើ ការប្រព្រឹត្តណាមួយជាក់លាក់ គឺជាបទល្មើសព្រហ្មទណ្ឌឋិតនៅក្នុងយុត្តាធិការតុលាការឬអត់ មិនត្រូវជាមូលហេតុសំរាប់ការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ។ ប៉ុន្តែ ការច្រឡំអំពីអង្គច្បាប់ ជាមូលហេតុសំរាប់ការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ បើសិនវាប្រឆាំងនឹងធាតុបញ្ញាស្មារតីដែលតម្រូវដោយបទល្មើសនោះ ឬ ដូចដែលមានចែងនៅក្នុងមាត្រា ៣៣។

## មាត្រា ៣៣ : អំពីបញ្ជាថ្នាក់លើ និង សេចក្តីបង្គាប់នៃច្បាប់ (prescription of law)

១. ហេតុដែលបទល្មើសព្រហ្មទណ្ឌមួយឋិតនៅក្នុងយុត្តាធិការតុលាការ ត្រូវបានប្រព្រឹត្តធ្វើឡើងដោយជនម្នាក់ តាមបញ្ជា របស់រដ្ឋាភិបាល ឬ របស់ថ្នាក់លើៈ ទោះជាស៊ីវិលក្តី ឬយោធាក្តី មិនត្រូវឱ្យជននោះរួចពីបន្ទុកនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ លើកលែងតែ :

(ក). ជននោះមានកាតព្វកិច្ចផ្លូវច្បាប់ត្រូវគោរពបញ្ជារបស់រដ្ឋាភិបាល ឬ របស់ថ្នាក់លើនោះ

(ខ). ជននោះមិនបានដឹងថាបញ្ជានោះខុសច្បាប់

(គ). បញ្ជានោះមិនបង្ហាញជាក់ស្តែងថាខុសច្បាប់

## ភាគទី ០៤ : សមាសភាព និង រដ្ឋបាល តុលាការ

## មាត្រា ៣៤ : អំពីអង្គការចាត់តាំងរបស់តុលាការ

តុលាការត្រូវមានសមាសភាពអង្គការចាត់តាំង(Organs) ដូចតទៅ :

(ក). ធិបតីប្រធាន (Presidency)

(ខ). ផ្នែកឧទ្ធរណ៍ ផ្នែកជំនុំជំរះ និង ផ្នែកមុនការជំនុំជំរះ

(គ). ការិយាល័យព្រះរាជអាជ្ញា (អយ្យការអមតុលាការ)

(ឃ). ក្រឡាបញ្ជី (Registry)

## មាត្រា ៣៥ : អំពីសេវារបស់ចៅក្រម

១. ចៅក្រមទាំងអស់ ត្រូវបានបោះឆ្នោតជ្រើសរើសជាសមាជិកពេញម៉ោងរបស់តុលាការ ហើយត្រូវត្រៀមខ្លួនបំរើការងារផ្នែកលើមូលដ្ឋាននោះ តាំងពីការចាប់ផ្តើមអាណត្តិរបស់ខ្លួន។

២. ចៅក្រមដែលជាសមាសភាពនៃធិបតីប្រធាន ត្រូវបំរើការងារលើមូលដ្ឋានពេញម៉ោង ចាប់ពីពេលដែលជាប់ឆ្នោត ភ្លាម។

៣. ធិបតីប្រធាន អាចសំអាងលើមូលដ្ឋានបន្ទុកការងាររបស់តុលាការ និង ដោយមានការពិគ្រោះយោបល់ជាមួយសមាជិកតុលាការ ពីមួយពេលទៅមួយពេល សំរេចពីវិសាលភាពកំរិតណា ដែលចៅក្រមដែលនៅសល់ត្រូវតម្រូវឱ្យបំរើការងារលើមូលដ្ឋានពេញម៉ោង។ ការចាត់ចែងនេះ ត្រូវធ្វើដោយឥតអគតិធម៌ ចំពោះបទប្បញ្ញត្តិនៃមាត្រា៤០។

៤. ការចាត់ចែងចុងក្រោយសំរាប់ចៅក្រមដែលមិនតម្រូវឱ្យបំរើការងារលើមូលដ្ឋានពេញម៉ោងត្រូវធ្វើឡើង ស្របតាមមាត្រា ៤៩។

## មាត្រា ៣៦ : អំពី គុណសម្បត្តិ ការចាត់តាំង និង ការបោះឆ្នោតជ្រើសរើសនៃចៅក្រម

១. យោងតាមបទបញ្ញត្តិនៃកថាខ័ណ្ឌទី០២ ត្រូវមានចៅក្រមតុលាការចំនួន ១៨នាក់។

២. (ក). ធិបតីប្រធាន ដើរតួរតាងនាមឱ្យតុលាការ អាចដាក់សំណើរបង្កើនចំនួនសមាជិកចៅក្រមដែលកំណត់ នៅក្នុងកថាខ័ណ្ឌទី០១ ដោយបង្ហាញនូវហេតុផល ហេតុអ្វីបានជាខ្លួនពិចារណាការបង្កើនចំនួនសមាជិកនេះជាការចាំបាច់និងសមស្រប។ ក្រឡាបញ្ជី ត្រូវបញ្ជូនចែកចាយសំណើរនោះទៅរដ្ឋភាគីទាំងអស់ យ៉ាងរហ័សទាន់ពេល។

(ខ). បន្ទាប់មក សំណើរទាំងឡាយនោះ ត្រូវពិចារណានៅក្នុងការប្រជុំរបស់សភានៃរដ្ឋភាគី ដែលត្រូវកោះធ្វើឡើងស្របតាមមាត្រា១១២។ សំណើរ ត្រូវចាត់ទុកថាបានត្រូវអនុម័ត ប្រសិនបើ ត្រូវបានយល់ព្រមនៅក្នុងការប្រជុំនោះដោយសម្លេង ២/៣នៃសមាជិកសន្និបាតនៃរដ្ឋភាគី ហើយត្រូវចូលជាធរមាននៅតាមពេលវេលាដែលសំរេចដោយសន្និបាតនៃរដ្ឋភាគី។

(គ). (i). នៅពេលដែលសំណើរបង្កើនចំនួនចៅក្រមត្រូវបានអនុម័តរួចមក អនុលោមតាមអនុកថាខ័ណ្ឌ(ខ) ការបោះឆ្នោតជ្រើសរើសចៅក្រមត្រូវប្រព្រឹត្តិធ្វើឡើងនៅក្នុងសម័យប្រជុំលើកក្រោយរបស់សន្និបាតនៃរដ្ឋភាគី ស្របតាម កថាខ័ណ្ឌទី៣ ដល់ ទី៨ រួមទាំង កថាខ័ណ្ឌទី២ នៃមាត្រា ៣៧។

(ii). នៅពេលដែលសំណើរបង្កើនចំនួនចៅក្រមត្រូវបានអនុម័តរួចមក ហើយបានចូលជាធរមានតាមអនុកថាខ័ណ្ឌ(ខ)និង(គ)(i)ត្រូវបើកឱ្យធិបតីប្រធាននៅពេលណាមួយបន្ទាប់ពីពេលនោះ ធ្វើសំណើរកាត់បន្ថយចំនួន

ចៅក្រម បើសិនបើបន្ទុកការងារតុលាការធ្វើយុត្តិកម្ម ដោយលក្ខខ័ណ្ឌថាចំនួនចៅក្រមមិនត្រូវបន្ថយមកនៅតិចជាងចំនួនដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី០១ឡើយ។ ត្រូវចាត់ការចំពោះសំណើរនោះ ស្របតាមនីតិវិធីដែលបាន

ចែងនៅក្នុងអនុកថាខ័ណ្ឌ(ក)និង(ខ)។ ក្នុងករណីដែលសំណើរនោះត្រូវបានអនុម័តចំនួនចៅក្រម ត្រូវកាត់បន្ថយតាមអាត្រាកំណើនតាមអាណត្តិបំរើការងាររបស់ចៅក្រម ផុតកំណត់ រហូតដល់នៅសល់ចំនួនដែលចាំបាច់។

៣. (ក). ចៅក្រមត្រូវជ្រើសរើសចេញពីក្នុងចំណោមបុគ្គលដែលមានចរិកសីលធម៌ខ្ពស់ មិនលំអៀង និង មានសេចក្តីសុច្ចរិតទៀងត្រង់ ដែលមានគុណសម្បត្តិដែលតម្រូវដោយរដ្ឋរបស់ខ្លួន សំរាប់ការតែងតាំងចូលកាន់តំណែងចៅក្រមថ្នាក់ខ្ពស់បំផុត។

(ខ). រាល់បេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសចូលបំរើការនៅក្នុងតុលាការ ត្រូវ :

(i). បានបង្ហាញថាមានសមត្ថភាពខាងច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌ និបបទពិសោធន៍ទាក់ទងចាំបាច់ជាចៅក្រម ព្រះរាជអាជ្ញា អ្នកការពារក្តី ឬ ក្នុងសម្បទាស្រដៀងគ្នាផ្សេងទៀត នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ឬ

(ii). បានបង្ហាញថាមានសមត្ថភាពខាងផ្នែកទាក់ទងនៃច្បាប់អន្តរជាតិ ដូចជា ច្បាប់មនុស្សធម៌អន្តរជាតិ និង ច្បាប់ស្តីពីសិទ្ធិមនុស្ស និង បទពិសោធន៍ដ៏ទូលំទូលាយនៅក្នុងនីតិសម្បទាវិជ្ជាជីវៈដែលទាក់ទងទៅនឹងការងារចៅក្រមនៃតុលាការ។

(គ). រាល់បេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសចូលបំរើការងារនៅក្នុងតុលាការ ត្រូវមានចំណេះដឹងដ៏ឧត្តម និង ចេះស្ទិនទូវភាសាដែលប្រើការនៅក្នុងតុលាការ យ៉ាងហោចមួយភាសា។

៤. (ក). ការចាត់តាំងបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសចូលបំរើការនៅក្នុងតុលាការ អាចធ្វើដោយរដ្ឋណាមួយដែលជាភាគីក្នុងច្បាប់លក្ខន្តិកៈនេះ និង ត្រូវធ្វើឡើងតាម :

(១). នីតិវិធីសំរាប់ការចាត់តាំងបេក្ខជនសំរាប់ការតែងតាំងឱ្យចូលកាន់តំណែងចៅក្រមជាន់ខ្ពស់បំផុតនៅក្នុងរដ្ឋនោះ ឬ

(២). នីតិវិធីដែលមានចែងសំរាប់ការចាត់តាំងបេក្ខជនសំរាប់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) នៅក្នុងច្បាប់លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិនោះ។

ការចាត់តាំងទាំងឡាយត្រូវអមដោយរបាការណ៍លំអិតតាមការិតដែលចាំបាច់ បញ្ជាក់ថា បេក្ខជនបំពេញលក្ខខ័ណ្ឌនៃកថាខ័ណ្ឌទី០៣ យ៉ាងណា។

(ខ). រដ្ឋភាគីនីមួយៗ អាចដាក់បេក្ខជនមួយរូបសំរាប់ការបោះឆ្នោតណាមួយ ដោយបេក្ខជននោះ មិនចាំបាច់តែជាពលរដ្ឋរបស់រដ្ឋភាគីនោះឡើយ ប៉ុន្តែ ក្នុងករណីណាក៏ដោយត្រូវតែជាពលរដ្ឋរបស់រដ្ឋភាគីមួយ។

(គ). ប្រសិនបើសមស្រប សន្និបាតនៃរដ្ឋភាគីទាំងឡាយ អាចសំរេចបង្កើតនូវគណៈកម្មាធិការប្រឹក្សាសំរាប់ការចាត់តាំង។ នៅក្នុងករណីនោះ សមាសភាព និង អាណត្តិរបស់គណៈកម្មាធិការ ត្រូវបង្កើតឡើងដោយសន្និបាតនៃរដ្ឋភាគីទាំងឡាយ។

៥. សំរាប់គោលបំណងនៃការបោះឆ្នោត ត្រូវមានបញ្ជីបេក្ខជនពីរប្រភេទ :

បញ្ជីបេក្ខជនប្រភេទ "ក" មានចុះ ឈ្មោះរបស់បេក្ខជន ព្រមទាំងគុណសម្បត្តិដែលចែងបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី ០៣(ខ)(i). និង

បញ្ជីបេក្ខជនប្រភេទ "ខ" មានចុះឈ្មោះរបស់បេក្ខជន ព្រមទាំងគុណសម្បត្តិដែលចែងបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី ០៣(ខ)(ii)។

បេក្ខជនដែលមានគុណសម្បត្តិគ្រប់គ្រាន់សំរាប់បញ្ជីទាំងពីរ អាចជ្រើសចុះឈ្មោះក្នុងបញ្ជីណាមួយក៏បាន។ នៅក្នុងការបោះឆ្នោតជ្រើសរើសចូលបំរើការងារក្នុងតុលាការលើកទីមួយ យ៉ាងហោច ចៅក្រមប្រាំបួននាក់ ត្រូវបានបោះឆ្នោតជ្រើសរើសពីបញ្ជី "ក" និងយ៉ាងហោចចៅក្រមប្រាំនាក់ពីបញ្ជី "ខ"។ ការបោះឆ្នោតជ្រើសរើសបន្តបន្ទាប់ទៀត ត្រូវរៀបចំឡើងដោយរក្សាទុកនូវសមាមាត្រស្មើគ្នាក្នុងតុលាការនូវចៅក្រមដែលមានគុណសម្បត្តិនៅក្នុងបញ្ជីទាំងពីរ ។

៦. (ក). ចៅក្រម ត្រូវបោះជ្រើសរើសដោយសន្លឹកឆ្នោតសំងាត់ នៅក្នុងការប្រជុំរបស់សន្និបាតនៃរដ្ឋភាគីទាំងឡាយ ដែល ប្រព្រឹត្តធ្វើឡើងសំរាប់គោលបំណងក្នុងមាត្រា១១២។ យោងតាមកថាខ័ណ្ឌទី៧ ជនទាំងឡាយដែលជាប់ឆ្នោះ ត្រូវជាបេក្ខជនទាំង១៨នាក់ ដែលបានទទួលចំនួនសន្លឹកឆ្នោតខ្ពស់បំផុត និង មានចំនួនភាគច្រើនពីរភាគបីនៃរដ្ឋភាគីទាំងឡាយមានវត្តមាននិងបោះឆ្នោត។

(ខ). នៅក្នុងករណី ដែលមិនមានចៅក្រមគ្រប់ចំនួន ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងការបោះឆ្នោតលើកទីមួយទេ ការបោះឆ្នោតស្ទួនបន្ត (successive bollots) ត្រូវធ្វើឡើង ស្របតាមនីតិវិធីដែលមានកំណត់ទុកក្នុងអនុកថាខ័ណ្ឌ (ក) រហូតទាល់បំពេញគ្រប់កន្លែងដែលនៅសល់។

៧. មិនអាចមានចៅក្រមពីររូបជាពលរដ្ឋរបស់រដ្ឋតែមួយដូចគ្នាទេ។

សំរាប់គោលបំណងនៃសមាជិកភាពនៅក្នុងតុលាការ ជនម្នាក់អាចចាត់ទុកជាពលរដ្ឋរបស់រដ្ឋច្រើនជាងមួយ ត្រូវសន្មត់ថាជាពលរដ្ឋរបស់រដ្ឋដែលជននោះអនុវត្តនូវសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយជាប្រក្រតី។

៨. (ក).នៅក្នុងការជ្រើសរើសចៅក្រម រដ្ឋភាគីទាំងឡាយ ត្រូវយកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការ នៅក្នុងសមាជិកភាពនៃតុលាការ សំរាប់ :

(i). ការតំណាងនូវប្រព័ន្ធច្បាប់ជាគោលទាំងឡាយនៃពិភពលោក

(ii). ការតំណាងខាងភូមិសាស្ត្រដែលមានសមធម៌

(iii). ការតំណាងត្រឹមត្រូវនូវចៅក្រមជាបុរស និង ចៅក្រមជាស្ត្រី

(ខ). រដ្ឋភាគីទាំងឡាយ ត្រូវយកចិត្តទុកដាក់ផងដែរចំពោះសេចក្តីត្រូវការបញ្ចូលចៅក្រមដែលមានជំនាញផ្នែកច្បាប់លើបញ្ហាជាក់លាក់ រួមមាន តែមិនកំរិតចំពោះ អំពើហិង្សាលើស្ត្រីនិងកុមារ ។

៩. (ក). ជាកម្មវត្ថុនៃអនុកថាខ័ណ្ឌ (ខ) ចៅក្រមត្រូវកាន់តំណែងសំរាប់អាណត្តិប្រាំបួនឆ្នាំ និង ជាកម្មវត្ថុនៃអនុកថាខ័ណ្ឌ (គ) និង តាមមាត្រា ៣៧ កថាខ័ណ្ឌទី ០២ មិនត្រូវមានសិទ្ធិសំរាប់ការបោះឆ្នោតសារជាថ្មីម្តងទៀតទេ ។

(ខ). នៅក្នុងការបោះឆ្នោតលើកទីមួយ មួយភាគបីនៃចៅក្រមដែលជាប់ឆ្នោត ត្រូវជ្រើសរើសដោយការចាប់ឈ្មោះឱ្យបំរើការសំរាប់អាណត្តិបីឆ្នាំ មួយភាគបីនៃចៅក្រមដែលជាប់ឆ្នោត ត្រូវជ្រើសរើសដោយការចាប់ឈ្មោះ ឱ្យបំរើការសំរាប់អាណត្តិប្រាំមួយឆ្នាំ ហើយចៅក្រមជាប់ឆ្នោតដែលនៅសល់ត្រូវបំរើការសំរាប់អាណត្តិប្រាំបួនឆ្នាំ ។

(គ). ចៅក្រមដែលត្រូវបានជ្រើសរើសឱ្យបំរើការសំរាប់អាណត្តិបីឆ្នាំ អនុលោមតាមអនុកថខ័ណ្ឌ(ខ) ត្រូវមានសិទ្ធិឈរឈ្មោះសំរាប់ការបោះឆ្នោតសារជាថ្មីម្តងទៀតសំរាប់អាណត្តិពេញលេញបាន ។

១០. ថ្វីបើមាន កថាខ័ណ្ឌទី០៩ ចៅក្រមដែលត្រូវបានចាត់ឱ្យធ្វើការក្នុងសភាជំនុំជំរះ ឬ សភាឧទ្ធរណ៍ ស្របតាមមាត្រា ៣៩ ត្រូវបន្តការងាររបស់ខ្លួនដើម្បីបញ្ចប់នូវការជំនុំជំរះ ឬ ការឧទ្ធរណ៍ណា ដែលមានការចាប់ផ្តើមសវនាការនៅក្នុងសភានោះទៅហើយ ។

## មាត្រា ៣៧ : អំពីការនៅទំនេរតំណែងចៅក្រម

១. ក្នុងករណីតំណែងនៅទំនេរ ត្រូវរៀបចំធ្វើការបោះឆ្នោត ស្របតាមមាត្រា៣៦ ដើម្បីបំពេញតំណែងដែលនៅទំនេរនោះ ។

២. ចៅក្រមដែលត្រូវបានបោះឆ្នោតជ្រើសរើសឱ្យបំពេញតំណែងដែលនៅទំនេរ ត្រូវបំរើការសំរាប់រយៈពេលដែលនៅសល់នៃអាណត្តិរបស់ចៅក្រមមុន (predecessor's term) និង បើសិនរយៈពេលដែលនៅសល់នោះគឺបីឆ្នាំ ឬ ខ្វះជាងបីឆ្នាំ អនុលោមតាមមាត្រា៣៦ ត្រូវមានសិទ្ធិឈរឈ្មោះសំរាប់ការបោះឆ្នោតសារជាថ្មីម្តងទៀតសំរាប់អាណត្តិពេញលេញ ។

## មាត្រា ៣៨ : អំពីធិបតីប្រធាន

១. ប្រធាន និង អនុប្រធានទីមួយនិងទីពីរ ត្រូវបោះឆ្នោតជ្រើសរើសដោយសំលេងភាគច្រើនដាច់ខាតនៃចៅក្រម ។ ពួកគេម្នាក់ៗ ត្រូវបំរើការសំរាប់អាណត្តិបីឆ្នាំ ឬ រហូតដល់ចុងបញ្ចប់នៃអាណត្តិរបស់ខ្លួនជាចៅក្រម ដោយយកតាមករណីមួយណាដែលផុតកំណត់មុនគេ ។ ពួកគេអាចមានសិទ្ធិឈរឈ្មោះសំរាប់ការបោះឆ្នោតសារជាថ្មីបានម្តងទៀត ។

២. អនុប្រធានទីមួយ ត្រូវដើរតួជាប្រធាន ក្នុងករណីដែល ប្រធានមិនទំនេរ ឬ បាត់គុណសម្បត្តិ។ អនុប្រធានទីពីរ ត្រូវដើរតួជាប្រធាន ក្នុងករណីដែល ទាំងប្រធាន និង អនុប្រធានទីមួយមិនទំនេរ ឬ បាត់គុណសម្បត្តិ។

៣. ប្រធាន ជាមួយនឹង អនុប្រធានទីមួយ និង អនុប្រធានទីពីរ ត្រូវបង្កបង្កើតជាធិបតីប្រធាន ដែលត្រូវទទួលខុសត្រូវចំពោះ :

(ក). ការគ្រប់គ្រងរដ្ឋបាលត្រឹមត្រូវនៃតុលាការ លើកលែងតែការិយាល័យព្រះរាជអាជ្ញា. និង

(ខ). មុខងារផ្សេងៗទៀតដែលត្រូវបានប្រគល់ឱ្យខ្លួន ស្របតាមច្បាប់លក្ខន្តិកៈនេះ។

៤. នៅក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួនតាមកថាខ័ណ្ឌទី០៣(ក) ធិបតីប្រធាន ត្រូវសម្របសម្រួលជាមួយ និង ស្វែងរកការស្របគ្នាជាមួយព្រះរាជអាជ្ញាលើរាល់បញ្ហានៃការព្រួយបារម្ភទូទៅភាគី។

## មាត្រា ៣៩ : អំពីសភា (Chambers)

១. តាមការឆាប់បំផុត បន្ទាប់ពីការបោះឆ្នោតជ្រើសរើសចៅក្រម តុលាការត្រូវរៀបចំខ្លួនជាផ្នែកៗតាមដែលមានចែងបញ្ជាក់នៅមាត្រា៣៤ កថាខ័ណ្ឌ(ខ)។ ផ្នែកឧទ្ធរណ៍ ត្រូវមានសមាសភាព ប្រធាន និង ចៅក្រមបួនរូបផ្សេងទៀត ផ្នែកជំនុំជំរះមានសមាសភាពមិនតិចជាងចៅក្រមប្រាំមួយរូប និង ផ្នែកមុនការជំនុំជំរះមានសមាភាពមិនតិចជាងចៅក្រមប្រាំមួយរូប។ ការចាត់ចៅក្រមចូលក្នុងផ្នែកទាំងឡាយ ត្រូវផ្អែកលើប្រភេទនៃមុខងារដែលត្រូវបំពេញដោយផ្នែកនីមួយៗ និង គុណសម្បត្តិព្រមទាំងបទពិសោធន៍របស់ចៅក្រមដែលជាប់ឆ្នោតជ្រើសរើសឱ្យបំរើការនៅក្នុងតុលាការ តាមរបៀបមួយដែលផ្នែកនីមួយៗត្រូវមានបន្សំសមរម្យនូវអ្នកមានជំនាញខាងច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ និងខាងច្បាប់អន្តរជាតិ។ ផ្នែកមុនការជំនុំជំរះ និង ផ្នែកជំនុំជំរះ ត្រូវមានសមាសភាពអធិកភាព (ភាគច្រើន)នូវចៅក្រមដែលមានបទពិសោធន៍ខាងជំនុំជំរះបទល្មើសព្រហ្មទណ្ឌ។

២. (ក). មុខងារចៅក្រមនៃតុលាការ ត្រូវបំពេញតាមផ្នែកនីមួយៗតាមរយៈសភា។

(ខ)(i). សភាឧទ្ធរណ៍ ត្រូវមានសមាសភាពនៃចៅក្រមផ្នែកឧទ្ធរណ៍ទាំងអស់

(ii). មុខងាររបស់សភាជំនុះជំរះ ត្រូវបំពេញដោយចៅក្រមបីរូបក្នុងចំណោមចៅក្រមផ្នែកជំនុំជំរះ

(iii). មុខងាររបស់សភាមុនការជំនុំជំរះ ត្រូវបំពេញដោយ ចៅក្រមបីរូបនៃចៅក្រមផ្នែកជំនុំជំរះ ឬ ដោយចៅក្រមតែមួយរូបនៃផ្នែកនោះ ស្របតាមច្បាប់លក្ខន្តិកៈនេះ និង វិធាននៃនីតិវិធីនិងភស្តុតាង

(គ). គ្មានអ្វីនៅក្នុងកថាខ័ណ្ឌនេះ ត្រូវប្រានចោលជាមុន(preclude)នូវការបង្កើតឡើងដំណាលៗគ្នានូវសភាជំនុំជំរះ ឬ សភាមុនការជំនុំជំរះ ច្រើនជាងមួយក្នុងពេលតែមួយឡើយ បើសិនការគ្រប់គ្រងមានប្រសិទ្ធភាពនូវបន្ទុកការងាររបស់តុលាការ តម្រូវឱ្យធ្វើ។

៣. (ក). ចៅក្រមដែលត្រូវបានចាត់ឱ្យនៅក្នុងផ្នែកមុនការជំនុំជំរះ និង ផ្នែកជំនុំជំរះ ត្រូវបំរើការក្នុងផ្នែកនោះសំរាប់រយៈពេលបីឆ្នាំ និង បន្ទាប់មករហូតដល់បញ្ចប់នូវករណីរឿងក្តីណាមួយដែលសវនាការនៅក្នុងផ្នែកនោះបានចាប់ផ្តើមធ្វើទៅហើយ ។

(ខ). ចៅក្រមដែលត្រូវចាត់ឱ្យនៅក្នុងផ្នែកឧទ្ធរណ៍ ត្រូវបំរើការក្នុងផ្នែកនោះសំរាប់រយៈពេលទាំងមូលនៃអាណត្តិរបស់ខ្លួន ។

៤. ចៅក្រមដែលត្រូវបានចាត់ឱ្យនៅក្នុងផ្នែកឧទ្ធរណ៍ ត្រូវបំរើតែនៅក្នុងផ្នែកនោះតែប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ គ្មានអ្វីនៅក្នុងមាត្រានេះ ត្រូវប្រានចោលជាមុននូវការដាក់ជាបណ្តោះអាសន្នចៅក្រមពីផ្នែកជំនុំជំរះ ទៅក្នុងផ្នែកមុនការជំនុះជំរះ ឬ បញ្ច្រាសមកវិញឡើយ បើសិនធិបតីប្រធានពិចារណាថាការគ្រប់គ្រងមានប្រសិទ្ធភាពនូវបន្ទុកការងាររបស់តុលាការតម្រូវឱ្យធ្វើ ដោយក្នុងលក្ខខ័ណ្ឌថា គ្មានករណីណាដែលចៅក្រមដែលចូលរួមនៅក្នុងតំណាក់កាលមុនការជំនុំជំរះនៃករណីរឿងក្តីមួយ អាចមានសិទ្ធិអង្គុយនៅក្នុងសភាជំនុំជំរះធ្វើសវនាការករណីនោះបានឡើយ ។

## មាត្រា ៤០ : អំពីឯករាជ្យភាពនៃចៅក្រម

១. ចៅក្រម ត្រូវមានឯករាជ្យនៅក្នុងការបំពេញមុខងាររបស់ខ្លួន ។

២. ចៅក្រមមិនត្រូវភ្ជាប់ការចូលរួមក្នុងសកម្មភាពណាមួយដែលទំនងជាជ្រៀតជ្រែកក្នុងមុខងារចៅក្រមរបស់ខ្លួន ឬប៉ះពាល់ដល់ទំនុកចិត្តក្នុងឯករាជ្យភាពរបស់ខ្លួនឡើយ ។

៣. ចៅក្រមទាំងឡាយដែលតម្រូវឱ្យបំរើការលើមូលដ្ឋានពេញម៉ោង នៅឯអាសនៈរបស់តុលាការ មិនត្រូវភ្ជាប់ការចូលរួមនៅក្នុងមុខរបរនៃប្រភេទវិជ្ជាជីវៈណាមួយផ្សេងទៀតឡើយ ។

៤. រាល់ចំណោទបញ្ហាទាក់ទងទៅនឹងការអនុវត្តន៍កថាខ័ណ្ឌទី២និងទី៣ ត្រូវសំរេចដោយសំលេងភាគច្រើនដាច់ខាតនៃចៅក្រម ។បើមានចំណោទបញ្ហាទាក់ទងទៅនឹងចៅក្រមណាមួយចៅក្រមនោះមិនត្រូវចូលរួមក្នុងការសំរេចឡើយ ។

## មាត្រា ៤១ : អំពីការបញ្ចេញ និង ការបាត់គុណសម្បត្តិនៃចៅក្រម

១. ដោយមានការស្នើរបស់ចៅក្រម ធិបតីប្រធាន អាចបញ្ចេញចៅក្រមនោះពីការអនុវត្តន៍មុខងារ តាមច្បាប់លក្ខន្តិកៈនេះ ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង ។

២. (ក). ចៅក្រមមិនត្រូវចូលរួមនៅក្នុងករណីរឿងក្តីណាមួយដែលមានមូលហេតុណាមួយថាមានវិមតិសង្ស័យសមហេតុផលពីភាពលំអៀងរបស់ខ្លួន ។ ចៅក្រមត្រូវបាត់គុណសម្បត្តិពីករណីរឿងក្តី ស្របតាមកថាខ័ណ្ឌនេះ បើក្នុង

ចំណោមរឿងផ្សេងៗ (if, inter alia) ចៅក្រមនោះបានពាក់ព័ន្ធនៅក្នុងសម្បទាណាមួយពីមុនមកក្នុងករណីដែលតុលាការកំពុងធ្វើការជំនុំជំរះ ឬ ក្នុងករណីព្រហ្មទណ្ឌដែលទាក់ទងនៅកំរិតជាតិពាក់ព័ន្ធលើជនដែលកំពុងត្រូវរងការស៊ើបអង្កេត ឬ កំពុងត្រូវនាំយកមកជំនុំជំរះ។ ចៅក្រមនឹងបាត់គុណសម្បត្តិផងដែរ ដោយសារមូលហេតុផ្សេងៗទៀត ដូចអាចមានចែងក្នុងវិធាននៃនីតិវិធីនិងភស្តុតាង។

(ខ). ព្រះរាជអាជ្ញា ឬ ជនដែលកំពុងត្រូវរងការស៊ើបអង្កេត ឬ កំពុងត្រូវបាននាំយកមកជំនុំជំរះ អាចស្នើសុំការបាត់គុណសម្បត្តិនៃចៅក្រម តាមកថាខ័ណ្ឌនេះបាន។

(គ). ចំណោទបញ្ហាណាមួយលើការបាត់គុណសម្បត្តិរបស់ចៅក្រម ត្រូវសំរេចដោយសំលេងភាគច្រើនដាច់ខាតនៃចៅក្រម។ ចៅក្រមដែលត្រូវប្រជែងតវ៉ានោះ ត្រូវមានសិទ្ធិបង្ហាញយោបល់របស់ខ្លួនលើបញ្ហានោះ ប៉ុន្តែ មិនត្រូវចូលរួមក្នុងការសំរេចឡើយ។

## មាត្រា ៤២ : អំពី ការិយាល័យអយ្យការ

១- ការិយាល័យអយ្យការ ត្រូវធ្វើសកម្មភាពដោយឯករាជ្យ ក្នុងនាមជាអង្គការដាច់ដោយឡែកមួយរបស់តុលាការ។ ការិយាល័យនេះ ត្រូវទទួលខុសត្រូវលើការទទួលការបញ្ជូននានា(referals) និង ពត៌មានណាមួយដែលបានចង្អុលភស្តុតាងអំពីបទល្មើសព្រហ្មទណ្ឌ នៅក្នុងយុត្តាធិការរបស់តុលាការ ដើម្បីពិនិត្យបទល្មើសទាំងនោះ និង ដើម្បីធ្វើការស៊ើបអង្កេត និងធ្វើការនាំយកមកជំនុំជំរះ នៅចំពោះមុខតុលាការ។ សមាជិកនៃការិយាល័យនេះ មិនត្រូវស្វែងរក ឬ ធ្វើសកម្មភាព តាមការណែនាំពីប្រភពខាងក្រៅណាមួយឡើយ ។

២- ការិយាល័យនេះ ត្រូវដឹកនាំដោយព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញានោះ ត្រូវមានអំណាចពេញលេញលើការគ្រប់គ្រង និង កិច្ចការរដ្ឋបាលនៃការិយាល័យ រួមមាន បុគ្គលិក គ្រឿងសម្រួលការផ្សេងៗ ធនធានដទៃទៀតនៃកិច្ចការរដ្ឋបាលនោះ។ ព្រះរាជអាជ្ញានោះ ត្រូវបានជួយជ្រោមជ្រែងដោយព្រះរាជអាជ្ញារងម្នាក់ ឬ ច្រើននាក់ ដែលមានសិទ្ធិអនុវត្តសកម្មភាពណាដែលតម្រូវឱ្យអនុវត្តដោយព្រះរាជអាជ្ញា តាមច្បាប់លក្ខន្តិកៈនេះ។ ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងទាំងឡាយ ត្រូវមានសញ្ជាតិផ្សេងគ្នា។ ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង ត្រូវបំរើការងារនេះពេញម៉ោង ។

៣- ព្រះរាជអាជ្ញានិងព្រះរាជ្ជអាជ្ញារងទាំងឡាយ ត្រូវតែជាបុគ្គលមានសីលធម៌ខ្ពស់ សមត្ថភាពខ្ពស់ក្នុងការងារ ហើយមានបទពិសោធអនុវត្តន៍ជាក់ស្តែងទូលំទូលាយខាងការនាំយកមកជំនុំជំរះ ឬ ខាងការជំរះក្តីនៃករណីរឿងក្តីព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញា និង ព្រះរាជ្ជអាជ្ញារងទាំងឡាយ ត្រូវមានចំណេះល្អឥតខ្ចោះ និង ស្ទាត់ជំនាញខាង ភាសាមួយយ៉ាងតិច នៃភាសាការងារទាំងឡាយរបស់តុលាការ ។

៤- ព្រះរាជអាជ្ញា ត្រូវជ្រើសរើសឡើង តាមការបោះឆ្នោតសម្ងាត់ ដោយមតិភាគច្រើនដាច់ខាតនៃសមាជិកសន្និបាតនៃរដ្ឋភាគី។ ព្រះរាជអាជ្ញារងទាំងឡាយ ត្រូវជ្រើសរើសឡើងតាមវិធីដូចគ្នា ពីបញ្ជីបេក្ខជនតាមការស្នើឡើងដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា ត្រូវតែងតាំងបេក្ខជនបីនាក់ សម្រាប់មុខតំណែងនីមួយៗនៃព្រះរាជអាជ្ញារង ដែលត្រូវជ្រើសរើសនោះ។ លើកលែងតែមានការសំរេចអំពីអាណត្តិខ្លីជាងនៅពេលបោះឆ្នោត ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងទាំងឡាយ ត្រូវកាន់តំណែងសំរាប់អាណត្តិប្រាំបួនឆ្នាំ និង មិនត្រូវមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោសារជាថ្មីទៀតឡើយ ។

៥- ទាំងព្រះរាជអាជ្ញា ទាំងព្រះរាជអាជ្ញារងទាំងឡាយ មិនត្រូវជាប់ពាក់ពន្ធ័សកម្មភាពណាមួយ ដែលទំនងជាជ្រៀតជ្រែកដល់មុខងារនៃការនាំយកមកជំនុំជំរះរបស់ខ្លួន ឬ ទំនងជាប៉ះពាល់ដល់សេចក្ដីទុកចិត្តនៃឯករាជ្យភាពរបស់ខ្លួនឡើយ។ ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងទាំងឡាយ មិនត្រូវជាប់ពាក់ពន្ធ័ក្នុងសកម្មភាពមុខរបរណាមួយដែលមានលក្ខណៈជាវិជ្ជាជីវៈឡើយ ។

៦- ធិបតីភាព អាចអនុគ្រោះ មិនចាត់វិធានការលើករណីជាក់លាក់ណាមួយ ដល់ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង តាមការស្នើសុំរបស់គេ។

៧- ទាំងព្រះរាជអាជ្ញា ទាំងព្រះរាជអាជ្ញារង មិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលអាចមានហេតុផលនាំឱ្យមានវិមតិសង្ស័យ លើភាពឥតលំអៀងរបស់ខ្លួន ទោះដោយមូលហេតុណាក៏ដោយ។ ព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញារង ត្រូវបាត់គុណសម្បត្តិពីរឿងក្ដីនោះ ស្របតាមកថាខ័ណ្ឌនេះ ប្រសិនបើក្នុងនោះព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញារង ធ្លាប់ជាប់ពាក់ព័ន្ធពីមុនក្នុងរឿងក្ដីនោះនៅក្នុងតុលាការ ទោះជាក្នុងឋានៈអ្វីក៏ដោយ ឬ ក្នុងសំណុំរឿងព្រហ្មទណ្ឌដែលពាក់ព័ន្ធនៅក្នុងកំរិតជាតិ ដែលពាក់ព័ន្ធនឹងជនដែលកំពុងត្រូវរងការស៊ើបអង្កេត ឬ ត្រូវបាននាំយកមកជំនុំជំរះនោះ ។

៨- រាល់បញ្ហាដែលទាក់ទងដល់ការបាត់គុណសម្បត្តិរបស់ព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញារង ចេញពីករណីរឿងក្ដីនោះ ត្រូវសំរេចដោយសភាឧទ្ធរណ៍ ។

(ក) នៅពេលណាក៏បាន ជនដែលកំពុងរងការស៊ើបអង្កេត ឬ កំពុងត្រូវបាននាំយកមកជំនុំជំរះ អាចស្នើសុំពីការបាត់គុណសម្បត្តិរបស់ព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញារង ពីករណីរឿងក្ដីនោះ តាមមូលហេតុណាមួយ ដែលបានកំណត់នៅក្នុងមាត្រានេះ.

(ខ) បើសមស្រប ព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញារង ត្រូវមានសិទ្ធិបញ្ចេញមតិយោបល់របស់ខ្លួនលើបញ្ហានោះ

៩- ព្រះរាជអាជ្ញា ត្រូវតែងតាំងទីប្រឹក្សាដែលមានជំនាញខាងច្បាប់លើបញ្ហាជាក់លាក់នានា រួមមាន ប៉ុន្តែមិនកំរិតដែនកំណត់ត្រឹមនេះឡើយ អំពើបង្ខំសេពសន្ថវៈ និង ការបំពានផ្នែកយេនឌ័រ ព្រមទាំងអំពើហឹង្សាប្រឆាំងនឹងកុមារ ។

## មាត្រា ៤៣ : អំពី ក្រឡាបញ្ជី

១- ផ្នែកក្រឡាបញ្ជី ត្រូវទទួលខុសត្រូវកិច្ចការផ្នែករដ្ឋបាលដែលមានទិដ្ឋភាពមិនមែនកិច្ចការរដ្ឋបាលនិងសេវាកម្មរបស់តុលាការឡើយ ដោយមិនមានអគតិចមិចំពោះមុខងារ និង អំណាចរបស់ព្រះរាជអាជ្ញាស្រមតាមមាត្រា ៤២ ឡើយ ។

២- ផ្នែកក្រឡាបញ្ជី ត្រូវដឹកនាំដោយក្រឡាបញ្ជី ដែលត្រូវជាមន្ត្រីរដ្ឋបាលគោលរបស់តុលាការ ។ ក្រឡាបញ្ជី ត្រូវអនុវត្តមុខងាររបស់ខ្លួន តាមការអនុញ្ញាតរបស់ប្រធានតុលាការ ។

៣- ក្រឡាបញ្ជី និង ក្រឡាបញ្ជីរង ត្រូវតែជាបុគ្គលដែលមានសីលធម៌ខ្ពស់ មានសមត្ថភាពខ្ពស់ និង ត្រូវមានចំណេះល្អឥតខ្ចោះក្នុងការងារ ព្រមទាំងស្ទាត់ជំនាញខាងភាសាមួយយ៉ាងតិចនៃភាសាការងារទាំងឡាយរបស់តុលាការ ។

៤- ចៅក្រមទាំងឡាយត្រូវជ្រើសរើស ក្រឡាបញ្ជី តាមការបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាត ដោយត្រូវពិចារណានូវអនុសាសន៍ ដែលធ្វើឡើងដោយសន្និបាតនៃរដ្ឋភាគីផងដែរ ។ ប្រសិនបើសេចក្តីត្រូវការកើនឡើង ហើយមានអនុសាសន៍របស់ក្រឡាបញ្ជីទៀតនោះ ចៅក្រម ត្រូវជ្រើរើសតាមរយៈវិធីដូចគ្នា នូវក្រឡាបញ្ជីរងម្នាក់ ។

៥- ក្រឡាបញ្ជី ត្រូវកាន់តំណែងអាណត្តិប្រាំឆ្នាំ ដែលមានសិទ្ធិឱ្យគេជ្រើសរើសជាថ្មីបានតែម្តងទៀតទេ និងត្រូវបំរើការងារពេញម៉ោង ។ ក្រឡាបញ្ជីរង ត្រូវកាន់តំណែងអាណត្តិប្រាំឆ្នាំ ឬ ក៏អាណត្តិខ្លីជាងនេះ

ដែលសំរេចដោយមតិភាគច្រើនដាច់ខាតរបស់ចៅក្រម ហើយអាចនឹងត្រូវគេជ្រើសរើស តាមមូលដ្ឋាន ដែលថាក្រឡាបញ្ជីរង នឹងត្រូវហៅមកបំរើការ តាមសេចក្តីត្រូវការចាំបាច់ ។

៦- ក្រឡាបញ្ជី ត្រូវបង្កើតឡើងនូវអង្គភាពការពារជនរងគ្រោះនិងសាក្សី នៅក្នុងផ្នែកក្រឡាបញ្ជី។ ដោយមានការពិគ្រោះយោបល់ជាមួយការិយាល័យអយ្យការ អង្គភាពនេះ ត្រូវផ្តល់នូវវិធានការការពារនានា និង ការរៀបចំខាងសន្តិសុខ ការផ្តល់ឱវាទនិងជំនួយការសមស្របដទៃទៀតឱ្យដល់សាក្សី ជនរងគ្រោះ ដែលបង្ហាញខ្លួននៅចំពោះមុខតុលាការ និង ជនដទៃទៀតដែលឋិតក្នុងសភាពគ្រោះថ្នាក់ បណ្តាលមកពីការផ្តល់សក្ខីកម្មដោយសាក្សី។ អង្គភាពនេះ ត្រូវឱ្យមានបុគ្គលិកដែលមានជំនាញខាងការប៉ះទង្គិចផ្លូវចិត្ត រួមទាំងការប៉ះទង្គិចផ្លូវចិត្តដែលទាក់ទងទៅនឹងអំពើបទល្មើសព្រហ្មទណ្ឌនៃការបំពានផ្លែកភេទ ។

## មាត្រា៤៤ : អំពី បុគ្គលិក

១- ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី ត្រូវតែងតាំងបុគ្គលិកមានលក្ខណៈសម្បត្តិក្នុងការងារ ដូចដែលតម្រូវឱ្យមានសំរាប់ការិយាល័យនីមួយៗ។ ចំពោះព្រះរាជអាជ្ញាវិញ ការតែងតាំងនេះត្រូវរួមមានទាំងការតែងតាំង អ្នកស៊ើបអង្កេតផងដែរ ។

២- ក្នុងការជ្រើសរើសបុគ្គលិកធ្វើការ ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី ត្រូវធានាថាមានបទដ្ឋានខ្ពស់បំផុតផ្នែកប្រសិទ្ធភាព សមត្ថភាព សុចរិតភាព ហើយបើចាំបាច់ ត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងកថាខ័ណ្ឌទី៨នៃមាត្រា ៣៦។

៣- ដោយមានការយល់ព្រមរបស់ធិបតីប្រធាននិងព្រះរាជអាជ្ញា ក្រឡាបញ្ជី ត្រូវដាក់ស្នើបទបញ្ជាគ្រប់គ្រងបុគ្គលិក ដែលមានទាំងខចែងនិងលក្ខខ័ណ្ឌនានាអំពីការតែងតាំង ការបើកប្រាក់បំណាច់ និង ការបណ្តេញចេញនៃបុគ្គលិករបស់តុលាការ។ បទបញ្ជាគ្រប់គ្រងបុគ្គលិកនោះ ត្រូវអនុម័តយល់ព្រមដោយសន្និបាតនៃរដ្ឋភាគី ។

៤- ក្នុងកាលៈទេសៈពិសេស តុលាការ អាចទទួលបុគ្គលិកជំនាញឱ្យបំរើការ ដែលធ្វើការមិនយកកម្រៃ ដែលផ្តល់ដោយរដ្ឋភាគី អង្គការអន្តរដ្ឋាភិបាល ឬ អង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីជួយកិច្ចការនានារបស់អង្គភាពណាមួយរបស់តុលាការ។ ព្រះរាជអាជ្ញា អាចទទួលយកសំណើផ្តល់បុគ្គលិកនោះ ក្នុងនាម

ការិយាល័យអយ្យការ។ បុគ្គលិកដែលធ្វើការមិនយកកម្រៃនេះ ត្រូវបានទទួលឱ្យបំរើការ ស្របតាមគោលការណ៍ណែនាំនានា ដែលនឹងបង្កើតឡើងដោយសន្និបាតនៃរដ្ឋភាគី។

## មាត្រា ៤៥ : អំពី ការប្រកាសជាឱឡារិក

តាមច្បាប់លក្ខន្តិកៈនេះ មុនពេលទទួលភារកិច្ចរបស់ខ្លួនរៀងខ្លួន ចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី ក្រឡាបញ្ជីរង ត្រូវធ្វើការប្រកាសជាឱឡារិកមួយ នៅក្នុងតុលាការជាសាធារណៈថានឹងបំពេញមុខងាររបស់ខ្លួនរៀងខ្លួន ដោយឥតលំអៀង និង ដោយមនសិការខ្ពស់ ។

## មាត្រា៤៦ : អំពី ការបញ្ឈប់ពីការងារ

១- ត្រូវបានបញ្ឈប់ពីការងារនូវចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី ក្រឡាបញ្ជីរង ប្រសិនបើមានសេចក្ដីសំរេចបញ្ឈប់ពីការងារដែលធ្វើឡើង ស្របតាមកថាខ័ណ្ឌទី២ ក្នុងករណីដែលបុគ្គលនោះ :

(ក) ត្រូវគេរកឃើញថាបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ឬ បានបំពានធ្ងន់ធ្ងរលើភារកិច្ចរបស់ខ្លួន តាមច្បាប់លក្ខន្តិកៈនេះ ដូចមានចែងនៅក្នុងវិធាននៃនីតិវិធីនិងភស្តុតាង, ឬ

(ខ) គ្មានលទ្ធភាពបំពេញមុខងារទាំងឡាយដែលតម្រូវដោយច្បាប់លក្ខន្តិកៈនេះ។

២- សេចក្ដីសំរេចអំពីការបញ្ឈប់នូវចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ពីការងារ តាមកថាខ័ណ្ឌទី១ ត្រូវសំរេចដោយសន្និបាតនៃរដ្ឋភាគី តាមការបោះឆ្នោតជាសម្ងាត់ :

(ក) ចំពោះករណីចៅក្រម តាមមតិភាគច្រើនពីរភាគបីនៃរដ្ឋភាគី តាមអនុសាសន៍ ដែលអនុម័តដោយមតិភាគច្រើនពីរភាគបីនៃចៅក្រមដទៃទៀត។

(ខ) ចំពោះករណីព្រះរាជអាជ្ញា តាមមតិភាគច្រើនដាច់ខាតនៃរដ្ឋភាគី។

(គ) ចំពោះករណីព្រះរាជអាជ្ញារង តាមមតិភាគច្រើនដាច់ខាតនៃរដ្ឋភាគី តាមអនុសាសន៍របស់ព្រះរាជអាជ្ញា។

៣- សេចក្តីសំរេចអំពីការបញ្ឈប់ ក្រឡាបញ្ជី ឬ ក្រឡាបញ្ជីរង ពីការងារ តាមកថាខ័ណ្ឌទី១ ត្រូវសំរេច ដោយមតិភាគច្រើនដាច់ខាតរបស់ចៅក្រមទាំងឡាយ ។

៤- ចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី ឬ ក្រឡាបញ្ជីរង ដែលមានការប្រព្រឹត្ត ឬ លទ្ធភាពបំពេញមុខងារនៃតំណែងរបស់ខ្លួន ដូចដែលតម្រូវដោយច្បាប់លក្ខន្តិកៈនេះ ត្រូវបានប្រជែងតវ៉ា ក្រោមមាត្រានេះ ត្រូវមានឱកាសយ៉ាងពេញលេញក្នុងការបង្ហាញ និង ទទួលភស្តុតាង ព្រមទាំងធ្វើការ ដាក់ជូន ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង។ បុគ្គលដែលឋិតក្នុងចំណោទបញ្ហានោះ មិនត្រូវចូលរួម ក្នុងការពិចារណាលើបញ្ហានោះទេ។

## មាត្រា ៤៧ : អំពី វិធានការដាក់វិន័យ

ចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី ឬ ក្រឡាបញ្ជីរងណា ដែលប្រព្រឹត្តកំហុស មិនសូវធ្ងន់ធ្ងរដូចកំហុសដែលបានចែងក្នុងនៅក្នុងកថាខ័ណ្ឌទី១នៃមាត្រា ៤៦ ទេនោះ ត្រូវជាកម្មវត្ថុនៃវិធាន ការដាក់វិន័យនេះ ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង។

## មាត្រា ៤៨ : អំពី បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ

១- តុលាការ ត្រូវមានបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ នៅលើដែនដីនៃរដ្ឋភាគីនីមួយៗ ដែលចាំបាច់សម្រាប់ ការបំពេញការងារ តាមគោលបំណងរបស់តុលាការ ។

២- នៅពេលបំពេញភារកិច្ច ឬ ដោយគោរពតាមភារកិច្ចរបស់តុលាការ ចៅក្រម ព្រះរាជអាជ្ញា ព្រះរាជ អាជ្ញារង និង ក្រឡាបញ្ជី ត្រូវមានបុព្វសិទ្ធ និង អភ័យឯកសិទ្ធិ ដូចដែលបានផ្តល់ដល់ប្រមុខនៃបេសក កម្មការទូតនានា ហើយបន្ទាប់ពីការផុតកំណត់នៃអាណត្តិបំពេញការងាររបស់ខ្លួនហើយនោះ ត្រូវបានបន្ត ផ្តល់អភ័យឯកសិទ្ធិពីដំណើរការផ្នែកច្បាប់រាល់គ្រប់សកម្មភាព ទាក់ទងលើពាក្យសំដីដែលបាននិយាយ ដោយផ្ទាល់មាត់ ឬ ពាក្យសំដីជាលាយល័ក្ខអក្សរ ព្រមទាំងសកម្មភាពទាំងឡាយដែលពួកគេបំពេញក្នុង សម្បទាផ្លូវការរបស់ខ្លួន។

៣- ក្រឡាបញ្ជីរង និង បុគ្គលិកនៃការិយាល័យអយ្យការ និង បុគ្គលិកនៃការិយាល័យផ្នែកក្រឡាបញ្ជី ត្រូវមានបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ ព្រមទាំងមធ្យោបាយសម្រួលការចាំបាច់ទាំងឡាយ ដើម្បីបំពេញមុខងាររបស់ខ្លួន ស្របតាមកិច្ចព្រមព្រៀងស្តីពី បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិរបស់តុលាការ ។

៤- អ្នកការពារ អ្នកជំនាញ សាក្សី ឬ បុគ្គលណាមួយដែលតម្រូវឱ្យមានវត្តមាននៅឯអាសនៈរបស់តុលាការ ត្រូវបានផ្តល់ឱ្យនូវបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិនោះ តាមការចាំបាច់ ដើម្បីឱ្យការប្រព្រឹត្តទៅរបស់តុលាការ ប្រព្រឹត្តទៅដោយសមរម្យ ស្របតាមកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់តុលាការ ។

៥- បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ របស់ :

(ក) ចៅក្រម ឬ ព្រះរាជអាជ្ញា អាចត្រូវបានបដិសេធវិញ តាមមតិភាគច្រើនដាច់ខាត់របស់ចៅក្រម

(ខ) ក្រឡាបញ្ជី អាចត្រូវបានបដិសេធវិញ ដោយធិបតីប្រធាន

(គ) ព្រះរាជអាជ្ញារង និង បុគ្គលិកនៃការិយាល័យអយ្យការ ត្រូវបានបដិសេធវិញ ដោយព្រះរាជអាជ្ញា

(ឃ) ក្រឡាបញ្ជីរង និង បុគ្គលិកនៃការិយាល័យផ្នែកសៀវភៅបញ្ជីអាចត្រូវបានបដិសេធវិញដោយក្រឡាបញ្ជី ។

## មាត្រា៤៩ : អំពី ប្រាក់បៀវត្ស វិភាជន៍ និង ប្រាក់ចំណាយ

ចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី ឬ ក្រឡាបញ្ជីរង ត្រូវទទួលបាក់បៀវត្ស វិភាជន៍ និង ប្រាក់ចំណាយផ្សេងៗ តាមសេចក្តីសំរេចរបស់សន្និបាតនៃរដ្ឋភាគី។ ប្រាក់បៀវត្ស និង វិភាជន៍ទាំងនេះ មិនត្រូវបានកាត់បន្ថយឡើយ ក្នុងកំឡុងពេលនៃការបំពេញការងារក្នុងអាណត្តិ ។

## មាត្រា៥០ : អំពី ភាសាការងារ និងភាសាផ្លូវការ

១- ភាសាផ្លូវការរបស់តុលាការ គឺភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្ប៉ាញ។ សាលក្រម តុលាការ ក៏ដូចជា សេចក្តីសំរេចដទៃទៀត ដែលដោះស្រាយបញ្ហាជាមូលដ្ឋានទាំងឡាយនៅក្នុង តុលាការ ត្រូវបោះពុម្ពផ្សាយជាភាសាផ្លូវការទាំងឡាយ។ ធិបតីប្រធាន ត្រូវកំណត់នូវសេចក្តីសំរេច នានាដែលពិចារណាថាសេចក្តីសំរេចមួយណា ជាដំណោះស្រាយបញ្ហាជាមូលដ្ឋាន សំរាប់គោលបំណងនៃ កថាខ័ណ្ឌនេះ ស្របតាមលក្ខណៈវិនិច្ឆ័យដែលបង្កើតឡើងដោយវិធាននៃនីតិវិធីនិងភស្តុតាង។

២- ភាសាការងាររបស់តុលាការ គឺភាសាអង់គ្លេស និង បារាំង។ វិធាននៃនីតិវិធីនិងភស្តុតាង ត្រូវកំណត់ ករណីណាខ្លះ ដែលត្រូវប្រើភាសាផ្លូវការផ្សេងៗទៀត ជាភាសាការងារដែរ ។

៣- តាមសំណើរបស់ភាគីណាមួយអំពីដំណើរការជំរះរឿងក្តី ឬ តាមសំណើររបស់រដ្ឋណាមួយដែលបានការ អនុញ្ញាតឱ្យធ្វើអន្តរាគមន៍ដល់ដំណើរការជំរះរឿងក្តី, តុលាការ ត្រូវអនុញ្ញាតឱ្យប្រើភាសាផ្សេងទៀត ក្រៅពីភាសាអង់គ្លេស ឬ បារាំង ទៅតាមសំណើរបស់ភាគី ឬ រដ្ឋនោះបាន, ដរាបណា តុលាការ ពិចារណាថ្លឹងថ្លែងយ៉ាងគ្រប់គ្រាន់អំពីការអនុញ្ញាតនោះ ។

## មាត្រា ៥១ : អំពី វិធាននៃនីតិវិធីនិងភស្តុតាង

១- វិធាននៃនីតិវិធីនិងភស្តុតាង ត្រូវចូលជាធរមាន តាមការអនុម័តដោយមតិភាគច្រើនពីរភាគបីនៃសមាជិកសន្និបាតនៃរដ្ឋភាគី។

២- ការធ្វើវិសោធនកម្ម ចំពោះវិធាននៃនីតិវិធីនិងភស្តុតាង អាចស្នើឡើងដោយ :

(ក) រដ្ឋភាគីណាមួយ

(ខ)ចៅក្រម ដែលបំពេញភារកិច្ច តាមមតិភាគច្រើនដាច់ខាត, ឬ

(គ) ព្រះរាជអាជ្ញា

ការធ្វើវិសោធនកម្មនេះ ត្រូវចូលជាធរមាន តាមការអនុម័តដោយមតិភាគច្រើនពីរភាគបីនៃសមាជិកសន្និបាតនៃរដ្ឋភាគី ។

៣- ក្នុងករណីនៃការចូលជាធរមានជាប្រញាប់ ដែលមិនមានចែងអំពីស្ថានភាពជាក់លាក់ចំពោះមុខតុលាការ បន្ទាប់ពីការអនុម័តនូវវិធាននៃនីតិវិធីនិងភស្តុតាងនោះដោយមតិភាគច្រើនពីរភាគបី, ចៅក្រម អាចបង្កើតឡើងនូវវិធានបណ្តោះអាសន្នដើម្បីអនុវត្តរហូតដល់វិធានបណ្តោះអាសន្ននោះ ត្រូវបានអនុម័ត ត្រូវបានធ្វើវិសោធនកម្ម ឬ ត្រូវបានបដិសេធចោល នៅក្នុងសម័យប្រជុំពិសេសឬសាមញ្ញនាពេលបន្ទាប់របស់សន្និបាតនៃរដ្ឋភាគី ។

៤- វិធាននៃនីតិវិធីនិងភស្តុតាង ការធ្វើវិសោធនកម្មលើវិធាននោះ និង វិធានបណ្តោះអាសន្ន ត្រូវធ្វើស្របតាមច្បាប់លក្ខន្តិកៈនេះ ។ ការធ្វើវិសោធនកម្មលើវិធាននៃនីតិវិធីនិងភស្តុតាង ក៏ដូចជា វិធានបណ្តោះអាសន្នដែរ មិនត្រូវមានប្រតិសកម្មនាំឱ្យខូចប្រយោជន៍នៃជនដែលកំពុងឋិតក្រោមការស៊ើបអង្កេត ឬ ការនាំយកមកជំនុំជំរះ ឬ ជនដែលត្រូវបានតុលាការផ្តន្ទាទោសឡើយ ។

៥- ក្នុងករណីមានការផ្ទុយគ្នា រវាងច្បាប់លក្ខន្តិកៈនេះជាមួយនិងវិធាននៃនីតិវិធីនិងភស្តុតាង ច្បាប់លក្ខន្តិកៈនេះត្រូវមានអានុភាពលុបលើវិធាននោះ ។

## មាត្រា ៥២ : អំពី បទបញ្ជាតុលាការ

១- ស្របតាមច្បាប់លក្ខន្តិកៈនេះ និង វិធាននៃនីតិវិធីនិងភស្តុតាង ចៅក្រម ត្រូវតែអនុម័តនូវបទបញ្ជាតុលាការចាំបាច់ទាំងឡាយសំរាប់ដំណើរការជាប្រក្រតីរបស់ខ្លួន ដោយមតិភាគច្រើនដាច់ខាត ។

២- ត្រូវមានការពិគ្រោះយោបល់ជាមួយព្រះរាជអាជ្ញា និង ក្រឡាបញ្ជី នូវភាពពិស្តារនៃបទបញ្ជា និង ការធ្វើវិសោធនកម្មលើបទបញ្ជានោះ ។

៣- បទបញ្ជា និង វិសោធនកម្មលើបទបញ្ជានោះ ត្រូវចូលជាធរមាននៅពេលត្រូវបានអនុម័ត លើកលែងតែមានសេចក្តីសំរេចផ្សេងពីនេះ ដោយចៅក្រម ។ បន្ទាប់ពីអនុម័តហើយភ្លាម សេចក្តីអនុម័តលើបទបញ្ជា

និង វិសោធនកម្មលើបទបញ្ជានោះ ត្រូវបញ្ជូនចែកចាយជូនដល់រដ្ឋភាគីទាំងឡាយ ដើម្បីស្នើសុំមតិយោបល់។ ប្រសិនបើ មិនមានការជំទាស់ពីរដ្ឋភាគីភាគច្រើនទេ នៅក្នុងកំឡុងពេលប្រាំមួយខែ សេចក្តីអនុម័តលើបទបញ្ជា និង វិសោធនកម្មលើបទបញ្ជានោះ ត្រូវនៅមានជាធរមាន។

## ភាគទី ៥ : ការស៊ើបអង្កេត និង ការនាំយកមកជំនុំជំរះ

### មាត្រា ៥៣ : អំពីការផ្តួចផ្តើមការស៊ើបអង្កេត

១. ដោយបានវាយតម្លៃលើពត៌មានដែលព្រះរាជអាជ្ញារកបាន ព្រះរាជអាជ្ញា ត្រូវផ្តួចផ្តើមធ្វើការស៊ើបអង្កេត លើកលែងតែព្រះរាជអាជ្ញាសំរេចថា មិនមានមូលដ្ឋានសមហេតុផលក្នុងការដំណើការជំរះរឿងក្តីក្រោមច្បាប់លក្ខន្តិកៈនេះ។ ក្នុងការសំរេចចិត្តថាត្រូវផ្តើមស៊ើបអង្កេតឬអត់នោះ ព្រះរាជអាជ្ញាត្រូវពិចារណាថា :

(ក) តើពត៌មានដែលព្រះរាជអាជ្ញារកបាននោះ មានមូលដ្ឋានសមហេតុផលឱ្យជឿទុកចិត្តបានថាបទល្មើសដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ត្រូវបានជនល្មើសប្រព្រឹត្ត ឬ កំពុងត្រូវបានជនល្មើសប្រព្រឹត្ត

(ខ) តើរឿងក្តីនេះអាច ឬ នឹងអាចទទួលយកបានក្រោមមាត្រា ១៧, និង

(គ) ដោយពិចារណាចំពោះភាពធ្ងន់ធ្ងរនៃបទល្មើស និង ផលប្រយោជន៍របស់ជនរងគ្រោះ តើមានហេតុផលសមរម្យដែល ទោះជាយ៉ាងណា ធ្វើអោយជឿថាការស៊ើបអង្កេត នឹងមិនបំរើប្រយោជន៍យុត្តិធម៌ទេ។

ប្រសិនបើព្រះរាជអាជ្ញាសំរេចថា មិនមានមូលដ្ឋានសមហេតុផលក្នុងការដំណើការជំរះរឿងក្តី ហើយការសំរេចរបស់ខ្លួនផ្អែក តែទៅលើអនុកថាខ័ណ្ឌ(គ) ខាងលើប៉ុណ្ណោះ ព្រះរាជអាជ្ញាត្រូវតែជូនដំណឹងមកសភាមុនការជំនុំជំរះ។

២. ក្រោយពេលស៊ើបអង្កេត បើសិនជាព្រះរាជអាជ្ញាសន្និដ្ឋានថា មិនមានមូលដ្ឋានគ្រប់គ្រាន់សំរាប់ការនាំខ្លួនមកជំនុំជំរះ ដោយសារ :

(ក) មិនមានមូលដ្ឋានអង្គហេតុ ឬ អង្គច្បាប់គ្រប់គ្រាន់ដើម្បីចេញដីកាចាប់ខ្លួន ឬដីកាកោះហៅឱ្យចូលខ្លួន តាមមាត្រា៥៨

(ខ) ករណីរឿងក្តីនេះមិនអាចទទួលយកបានក្រោមមាត្រា ១៧ ឬ

(គ) ការនាំយកមកជំនុំជំរះមិនបំរើប្រយោជន៍យុត្តិធម៌ ដោយបានពិចារណាលើគ្រប់កាលៈទេសៈទាំងអស់ រួមទាំងភាពធ្ងន់ធ្ងរនៃបទល្មើសព្រហ្មទណ្ឌ ប្រយោជន៍របស់ជនរងគ្រោះ ព្រមទាំងអាយុ ឬពិការភាពរបស់ជនជាប់ចោទ និងតួនាទីរបស់គេ ក្នុងអំពើល្មើសព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ឡើង។

ព្រះរាជអាជ្ញាត្រូវជូនដំណឹងមកសភាមុនការជំនុំជំរះ និង មករដ្ឋដែលបានលើករឿងក្តីនេះឡើងក្រោមមាត្រា១៤ ឬ មកក្រុមប្រឹក្សាសន្តិសុខតាមកថាខ័ណ្ឌ(ខ)នៃមាត្រា១៣ អំពីការសន្និដ្ឋានរបស់ខ្លួន និងអំពីហេតុផលនៃការសន្និដ្ឋាននោះ។

៣. (ក) តាមសំណើសុំរបស់រដ្ឋដែលបានលើករឿងក្តីនេះឡើងក្រោមមាត្រា ១៤ ឬ តាមសំណើរបស់ក្រុមប្រឹក្សាសន្តិសុខ ក្រោមកថាខ័ណ្ឌ(ខ)នៃមាត្រា១៣ សភាមុនការជំនុំជំរះអាចពិនិត្យឡើងវិញនូវសេចក្តីសំរេចមិនដំណើរការជំរះរឿងក្តីរបស់ព្រះរាជអាជ្ញា តាមកថាខ័ណ្ឌទី១ ឬទី២ ហើយអាចធ្វើសំណើសុំឱ្យព្រះរាជអាជ្ញាពិចារណាលើសេចក្តីសំរេចនោះឡើងវិញ ។

(ខ) ជាងនេះទៅទៀត តាមគំនិតផ្តួចផ្តើមផ្ទាល់របស់សភាមុនការជំនុំជំរះ ខ្លួនអាចពិនិត្យឡើងវិញនូវសេចក្តីសំរេចមិនដំណើរការជំរះរឿងក្តីរបស់ព្រះរាជអាជ្ញា បើសេចក្តីសំរេចនេះផ្អែកតែទៅលើកថាខ័ណ្ឌទី១(គ) ឬទី២(គ)ប៉ុណ្ណោះ ។ ក្នុងករណីនេះ សេចក្តីសំរេចរបស់ព្រះរាជអាជ្ញាមានប្រសិទ្ធភាពបាន កាលណា សភាមុនការជំនុំជំរះយល់ស្របតាម ។

៤. នៅពេលណាក៏បានព្រះរាជអាជ្ញាអាចពិចារណាឡើងវិញលើសេចក្តីសំរេចថាតើត្រូវផ្តួចផ្តើមការស៊ើបអង្កេត ឬ ការនាំយកមកជំនុំជំរះដោយផ្អែកលើអង្គហេតុ ឬ ពត៌មានថ្មីៗ ។

### មាត្រា ៥៤ : អំពីភារៈកិច្ច និង អំណាចរបស់ព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការស៊ើបអង្កេត

១. ព្រះរាជអាជ្ញា :

(ក) ដើម្បីប្រមូលនូវការពិត ត្រូវពង្រីកការស៊ើបអង្កេតដើម្បីគ្របដណ្តប់គ្រប់អង្គហេតុ និង ភស្តុតាងពាក់ព័ន្ធនឹងការវាយតម្លៃ ថាតើមានឬគ្មានការទទួលខុសត្រូវខាងព្រហ្មទណ្ឌក្រោមច្បាប់លក្ខន្តិកៈនេះ ហើយដើម្បីធ្វើការនេះ ត្រូវស៊ើបអង្កេតប្រកបដោយសមភាព លើកាលៈទេសៈសង្ស័យជាប់ជំពាក់ក្នុងបទល្មើសព្រហ្មទណ្ឌ និង កាលៈទេសៈរួចពីពិរុទ្ធភាព ។

(ខ) ត្រូវចាត់វិធានការសមស្របដើម្បីធានាដល់ការស៊ើបអង្កេត និង ការនាំយកមកជំនុំជំរះប្រកបដោយប្រសិទ្ធភាព ក្រោមយុត្តាធិការតុលាការនេះ ហើយដើម្បីធ្វើការនេះ ត្រូវគោរពនូវប្រយោជន៍ និងកាលៈទេសៈបុគ្គលនៃជនរងគ្រោះ និង សាក្សី រួមមានអាយុ ភេទ ដូចមានចែងក្នុងកថាខ័ណ្ឌទី៣ នៃមាត្រា៧ និងរួមទាំងសុខភាពទៀតផង ហើយត្រូវពិចារណាលើចរិកលក្ខណៈនៃបទល្មើសព្រហ្មទណ្ឌនោះ ជាពិសេសកាលណាមានការពាក់ព័ន្ធជាមួយការបំពានខាងផ្លូវភេទ ការបំពានខាងជែនឌ័រ ឬ អំពើហិង្សាប្រឆាំងនឹងកុមារ, និង

(គ) គោរពយ៉ាងពេញលេញនូវសិទ្ធិបុគ្គលទាំងឡាយដែលបានលើកឡើងក្រោមច្បាប់លក្ខន្តិកៈនេះ ។

២. ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតលើទឹកដីនៃរដ្ឋមួយ :

(ក) ដោយស្របតាមបទប្បញ្ញត្តិនៃភាគទី៩ . ឬ

(ខ) ដោយមានការអនុញ្ញាតរបស់សភាជំនុំជំរះ ស្របតាម កថាខ័ណ្ឌទី ៣(ឃ) នៃមាត្រា ៥៧

៣. ព្រះរាជអាជ្ញា :

(ក) អាចប្រមូល និង ពិនិត្យភស្តុតាង

(ខ) អាចសុំឱ្យបង្ហាញខ្លួន និង សួរចំលើយ ជនដែលកំពុងត្រូវបានស៊ើបអង្កេត ជនរងគ្រោះ និងសាក្សី

(គ) អាចស្វែងរកកិច្ចសហប្រតិបត្តិការពីបណ្តារដ្ឋ ឬ អង្គការអន្តររដ្ឋាភិបាលនានា ឬ អាចស្វែងរកការចាត់ចែងណាមួយ ស្របតាមសមត្ថកិច្ច និង/ឬ អាណត្តិរៀង១ខ្លួន ។

(ឃ) អាចធ្វើការចាត់ចែង ឬ កិច្ចព្រមព្រៀង ដែលមិនផ្ទុយពីច្បាប់លក្ខន្តិកៈនេះ ហើយដែលអាចជាការចាំបាច់ ដើម្បីសម្រួលដល់កិច្ចសហប្រតិបត្តិការពីរដ្ឋ អង្គការអន្តររដ្ឋាភិបាល ឬ ពីបុគ្គលណាមួយ ។

(ង) នៅដំណាក់កាលណាមួយនៃដំណើរការជំរះរឿងក្តី អាចយល់ព្រមមិនលាតត្រដាងបង្ហាញនូវឯកសារ ឬ ពត៌មានដែលព្រះរាជអាជ្ញាទទួលបានក្នុងលក្ខខ័ណ្ឌរក្សាអាថិកំបាំង ឬ ក្នុងលក្ខខ័ណ្ឌដើម្បីបង្កើនភស្តុតាងថ្មីតែប៉ុណ្ណោះ លើកលែងតែអ្នកផ្តល់ពត៌មាន នោះបានយល់ព្រម ។ និង

(ច) អាចចាត់វិធានការចាំបាច់ ឬ ស្នើសុំឱ្យមានវិធានការចាំបាច់ ដើម្បីធានាអាថិកំបាំងនៃពត៌មាន ធានាការពារបុគ្គលណាមួយ ឬ ធានាការរក្សាភស្តុតាង ។

## មាត្រា ៥៥ : អំពីសិទ្ធិរបស់បុគ្គលក្នុងកំឡុងពេលស៊ើបអង្កេត

១. ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតក្រោមច្បាប់លក្ខន្តិកៈនេះ ជនមួយរូប :

(ក) មិនត្រូវគេបង្ខំឱ្យទំលាក់ការជាប់ជំពាក់ក្នុងបទល្មើសព្រហ្មទណ្ឌលើខ្លួនឯង ឬ បង្ខំឱ្យទទួលសារភាពពិរុទ្ធភាពឡើយ

(ខ) មិនត្រូវជាកម្មវត្ថុនៃការបង្ខិតបង្ខំ អំពើហិង្សា ឬ ការគំរាមកំហែងក្រោមរូបភាពណាមួយ ឬ ជាកម្មវត្ថុនៃការធ្វើទារុណកម្ម ឬ នៃការដាក់ទណ្ឌកម្មក្រោមរូបភាពណាមួយ ដែលមានសភាពសាហាវយង់ឃ្នង អមនុស្សធម៌ និងបន្ទាបបន្ថោកសេចក្តីថ្លៃថ្នូរជាមនុស្សឡើយ ។

(គ) បើសិនការសួរចម្លើយធ្វើឡើងជាភាសាដទៃក្រៅពីភាសាដែលជននោះអាចយល់ និង និយាយបានពេញលេញ ត្រូវមានជំនួយដោយឥតគិតថ្លៃនៃអ្នកបកប្រែភាសាដែលមានសមត្ថភាព ហើយការបកប្រែនោះ គឺចាំបាច់ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃភាពយុត្តិធម៌ ។

(ឃ) មិនត្រូវជាកម្មវត្ថុនៃការចាប់ខ្លួន ឬការឃុំខ្លួនដោយបំពាន ហើយមិនត្រូវបានគេដកហូតសិទ្ធិសេរីភាព លើកលែងតែ មានមូលដ្ឋានដូចដែល និង ស្របតាមនីតិវិធីដែលមានចែងឡើងនៅក្នុងច្បាប់លក្ខន្តិកៈនេះ ។

៤. ខណៈដែលមានមូលដ្ឋានធ្វើអោយជឿថា ជននោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌក្រោមយុត្តាធិការរបស់តុលាការ ហើយជននោះ ជិតត្រូវបានព្រះរាជអាជ្ញាសួរចម្លើយ ឬ ជិតត្រូវបានអាជ្ញាធរជាតិសួរចំលើយ ដោយអនុលោមទៅតាមសំណើដែលធ្វើឡើង ក្រោមភាគទី៩នៃច្បាប់លក្ខន្តិកៈនេះ ជននោះនឹងត្រូវមានផងដែរនូវសិទ្ធិដូចខាងក្រោម ដែលជាសិទ្ធិត្រូវបានគេជូនដំណឹងមុនពេលត្រូវរងការសួរចំលើយ ដូចជា :

(ក) មុនពេលគេសួរចំលើយ ត្រូវបានគេជូនដំណឹងថា មានមូលដ្ឋានធ្វើអោយជឿថា គាត់បានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌក្រោម យុត្តាធិការតុលាការ ។

(ខ) នៅស្ងៀមស្ងាត់ ដោយមិនចាត់ទុកការស្ងៀមស្ងាត់នោះ ដើម្បីកំណត់អំពីពិរុទ្ធភាព ឬ និរទោសភាពឡើយ

(គ) មានជំនួយផ្នែកច្បាប់តាមការជ្រើសរើសរបស់ជននោះ ឬប្រសិនបើជននោះគ្មានជំនួយផ្នែកច្បាប់ទេ ជននោះត្រូវមានជំនួយផ្នែកច្បាប់ដែលត្រូវបានគេចាត់ឱ្យខ្លួន ក្នុងករណីណាមួយដែលប្រយោជន៍នីយុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និង ដោយគ្មានបង់ប្រាក់ឈ្នួលអ្វីឡើយ ប្រសិនបើជននោះគ្មានមធ្យោបាយគ្រប់គ្រាន់សម្រាប់បង់ប្រាក់ឈ្នួលនោះ ។

(ឃ) ក្នុងពេលសួរចំលើយ ត្រូវតែមានវត្តមានស្មារក្ដីនៃជននោះ លើកលែងតែជននោះស្ម័គ្រចិត្តបោះបង់សិទ្ធិត្រូវមានស្មារក្ដីនេះ ។

មាត្រា ៥៦ : អំពីតួនាទីរបស់សភាមុនការជំនុំជំរះពាក់ព័ន្ធនឹងឱកាសនៃការស៊ើបអង្កេតតែម្តងគត់

១. (ក) កាលណាព្រះរាជអាជ្ញាពិចារណាទៅឃើញថា ការស៊ើបអង្កេតបង្ហាញនូវឱកាសតែម្តងគត់ក្នុងការស្រង់យកសក្ខីកម្ម ឬ សេចក្តីថ្លែងការណ៍ពីសាក្សី ឬ ក្នុងការពិនិត្យ ប្រមូល ឬ ពិសោធភស្តុតាងដែលក្រោយមកអាចនឹងរកមិនបាន សម្រាប់គោលបំណងនៃការជំនុំជំរះ ព្រះរាជអាជ្ញាត្រូវតែជូនដំណឹងមកសភាមុនការជំនុំជំរះ ។

(ខ) នៅក្នុងករណីនេះ តាមសំណើរបស់ព្រះរាជអាជ្ញា សភាមុនការជំនុំជំរះ អាចចាត់វិធានការនោះដែលអាចចាំបាច់ដើម្បីធានានូវប្រសិទ្ធភាព និងឯករាជ្យភាពនៃដំណើរការជំរះរឿងក្តី ហើយជាពិសេសដើម្បីការពារនូវសិទ្ធិការពារខ្លួន ។

(គ) លើកលែងតែ សភាមុនការជំនុំជំរះបញ្ជាផ្ទុយពីនេះ ព្រះរាជអាជ្ញា ត្រូវតែផ្តល់ពត៌មានពាក់ព័ន្ធទៅជនដែលត្រូវបានចាប់ខ្លួន ឬដែលត្រូវបង្ហាញខ្លួនតបតាមដីកាកោះហៅឱ្យចូលខ្លួនដែលមានការពាក់ព័ន្ធជាមួយការស៊ើបអង្កេតដែលបានលើកឡើងក្នុង អនុកថាខ័ណ្ឌ(ក) ដើម្បីស្តាប់ជននោះបកស្រាយអំពីរឿងហេតុ ។

២. វិធានការដែលបានលើកឡើងក្នុងកថាខ័ណ្ឌទី១(ខ) អាចរួមមាន :

(ក) ធ្វើអនុសាសន៍ ឬ ចេញបញ្ជាទាំងឡាយដែលពាក់ព័ន្ធនឹងនីតិវិធីដែលត្រូវប្រតិបត្តិតាម

(ខ) ណែនាំឱ្យគេធ្វើកំណត់ហេតុអំពីដំណើរការជំរះរឿងក្តី

(គ) តែងតាំងអ្នកជំនាញដើម្បីជួយ

(ឃ) អនុញ្ញាតឱ្យមានស្មារក្តី សម្រាប់ជនដែលត្រូវបានចាប់ខ្លួន និង ដែលត្រូវបង្ហាញខ្លួននៅមុខតុលាការតបតាមដីកាកោះហៅឱ្យចូលខ្លួន ដើម្បីចូលរួម ឬ កាលណាជននោះមិនទាន់ត្រូវបានចាប់ខ្លួន ឬ បង្ហាញខ្លួននៅឡើយ ឬ ស្មារក្តីមិនទាន់ត្រូវបានចាត់តាំងឡើង ត្រូវតែងតាំងស្មារក្តីមួយរូបផ្សេងទៀត ដើម្បីចូលរួម និង តំណាងផលប្រយោជន៍របស់ចុងចោទ ។

(ង) ចាត់តាំងសមាជិកណាម្នាក់នៃសមាជិកទាំងអស់របស់ខ្លួន បើសិនមានការចាំបាច់ត្រូវចាត់តាំងចៅក្រមដែលអាចរកបានពីចំណោមចៅក្រមរបស់សភាមុនការជំនុំជំរះឬផ្នែកជំនុំជំរះ ដើម្បីសង្កេត និង ធ្វើអនុសាសន៍ ឬ ចេញបញ្ជា ដែលពាក់ព័ន្ធនឹងការប្រមូលនិងរក្សាភស្តុតាង និង ដែលពាក់ព័ន្ធនឹងការសួរចំលើយ ។

(ច) ចាត់វិធានការផ្សេងទៀត ដែលអាចចាំបាច់ ដើម្បីប្រមូលនិងរក្សាភស្តុតាង ។

៣. (ក) កាលណាព្រះរាជអាជ្ញាមិនបានស្វែងរកវិធានការស្របតាមមាត្រានេះ ប៉ុន្តែ សភាជំនុំជំរះពិចារណាឃើញថា វិធានការនោះត្រូវការចាំបាច់ដើម្បីរក្សាភស្តុតាងដែលត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ដើម្បីការការពារខ្លួននៅពេលជំនុំជំរះ សភាមុនការជំនុំជំរះត្រូវតែពិគ្រោះជាមួយព្រះរាជអាជ្ញាក្រែងលោមានហេតុផលល្អឬយ៉ាងណាចំពោះការខកខានរបស់ព្រះរាជអាជ្ញាក្នុងការស្នើសុំវិធានការ ។ ក្រោយពេលពិគ្រោះយោបល់ ប្រសិនបើ សភាមុនការជំនុំជំរះសន្និដ្ឋានថា ការខកខានរបស់ព្រះរាជអាជ្ញាក្នុងការសុំវិធានការបែបនោះមិនត្រឹមត្រូវតាមច្បាប់ នោះ សភាមុនការជំនុំជំរះ អាចចាត់វិធានការបែបនោះតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ។

(ខ) សេចក្តីសម្រេចរបស់សភាមុនការជំនុំជំរះ ក្នុងការធ្វើសកម្មភាពតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ក្រោមកថាខ័ណ្ឌនេះ អាចប្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញាបាន។ បណ្តឹងឧទ្ធរណ៍នឹងត្រូវធ្វើសវនាការផ្អែកលើមូលដ្ឋានលឿនរហ័ស។

៤. ភាពអាចទទួលយកបាននៃភស្តុតាងដែលបានរក្សាទុកឬដែលប្រមូល សម្រាប់ការជំនុំជំរះតាមមាត្រានេះ ឬ កំណត់ហេតុនៃភស្តុតាងនោះ នឹងត្រូវគ្រប់គ្រងនៅពេលជំនុំជំរះដោយមាត្រា៦៩ និង មានទម្ងន់តាមការកំណត់របស់ សភាមុនការជំនុំជំរះ។

## មាត្រា ៥៧ : អំពីមុខងារ និង អំណាចរបស់សភាមុនការជំនុំជំរះ

១. លើកលែងតែមានការចែងផ្ទុយពីច្បាប់លក្ខន្តិកៈនេះ សភាមុនការជំនុំជំរះ ត្រូវអនុវត្តមុខងាររបស់ខ្លួនស្របតាមបទប្បញ្ញត្តិនៃមាត្រានេះ។

២. (ក) បញ្ហា ឬ សេចក្តីសំរេចរបស់សភាមុនការជំនុំជំរះដែលចេញក្រោមមាត្រា ១៥, ១៨, ១៩, កថាខ័ណ្ឌ ទី២នៃមាត្រា៥៤, កថាខ័ណ្ឌទី៧នៃមាត្រា៦១, និងមាត្រា៧២ ត្រូវតែមានការយល់ព្រមដោយមតិភាគច្រើននៃចៅក្រមរបស់ខ្លួន ។

(ខ) ក្នុងករណីផ្សេងៗទៀត ចៅក្រមមួយរូបនៃ សភាមុនការជំនុំជំរះអាចអនុវត្តមុខងារដែលបានចែងនៅក្នុងច្បាប់លក្ខន្តិកៈនេះ លើកលែងតែមានការចែងផ្ទុយនៅក្នុងវិធាននៃនីតិវិធីនិងភស្តុតាង ឬ ដោយសំលេងភាគច្រើននៃសភាមុនការជំនុំជំរះ ។

៣. បន្ថែមលើមុខងារដទៃទៀតរបស់ខ្លួនតាមច្បាប់លក្ខន្តិកៈនេះ :

(ក) តាមសំណើសុំរបស់ព្រះរាជអាជ្ញា សភាមុនការជំនុំជំរះអាចចេញបញ្ជា និង ដីកា ដែលអាចចាំបាច់សម្រាប់គោលបំណងនៃការស៊ើបអង្កេត ។

(ខ) តាមសំណើសុំរបស់ជនដែលត្រូវបានចាប់ខ្លួន ឬ ជនដែលបានបង្ហាញខ្លួនតាមដីកាកោះហៅឱ្យចូលខ្លួនតាមមាត្រា៥៨ សភាមុនការជំនុំជំរះអាចចេញបញ្ជា រួមទាំងវិធានការផ្សេងៗ ដូចយ៉ាង វិធានការទាំងឡាយដែលបានចែងក្នុងមាត្រា៥៦ ឬ អាចស្វែងរកកិច្ចសហប្រតិបត្តិការ អនុលោមតាមភាគទី៩ដែលអាចជាការចាំបាច់សម្រាប់ជួយជននោះ ក្នុងការរៀបចំកិច្ចការពារខ្លួន។

(គ) កាលណាមានការចាំបាច់ សភាមុនការជំនុំជំរះ អាចផ្តល់នូវការការពារនិង ភាពស្ងៀមស្ងាត់គ្មានការរំខានឯកជន (privacy)ដល់ជនរងគ្រោះនិងសាក្សី អាចជួយរក្សាភស្តុតាង អាចជួយការពារជនដែលត្រូវបានចាប់ខ្លួន ឬ ជនដែលបានបង្ហាញខ្លួនតាមដីកាកោះហៅឱ្យចូលខ្លួន និង អាចជួយការពារពត៌មានសន្តិសុខ ជាតិ ។

(ឃ) សភាមុនការជំនុំជំរះ អាចអនុញ្ញាតឱ្យព្រះរាជអាជ្ញាធ្វើការស៊ើបអង្កេតពិសេសណាមួយ ក្នុងទឹកដីនៃរដ្ឋភាគី ដោយគ្មានការធានានៃកិច្ចសហប្រតិបត្តិការពីរដ្ឋភាគីនោះ ក្រោមភាគទី៩ ប្រសិនបើដោយយកចិត្តទុកដាក់តាមដែលអាចធ្វើទៅបាន ចំពោះទស្សនៈយល់ឃើញរបស់រដ្ឋដែលមានការពាក់ព័ន្ធនោះ សភាមុនការជំនុំជំរះបានសំរេចនៅក្នុងករណីនេះថា រដ្ឋនោះមិនមានលទ្ធភាពយ៉ាងជាក់ច្បាស់

ក្នុងការប្រតិបត្តិនូវសំណើសុំកិច្ចសហប្រតិបត្តិការ ដោយសារមិនមានអាជ្ញាធរណាមួយ ឬ អង្គភាពណាមួយនៃប្រព័ន្ធយុត្តាធិការនៃរដ្ឋរបស់ខ្លួន ដែលមានសមត្ថកិច្ចដើម្បីប្រតិបត្តិនូវសំណើសុំកិច្ចសហប្រតិបត្តិការ ក្រោមភាគទី ៩ ទេ។

(ង) កាលណាដីកាចាប់ខ្លួនឬ ដីកាកោះហៅឱ្យចូលខ្លួនត្រូវបានចេញក្រោមមាត្រា៥៨ និង ដោយបានពិចារណាលើអនុភាពនៃភស្តុតាង និងសិទ្ធិនៃបណ្តាភាគីដែលមានការពាក់ព័ន្ធ ដូចមានចែងនៅក្នុងច្បាប់លក្ខន្តិកៈនេះនិងក្នុងវិធាននៃនីតិវិធីនិងភស្តុតាង សភាមុនការជំនុំជំរះ អាចស្វែងរកកិច្ចសហប្រតិបត្តិការពីបណ្តារដ្ឋនានា ស្របតាមកថាខ័ណ្ឌទី១(ញ)នៃមាត្រា៩៣ ដើម្បីចាត់វិធានការការពារសំរាប់គោលបំណងនៃការរឹបអូស ជាពិសេស សំរាប់ជាប្រយោជន៍ដ៏កំពូលរបស់ជនរងគ្រោះ ។

មាត្រា ៥៨ : អំពីការចេញដីកាចាប់ខ្លួននិងដីកាកោះហៅឱ្យចូលខ្លួន ដោយសភាមុនការជំនុំជំរះ

១. នៅពេលណាមួយ បន្ទាប់ពីមានការផ្តួចផ្តើមការស៊ើបអង្កេត តាមរយៈពាក្យសុំរបស់ព្រះរាជអាជ្ញា និង ដោយបានពិនិត្យលើពាក្យសុំនិងភស្តុតាងឬពត៌មានដទៃទៀតដែលដាក់ជូនដោយព្រះរាជអាជ្ញា សភាមុនការជំនុំជំរះត្រូវចេញដីកាចាប់ខ្លួនជនណាមួយ បើសិនបានបំពេញតាមលក្ខខ័ណ្ឌដូចតទៅ :

(ក) មានមូលដ្ឋានសមហេតុផលដែលធ្វើអោយជឿថា ជននោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ក្រោមយុត្តាធិការនៃតុលាការ ។

(ខ) ការចាប់ខ្លួនជននោះ គឺជាការចាំបាច់ :

(1) ដើម្បីធានាថា ជននោះនឹងបង្ហាញខ្លួននៅពេលជំនុំជំរះ

(2) ដើម្បីធានាថា ជននោះមិនបង្កឧបសគ្គ ឬ គ្រោះថ្នាក់ចំពោះការស៊ើបអង្កេត ឬ ដំណើរការជំរះរឿងក្តីនៃតុលាការ ឬ

(3) កាលណាអាចអនុវត្តទៅបាន ដើម្បីបង្ការជននោះមិនឱ្យបន្តប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌនោះ ឬ បទល្មើសព្រហ្មទណ្ឌពាក់ព័ន្ធ ដែលស្ថិតនៅក្រោមយុត្តធិការនៃតុលាការ និងដែលកើតចេញពីកាលៈទេសៈតែមួយដូចគ្នា ។

២. ពាក្យសុំរបស់ព្រះរាជអាជ្ញា ត្រូវមាន :

(ក) ឈ្មោះនៃជននោះ និង ពត៌មានអំពីអត្តសញ្ញាណទាក់ទងដទៃទៀត ។

(ខ) សេចក្តីយោងជាក់លាក់អំពីបទល្មើសព្រហ្មទណ្ឌដែលស្ថិតក្រោមយុត្តាធិការតុលាការ ដែលជននោះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ ។

(គ) សេចក្តីថ្លែងការណ៍សង្ខេបអំពីអង្គហេតុដែលត្រូវបានគេចោទថាបានបង្កើតជាបទល្មើសព្រហ្មទណ្ឌទាំងនោះ ។

(ឃ) សេចក្តីសង្ខេបអំពីភស្តុតាង និង ពត៌មានដទៃទៀត ដែលបង្កើតបានជាមូលដ្ឋានសមហេតុផលដែលធ្វើអោយជឿថា ជននោះបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌទាំងនោះ ។ និង

(ង) ហេតុផលដែលធ្វើអោយព្រះរាជអាជ្ញាជឿថា ការចាប់ខ្លួនជននោះ គឺជាការចាំបាច់ ។

៣. ដីកាចាប់ខ្លួន ត្រូវមាន :

(ក) ឈ្មោះនៃជននោះ និង ពត៌មានអំពីអត្តសញ្ញាណទាក់ទងដទៃទៀត ។

(ខ) សេចក្តីយោងជាក់លាក់អំពីបទល្មើសព្រហ្មទណ្ឌដែលស្ថិតក្រោមយុត្តាធិការតុលាការ ដែលជននោះត្រូវបានស្វែងរកដើម្បីចាប់ខ្លួន ។

(គ) សេចក្តីថ្លែងការណ៍សង្ខេបអំពីអង្គហេតុដែលត្រូវបានគេចោទថាបានបង្កើតជាបទល្មើសព្រហ្មទណ្ឌទាំងនោះ ។

៤. ដីកាចាប់ខ្លួន ត្រូវមានសុពលភាពជានិច្ចរហូតទាល់តែមានបញ្ជាផ្ទុយដែលចេញដោយតុលាការ ។

៥. ដោយឈរលើមូលដ្ឋាននៃដីកាចាប់ខ្លួន តុលាការអាចស្នើសុំអោយមានការចាប់ខ្លួនជាបណ្តោះអាសន្ន ឬ អោយមានការចាប់និងបញ្ជូនខ្លួនជនណាម្នាក់ ក្រោមភាគទី៩ ។

៦. ព្រះរាជអាជ្ញាអាចស្នើសុំសភាមុនការជំនុំជំរះ អោយធ្វើវិសោធនកម្មដីកាចាប់ខ្លួន ដោយកែប្រែឬបន្ថែម បទល្មើសព្រហ្មទណ្ឌដែលបានចែងក្នុងដីកាចាប់ខ្លួននោះ។ សភាមុនការជំនុំជំរះត្រូវធ្វើវិសោធនកម្មដីកា នោះ បើសិនខ្លួនពេញចិត្តថាមានមូលដ្ឋានសមហេតុផល ដែលធ្វើអោយជឿថា ជននោះបានប្រព្រឹត្ត បទល្មើសព្រហ្មទណ្ឌដែលបានកែប្រែនិងបន្ថែមថ្មីនោះ ។

៧. ក្រៅអំពីការសុំដីកាចាប់ខ្លួន ព្រះរាជអាជ្ញាអាចដាក់ពាក្យដើម្បីស្នើសុំអោយ សភាមុនការជំនុំជំរះចេញ ដីកាកោះជននោះឱ្យចូលខ្លួន។ បើសិន សភាមុនការជំនុំជំរះពេញចិត្ត ថាមានមូលដ្ឋានសមហេតុផលដែល ធ្វើឱ្យជឿថាជននោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដូចដែលគេបានចោទ ហើយ ដីកាកោះមានប្រសិទ្ធ ភាពគ្រប់គ្រាន់ដើម្បីធានានូវការចូលខ្លួន សភាមុនការជំនុំជំរះត្រូវចេញដីកាកោះជននោះឱ្យចូលខ្លួន ដោយមានឬគ្មានលក្ខខ័ណ្ឌក៏រិតសិទ្ធិសេរីភាព(ក្រៅអំពីការឃុំឃាំង) បើសិនជាមានចែងដោយច្បាប់ជាតិ ។ ដីកាកោះ ត្រូវមាន :

(ក) ឈ្មោះរបស់ជននោះ និង ពត៌មានអំពីអត្តសញ្ញាណទាក់ទងដទៃទៀត ។

(ខ) កាលបរិច្ឆេទដែលបានកំណត់សំរាប់បជននោះចូលខ្លួន

(គ) សេចក្តីយោងជាក់លាក់អំពីបទល្មើសព្រហ្មទណ្ឌដែលស្ថិតក្រោមយុត្តាធិការតុលាការ ដែលជននោះ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ។ និង

(ឃ) សេចក្តីថ្លែងការណ៍សង្ខេបអំពីអង្គហេតុដែលត្រូវបានគេចោទថាបានបង្កើតជាបទល្មើសព្រហ្មទណ្ឌ ទាំងនោះ ។

ដីកាកោះឱ្យចូលខ្លួនទាំងឡាយត្រូវប្រគល់ឱ្យដល់ដៃជននោះ។

## មាត្រា៥៩ : អំពីដំណើរការចាប់ខ្លួនក្នុងរដ្ឋដែលគ្រប់គ្រងជននោះ

១- រដ្ឋភាគីដែលទទួលបានសំណើសុំការចាប់ខ្លួនជាបណ្តោះអាសន្ន ឬ ការចាប់និងការប្រគល់ខ្លួន ត្រូវចាត់ វិធានការណ៍ជាបន្ទាន់ដើម្បីចាប់ខ្លួនជននេះ ស្របតាមច្បាប់របស់ខ្លួន និង តាមបទប្បញ្ញត្តិក្នុងភាគទី៩។

២- ជនដែលត្រូវបានចាប់ខ្លួន ត្រូវនាំខ្លួនយ៉ាងរហ័ស មកកាន់អាជ្ញាធរយុត្តិធម៌មានសមត្ថកិច្ចនៅក្នុងរដ្ឋដែលគ្រប់គ្រងជននោះ ដែលត្រូវកំណត់ស្របតាមច្បាប់រដ្ឋនោះ ថា :

ក- ដីកាអនុវត្តលើជននោះ

ខ- ជននោះត្រូវចាប់ខ្លួន ស្របតាមដំណើរការត្រឹមត្រូវ. និង

គ- សិទ្ធិរបស់ជននោះត្រូវបានគេគោរព

៣- ជនដែលត្រូវបានចាប់ខ្លួនមានសិទ្ធិដាក់ពាក្យសុំទៅអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋដែលគ្រប់គ្រងជននោះ ឱ្យដោះលែងនៅក្រៅឃុំជាបណ្ដោះអាសន្នក្នុងរយៈពេលរង់ចាំការប្រគល់ខ្លួន។

៤- ក្នុងការសំរេចបានសេចក្តីសំរេចលើពាក្យសុំណាមួយនោះ អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋដែលគ្រប់គ្រងជននោះត្រូវពិចារណា ថាតើមានកាលៈទេសៈបន្ទាន់ ឬ ពិសេស ឬអត់ ដើម្បីធ្វើយុត្តិកម្មលើការដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ចំពោះភាពធ្ងន់ធ្ងរនៃបទល្មើសព្រហ្មទណ្ឌដែលត្រូវគេចោទប្រកាន់ និងថាតើមានការការពារចាំបាច់ឬទេ ដើម្បីធានាថា រដ្ឋដែលគ្រប់គ្រងជននោះអាចបំពេញភារកិច្ចរបស់ខ្លួនដើម្បីប្រគល់ខ្លួនជននោះទៅតុលាការបាន។ វាមិនត្រូវបានបើកចំហរឱ្យអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋដែលគ្រប់គ្រងជននោះពិចារណាថាតើដីកាចាប់ខ្លួនជននោះបានចេញដោយត្រឹមត្រូវ តាមកថាខ័ណ្ឌទី១ (ក)និង(ខ)នៃមាត្រា៥៨ ឬអត់។

៥- សភាមុនការជំនុំជំរះ ត្រូវបានទទួលការជូនដំណឹងពីសំណើសុំដោះលែងនៅក្រៅឃុំជាបណ្ដោះអាសន្ន និងត្រូវផ្តល់អនុសាសន៍ឱ្យទៅអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋដែលគ្រប់គ្រងជននោះ។ អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋដែលគ្រប់គ្រងជននោះ ត្រូវពិចារណាឱ្យបានល្អិតល្អន់លើអនុសាសន៍នោះ រួមទាំងអនុសាសន៍នានាស្តីពីវិធានការណ៍ការពារការរត់គេចខ្លួនរបស់ជននោះមុនពេលចេញសំរេច។

៦- ប្រសិនបើជននោះ ត្រូវបានគេយល់ព្រមដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន សភាមុនការជំនុំជំរះអាចស្នើសុំ របាយការណ៍មួយរយៈម្តង១អំពីស្ថានភាពនៃការដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ននោះ។

៧- នៅពេលដែលត្រូវបញ្ជាឱ្យមានការប្រគល់ខ្លួនដោយរដ្ឋដែលគ្រប់គ្រងជននោះ ជននោះត្រូវបញ្ជូនទៅតុលាការឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។

## មាត្រា៦០ : អំពីដំណើរជំរះរឿងក្តីបឋមនៅតុលាការ

១- នៅពេលមានការប្រគល់ខ្លួនជននោះទៅតុលាការ ឬ មានការចូលបង្ហាញខ្លួនរបស់ជននោះចំពោះមុខតុលាការដោយស្ម័គ្រចិត្ត ឬ អនុលោមតាមដីកាកោះហៅឱ្យចូលខ្លួន សភាមុនការជំនុំជំរះ ត្រូវធ្វើឱ្យខ្លួនឯងពេញចិត្តថាជននោះត្រូវបានគេជូនដំណឹងពីបទល្មើសព្រហ្មទណ្ឌដែលគាត់ត្រូវបានគេចោទប្រកាន់ថាបានប្រព្រឹត្ត និង ពីសិទ្ធិរបស់គាត់ ក្រោមច្បាប់លក្ខន្តិកៈនេះ រួមទាំងសិទ្ធិស្នើសុំឱ្យមានការដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នក្នុងរយៈពេលរង់ចាំការជំនុំជំរះ។

២- ជនណាម្នាក់ដែលជាកម្មវត្ថុនៃដីកាចាប់ខ្លួនអាចស្នើសុំឱ្យដោះលែងនៅក្រៅឃុំជាបណ្តោះអាសន្នក្នុងពេលរង់ចាំការជំនុំជំរះ។ ប្រសិនបើ សភាមុនការជំនុំជំរះ ពេញចិត្តថាលក្ខខ័ណ្ឌដែលមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រា៥៨ ត្រូវបានបំពេញ ជននោះត្រូវនៅក្នុងឃុំជាបន្តទៀត។ ប្រសិនបើសភាមុនការជំនុំជំរះមិនបានពេញចិត្តទេនោះ ខ្លួនត្រូវដោះលែងជននោះ ដោយមានឬដោយ គ្មានលក្ខខ័ណ្ឌ។

៣- សភាមុនការជំនុំជំរះត្រូវត្រួតពិនិត្យឡើងវិញក្នុងមួយរយៈពេលម្តង១នូវការវិនិច្ឆ័យរបស់ខ្លួនលើការដោះលែង ឬលើការឃុំជននោះ ហើយ អាចធ្វើបែបនេះនៅពេលណាក៏បានតាមសំណើរបស់ព្រះរាជអាជ្ញា ឬរបស់ជននោះ។ នៅពេលធ្វើការត្រួតពិនិត្យឡើងវិញនោះ សភាមុនការជំនុំជំរះ អាចកែប្រែការវិនិច្ឆ័យរបស់ខ្លួនទាក់ទង នឹងការឃុំខ្លួន ការដោះលែង ឬ លក្ខខ័ណ្ឌនៃការដោះលែង ប្រសិនបើខ្លួនពេញចិត្តថាកាលៈទេសៈដែលមានការផ្លាស់ប្តូរតម្រូវឱ្យធ្វើ។

៤- សភាមុនការជំនុំជំរះ ត្រូវធានាថាគ្មានជនណាម្នាក់ត្រូវជាប់ឃុំក្នុងរយៈពេលមួយមិនសមហេតុផល មុនពេលមានការជំនុំជំរះ ដែលបណ្តាលមកពីការពន្យាពេលមិនសមស្របរបស់ព្រះរាជអាជ្ញា។ ប្រសិនបើការពន្យាពេលបែបនេះកើតឡើង តុលាការត្រូវពិចារណាលើការដោះលែងជននោះដោយមានឬ ដោយគ្មានលក្ខខ័ណ្ឌ ។

៥. ប្រសិនបើចាំបាច់ សភាមុនការជំនុំជំរះ អាចចេញដីកាចាប់ខ្លួន ដើម្បីធានាវត្តមានរបស់ជនដែលត្រូវបាន ដោះលែង។

## មាត្រា ៦១ : អំពី ការបញ្ជាក់បទចោទប្រកាន់ចំពោះមុខការជំនុំជំរះ

១- ជាកម្មវត្ថុនៃបទប្បញ្ញត្តិនៃកថាខ័ណ្ឌទី២ ក្នុងពេលវេលាសមហេតុផលមួយ បន្ទាប់ពីការប្រគល់ខ្លួន ឬ ការបង្ហាញខ្លួនរបស់ជននោះ ដោយស្ម័គ្រចិត្តនៅចំពោះមុខតុលាការ សភាមុនការជំនុំជំរះ ត្រូវបើក សវនាការ ដើម្បីបញ្ជាក់ពីបទចោទប្រកាន់ ដែលព្រះរាជអាជ្ញាប៉ុនប៉ងស្វែងរកឱ្យមានការជំនុំជំរះ។ សវនាការ ត្រូវបានបើកធ្វើឡើងដោយមានវត្តមាននៃព្រះរាជអាជ្ញា និង ជនជាប់ចោទ ព្រមទាំង អ្នកការពារក្តីរបស់ជនជាប់ចោទផងដែរ ។

២- យោងតាមសំណើររបស់ព្រះរាជអាជ្ញា ឬ តាមសេចក្តីស្នើរបស់ខ្លួនផ្ទាល់ សភាមុនការជំនុំជំរះ អាច បើកសវនាការមួយ ដោយគ្មានវត្តមាននៃជនដែលត្រូវបានចោទប្រកាន់ ដើម្បីបញ្ជាក់អំពីបទចោទ ប្រកាន់ដែល ព្រះរាជអាជ្ញាប៉ងស្វែងរកឱ្យមានការជំនុំជំរះ នៅពេលដែលជននោះ បាន :

(ក) លះបង់ចោលនូវសិទ្ធិរបស់ខ្លួនក្នុងការមានវត្តមាន, ឬ

(ខ) គេចខ្លួន ឬ គេចខ្លួនបាត់រកមិនឃើញ ហើយគ្រប់មធ្យោបាយសមហេតុផលទាំងអស់ត្រូវបាន ប្រើប្រាស់ដើម្បីធ្វើឱ្យគាត់មានវត្តមានចំពោះមុខតុលាការ និងដើម្បីផ្តល់ពតិមានដល់ជននោះ អំពីបទ ចោទប្រកាន់ ហើយថាសវនាការមួយនឹងត្រូវធ្វើឡើងដើម្បីបញ្ជាក់អំពីបទចោទប្រកាន់ទាំងនោះ។ ក្នុងករណីនោះ ជននោះ នឹងត្រូវតំណាងដោយអ្នកការពារក្តី ពេលដែលសភាមុនការជំនុំជំរះកំណត់ ថាការតំណាងនោះ គឺដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ។

៣- ក្នុងពេលវេលាសមហេតុផលមួយ មុនពេលសវនាការ ជននោះត្រូវ :

(ក) បានផ្តល់ឱ្យនូវឯកសារមួយច្បាប់ដែលមានចុះពីបទចោទប្រកាន់ ដែលព្រះរាជអាជ្ញាប៉ងនាំយក ជននោះទៅធ្វើការជំនុំជំរះ, និង

(ខ) បានផ្តល់ឱ្យនូវពតិមានអំពីភស្តុតាង ដែលព្រះរាជអាជ្ញាប៉ងប្រើជាសំអាងក្នុងពេលសវនាការ ។

សភាមុនការជំនុំជំរះ អាចចេញបទបញ្ជានានា អំពីការបង្ហាញពត៌មាន សម្រាប់គោលបំណងនានានៃសវនាការ ។

៤- មុនពេលសវនាការ ព្រះរាជអាជ្ញា អាចបន្តការស៊ើបអង្កេត និង អាចកែប្រែ ឬ ដកចេញបទចោទប្រកាន់ណាមួយវិញបាន ។ ជននោះ ត្រូវបានទទួលការជូនដំណឹងដ៏សមហេតុផល អំពីការកែប្រែ ឬ ការដកចេញបទចោទប្រកាន់ណាមួយនោះ មុនពេលសវនាការ ។ ក្នុងករណីដកចេញវិញនូវបទចោទប្រកាន់ ព្រះរាជអាជ្ញា ត្រូវជូនដំណឹងដល់សភាមុនការជំនុំជំរះអំពីហេតុផលនានា សម្រាប់ការដកចេញវិញនូវបទចោទប្រកាន់នោះ ។

៥- នៅពេលសវនាការ ព្រះរាជអាជ្ញា ត្រូវគាំទ្របទចោទប្រកាន់នីមួយៗ ដោយមានភស្តុតាងយ៉ាងគ្រប់គ្រាន់ ដើម្បីបង្កើតជាមូលហេតុសំខាន់ៗ ដើម្បីឱ្យជឿថា ជននោះបានប្រព្រឹត្តិបទល្មើសដែលត្រូវចោទប្រកាន់ នោះពិតមែន ។ ព្រះរាជអាជ្ញា អាចសំអាងលើភស្តុតាង ជាឯកសារ ឬ សេចក្តីសង្ខេប ហើយ មិនចាំបាច់ ហៅសាក្សី ដែលរំពឹងទុកឱ្យមកផ្តល់សក្ខីកម្មនៅក្នុងការជំនុំជំរះឡើយ ។

៦- នៅពេលសវនាការ ជននោះអាច :

(ក) ជំទាស់ទៅនឹងបទចោទប្រកាន់.

(ខ) ប្រដេងតវ៉ា អំពីភស្តុតាងដែលបានបង្ហាញដោយព្រះរាជអាជ្ញា. និង

(គ) បង្ហាញភស្តុតាង ។

៧- ផ្អែកលើមូលដ្ឋាននៃសវនាការ សភាមុនការជំនុំជំរះ ត្រូវកំណត់ថាតើមានភស្តុតាងគ្រប់គ្រាន់ឬទេ ដើម្បីបង្កើតជាមូលហេតុសំខាន់ ដើម្បីឱ្យជឿថា ជននោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនីមួយៗ ដែលត្រូវបានចោទប្រកាន់ ។ ផ្អែកតាមការកំណត់របស់ខ្លួន សភាមុនការជំនុំជំរះ ត្រូវ :

(ក) បញ្ជាក់អំពីបទចោទប្រកាន់ទាំងឡាយនោះ ដែលទាក់ទងនឹងអ្វីដែលសភាជំនុំជំរះនោះបានកំណត់ថាមានភស្តុតាងគ្រប់គ្រាន់ និង ប្រគល់ជននោះឱ្យសភាជំនុំជំរះ ដើម្បីធ្វើការជំនុំជំរះអំពីបទចោទប្រកាន់ ដូចបានបញ្ជាក់ទាំងនោះ ។

(ខ) បដិសេធមិនបញ្ជាក់អំពីបទចោទប្រកាន់ទាំងឡាយនោះ ដែលទាក់ទងនឹងអ្វី ដែលខ្លួនបានកំណត់ថាគ្មានភស្តុតាងគ្រប់គ្រាន់ទេ ។

(គ) ផ្អាកការធ្វើសវនាការ និង ស្នើសុំព្រះរាជអាជ្ញាឱ្យពិចារណា :

(i) ការផ្តល់ភស្តុតាងបន្ថែម ឬ ធ្វើការស៊ើបអង្កេតបន្ថែមទៀត លើបទចោទប្រកាន់ជាក់លាក់មួយ. ឬ

(ii) កែប្រែបទចោទប្រកាន់ណាមួយ ដោយហេតុថា ភស្តុតាងដែលបានដាក់ជូន បង្ហាញថាមានលេចឡើងនូវបទល្មើសព្រហ្មទណ្ឌផ្សេងមួយទៀត ដែលស្ថិតក្នុងវង្វង់យុត្តាធិការរបស់តុលាការ ។

៨- ពេលដែលសភាមុនការជំនុំជំរះបដិសេធមិនបញ្ជាក់ចំពោះបទចោទប្រកាន់គឺមិនមែនច្រានចោលជាមុន មិនឱ្យព្រះរាជអាជ្ញាស្នើសុំជាបន្តបន្ទាប់នូវការបញ្ជាក់អះអាងរបស់ខ្លួនទេ ប្រសិនបើ សំណើរនោះត្រូវបានគាំទ្រដោយមានភស្តុតាងបន្ថែមទៀត ។

៩- បន្ទាប់ពីការចោទប្រកាន់ត្រូវបានបញ្ជាក់ ហើយមុនពេលការជំនុំជំរះចាប់ផ្តើម ព្រះរាជអាជ្ញាអាចកែប្រែបទចោទប្រកាន់បាន ដោយមានការអនុញ្ញាតពីសភាមុនការជំនុំជំរះ និង បន្ទាប់ពីការជូនដំណឹងដល់ជនជាប់ចោទរួចហើយ។ ប្រសិនបើ ព្រះរាជអាជ្ញា ស្វែងរកការដាក់បទចោទប្រកាន់ បន្ថែមទៀត ឬ ដាក់ជំនួសនូវបទចោទប្រកាន់ដែលមានស្ថានទម្ងន់ធ្ងន់ជាងមុននោះ ក្រោមមាត្រានេះ ត្រូវតែធ្វើសវនាការមួយ ដើម្បីបញ្ជាក់បទចោទប្រកាន់ទាំងនោះ។ បន្ទាប់ពីការចាប់ផ្តើមការជំនុំជំរះ ព្រះរាជ-អាជ្ញាអាចដកបទចោទប្រកាន់ចេញវិញបាន ដោយមានការអនុញ្ញាតិ ពីសភាមុនការជំនុំជំរះ ។

១០- ដីកាណាមួយដែលត្រូវបានចេញពីមុនមក ត្រូវលែងមានប្រសិទ្ធភាពចំពោះបទចោទប្រកាន់ណាមួយ ដែលមិនទាន់ត្រូវបានបញ្ជាក់ដោយសភាមុនការជំនុំជំរះ ឬ ដែលត្រូវបានដកចេញវិញដោយព្រះរាជអាជ្ញា ។

១១- កាលណាបទចោទប្រកាន់ត្រូវបានបញ្ជាក់ស្របតាមមាត្រានេះ ធិបតីប្រធាន ត្រូវបង្កើតឡើងនូវសភាជំនុំជំរះមួយ ស្របតាមកថាខ័ណ្ឌទី ៨ នៃមាត្រានេះ និង កថាខ័ណ្ឌទី ៤ នៃមាត្រា៦៤ ដែលត្រូវទទួលខុសត្រូវលើការប្រព្រឹត្តទៅនៃដំណើរការជំរះរឿងក្តីជាបន្តបន្ទាប់ទៀត ហើយអាចប្រើប្រាស់មុខងារណាមួយរបស់សភាមុនការជំនុំជំរះដែលទាក់ទង និង ដែលអាចអនុវត្តក្នុងដំណើរការជំរះរឿងក្តីនោះបាន ។

## ភាគទី៦ : អំពីការជំនុំជំរះ

### មាត្រា ៦២ : អំពីទីកន្លែងជំនុំជំរះ

ទីកន្លែងជំនុំជំរះ ត្រូវធ្វើនៅឯអាសនៈរបស់តុលាការ លើកលែងតែបានសំរេចផ្សេងពីនេះ ។

### មាត្រា ៦៣ : អំពីជំនុំជំរះដោយមានវត្តមានរបស់ជនជាប់ចោទ

១- ជនជាប់ចោទ ត្រូវមានវត្តមានក្នុងអំឡុងពេលជំនុំជំរះ ។

២- ប្រសិនបើជនជាប់ចោទបន្តធ្វើការរំខានដល់ការជំនុំជំរះ ដែលខ្លួនកំពុងមានវត្តមាននៅចំពោះមុខតុលាការ សភាជំនុំជំរះ អាចដកជនជាប់ចោទចេញក្រៅបន្ទប់តុលាការ ហើយត្រូវចាត់វិធានបណ្តោះអាសន្នឱ្យជនជាប់ចោទនោះ តាមដានសង្កេតមើលការជំនុំជំរះ ហើយ បើចាំបាច់ ត្រូវណែនាំប្រាប់ទៅដល់អ្នកការពារក្តីពីខាងក្រៅបន្ទប់តុលាការ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ ។ វិធានការទាំងនេះ ត្រូវអនុវត្តតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ បន្ទាប់ពីជំរើសសមហេតុផលផ្សេងៗទៀតត្រូវបានបង្ហាញឱ្យឃើញថាមិនគ្រប់គ្រាន់ទេ ហើយអនុវត្តតែក្នុងអំឡុងពេលដែលត្រូវការចាំបាច់បំផុតប៉ុណ្ណោះ ។

### មាត្រា ៦៤ : អំពីមុខងារ និង អំណាចរបស់សភាជំនុំជំរះ

១- មុខងារនិងអំណាចរបស់សភាជំនុំជំរះ ចែងក្នុងមាត្រានេះ ត្រូវអនុវត្ត ស្របតាមច្បាប់លក្ខន្តិកៈនេះ និង តាមវិធាននៃនីតិវិធីនិងភស្តុតាង ។

២- សភាជំនុំជំរះ ត្រូវធ្វើឱ្យប្រាកដថាការជំនុំជំរះមានលក្ខណៈយុត្តិធម៌និងឆាប់រហ័ស ហើយត្រូវបានធ្វើឡើង ដោយមានការគោរពពេញលេញដល់សិទ្ធិរបស់ជនជាប់ចោទ និង គិតគូរបានសមរម្យដល់ការការពារជនរងគ្រោះ និង សាក្សី ។

៣- តាមការប្រគល់ឱ្យនូវករណីរឿងក្តីណាមួយ ដើម្បីធ្វើការជំនុំជំរះ ស្របតាមច្បាប់លក្ខន្តិកៈនេះ សភាជំនុំជំរះ ដែលត្រូវបានចាត់ឱ្យជំនុំជំរះករណីនេះត្រូវ :

(ក)- ពិគ្រោះយោបល់ជាមួយភាគីទាំងឡាយ និង អនុម័តនូវនីតិវិធីចាំបាច់ ដើម្បីសម្រួលដល់ការប្រព្រឹត្តទៅដោយយុត្តិធម៌ និងឆាប់រហ័ស នៃដំណើរការជំរះរឿងក្តី ។

(ខ) - កំណត់ភាសាមួយ ឬ ច្រើនដែលត្រូវប្រើក្នុងពេលជំនុំជំរះ, និង

(គ) - ជាកម្មវត្ថុនៃបទបញ្ញត្តិដែលពាក់ព័ន្ធដទៃទៀតនៃច្បាប់លក្ខន្តិកៈនេះ ដែលចែងអំពីការបង្ហាញនូវឯកសារ ឬ ពត៌មាន ដែលមិនត្រូវបានបង្ហាញពីមុនមក ឱ្យបានគ្រប់គ្រាន់មុនការចាប់ផ្តើមការជំនុំជំរះ ដើម្បីជួយ ឱ្យការរៀបចំបានគ្រប់គ្រាន់សម្រាប់ជំនុំជំរះ។

៤- ប្រសិនបើចាំបាច់ ដើម្បីឱ្យដំណើរការរបស់ខ្លួនមានប្រសិទ្ធភាព និង មានយុត្តិធម៌ សភាជំនុំជំរះ អាចលើកនូវបញ្ហាបឋមនានាជូនទៅសភាមុនការជំនុំជំរះ ឬ បើចាំបាច់ អាចលើកជូនទៅចៅក្រមម្នាក់ផ្សេងទៀត នៃផ្នែកមុនការជំនុំជំរះដែលនៅទំនេរ ។

៥- តាមការផ្តល់ដំណឹងដល់ភាគីទាំងឡាយ សភាជំនុំជំរះ តាមការសមស្រប អាចបញ្ជាឱ្យមានការជំនុំជំរះរួម ឬ ដាច់ដោយឡែកពីគ្នា ចំពោះបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទលើសពីម្នាក់ ។

៦- ក្នុងការបំពេញមុខងាររបស់ខ្លួន មុនពេលជំនុំជំរះ ឬ ក្នុងពេលកំពុងធ្វើការជំនុំជំរះ បើចាំបាច់ សភាជំនុំជំរះ អាច :

(ក) - អនុវត្តមុខងារណាមួយរបស់សភាមុនការជំនុំជំរះ ដែលបានពោលនៅក្នុងកថាខ័ណ្ឌទី១១ នៃមាត្រា ៦១។

(ខ) - តម្រូវឱ្យមានអ្នកចូលរួមនិងសក្ខីកម្មរបស់សាក្សី និង ការផលិតឯកសារនិងភស្តុតាងដទៃទៀត ដោយការទទួលជំនួយពីរដ្ឋ ដូចមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ បើចាំបាច់។

(គ) - ចែងអំពីការការពារពត៌មានអាថ៌កំបាំង។

(ឃ) - បញ្ជាឱ្យផលិតភស្តុតាងបន្ថែមពីលើភស្តុតាងដែលបានប្រមូលរួចហើយកាលមុនពេលជំនុំជំរះ ឬ ដែលបានបង្ហាញដោយភាគីទាំងឡាយនៅក្នុងអំឡុងពេលជំនុំជំរះ។

(ង) - ចែងអំពីការការពារជនជាប់ចោទ សាក្សី និង ជនរងគ្រោះ, និង

(ច) - វិនិច្ឆ័យបញ្ហាដែលទាក់ទងដទៃទៀត ។

៧- ការជំនុំជំរះ ត្រូវធ្វើឡើងជាសាធារណៈ។ ទោះជាយ៉ាងណាក្តី សភាជំនុំជំរះ អាចកំណត់ថាកាលៈទេសៈពិសេស តម្រូវថាដំណើរការជំរះរឿងក្តីខ្លះ ត្រូវធ្វើឡើងក្នុងបន្ទប់សំងាត់ សម្រាប់គោលបំណងដែលបានកំណត់ក្នុងមាត្រា ៦៨ ឬ ដើម្បីការពារពត៌មានអាថ៌កំបាំង ឬ ពត៌មានប៉ះពាល់ដល់ស្មារតីដើម្បីផ្តល់ជាភស្តុតាង ។

៨- (ក) នៅពេលចាប់ផ្តើមការជំនុំជំរះ សភាជំនុំជំរះ ត្រូវអានឱ្យជនជាប់ចោទស្តាប់ នូវបទចោទប្រកាន់ ដែលបានបញ្ជាក់ពីមុនមក ដោយសភាមុនការជំនុំជំរះ។ សភាជំនុំជំរះ ត្រូវធ្វើឱ្យខ្លួនឯងពេញចិត្តថាជនជាប់ចោទយល់ពីប្រភេទនៃបទចោទប្រកាន់ទាំងឡាយ។ សភាជំនុំជំរះត្រូវផ្តល់ឱកាសឱ្យជនជាប់ចោទធ្វើការឆ្លើយទទួលពិរុទ្ធភាព ឬបដិសេធពិរុទ្ធភាព ស្របតាមមាត្រា៦៥។

(ខ) នៅពេលជំនុំជំរះ ចៅក្រមប្រធាន អាចចេញការណែនាំប្រាប់អំពីការប្រព្រឹត្តទៅនៃដំណើរការជំរះរឿងក្តី រួមទាំងធ្វើឱ្យប្រាកដថាដំណើរការជំរះរឿងក្តីនេះ ត្រូវបានធ្វើឡើងក្នុងលក្ខណៈមួយមានយុត្តិធម៌និងឥតលំអៀង។ អនុលោមតាមការណែនាំរបស់ចៅក្រមប្រធាន ភាគីទាំងឡាយ អាចដាក់ជូននូវភស្តុតាង ស្របតាមបទប្បញ្ញត្តិនៃច្បាប់លក្ខន្តិកៈនេះ ។

៩- សភាជំនុំជំរះ ត្រូវមានក្នុងចំណោមអំណាចផ្សេងៗទៀត តាមសំណើររបស់ភាគីមួយ ឬ តាមការស្នើរបស់ខ្លួនផ្ទាល់ នូវអំណាចដើម្បី :

(ក) វិនិច្ឆ័យ អំពីភាពទទួលយកបាន ឬ ភាពទាក់ទងនៃភស្តុតាង. និង

(ខ) អនុវត្តជំហានសំខាន់ៗទាំងអស់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលដំណើរការសវនាការ ។

១០- សភាជំនុំជំរះ ត្រូវធ្វើឱ្យប្រាកដថា កំណត់ហេតុពេញលេញមួយនៃការជំនុំជំរះដែលឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីដំណើរការជំរះរឿងក្តី ហើយកំណត់ហេតុនោះ ត្រូវបានរក្សាទុក និង អភិរក្សការពារទុកដោយក្រឡាបញ្ជី ។

មាត្រា ៦៥ : អំពីដំណើរការជំរះរឿងក្តី លើការឆ្លើយទទួលពិរុទ្ធភាព

១- ពេលដែលជនជាប់ចោទឆ្លើយទទួលពិរុទ្ធភាព ស្របតាមកថាខ័ណ្ឌទី៨(ក)នៃមាត្រា៦៤ សភាជំនុំជំរះ ត្រូវកំណត់ថាតើ :

(ក) ជនជាប់ចោទយល់អំពីប្រភេទ និង វិបាកនៃការឆ្លើយទទួលពិរុទ្ធភាពឬអត់.

(ខ) ការឆ្លើយទទួលពិរុទ្ធភាព ត្រូវបានធ្វើដោយស្ម័គ្រចិត្ត ដោយជនជាប់ចោទ បន្ទាប់ពីមានការពិគ្រោះយោបល់គ្រប់គ្រាន់ ជាមួយអ្នកការពារក្តី. និង

(គ) ការឆ្លើយទទួលពិរុទ្ធភាព ត្រូវបានគាំទ្រដោយអង្គហេតុនៃសំណុំរឿង ដែលមាននៅក្នុង :

(1) បទចោទប្រកាន់ដែលលើកឡើងដោយព្រះរាជអាជ្ញា និង ត្រូវបានឆ្លើយទទួលយក ដោយជនជាប់ចោទ ។

(2) សម្ភារៈនានាដែលបានបង្ហាញ ដោយព្រះរាជអាជ្ញា ដែលបន្ថែមលើបទចោទប្រកាន់ និង ដែលជនជាប់ចោទទទួលយក, និង

(3) ភស្តុតាងដទៃៗទៀត ដូចជា សក្ខីកម្មរបស់សាក្សី ដែលបានបង្ហាញដោយព្រះរាជអាជ្ញា ឬ ដោយជនជាប់ចោទ ។

២- ពេលដែលសភាជំនុំជំរះមិនពេញចិត្តថា បញ្ហាទាំងឡាយដែលពោលនៅក្នុងកថាខ័ណ្ឌទី១នេះ ត្រូវបានកើតឡើងទេ ខ្លួនត្រូវពិចារណាអំពីការឆ្លើយទទួលពិរុទ្ធភាព ព្រមទាំងភស្តុតាងបន្ថែមណាមួយ ដែលបានបង្ហាញ ខណៈដែលបង្កើតឡើងគ្រប់អង្គហេតុសំខាន់ៗ ដែលតម្រូវឱ្យបង្ហាញភស្តុតាងចំពោះបទល្មើសព្រហ្មទណ្ឌ ដែលទាក់ទងដល់ការឆ្លើយទទួលពិរុទ្ធភាព និង អាចថ្កោលទោសជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌនោះបាន ។

៣- ពេលដែលសភាជំនុំជំរះ មិនពេញចិត្តថាបញ្ហាទាំងឡាយដែលពោលនៅក្នុងកថាខ័ណ្ឌទី១ ត្រូវបានកើតឡើងទេ ខ្លួនត្រូវពិចារណាការឆ្លើយទទួលយកពិរុទ្ធភាព ដូចមិនត្រូវបានធ្វើ ដែលក្នុងករណីនោះ ខ្លួនត្រូវបញ្ជាឱ្យបន្តការជំនុំជំរះតាមនីតិវិធីជំនុំជំនះជាធម្មតាដូចមានចែងដោយច្បាប់លក្ខន្តិកៈនេះ និង អាចបង្វិលករណីរឿងក្តីនោះ ទៅ ឱ្យសភាជំនុំជំរះផ្សេងទៀតបាន ។

៤- ពេលដែលសភាជំនុំជំរះ មានទស្សនៈយល់ឃើញយថា ជាការចាំបាច់ត្រូវមានការបង្ហាញឱ្យគ្រប់គ្រាន់ជាងនូវអង្គហេតុនៃករណីរឿងក្តី ត្រូវតម្រូវឱ្យធ្វើដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ជាពិសេសដើម្បីជាប្រយោជន៍ នៃជនរងគ្រោះ នោះសភាជំនុំជំរះអាច :

(ក) ស្នើរឱ្យព្រះរាជអាជ្ញាបង្ហាញភស្តុតាងបន្ថែមទៀត រួមទាំងសក្ខីកម្មរបស់សាក្សីផង , ឬ

(ខ) បញ្ជាឱ្យបន្តដំណើរការជំនុំជំរះតាមនិតិវិធីជំនុំជំរះធម្មតា ដូចមានចែងដោយច្បាប់លក្ខន្តិកៈនេះ ដែលក្នុងករណីនោះ ខ្លួនត្រូវពិចារណានូវការឆ្លើយទទួលពិរុទ្ធភាព ដូចមិនត្រូវបានធ្វើឡើង និង អាចបង្វិលករណីរឿងក្តីនោះ ទៅឱ្យសភាជំនុំជំរះ ផ្សេងទៀតបាន ។

៥- ការពិភាក្សាណាមួយរវាងព្រះរាជអាជ្ញា និង អ្នកការពារក្តី លើការកែប្រែបទចោទប្រកាន់ ការឆ្លើយទទួលពិរុទ្ធភាព ឬ ទណ្ឌកម្មដែលនឹងត្រូវដាក់នោះមិនត្រូវចងកាតព្វកិច្ចចំពោះតុលាការទេ ។

## មាត្រា ៦៦ : អំពីការសន្និដ្ឋានជាមុនថាគ្មានទោស (សច្ចធារណ៍នៃនិរទោស)

១- ជនរាល់រូប ត្រូវសន្និដ្ឋានទុកជាមុនថានិរទោស រហូតដល់ត្រូវបានបង្ហាញភស្តុតាងនៅចំពោះមុខតុលាការថាមានពិរុទ្ធភាព ស្របតាមច្បាប់ដែលយកមកអនុវត្ត ។

២- បន្ទុក គឺឋិតនៅលើព្រះរាជអាជ្ញាដែលត្រូវបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

៣- ដើម្បីផ្តន្ទាទោសជនជាប់ចោទ ត្រូវធ្វើឱ្យតុលាការជឿថាជនជាប់ចោទពិតជាមានពិរុទ្ធភាព ដោយគ្មានវិមតិសង្ស័យ ។

## មាត្រា ៦៧ : អំពី សិទ្ធិរបស់ជនជាប់ចោទ

១- ក្នុងការកំណត់បទចោទប្រកាន់ណាមួយ ដោយគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ជនជាប់ចោទ ត្រូវមានសិទ្ធិទទួលបាននូវសវនាការជាសាធារណៈ សវនាការដ៏យុត្តិធម៌មួយដែលធ្វើឡើងដោយឥតលំអៀង និង មានសិទ្ធិទទួលនូវការធានាជាអប្បបរិមា ដោយសមភាពបំផុត ដូចតទៅនេះ :

(ក)- ត្រូវបានទទួលពត៌មានរហ័សទាន់ពេលនិងពត៌មានពិស្តារ អំពីប្រភេទ មូលហេតុ និង ខ្លឹមសារនៃការចោទប្រកាន់នៅក្នុងភាសាមួយដែលជនជាប់ចោទយល់ និង និយាយបានយ៉ាងពេញលេញ។

(ខ)- ត្រូវមានពេលវេលា និង បរិក្ខាគ្រប់គ្រាន់ សម្រាប់ត្រៀមការការពារ និង ដើម្បីធ្វើការប្រាស្រ័យទាក់ទងដោយសេរីជាមួយអ្នកការពារក្តីនូវការជ្រើសរើសជនជាប់ចោទដោយសំងាត់។

(គ)- ត្រូវបានជំនុំជំរះ ដោយគ្មានការពន្យាពេលអត់សមរម្យ។

(ឃ)- ត្រូវមានវត្តមាននៅពេលជំនុំជំរះ ស្របតាមកថាខ័ណ្ឌទី ២ នៃមាត្រា ៦៣ ដើម្បីធ្វើការការពារខ្លួន ដោយផ្ទាល់ខ្លួន ឬ តាមរយៈជំនួយការផ្នែកច្បាប់ នូវការជ្រើសរើសដោយជនជាប់ចោទ។ ត្រូវបានទទួលពត៌មាន ប្រសិនបើជនជាប់ចោទ មិនមានជំនួយការផ្នែកច្បាប់អំពីសិទ្ធិនេះ ហើយត្រូវមានជំនួយការផ្នែកច្បាប់ដែលត្រូវចាត់ឱ្យធ្វើដោយតុលាការនៅក្នុងករណីណាមួយដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមាន និង ដោយឥតគិតថ្លៃ

ប្រសិនបើ ជនជាប់ចោទខ្វះខាតមធ្យោបាយគ្រប់គ្រាន់ដើម្បីបង់ប្រាក់ថ្លៃ ឬលជំនួយការផ្នែកច្បាប់នោះ។

(ង)- ត្រូវពិនិត្យ ឬបានពិនិត្យ សាក្សីប្រឆាំងនឹងខ្លួន ហើយ ទទួលបានការចូលរួម និង ការពិនិត្យសាក្សី ក្នុងនាមខ្លួន ក្រោមលក្ខខ័ណ្ឌដូចគ្នានឹងសាក្សីប្រឆាំងនឹងខ្លួនដែរ ។ ជនជាប់ចោទត្រូវមានសិទ្ធិផងដែរ ដើម្បីធ្វើការការពារខ្លួន និង បង្ហាញភស្តុតាងដទៃទៀត ដែលអាចទទួលយកបានតាមច្បាប់លក្ខន្តិកៈនេះ។

(ច)- ត្រូវមានជំនួយការ ដោយឥតគិតថ្លៃ នូវអ្នកបកប្រែផ្ទាល់មាត់ដែលមានសមត្ថភាព ហើយការបកប្រែនោះចាំបាច់ ដើម្បីឱ្យបំពេញបានតាមលក្ខខ័ណ្ឌតម្រូវនៃភាពយុត្តិធម៌ ប្រសិនបើដំណើរការជំរះរឿងក្តី ឬ ឯកសារណាមួយ ដែលបានបង្ហាញដល់តុលាការមិនធ្វើឡើងជាភាសា ដែលជនជាប់ចោទយល់ និង និយាយបានយ៉ាងពេញលេញទេនោះ។

(ឆ)- មិនត្រូវបានបង្ខំឱ្យផ្តល់សក្ខីកម្ម ឬ សារភាពទទួលពិរុទ្ធភាព និង នៅស្ងៀមស្ងាត់នោះទេ ដោយការនៅស្ងៀមស្ងាត់នោះមិនត្រូវបានយកមកធ្វើជាការពិចារណាក្នុងការកំណត់ថាមានពិរុទ្ធ ឬ និរទោសឡើយ ។

(ជ)- ត្រូវធ្វើការថ្លែងដោយផ្ទាល់មាត់ ឬ ជាលាយល័ក្ខអក្សរដោយគ្មានសម្បថ នៅក្នុងការការពារខ្លួន. និង

(ឈ)- មិនបានដាក់លើខ្លួន នូវការបដិសេធចំពោះបន្ទុកនៃភស្តុតាង ឬ បន្ទុកនៃការបដិសេធប្រឆាំងណាមួយឡើយ ។

២-បន្ថែមលើការបង្ហាញដទៃទៀត ដូចមានចែងនៅក្នុងច្បាប់លក្ខន្តិកៈនេះ ព្រះរាជអាជ្ញាត្រូវបង្ហាញ ភ្លាមតាមដែលអាចធ្វើទៅបានដល់អ្នកការពារក្តី នូវភស្តុតាង ដែលមាននៅក្នុងដៃ ឬ ដែលឋិតនៅក្រោមការត្រួតត្រារបស់ព្រះរាជអាជ្ញា ដែលខ្លួនជឿថា ការបង្ហាញ ឬ ការប៉ងបង្ហាញ អំពីនិរទោស នៃជនជាប់ចោទ ឬ ដើម្បីសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬ ដែលអាចប៉ះពាល់ដល់ភាពដែលអាចប្រើការបាននៃភស្តុតាងចោទប្រកាន់។ ក្នុងករណីវិមតិសង្ស័យ ចំពោះការអនុវត្តន៍កថាខ័ណ្ឌនេះ តុលាការត្រូវជាអ្នកសំរេច ។

## មាត្រា ៦៨ : អំពីការការពារជនរងគ្រោះនិងសាក្សី និង ការចូលរួមរបស់ពួកគេក្នុងដំណើរការជំរះរឿងក្តី

១- តុលាការ ត្រូវចាត់វិធានការសមស្រប ដើម្បីការពារសុវត្ថិភាព សុខមាលភាពខាងផ្លូវកាយ និង ខាងផ្លូវចិត្ត សេចក្តីថ្លៃថ្នូ និង ការនៅស្ងៀមស្ងាត់គ្មានការរំខានឆាឆៅ(privacy)របស់ជនរងគ្រោះ និង សាក្សី។ ដើម្បីធ្វើដូច្នោះ តុលាការ ត្រូវគិតគូរលើកត្តា ទាក់ទិនទាំងអស់ រួមទាំង កត្តាអាយុ កត្តាជែនឌ័រ ដូច មានកំណត់ក្នុងកថាខ័ណ្ឌទី៣ នៃមាត្រា២ ព្រមទាំងកត្តាសុខភាព និង ជាពិសេស ប៉ុន្តែមិនកំរិតត្រឹមនេះទេ ប្រភេទបទល្មើសព្រហ្មទណ្ឌដែលបទល្មើសព្រហ្មទណ្ឌនោះពាក់ព័ន្ធលើការបំពានផ្នែកភេទ ឬ ផ្នែកជែនឌ័រ ឬ អំពើហឹង្សាលើកុមារនោះទេ។ ព្រះរាជអាជ្ញា ត្រូវចាត់វិធានការនេះ ជាពិសេស អំឡុងពេលស៊ើបអង្កេត និង ការនាំយកមកជំនុំជំរះនូវបទល្មើសព្រហ្មទណ្ឌប្រភេទនេះ។ វិធានការទាំងអស់នេះ មិនត្រូវមានលក្ខណៈអគតិចំពោះ ឬ មានលក្ខណៈមិនស្របគ្នាជាមួយសិទ្ធិរបស់ជនជាប់ចោទ និង ការជំនុំជំរះ ដោយយុត្តិធម៌ និង ឥតលំអៀងឡើយ។

២- មានការលើកលែង ចំពោះគោលការណ៍សវនការជាសាធារណៈ ដូចមានចែងក្នុង មាត្រា ៦៧ សភាទាំងឡាយនៃតុលាការ អាចបើកដំណើរការជំរះរឿងក្តីផ្នែកណាមួយ នៅក្នុងបន្ទប់សំងាត់ឬអនុញ្ញាតឱ្យបង្ហាញភស្តុតាង តាមមធ្យោបាយគ្រឿងអេឡិចត្រូនិច ឬ តាមមធ្យោបាយពិសេសផ្សេងទៀត ដើម្បីការពារជនរងគ្រោះ និង សាក្សី ឬ ជនជាប់ចោទ ។ ជាពិសេស វិធានការទាំងឡាយនោះ ត្រូវអនុវត្តក្នុងករណីជនរងគ្រោះដោយសារការបំពានផ្លូវភេទ បង្ខំសេពសន្ថវៈ ឬ កុមារដែលជាជនរងគ្រោះ ឬ ជាសាក្សី លើកលែងតែមានបញ្ជារបស់តុលាការ ដោយគិតគូរដល់គ្រប់កាលៈទេសៈទាំងអស់ ជាពិសេស ទស្សនៈរបស់ជនរងគ្រោះ ឬ របស់សាក្សី ។

៣- កាលណាប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះត្រូវប៉ះពាល់ តុលាការត្រូវអនុញ្ញាតឱ្យគេបញ្ចេញបង្ហាញ និង ត្រូវបានពិចារណានូវទស្សនៈ និង កង្វល់របស់គេ នៅក្នុងដំណាក់កាលនានានៃដំណើរការជំរះរឿងក្តីដែលត្រូវតុលាការបានកំណត់ថាសមស្រប និង នៅក្នុងលក្ខណៈមួយដែលមិនមានលក្ខណៈអគតិ ឬ មិនមានលក្ខណៈមិនស្របជាមួយសិទ្ធិរបស់ជនជាប់ចោទ និង ការជំនុំជំរះដោយយុត្តិធម៌

និង ឥតលំអៀង ។ ទស្សនៈ និង កង្វល់នោះ អាចត្រូវបង្ហាញ ដោយអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ពេលដែលតុលាការពិចារណាយល់ឃើញថាសមស្រប អនុលោមតាមវិធាននៃនីតិវិធី និងភស្តុតាង ។

៤- អង្គភាពការពារជនរងគ្រោះនិងសាក្សី អាចផ្តល់យោបល់ដល់ព្រះរាជអាជ្ញា និង តុលាការ អំពីវិធានការការពារ ការរៀបចំសន្តិសុខ ការការពារ និង ជំនួយការ ដែលសមស្រប ដូចមានចែងក្នុងកថាខ័ណ្ឌទី ៦ នៃមាត្រាទី ៤៣ ។

៥- កាលបើការបង្ហាញភស្តុតាង ឬ ពត៌មាន អនុលោមតាមច្បាប់លក្ខន្តិកៈនេះអាចនាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សន្តិសុខរបស់សាក្សី ឬ ក្រុមគ្រួសាររបស់គាត់ ព្រះរាជអាជ្ញា អាចមិនលើកឡើងនូវភស្តុតាង ឬ ពត៌មាននោះ ហើយជំនួសដោយការដាក់ជូនកំណត់ហេតុសង្ខេបវិញ សម្រាប់គោលបំណងនៃដំណើរការជំរះរឿងក្តី ដែលបានធ្វើឡើងមុនពេលចាប់ផ្តើមការជំនុំជំរះ ។ វិធានការនេះត្រូវអនុវត្តក្នុងរបៀបមួយ ដែលមិនមានលក្ខណៈអគតិ ឬ មិនមានលក្ខណៈមិនស្របជាមួយសិទ្ធិរបស់ជនជាប់ចោទ និង ការជំនុំជំរះ ដោយយុត្តិធម៌ និង ឥតលំអៀងឡើយ ។

៦- រដ្ឋអាចស្នើសុំវិធានការចាំបាច់ ដែលត្រូវអនុវត្តចំពោះការការពារ អ្នកបំរើការងារ និង ភ្នាក់ងាររបស់ខ្លួន ព្រមទាំងការពារពត៌មានសំងាត់ ឬ ពត៌មានដែលអាចប៉ះពាល់ដល់ស្មារតី ។

## មាត្រា ៦៩ : អំពីភស្តុតាង

១- ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង មុនពេលផ្តល់សក្ខីកម្ម សាក្សីម្នាក់ៗត្រូវផ្តល់ការសន្យាចំពោះភាពពិតប្រាកដនៃភស្តុតាង ដែលត្រូវផ្តល់ឱ្យដោយសាក្សីនោះ ។

២- សក្ខីកម្មរបស់សាក្សីក្នុងពេលជំនុំជំរះ ត្រូវផ្តល់ដោយបុគ្គលផ្ទាល់ខ្លួន លើកលែងតែបិតក្នុងកំរិតវិសាលភាពដែលមានចែងក្នុងវិធានការដែលបានកំណត់ក្នុងមាត្រា៦៨ ឬ ក្នុងវិធាននៃនីតិវិធីនិងភស្តុតាង ។ តុលាការ ក៏អាចអនុញ្ញាតផងដែរ ឱ្យផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ឬ សក្ខីកម្មដែលបានថតទុករបស់សាក្សីណាម្នាក់ តាមមធ្យោបាយបច្ចេកវិទ្យាវីដេអូឬខ្សែអាត់ ព្រមទាំងការណែនាំបង្ហាញពីឯកសារ ឬ លិខិតបញ្ជាក់ជាលាយល័ក្ខអក្សរ ដែលជាកម្មវត្ថុនៃច្បាប់លក្ខន្តិកៈនេះ និង ស្របតាមវិធាននៃ

នីតិវិធីនិងភស្តុតាង។ វិធានការទាំងនេះ មិនត្រូវមានលក្ខណៈអគតិធម៌ចំពោះ ឬ មិនត្រូវមានលក្ខណៈមិនស្របជាមួយសិទ្ធិរបស់ជនជាប់ចោទឡើយ។

៣- ភាគីទាំងឡាយ អាចដាក់ជូនភស្តុតាងដែលទាក់ទងនឹងករណីនោះ ស្របតាមមាត្រា៦៤។ តុលាការត្រូវមានអំណាចស្នើសុំឱ្យដាក់ជូននូវភស្តុតាងទាំងអស់ ដែលខ្លួនពិចារណាយល់ឃើញថាចាំបាច់ ដើម្បីធ្វើការកំណត់រកការពិត ។

៤- តុលាការ អាចវិនិច្ឆ័យពីភាពមានទំនាក់ទំនង ឬ ភាពអាចទទួលយកបាននៃភស្តុតាងណាមួយ ដោយយកមកពិចារណា ក្នុងចំណោមតម្លៃផ្សេងៗទៀត នូវតម្លៃមានលក្ខណ៍នៃភស្តុតាង និង អគតិធម៌ណាដែលបណ្តាលមកពីភស្តុតាងនោះ ចំពោះការជំនុំជំរះប្រកបដោយយុត្តិធម៌ ឬ ដល់ការវាយតម្លៃដោយយុត្តិធម៌នៃសក្ខីកម្មរបស់សាក្សី ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង។

៥- តុលាការត្រូវគោរព និង ធ្វើការកត់សំគាល់ពី បុព្វសិទ្ធិនៃភាពអាថិកំបាំង ដូចមានចែងក្នុងវិធាននៃនីតិវិធី និងភស្តុតាង ។

៦- តុលាការ មិនត្រូវតម្រូវឱ្យបញ្ជាក់អំពីអង្គហេតុ នៃការយល់ដឹងរួមទេ ប៉ុន្តែអាចធ្វើការកត់សំគាល់ដោយយុត្តិធម៌ ចំពោះអង្គហេតុនោះ ។

៧- ភស្តុតាងដែលទទួលបាន តាមមធ្យោបាយបំពានលើច្បាប់លក្ខន្តិកៈនេះ ឬ បំពានលើសិទ្ធិមនុស្សទាំងឡាយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ មិនត្រូវអាចទទួលយកបានឡើយ ប្រសិនបើ:

ក- ការបំពាននាំឱ្យមានវិមតិសង្ស័យជាដុំកំភួន លើភាពអាចយកជាការបាននៃភស្តុតាង. ឬ

ខ- ការទទួលយកភស្តុតាង ទំនងជាប្រឆាំងដល់ និង ទំនងជាបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់ភាពសុច្ចរិតនៃដំណើរការជំរះរឿងក្តី។

៨- នៅពេលធ្វើសេចក្តីសំរេច អំពីភាពមានទំនាក់ទំនង ឬ ភាពអាចទទួលយកបាននៃភស្តុតាងដែលប្រមូលបានដោយរដ្ឋណាមួយ តុលាការមិនត្រូវវិនិច្ឆ័យផ្អែកលើការអនុវត្តនៃច្បាប់ជាតិរបស់រដ្ឋនោះទេ ។

### មាត្រា ៧០ : អំពីបទល្មើសប្រឆាំងនឹងរដ្ឋបាលយុត្តិធម៌

១- តុលាការ ត្រូវមានយុត្តាធិការលើបទល្មើសដូចតទៅនេះ ដែលប្រឆាំងនឹងរដ្ឋបាលយុត្តិធម៌របស់ខ្លួន នៅពេលដែលបានប្រព្រឹត្តដោយចេតនា :

(ក) ការផ្តល់សក្ខីកម្មមិនពិត នៅពេលខ្លួនមានកាតព្វកិច្ចត្រូវប្រាប់ការពិត ស្របតាមកថាខ័ណ្ឌទី១ នៃ មាត្រា ៦៩.

(ខ) ការបង្ហាញភស្តុតាង ដែលភាគីនោះដឹងថាជាភស្តុតាងមិនពិត ឬ ក្លែងក្លាយ.

(គ) ការប្រើឥទ្ធិពលយ៉ាងពុករលួយលើសាក្សី ការរារាំង ឬ ជ្រៀតជ្រែកដល់ការចូលរួម ឬ ដល់សក្ខីកម្មរបស់សាក្សី ការសងសឹកចំពោះសាក្សីដែលផ្តល់សក្ខីកម្ម ឬ ការបំផ្លាញភស្តុតាង ការអុកឡុក ឬ ការជ្រៀតជ្រែកដល់ការប្រមូលភស្តុតាង.

(ឃ) ការបង្អាក់ ការបំភិតបំភ័យ ឬ ការប្រើឥទ្ធិពលយ៉ាងពុករលួយ លើមន្ត្រីណាម្នាក់របស់តុលាការ ក្នុងគោលបំណងបង្ខំ ឬ បញ្ចុះបញ្ចូលឱ្យមន្ត្រីនោះ មិនបំពេញការងារ ឬ នឹងបំពេញការងារដោយ មិនត្រឹមត្រូវទៅតាមភារកិច្ចរបស់គាត់ ។

(ង) ការសងសឹកចំពោះមន្ត្រីរបស់តុលាការ ឬ មន្ត្រីផ្សេងទៀត ដែលទទួលខុសត្រូវបំពេញភារកិច្ចនោះ.

(ច) ការអន្ទងចិត្ត ឬ ការទទួលយកសំណូក ក្នុងនាមជាមន្ត្រីរបស់តុលាការ ដែលជាប់ពាក់ព័ន្ធនឹងភារកិច្ចផ្លូវការរបស់ខ្លួន ។

២- គោលការណ៍ និង នីតិវិធីគ្រប់គ្រងការអនុវត្តន៍យុត្តាធិការរបស់តុលាការ លើបទល្មើស ក្រោមមាត្រានេះ ត្រូវជាគោលការណ៍ និង នីតិវិធីទាំងឡាយ ដែលមានចែងនៅក្នុងវិធាននៃនីតិវិធីនិងភស្តុតាង។ លក្ខខ័ណ្ឌដើម្បីផ្តល់ការសហការជាអន្តរជាតិជាមួយតុលាការ លើដំណើរការជំរះរឿងក្តីរបស់ខ្លួន តាមមាត្រានេះ ត្រូវគ្រប់គ្រងដោយច្បាប់ក្នុងស្រុក នៃរដ្ឋដែលស្នើសុំ ។

៣- នៅក្នុងករណីមានការថ្កោលទោស តុលាការអាចដាក់អាណត្តិទោសពន្ធនាគារក្នុងកំរិតមួយ មិនលើសពី៥ឆ្នាំ ឬ ការដាក់ពិន័យជាប្រាក់ ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង ឬ ទាំងពីរ ។

៤- (ក) រដ្ឋភាគីនីមួយៗ ត្រូវពង្រីងយុត្តាធិការច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ដើម្បីផ្តន្ទាទោសពីបទល្មើសប្រឆាំងនឹងភាពសុច្ចរិតនៃដំណើរការស៊ើបអង្កេតនិងការរកយុត្តិធម៌របស់ខ្លួនផ្ទាល់ ចំពោះបទល្មើសប្រឆាំងនឹងរដ្ឋបាលយុត្តិធម៌ ដូចមានចែងក្នុងមាត្រានេះ ដែលបានប្រព្រឹត្តនៅលើទឹកដីរបស់ខ្លួន ឬ បានប្រព្រឹត្តដោយពលរដ្ឋណាម្នាក់របស់ខ្លួន.

(ខ) តាមសំណើររបស់តុលាការ នៅពេលណាដែលតុលាការចាត់ទុកថាសមស្រប រដ្ឋភាគី ត្រូវដាក់ជូនសំណុំរឿង ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ក្នុងគោលបំណង ដើម្បីធ្វើការនាំយក

មកជំនុំជំរះ ។ អាជ្ញាធរទាំងអស់នោះ ត្រូវចាត់ចែងសំណុំរឿងនេះ ដោយយកចិត្តទុកដាក់ និង លះបង់ធនធានល្មមគ្រប់គ្រាន់ដើម្បីឱ្យសំណុំរឿងទាំងនោះដំណើរការយ៉ាងមានប្រសិទ្ធភាព ។

### មាត្រា ៧១ : អំពីកម្មវិបាកចំពោះកំហុសឆ្គងនៅមុខតុលាការ

១- តុលាការ អាចដាក់កម្មវិបាកជាវិធានការរដ្ឋបាល ក្រៅពីការដាក់ពន្ធនាគារ ដូចជា ការបណ្តេញចេញពីបន្ទប់តុលាការជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍ ការផាកពិន័យជាប្រាក់ ឬ វិធានការប្រហាក់ប្រហែលផ្សេង១ទៀត ដូចមានចែងក្នុងវិធាននៃនីតិវិធីនិងភស្តុតាង ចំពោះជនដែលមានវត្តមាននៅចំពោះមុខតុលាការ ដែលប្រព្រឹត្តកំហុសឆ្គង រួមមាន ការរោរនៅរំខានដល់ដំណើរការជំរះរឿងក្តីរបស់តុលាការ ឬ ការបដិសេធមិនព្រមធ្វើតាមការណែនាំរបស់តុលាការដោយចេតនា ។

២- នីតិវិធីគ្រប់គ្រងលើការចាត់វិធានការទាំងឡាយ ដូចមានចែងក្នុងកថាខ័ណ្ឌទី១ ត្រូវជានីតិវិធីទាំងឡាយដូចមានចែងនៅក្នុងវិធាននៃនីតិវិធី និងភស្តុតាង ។

### មាត្រា ៧២ : អំពីការការពារពត៌មានសន្តិសុខជាតិ

១- មាត្រានេះ អនុវត្តនៅក្នុងករណីដែលការបង្ហាញពត៌មាន ឬ ឯកសាររបស់រដ្ឋ អាចបង្កអគតិធម៌ចំពោះប្រយោជន៍សន្តិសុខជាតិរបស់ខ្លួន តាមទស្សនៈរបស់រដ្ឋនោះ ។ ករណីនេះ រាប់បញ្ចូលទាំងពត៌មានដែលស្ថិតក្នុងកំរិតវិសាលភាពនៃកថាខ័ណ្ឌទី២និងទី៣នៃមាត្រា៥៦, កថាខ័ណ្ឌទី៣នៃមាត្រា៦១, កថាខ័ណ្ឌទី៣នៃមាត្រា៦៤, កថាខ័ណ្ឌទី២នៃមាត្រា៦៧, កថាខ័ណ្ឌទី៦នៃមាត្រា៦៨, កថាខ័ណ្ឌទី៦នៃមាត្រា៨៧ និង មាត្រា៩៣ ក៏ដូចជាករណីណាដែលកើតចេញពីដំណាក់កាលណាមួយផ្សេងទៀតនៃដំណើរការជំរះរឿងក្តី ដែលការបង្ហាញនោះអាចមានបញ្ហា ។

២- មាត្រានេះត្រូវអនុវត្តផងដែរ នៅពេលដែលមានការស្នើសុំឱ្យជនណាម្នាក់ផ្តល់ពត៌មាន ឬ ភស្តុតាង ហើយជននោះ បានបដិសេធពុំព្រមធ្វើតាម ឬ បានទម្លាក់បញ្ហានោះលើរដ្ឋ ដោយបញ្ជាក់មូលហេតុថា ការបង្ហាញនោះ អាចបង្កអគតិធម៌ចំពោះប្រយោជន៍សន្តិសុខជាតិនៃរដ្ឋនោះ ហើយរដ្ឋដែល

ពាក់ពន្ធ័នោះបានបញ្ជាក់តាមទស្សនៈរបស់ខ្លួនថា ការបង្ហាញនេះ អាចមានអគតិធមិចំពោះប្រយោជន៍សន្តិសុខជាតិរបស់ខ្លួនពិតមែន ។

៣- គ្មានអ្វីនៅក្នុងមាត្រានេះ ត្រូវមានលក្ខណៈអគតិធមិចំពោះលក្ខខ័ណ្ឌតម្រូវនៃអាថិកំបាំងដែលអាចអនុវត្តបាន ក្រោមកថាខ័ណ្ឌទី៣(ង)និង(ច)នៃមាត្រា៥៤ ឬ ការអនុវត្តន៍នៃមាត្រា៧៣ទេ ។

៤- បើរដ្ឋណាមួយដឹងថា ពត៌មាន ឬ ឯកសាររបស់ខ្លួនកំពុងត្រូវ ឬ ទំនងជាត្រូវបានបង្ហាញក្នុងដំណាក់កាលណាមួយនៃដំណើរការជំរះរឿងក្តីនោះ ហើយក្នុងទស្សនៈរបស់ខ្លួន រដ្ឋនោះយល់ថា ការបង្ហាញនោះ មានអគតិធមិចំពោះប្រយោជន៍សន្តិសុខជាតិរបស់ខ្លួន រដ្ឋនោះ ត្រូវមានសិទ្ធិធ្វើអន្តរាគម៍ដើម្បីទទួល បានដំណោះស្រាយបញ្ហានេះ ស្របតាមមាត្រានេះ ។

៥- ក្នុងទស្សនៈរបស់រដ្ឋនោះ ប្រសិនបើ ការបង្ហាញពត៌មានអាចមានលក្ខណៈអគតិធមិចំពោះប្រយោជន៍សន្តិសុខជាតិរបស់ខ្លួន រដ្ឋនោះនឹងអនុវត្តជំហ៊ានដែលសមស្របទាំងអស់ ដោយមានការសហការជាមួយព្រះរាជអាជ្ញា អ្នកការពារក្តី ឬ សភាមុនការជំនុំជំរះ ឬ សភាជំនុំជំរះ ទៅតាមករណីជាក់ស្តែងដើម្បីស្វែងរកដោះស្រាយបញ្ហាតាមមធ្យោបាយសហការគ្នា ។ជំហ៊ានទាំងឡាយនេះអាចរួមមាន :

(ក) ការកែប្រែ ឬ ការបំភ្លឺបញ្ជាក់នៃសំណើរ,

(ខ) ការកំណត់មួយ ដោយតុលាការ លើភាពមានទំនាក់ទំនងនៃពត៌មាន ឬ ភស្តុតាងដែលបានស្វែងរក ឬ ការកំណត់ភស្តុតាងដែលទោះជាភស្តុតាងទាក់ទង ថាតើត្រូវបាន ឬ បានទទួលពីប្រភពមួយក្រៅពីរដ្ឋដែលស្នើសុំ ឬ ទេ,

(គ) ការទទួលបាននូវពត៌មាន ឬ ភស្តុតាងពីប្រភពផ្សេងៗ ឬ តាមទម្រង់ខុសៗគ្នា, ឬ

(ឃ) ការព្រមព្រៀងអំពីលក្ខខ័ណ្ឌ ដែលជំនួយការអាចត្រូវបានផ្តល់ឱ្យ ក្នុងចំណោមជំនួយការនានា រួមមាន ការផ្តល់របាយការណ៍សង្ខេប ឬ ការរៀបរៀងឯកសារដោយប្រុងប្រយត្ន័, ការកំរិតលើការបង្ហាញ, ការប្រើដំណើរការជំរះរឿងក្តីក្នុងបន្ទប់សំងាត់ (in camera proceeding) ឬ ដំណើរការជំរះ រឿងក្តីដោយមានវត្តមានភាគីតែម្ខាង (ex Parte proceeding), ឬ វិធានការការពារ ផ្សេងៗ ដែលបានអនុញ្ញាតដោយច្បាប់លក្ខន្តិកៈនេះ និងវិធាននានា ។

៦- នៅពេលបានអនុវត្តជំហ៊ានសមស្របទាំងអស់ហើយ តាមមធ្យោបាយសហការគ្នា ដើម្បីដោះស្រាយបញ្ហា ហើយប្រសិនបើ រដ្ឋនោះពិចារណាថា គ្មានមធ្យោបាយណាឬលក្ខខ័ណ្ឌណា ពត៌មាន ឬឯកសារគួរត្រូវបានផ្តល់ឱ្យ ឬ ត្រូវបានបង្ហាញ ដោយគ្មានអគតិធមិចំពោះប្រយោជន៍សន្តិសុខជាតិរបស់ខ្លួនទេ រដ្ឋនោះត្រូវជូនដំណឹងទៅ ព្រះរាជអាជ្ញា ឬ តុលាការអំពីហេតុផលជាក់លាក់សម្រាប់សេចក្តីសំរេចរបស់ខ្លួន លុះត្រាតែការអធិប្បាយជាក់លាក់អំពីហេតុផលនោះ អាចជាចាំបាច់បង្កអគតិធមិចំពោះប្រយោជន៍សន្តិសុខជាតិរបស់រដ្ឋនោះ ។

៧- បន្ទាប់មកទៀត ប្រសិនបើ តុលាការកំណត់ថា ភស្តុតាងមានលក្ខណៈទាក់ទង ហើយសំខាន់ក្នុងការបង្កើតពិរុទ្ធភាព ឬ និរទោសភាពលើជនជាប់ចោទនោះ តុលាការអាចធ្វើសកម្មភាពដូចតទៅ :

(ក) ពេលការបង្ហាញពត៌មាន ឬ ឯកសារ ត្រូវបានស្វែងរក អនុលោមតាមសំណើរឱ្យមានការសហការ ស្របតាមភាគទី ៩ ឬ កាលៈទេសៈ ដូចបានពណ៌នានៅក្នុងកថាខ័ណ្ឌទី២ ហើយរដ្ឋនោះ បានលើកឡើងមូលហេតុសម្រាប់ការបដិសេធ ដែលមានចែងក្នុងកថាខ័ណ្ឌទី៤នៃមាត្រា ៩៣ :

(i) មុនពេលធ្វើការសន្និដ្ឋាន តាមអនុកថាខ័ណ្ឌទី ៧ (ក) (២) តុលាការ អាចស្នើសុំការប្រឹក្សាយោបល់ថែមទៀត ក្នុងបំណងពិចារណាអំពីការតំណាងរបស់រដ្ឋនោះ តាមការសមស្រប ដែលអាចរាប់បញ្ចូល ទាំងសវនការក្នុងបន្ទប់សំងាត់ និង សវនាការដែលមានវត្តមានភាគីតែម្ខាង,

(ii) តាមការលើកឡើងមូលហេតុសម្រាប់ការបដិសេធ ក្រោមកថាខ័ណ្ឌទី៤ នៃមាត្រា ៩៣ ក្នុងកាលៈទេសៈនៃករណីរឿងក្តីនេះ បើតុលាការសន្និដ្ឋានថា រដ្ឋដែលបានស្នើសុំមិនកំពុងធ្វើសកម្មភាព តាមកាតព្វកិច្ចរបស់ខ្លួន ក្រោមច្បាប់លក្ខន្តិកៈនេះ តុលាការ អាចបង្វិលករណីរឿងក្តីនេះ ស្របតាមកថាខ័ណ្ឌទី៧នៃមាត្រា៨៧ ដែលបញ្ជាក់អំពីហេតុផលសម្រាបការសន្និ ដ្ឋានរបស់ខ្លួន, និង

(iii) តុលាការ អាចធ្វើបេយ្យាលន័យ(inference) នៅក្នុងជំនុំជំរះជនជាប់ចោទ ទៅតាមការមាន ឬ គ្មានអង្គហេតុ ដែលសមស្របតាមកាលៈទេសៈ ឬ

(ខ) ក្នុងគ្រប់កាលៈទេសៈផ្សេងទៀតទាំងអស់ :

(i) បញ្ជាឱ្យបង្ហាញ ឬ

(ii) នៅក្រិតមួយដែលតុលាការមិនបញ្ជាឱ្យបង្ហាញ តុលាការអាចធ្វើបេយ្យាលន័យនេះ នៅក្នុងការជំនុំជំរះជនជាប់ចោទ តាមការមាន ឬ គ្មានអង្គហេតុ ដែលសមស្រប តាមកាលៈទេសៈ។

### មាត្រា ៧៣ : អំពីពត៌មាន ឬ ឯកសាររបស់តតិយជន

បើសិនជា រដ្ឋភាគីត្រូវបានស្នើសុំ ដោយតុលាការ ឱ្យផ្តល់ឯកសារ ឬ ពត៌មានដែលខ្លួនមាននៅក្នុងដៃ ដែលស្ថិតក្រោមការកាន់កាប់ ឬ ការត្រួតត្រារបស់ខ្លួន ដែលត្រូវបានបង្ហាញដល់ខ្លួនជាការសំងាត់ដោយរដ្ឋមួយដោយអង្គការអន្តររដ្ឋាភិបាលមួយ ឬ ដោយអង្គការអន្តរជាតិមួយ តុលាការត្រូវស្វែងរកការយល់ព្រមពីអ្នកប្រភពដើម ដើម្បីបង្ហាញឯកសារ ឬ ពត៌មាននោះ។ បើអ្នកប្រភព ដើមជារដ្ឋភាគីមួយ រដ្ឋនោះត្រូវមានការយល់ព្រមឱ្យបង្ហាញនូវពត៌មាន ឬ ឯកសារ ឬ ក៏ទទួលខុសត្រូវលើការដោះស្រាយបញ្ហានៃការបង្ហាញពត៌មានដល់តុលាការ ដោយអនុលោមតាមបទប្បញ្ញត្តិ នៃ មាត្រា៧២។ បើអ្នកប្រភពដើម មិនមែនជារដ្ឋភាគីទេ ហើយបដិសេធមិនយល់ព្រមឱ្យបង្ហាញទេ នោះរដ្ឋដែលត្រូវបានស្នើសុំត្រូវផ្តល់ដំណឹងដល់តុលាការថាខ្លួនមិនអាចផ្តល់នូវឯកសារ ឬ ពត៌មាន បានទេ ដោយសារខ្លួនមានការតព្វកិច្ចរក្សាអាថ៌កំបាំងឱ្យអ្នកប្រភពដើមជាមុនទៅហើយ ។

### មាត្រា ៧៤ : អំពីលក្ខខ័ណ្ឌតម្រូវសម្រាប់សេចក្តីសំរេច

១- ចៅក្រមទាំងអស់នៃសភាជំនុំជំរះ ត្រូវមានវត្តមាននៅដំណាក់កាលនីមួយៗ នៃការជំនុំជំរះ និង មានវត្តមានតាំងពីដើមដល់ចប់នៅក្នុងការពិភាក្សាសំរេចរបស់ខ្លួន។ ដោយឈរលើគោលការណ៍ មួយករណីម្តងៗ ធិបតីប្រធានអាចចាត់ចៅក្រមបំរុងម្នាក់ ឬ ច្រើននាក់តាមដែលមាន ឱ្យមានវត្តមាននៅក្នុងដំណាក់កាលនីមួយៗនៃការជំនុំជំរះ និង ដើម្បីជំនួសសមាជិកម្នាក់ នៃសភាជំនុំជំរះ ប្រសិនបើសមាជិករូបនោះ មិនអាចបន្តការចូលរួមបាន ។

២- សេចក្តីសំរេចរបស់សភាជំនុំជំរះ ត្រូវផ្អែកលើការវាយតម្លៃរបស់ខ្លួន លើភស្តុតាង និង ដំណើរការជំរះរឿងក្តីទាំងមូល។ សេចក្តីសំរេច មិនត្រូវធ្វើឱ្យហួសពីអង្គហេតុ និង កាលៈទេសៈដែលបានពណ៌នានៅក្នុងបទចោទប្រកាន់ និង ក្នុងការកែប្រែបទចោទប្រកាន់នានា ។ តុលាការ អាចផ្អែកលើ

សេចក្ដីសំរេចរបស់ខ្លួន តែទៅលើកស្តុតាងដែលបានដាក់ជូន និង បានពិភាក្សានៅចំពោះមុខតុលាការ ក្នុងពេលជំនុំជំរះប៉ុណ្ណោះ ។

៣- ចៅក្រមត្រូវមានបំណងឱ្យទទួលបានសំលេងជាឯកច្ឆន្ទនៅក្នុងសេចក្ដីសំរេចរបស់ខ្លួន ការខកខានមិនបាននូវសេចក្ដីសំរេចជាឯកច្ឆន្ទ សេចក្ដីសំរេចត្រូវធ្វើឡើងតាមមតិភាគច្រើនរបស់ចៅក្រមទាំងឡាយ ។

៤- ការពិភាក្សាសំរេចរបស់សភាជំនុំជំរះ ត្រូវរក្សាជាការសំងាត់ ។

៥- សេចក្ដីសំរេច ត្រូវធ្វើជាលាយល័ក្ខអក្សរ ហើយត្រូវមានសេចក្ដីថ្លែង អំពីការរកឃើញលើកស្តុតាង និង សេចក្ដីសន្និដ្ឋានពេញលេញ ព្រមទាំងមានហេតុផល។ សភាជំនុំជំរះ ត្រូវចេញនូវសេចក្ដីសំរេចតែមួយគត់ ។ នៅពេលគ្មានភាពឯកច្ឆន្ទ សេចក្ដីសំរេចរបស់សភាជំនុំជំរះ ត្រូវមានទាំងទស្សនៈរបស់មតិភាគច្រើន និង ទស្សនៈរបស់មតិភាគតិច។ សេចក្ដីសំរេច ឬ សេចក្ដីសង្ខេបនោះ ត្រូវប្រកាសនៅក្នុងតុលាការជាចំហរ ។

## មាត្រា ៧៥ : អំពីការជួសជុលដល់ជនរងគ្រោះ

១- តុលាការ ត្រូវបង្កើតជាគោលការណ៍ដែលទាក់ទងដល់ការជួសជុលដល់ ឬទាក់ទងនឹងជនរងគ្រោះ រួមមាន ការសងវិញ, សំណងជម្ងឺចិត្ត និង ការស្តារនីតិសម្បទាឡើងវិញ។ ដោយឈរលើមូលដ្ឋាននេះ នៅក្នុងសេចក្ដីសំរេចរបស់ខ្លួន តុលាការអាចកំណត់តាមសំណើរ ឬ តាមការស្នើរបស់ខ្លួននៅក្នុងកាលៈទេសៈពិសេស១ នូវកំរិតវិសាលភាព និង ទំហំនៃព្យសនកម្ម ការបាត់បង់ និង គ្រោះថ្នាក់ដល់ឬទាក់ទងនឹងជនរងគ្រោះ ហើយថ្លែងពីគោលការណ៍ទាំងឡាយដែលខ្លួនកំពុងសំអាងលើ ។

២- តុលាការ អាចចេញបញ្ជាផ្ទាល់លើពិរុទ្ធជន ដោយបញ្ជាក់នូវការជួសជុលដែលសមស្របដល់ឬទាក់ទងនឹងជនរងគ្រោះ រួមមាន ការសងវិញ, សំណងជម្ងឺចិត្ត និង ការស្តារនីតិសម្បទាឡើងវិញ ។ បើសមស្រប តុលាការ អាចបញ្ជា ថាការផ្តល់ឱ្យសម្រាប់ការជួសជុល ត្រូវធ្វើឡើងតាមរយៈមូលនីធិក្នុងភារៈគ្រប់គ្រង ដូចមានចែងក្នុងមាត្រា ៧៩ ។

៣- មុនពេលចេញបញ្ជាណាមួយតាមមាត្រានេះ តុលាការអាចអញ្ជើញ ហើយត្រូវមានការគិតគូរចំពោះការតំណាង ពីឬក្នុងនាម ពិរុទ្ធជន, ជនរងគ្រោះ ជនដែលមានផលប្រយោជន៍ ឬ រដ្ឋដែលមានផលប្រយោជន៍ផ្សេង១ទៀត ។

៤- ក្នុងការអនុវត្តន៍អំណាចរបស់ខ្លួន តាមមាត្រានេះ បន្ទាប់ពីជនណាម្នាក់ត្រូវថ្កោលទោសចំពោះបទល្មើសព្រហ្មទណ្ឌនៅក្នុងយុត្តាធិការរបស់ខ្លួន តុលាការ អាចកំណត់ថាតើចាំបាច់ត្រូវរកវិធានការ តាមកថាខ័ណ្ឌទី១នៃមាត្រា៩៣ ដើម្បីដាក់ឱ្យមានប្រសិទ្ធភាពនូវបញ្ជាដែលខ្លួនអាចធ្វើឡើងតាមមាត្រានេះ ឬ អត់ ។

៥- រដ្ឋភាគី ត្រូវដាក់ឱ្យមានប្រសិទ្ធភាពនូវសេចក្តីសំរេចតាមមាត្រានេះ ហាក់ដូចជាបទបញ្ញត្តិនៃមាត្រា១០៩ អាចអនុវត្តបានចំពោះមាត្រានេះបានអញ្ចឹង ។

៦- គ្មានអ្វីមួយក្នុងមាត្រានេះ ត្រូវបានយកទៅបកស្រាយឱ្យមានលក្ខណៈអគតិធម៌ចំពោះសិទ្ធិរបស់ជនរងគ្រោះ តាមច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិឡើយ ។

## មាត្រា ៧៦ : អំពីការដាក់ទោស

១- ក្នុងករណីមានការថ្កោលទោស សភាជំនុំជំរះ ត្រូវពិចារណាទោសដែលសមស្របដើម្បីដាក់ ហើយត្រូវយកចិត្តទុកដាក់ចំពោះភស្តុតាងដែលបានបង្ហាញ និង ការដាក់ជូនក្នុងអំឡុងពេលជំនុំជំរះដែលទាក់ទងនឹងទោសនោះ។

២- លើកលែងតែ ករណីអនុវត្តតាមមាត្រា៦៥ ហើយមុនពេលបញ្ចប់ការជំនុំជំរះ តាមការស្នើរបស់ខ្លួន សភាជំនុំជំរះត្រូវបើកសវនាការបន្តមួយទៀត តាមសេចក្តីស្នើរបស់ព្រះរាជអាជ្ញា ឬ របស់ជនជាប់ចោទ ដើម្បីស្តាប់មើលភស្តុតាងបន្ថែម ឬ ការដាក់ជូនបន្ថែមដែលទាក់ទងនឹងការដាក់ទោសនោះស្របតាមវិធាននៃនីតិវិធី និងភស្តុតាង ។

៣- ពេលអនុវត្តតាមកថាខ័ណ្ឌទី២ ការតំណាងណាមួយ ក្រោមមាត្រា៧៥ ត្រូវស្តាប់ក្នុងអំឡុងពេលសវនាការបន្ត យោងតាមកថាខ័ណ្ឌទី២ ហើយបើចាំបាច់ ត្រូវស្តាប់នៅក្នុងសវនាការបន្ថែមទៀតណាមួយក៏បាន ។

៤- ទោស ត្រូវប្រកាសជាសាធារណៈ ហើយមានវត្តមាននៃជនជាប់ចោទ ក្នុងពេលដែលអាចធ្វើទៅបាន ។

## ភាគទី៧ : អំពីទណ្ឌកម្ម

### មាត្រា ៧៧ : អំពីទណ្ឌកម្មដែលអាចយកទៅអនុវត្តបាន

១- ជាកម្មវត្ថុនៃមាត្រា១១០ តុលាការ អាចដាក់ទណ្ឌកម្ម លើជនដែលមានពិរុទ្ធ ពីបទល្មើសព្រហ្មទណ្ឌ ក្រោមមាត្រា ៥ នៃច្បាប់លក្ខន្តិកៈនេះ នូវទណ្ឌកម្មមួយក្នុងចំណោមទណ្ឌកម្មទាំងឡាយ ដូចតទៅនេះ :

ក- ទោសពន្ធនាគារ តាមចំនួនឆ្នាំដែលបានកំណត់ ដែលមិនលើសពីចំនួនទោសអតិបរិមា៣០ឆ្នាំឡើយ. ឬ

ខ- ទោសពន្ធនាគារអស់មួយជីវិត បើត្រូវបានធ្វើយុត្តិកម្មដោយស្ថានទម្ងន់ដ៏ធ្ងន់នៃបទល្មើសព្រហ្មទណ្ឌ ព្រមទាំងកាលៈទេសៈឯកត្តបុគ្គលរបស់ពិរុទ្ធជន ។

២- តុលាការ អាចដាក់ទណ្ឌកម្មបន្ថែមលើទោសពន្ធនាគារ នូវ :

ក- ការផាកពិន័យជាប្រាក់ តាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាននៃនីតិវិធីនិងភស្តុតាង

ខ- ការដកហូតផលពីការលក់ទ្រព្យ ការដកហូតទ្រព្យសម្បត្តិ និង ទ្រព្យធន ដែលបានមកដោយផ្ទាល់ឬមិនផ្ទាល់ ពីបទល្មើសព្រហ្មទណ្ឌនោះ ដោយមិនមានអគតិចម៌ចំពោះសិទ្ធិរបស់តតិយភាគីដែលសុចរិតឡើយ ។

### មាត្រា ៧៨ : អំពីការកំណត់ទោស

១- ក្នុងការកំណត់ទោស ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង តុលាការត្រូវលើកយកមកពិចារណានូវកត្តាទាំងឡាយ ដូចជា ស្ថានទម្ងន់នៃបទល្មើសព្រហ្មទណ្ឌ និងកាលៈទេសៈឯកត្តបុគ្គលរបស់ ពិរុទ្ធជន ។

២- ក្នុងការដាក់ទោសពន្ធនាគារ តុលាការ ត្រូវកាត់បន្ថយនូវរយៈពេល ដែលបានចំណាយពីមុនក្នុងការឃុំខ្លួន ស្របតាមដីការរបស់តុលាការ ប្រសិនបើមាន។ តុលាការ អាចកាត់បន្ថយរយៈពេលដែលបានចំណាយក្រៅពីការចំណាយក្នុងការឃុំខ្លួន ដែលទាក់ទងនឹងការប្រព្រឹត្តដែលជាដើមកំណើតនៃបទល្មើសព្រហ្មទណ្ឌនោះ ។

៣- ពេលណាជនណាម្នាក់ ត្រូវបានដាក់ឱ្យជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌលើសពីមួយ តុលាការត្រូវប្រកាសទោសចំពោះបទល្មើសព្រហ្មទណ្ឌទាំងនោះមួយម្តងៗ និង ទោសរួម ដែលបញ្ជាក់នូវរយៈពេលសរុបនៃទោសពន្ធនាគារ។ រយៈពេលនេះ មិនត្រូវឱ្យតិចជាងទោសខ្ពស់បំផុតក្នុងចំណោមទោសទាំងឡាយដែល

ត្រូវបានប្រកាសឡើយ ហើយមិនត្រូវលើពីទោសពន្ធនាគារ៣០ឆ្នាំ ឬ លើស ពីទោសពន្ធនាគារអស់មួយជីវិត អនុលោមតាម កថាខ័ណ្ឌទី១(ខ)នៃមាត្រា ៧៧ ឡើយ ។

### មាត្រា ៧៩ : មូលនិធិក្នុងភារៈគ្រប់គ្រង

១- មូលនិធិក្នុងភារៈគ្រប់គ្រង ត្រូវបង្កើតឡើងដោយសេចក្តីសំរេច របស់សន្និបាតនៃរដ្ឋភាគីទាំងឡាយ សម្រាប់ជាប្រយោជន៍នៃជនរងគ្រោះ និង ក្រុមគ្រួសាររបស់ជនគ្រោះនោះ ដោយសារបទល្មើសព្រហ្មទណ្ឌ ដែលឋិតក្នុងវង្វង់យុត្តាធិការរបស់តុលាការ ។

២- តុលាការ អាចបញ្ជាឱ្យផ្ទេរប្រាក់ និង ទ្រព្យសម្បត្តិផ្សេងៗដែលប្រមូលបាន ពីការផាកពិន័យ ឬ ពីការដកហូតទ្រព្យសម្បត្តិ ចូលទៅក្នុងមូលនិធិក្នុងភារៈគ្រប់គ្រង តាមដីការបស់តុលាការ ។

៣- មូលនិធិក្នុងភារៈគ្រប់គ្រង ត្រូវចាត់ចែងស្របតាមលក្ខណៈវិនិច្ឆ័យ ដែលនឹងត្រូវកំណត់ដោយសន្និបាតនៃរដ្ឋភាគី ទាំងឡាយ ។

### មាត្រា ៨០ : អំពីការមិនមានអគតិធម៌ចំពោះការអនុវត្តន៍ទណ្ឌកម្មជាតិ និង ច្បាប់ជាតិ

គ្មានអ្វីមួយនៅក្នុងភាគនេះនៃច្បាប់លក្ខន្តិកៈនេះត្រូវប៉ះពាល់ដល់ការអនុវត្តន៍ដោយរដ្ឋទាំងឡាយនូវទណ្ឌកម្មដែលបានចែងនៅក្នុងច្បាប់ជាតិរបស់ខ្លួន ឬ ក៏ប៉ះពាល់ដល់ច្បាប់លក្ខន្តិកៈរបស់រដ្ឋទាំងឡាយ ដែលមិនមានចែងអំពីទណ្ឌកម្ម ដែលបានពណ៌នា នៅក្នុងភាគនេះឡើយ ។

## ភាគទី៨ : អំពីបណ្តឹងឧទ្ធរណ៍ និង បណ្តឹងសើរើ

### មាត្រា ៨១ :

### អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសំរេចឱ្យរួចខ្លួន ឬ ឱ្យមានពិរុទ្ធ ឬ ប្រឆាំងនឹងការកាត់ទោស

១- ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង សេចក្តីសំរេចក្រោមមាត្រា៧៤ អាចត្រូវបានប្តឹងឧទ្ធរណ៍ដូចខាងក្រោម:

ក- ព្រះរាជអាជ្ញា អាចប្តឹងឧទ្ធរណ៍ ផ្អែកលើមូលហេតុណាមួយដូចតទៅនេះ :

១ - កំហុសផ្នែកនីតិវិធី

២ - កំហុសនៃអង្គហេតុ

៣ - កំហុសនៃអង្គច្បាប់

ខ- ពិរុទ្ធជន ឬ ព្រះរាជអាជ្ញា ដែលធ្វើក្នុងនាមពិរុទ្ធជននោះ អាចប្តឹងឧទ្ធរណ៍ ផ្អែកលើមូលហេតុណាមួយដូចតទៅនេះ :

១ - កំហុសផ្នែកនីតិវិធី

២ - កំហុសនៃអង្គហេតុ

៣ - កំហុសនៃអង្គច្បាប់

៤ - មូលហេតុផ្សេងទៀត ដែលប៉ះពាល់ដល់ភាពយុត្តិធម៌ ឬ ដល់ភាពអាចយកជាការបាននៃដំណើរការជំរះរឿងក្តី ឬ នៃសេចក្តីសំរេច ។

២- ក- ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង ទោស អាចត្រូវបានប្តឹងឧទ្ធរណ៍ ដោយព្រះរាជអាជ្ញា ឬ ពិរុទ្ធជន ផ្អែកលើមូលហេតុនៃភាពមិនសមាមាត្រគ្នា រវាងបទល្មើសព្រហ្មទណ្ឌនិងទោសនោះ ។

ខ- ប្រសិនបើ នៅក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងទោស តុលាការពិចារណាថា មានមូលហេតុនានា ដែលការកាត់ឱ្យមានពិរុទ្ធភាពអាចត្រូវចាត់ទុកជាអត់បានការ ទាំងស្រុង ឬ មួយផ្នែក តុលាការអាចអញ្ជើញឱ្យ ព្រះរាជអាជ្ញា ឬ ពិរុទ្ធជន ដាក់ជូននូវមូលហេតុនានាក្រោមកថាខ័ណ្ឌទី១(ក) ឬ (ខ)នៃមាត្រា ៨១ ហើយ អាចចេញនូវសេចក្តីសំរេចមួយ អំពីពិរុទ្ធភាព ស្របតាមមាត្រា ៨៣ ។

គ- អនុវត្តនីតិវិធីដដែលនេះ តែក្នុងករណីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងពិរុទ្ធភាពប៉ុណ្ណោះ ពេលណាតុលាការពិចារណាថា មានមូលហេតុក្នុងការបន្ថយទោស ក្រោមកថាខ័ណ្ឌទី២(ក) ។

៣- ក- ពិរុទ្ធជន ត្រូវបន្តឋិតនៅក្នុងការឃុំខ្លួន ក្នុងពេលតម្កល់បណ្តឹងឧទ្ធរណ៍ លុះត្រាតែ សភាជំនុំជំរះបញ្ជាឱ្យធ្វើផ្សេងពីនេះ ។

ខ- នៅពេលដែលរយៈពេលនៃការឃុំខ្លួនរបស់ពិរុទ្ធជន ហួសពីទោសពន្ធនាគារដែលបានដាក់ ត្រូវដោះលែងជននោះវិញ លើកលែងតែ ប្រសិនបើព្រះរាជអាជ្ញាក៏ប្តឹងឧទ្ធរណ៍ដែរ ដែលការដោះលែងនោះ អាចជាកម្មវត្ថុនៃលក្ខខ័ណ្ឌ ក្រោមអនុកថាខ័ណ្ឌ (គ)ខាងក្រោម ។

គ- ក្នុងករណីឱ្យរួចខ្លួន ត្រូវដោះលែង ជនជាប់ចោទ ជាបន្ទាន់ តាមលក្ខខ័ណ្ឌដូចតទៅ :

(១) ក្រោមកាលៈទេសៈពិសេស និង មានការគិតគូរ ក្នុងចំណោមការប្រថុយផ្សេងៗ ចំពោះការប្រថុយយ៉ាងខ្លាំងនៃការគេចខ្លួន ចំពោះភាពធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និង ចំពោះប្រូបាប៊ីលីតេនៃជោគជ័យក្នុងការប្តឹងឧទ្ធរណ៍ តាមសំណើរបស់ព្រះរាជអាជ្ញា សភាជំនុំជំរះ អាចបន្តការឃុំខ្លួនជននោះ ក្នុងពេលប្តឹងឧទ្ធរណ៍ បាន។

(២) ក្រោមអនុកថាខ័ណ្ឌ(គ)(i) សេចក្តីសំរេចរបស់សភាជំនុំជំរះ អាចត្រូវបានប្តឹងឧទ្ធរណ៍ ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង។

៤- ជាកម្មវត្ថុនៃបទប្បញ្ញត្តិនៃកថាខ័ណ្ឌទី៣(ក)និង(ខ) ការអនុវត្តសេចក្តីសំរេច ឬ ទោសនោះ ត្រូវព្យួរទុកសិនក្នុងអំឡុងពេលដែលបានអនុញ្ញាតសម្រាប់ការប្តឹងឧទ្ធរណ៍ និង សម្រាប់ថិរៈវេលានៃដំណើរការជំរះរឿងក្តីប្តឹងឧទ្ធរណ៍ ។

## មាត្រា ៨២ : អំពីការប្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសំរេចផ្សេងៗ

១- ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង ភាគីមួយណា ក៏អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសំរេចដូចខាងក្រោម :

ក- សេចក្តីសំរេចទាក់ទងនឹងយុត្តាធិការ ឬ ភាពអាចទទួលយក.

ខ- សេចក្តីសំរេចផ្តល់ ឬ បដិសេធចំពោះការដោះលែងជន ដែលកំពុងត្រូវរងការស៊ើបអង្កេត ឬ កំពុងត្រូវនាំយកមកជំនុំជំរះ.

គ- សេចក្តីសំរេចរបស់សភាមុនការជំនុំជំរះ ដែលធ្វើតាមការផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ក្រោមកថាខ័ណ្ឌទី៣ នៃមាត្រា ៥៦.

ឃ- សេចក្តីសំរេចដែលទាក់ទងនឹងបញ្ហាណាមួយ ដែលទំនងជាប៉ះពាល់យ៉ាងសំខាន់ ដល់ការប្រព្រឹត្តទៅដោយយុត្តិធម៌និងដោយល្បឿនរហ័យនៃដំណើរការជំរះរឿងក្តី ឬ ប៉ះពាល់យ៉ាងសំខាន់ដល់លទ្ធផលនៃការជំនុំជំរះ ហើយជាទស្សនៈរបស់សភាមុនការជំនុំជំរះ ឬ សភាជំនុំជំរះ ដំណោះស្រាយជាបន្ទាន់មួយ ដោយសភាឧទ្ធរណ៍ អាចជំរុញយ៉ាងសំខាន់ដល់ដំណើរការជំរះរឿងក្តីនោះ ។

២- ក្រោមកថាខ័ណ្ឌទី៣(យ) នៃមាត្រា៩៧ សេចក្តីសំរេចរបស់សភាមុនការជំនុំជំរះ អាចត្រូវបានរដ្ឋ ដែលពាក់ពន្ធ័ ឬ ព្រះរាជអាជ្ញា ប្តឹងឧទ្ធរណ៍ដោយមានការអនុញ្ញាតរបស់សភាជំនុំជំរះ។ បណ្តឹងឧទ្ធរណ៍ ត្រូវបើកសវនាការ ផ្អែកលើមូលដ្ឋានលឿនរហ័ស ។

៣- ការប្តឹងឧទ្ធរណ៍ មិនត្រូវមានអានុភាពព្យួរទុកដោយឯកឯងឡើយ លុះត្រាតែសភាឧទ្ធរណ៍ បញ្ជាយ៉ាងនោះនៅពេលមានសំណើរ ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង ។

៤- អ្នកតំណាងផ្នែកច្បាប់នៃជនរងគ្រោះ ពិរុទ្ធជន ឬ ម្ចាស់សុចរិតនៃទ្រព្យសម្បត្តិ ដែលរងអានុភាពប្រឆាំង ដោយសារការបញ្ជារឃុំតុលាការ ក្រោមមាត្រា៧៣ អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងបញ្ជានេះ ដើម្បីការជួសជុលឡើងវិញ ដូចមានចែងក្នុង វិធាននៃនីតិវិធីនិងភស្តុតាង ។

### មាត្រា ៨៣ : អំពីដំណើរការបណ្តឹងឧទ្ធរណ៍

១. សំរាប់គោលបំណងនៃដំណើរការដែលមានចែងនៅក្នុងមាត្រា៨១ និង ក្នុងមាត្រានេះ សភាឧទ្ធរណ៍ត្រូវមានអំណាចទាំងអស់ដែលសភាជំនុំជំរះមាន ។

២. បើសិនជាសភាឧទ្ធរណ៍ យល់ឃើញថា ដំណើរការដែលត្រូវគេប្តឹងឧទ្ធរណ៍ មានភាពអយុត្តិធម៌ក្នុងសភាពមួយដែលប៉ះពាល់ដល់ភាពដែលអាចទុកចិត្តបាននៃសេចក្តីសំរេច ឬ លើការដាក់ទោស ឬ បើសិនជាសភាឧទ្ធរណ៍ យល់ឃើញថាសេចក្តីសំរេច ឬ ការដាក់ទោសដែលត្រូវបានគេប្តឹងឧទ្ធរណ៍បានត្រូវប៉ះពាល់ជាធំដុំដោយការភាន់ច្រឡំលើអង្គហេតុ ឬ លើអង្គច្បាប់ ឬ ការភាន់ច្រឡំខាងនីតិវិធី សភាឧទ្ធរណ៍អាច :

ក. បដិសេធ ឬ កែប្រែ សេចក្តីសំរេចឬការដាក់ទោស នោះបាន. ឬ

ខ. បញ្ជាឱ្យធ្វើការជំនុំជំរះសារជាថ្មី ដោយសភាជំនុំជំរះមួយផ្សេងទៀត។

សំរាប់គោលបំណងទាំងនេះ សភាឧទ្ធរណ៍ អាចបញ្ជូនបញ្ហាអង្គហេតុត្រឡប់ទៅសភាជំនុំជំរះដើមវិញ ដើម្បីឱ្យសភាជំនុំជំរះនោះ កំណត់អង្គហេតុសារជាថ្មីនិងរាយការណ៍ជូនសភាឧទ្ធរណ៍វិញ ឬ សភាឧទ្ធរណ៍ អាចរកភស្តុតាងដោយខ្លួនឯងដើម្បីកំណត់អង្គហេតុ។ នៅពេលដែលសេចក្តីសំរេចឬការដាក់ទោសត្រូវបានប្តឹងឧទ្ធរណ៍ដោយពិរុទ្ធជនតែឯង ឬ ដោយព្រះរាជអាជ្ញាក្នុងនាមពិរុទ្ធជននោះ សេចក្តីសំរេច ឬ ការដាក់ទោសមិនអាចត្រូវកែប្រែដើម្បីធ្វើឱ្យខូចប្រយោជន៍ពិរុទ្ធជនឡើយ ។

៣. ប្រសិនបើនៅក្នុងបណ្តឹងឧទ្ធរណ៍មួយជំទាស់នឹងការដាក់ទោស សភាឧទ្ធរណ៍យល់ឃើញថា ការដាក់ទោសពុំសមាមាត្រនឹងបទល្មើសព្រហ្មទណ្ឌនោះទេ សភាឧទ្ធរណ៍អាចកែប្រែការដាក់ទោស ស្របតាមតាមភាគទី ៧ ។

៤. សាលដីការបស់សភាឧទ្ធរណ៍ ត្រូវសំរេចដោយសំលេងភាគច្រើននៃអង្គចៅក្រម នឹងត្រូវប្រកាសជាចំហរនៅក្នុងតុលាការ។ សាលដីកាត្រូវបញ្ជាក់អំពីហេតុផលទាំងឡាយដែលបានសំអាង។ នៅពេលគ្មានការយល់ព្រមជាឯកច្ឆ័នទេ សាលដីការបស់សភាឧទ្ធរណ៍ត្រូវមានទាំងទស្សនៈរបស់មតិភាគច្រើន និងទស្សនៈរបស់មតិភាគតិច ប៉ុន្តែចៅក្រមមួយរូប១ អាចបញ្ចេញមតិដាច់ដោយឡែក ឬ មតិជំទាស់ ដែលទាក់ទងនឹងបញ្ហាអង្គច្បាប់ ។

សភាឧទ្ធរណ៍ អាចចេញសាលដីការបស់ខ្លួនដោយគ្មានវត្តមានជនដែលត្រូវសំរេចថាមានពិរុទ្ធភាព ឬ គ្មានពិរុទ្ធភាព ។

## មាត្រា ៨៤ : បណ្តឹងសើរើលើការសំរេចថាមានពិរុទ្ធភាព ឬ ការដាក់ទោស

១. ពិរុទ្ធជនខ្លួនឯង ឬ ក្រោយពេលខ្លួនទទួលមរណៈភាព សហព័ទ្ធ កូន ឪពុកម្តាយ ឬ ជនណាម្នាក់ដែលនៅរស់រានមានជីវិត នៅពេលដែលជនជាប់ចោទបានទទួលមរណៈភាព និងដែលបានទទួលការផ្តាំផ្ញើរជាលាយល័ក្ខអក្សរពីជនជាប់ចោទឱ្យធ្វើបណ្តឹងសើរើនោះ ឬ ព្រះរាជអាជ្ញាតាងនាមឱ្យជននោះ អាចដាក់ពាក្យសុំឱ្យសភាឧទ្ធរណ៍ ធ្វើការសើរើសាលក្រមស្ថាពរដែលបានសំរេចថាមានពិរុទ្ធភាព ឬ ដាក់ទោស ជននោះ ដោយឈរលើមូលដ្ឋានថា :

ក. ភស្តុតាងថ្មី ត្រូវបានរកឃើញ ដែល :

(i) មិនអាចរកបាននៅពេលកំពុងជំនុំជំរះ ហើយការរកមិនបាននេះ មិនមែនបណ្តាលទាំងស្រុង ឬ មួយផ្នែក មកពីភាគីដែលបានដាក់ពាក្យសុំឡើយ។

(ii) មានសារៈសំខាន់គ្រប់គ្រាន់ ដែលបើសិនជាភស្តុតាងនេះត្រូវបានលើកបង្ហាញនៅពេលជំនុំជំរះនោះលទ្ធផលទំនងជាមានសេចក្តីវិនិច្ឆ័យមួយផ្សេង ។

ខ. ត្រូវបានគេរកឃើញថ្មីថា ភស្តុតាងដែលមានឥទ្ធិពល លើសេចក្តីសំរេចដែលត្រូវបានពិចារណា នៅពេលជំនុំជំរះ និង ដែលការសំរេចថាមានពិរុទ្ធភាពសំអាងលើ ជាភស្តុតាងមិនពិត ក្លែងក្លាយ ឬ ត្រូវបានគេកែបន្លំ ។

គ. ចៅក្រមម្នាក់ ឬ ច្រើននាក់ដែលបានចូលរួមក្នុងការសំរេចពិរុទ្ធភាព ឬ ដែលបានចូលរួមក្នុងការបញ្ជាក់បទចោទប្រកាន់ដែលបានប្រព្រឹត្ត នៅក្នុងករណីនោះ នូវអំពើកំហុសធ្ងន់ធ្ងរ ឬ នូវអំពើបំពានភារៈកិច្ចដែលមានសភាពធ្ងន់ធ្ងរល្មមសំរាប់ធ្វើយុត្តិកម្មលើការដកចៅក្រម ឬ ចៅក្រមទាំងនោះចេញពីមុខតំណែង ក្រោមមាត្រា ៤៦ ។

២. សភាឧទ្ធរណ៍ ត្រូវបដិសេធពាក្យបណ្តឹងសើរើ បើសិនជាខ្លួនពិចារណាថាវាពុំមានមូលដ្ឋាន។ បើសិនជាសភាឧទ្ធរណ៍សំរេចថាពាក្យបណ្តឹងសើរើមានគុណសម្បត្តិគ្រប់គ្រាន់នោះ តាមការសមស្រប សភាឧទ្ធរណ៍អាច :

ក. កោះបើកសភាជំនុំជំរះដើមសារជាថ្មី

ខ. បង្កើតសភាជំនុំជំរះថ្មីមួយទៀត. ឬ

គ. រក្សាទុកខ្លួនឯងនូវយុត្តាធិការលើរឿងក្តីនោះ

ដោយមានគោលបំណងដើម្បីឈានទៅដល់ការសំរេចថា តើគួរកែប្រែសាលក្រមនោះឬអត់ បន្ទាប់ពីស្តាប់ភាគីទាំងឡាយ តាមលក្ខខ័ណ្ឌដែលមានចែងនៅក្នុងវិធាននៃនីតិវិធីនិងភស្តុតាង ។

### មាត្រា ៨៥ : ការសងជំងឺចិត្តចំពោះជនដែលត្រូវបានចាប់ខ្លួន ឬ សំរេចថាមានពិរុទ្ធភាព

១. ជនទាំងឡាយណាដែលជាជនរងគ្រោះពីការចាប់ខ្លួន ឬ ឃុំខ្លួនដោយខុសច្បាប់ មានសិទ្ធិបង្ខំឱ្យតុលាការសងជំងឺចិត្តមកខ្លួន ។

២. នៅពេលដែលជនណាមួយ ត្រូវបានតុលាការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដោយសាលក្រមស្ថាពរ ហើយនៅពេលបន្ទាប់មកពិរុទ្ធភាពរបស់ជននោះត្រូវបានតុលាការសើរើឡើងវិញ ដោយសារអង្គហេតុថ្មី

ឬ ដែលទើបរកឃើញថ្មី បានបង្ហាញយ៉ាងពិតប្រាកដថា មានកំហុសឆ្គងខាងតុលាការ ដូច្នេះជនដែលទទួលរងទណ្ឌកម្មដែលជាលទ្ធផលនៃការសំរេចថាមានពិរុទ្ធភាពនោះត្រូវបានទទួលសំណងជំងឺចិត្តតាមច្បាប់បាន លុះត្រាតែភស្តុតាងបង្ហាញថាការមិនបានបង្ហាញអំពីអង្គហេតុ ដែលគ្មាននរណាដឹងនៅពេលជំនុំជំរះនោះ មិនបណ្តាល ទាំងស្រុងឬមួយផ្នែក មកពីជននោះឡើយ ។

៣. នៅក្នុងកាលៈទេសៈពិសេស នៅពេលដែលតុលាការរកឃើញនូវភស្តុតាងពិតប្រាកដដែលបង្ហាញថាមានកំហុសឆ្គងខាងតុលាការធ្ងន់ធ្ងរនិងជាក់ស្តែង តុលាការអាច ដោយអំណាចឆន្ទានុសិទ្ធិរបស់ខ្លួននិងយោងទៅតាមលក្ខណៈវិនិច្ឆ័យនៅក្នុងវិធាននៃនីតិវិធីនិងភស្តុតាង ផ្តល់សំណងជំងឺចិត្តចំពោះជនដែលត្រូវបានដោះលែងពីការឃុំខ្លួន បន្ទាប់ពីចេញសាលក្រមស្ថាពរអោយរួចខ្លួន ឬ បន្ទាប់ពីបញ្ចប់ដំណើរការជំរះក្តីដោយសារមូលហេតុខាងលើ ។

## ភាគទី៩ : កិច្ចសហប្រតិបត្តិការ និង ការជួយជ្រោមជ្រែងតុលាការ ជាអន្តរជាតិ

### មាត្រា ៨៦ : អំពីកាតព្វកិច្ចទូទៅដើម្បីសហប្រតិបត្តិការ

ដោយអនុលោមទៅតាមបទបញ្ញត្តិនៃច្បាប់លក្ខន្តិកៈនេះ រដ្ឋភាគីទាំងអស់ត្រូវតែសហប្រតិបត្តិការដោយពេញលេញជាមួយតុលាការក្នុងការងារស៊ើបអង្កេត និងការនាំយកមកជំនុំជំរះ នូវបទល្មើសព្រហ្មទណ្ឌដែលឋិតក្នុងយុត្តាធិការនៃតុលាការនេះ ។

### មាត្រា ៨៧ : អំពីសំណើសុំកិច្ចសហប្រតិបត្តិការ : បទបញ្ញត្តិទូទៅ

១. (ក) តុលាការនេះ មានអំណាចក្នុងការស្នើសុំរដ្ឋភាគីទាំងឡាយឱ្យសហប្រតិបត្តិការ ។ សំណើសុំ ត្រូវបញ្ជូនតាមរយៈបណ្តាញការទូត ឬ តាមបណ្តាញសមស្របដទៃទៀត ដូចដែលអាចបានកំណត់ទុកជាមុនដោយរដ្ឋភាគីនីមួយៗ នៅពេលខ្លួនផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬ យល់ព្រមចូលជាសមាជិកនៃច្បាប់លក្ខន្តិកៈនេះ ។

រាល់ការផ្លាស់ប្តូរនាពេលបន្តបន្ទាប់នូវបណ្តាញដែលបានកំណត់រួចហើយត្រូវតែធ្វើឡើងដោយរដ្ឋភាគីនីមួយៗ ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង ។

(ខ) នៅពេលសមស្រប ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិនៃអនុកថាខ័ណ្ឌ(ក) សំណើសុំកិច្ចសហប្រតិបត្តិការ ក៏អាចបញ្ជូនផងដែរ តាមរយៈអង្គការប៉ូលីសឧក្រិដ្ឋកម្មអន្តរជាតិ ឬ តាមរយៈអង្គការក្នុងតំបន់ណាមួយដែលសមស្រប ។

២ សំណើសុំកិច្ចសហប្រតិបត្តិការ និង ឯកសារណាមួយសំរាប់គាំទ្រសំណើ ត្រូវធ្វើឡើង ឬ ត្រូវអមជាមួយច្បាប់បកប្រែជាភាសាផ្លូវការរបស់រដ្ឋហត្ថលេខីនោះ ឬ ជាភាសាការងារមួយរបស់តុលាការនេះ ស្របតាម ការជ្រើសរើសដែលធ្វើឡើងដោយរដ្ឋនោះ នៅពេលផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬ យល់ព្រមចូលជាសមាជិក ។

រាល់ការផ្លាស់ប្តូរជំរើសនាពេលបន្តបន្ទាប់ ត្រូវតែធ្វើឡើងដោយប្រទេសហត្ថលេខីនីមួយៗ ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង ។

៣. រដ្ឋដែលបានទទួលនូវសំណើ ត្រូវរក្សាការសំងាត់នៃសំណើសុំកិច្ចសហប្រតិបត្តិការ ឬ នៃឯកសារណាមួយសំរាប់គាំទ្រសំណើ លើកលែងតែក្នុងករណីការលើកបង្ហាញការសំងាត់នោះ មានសារៈសំខាន់ចាំបាច់សំរាប់ការប្រតិបត្តិសំណើនោះ ។

៤. ទាក់ទងទៅនឹងសំណើណាមួយដើម្បីសុំជំនួយដែលមានចែងនៅក្នុងភាគទី៩នេះ តុលាការអាចចាត់វិធានការ រួមទាំងវិធានការទាំងឡាយដែលទាក់ទងនឹងការការពារពត៌មាន និង ដែលអាចចាំបាច់ ដើម្បីធានាសុវត្ថិភាពឬសុខុមាលភាពខាងផ្លូវកាយឬផ្លូវចិត្តនៃជនរងគ្រោះ សាក្សីសក្តានុពល និង គ្រួសាររបស់ពួកគេ។ តុលាការអាចស្នើសុំដូចជា ពត៌មានណាមួយដែលអាចរកបាន ក្រោមភាគទី៩នេះ ត្រូវបានទទួល ឬ ត្រូវបានចាត់ចែងក្រោមរូបភាពដែលការពារសុវត្ថិភាព និងសុខុមាលភាពខាងផ្លូវកាយឬផ្លូវចិត្តនៃជនរងគ្រោះ សាក្សីសក្តានុពល និង គ្រួសាររបស់ពួកគេ ។

៥. តុលាការអាចអញ្ជើញរដ្ឋណាមួយ ដែលមិនមែនជារដ្ឋភាគីនៃច្បាប់លក្ខន្តិកៈនេះ ឱ្យជួយជ្រោមជ្រែងតាមបទប្បញ្ញត្តិក្នុងភាគទី៩នេះ ផ្អែកលើមូលដ្ឋាននៃការចាត់ចែងពិសេស តាមការព្រមព្រៀងគ្នាជាមួយនឹងរដ្ឋនោះ ឬ តាមមូលដ្ឋានដទៃ ដែលមានលក្ខណៈសមស្រប ។

នៅពេលរដ្ឋមួយ ដែលមិនមែនជារដ្ឋភាគីនៃច្បាប់លក្ខន្តិកៈ ហើយដែលបានយល់ព្រមតាមមូលដ្ឋាននៃការចាត់ចែងពិសេស ឬដែលបានយល់ព្រមជាមួយតុលាការ ខកខានមិនបានសហការតាមការស្នើសុំ

ស្របតាមការចាត់ចែងឬការព្រមព្រៀងណាមួយនោះ តុលាការអាចជូនដំណឹងនេះទៅសន្និបាតនៃរដ្ឋភាគី ឬ ទៅក្រុមប្រឹក្សាសន្តិសុខនៅពេលដែលក្រុមប្រឹក្សាសន្តិសុខបានបញ្ជូនរឿងនេះទៅតុលាការ ។

៦. តុលាការអាចស្នើសុំអង្គការអន្តររដ្ឋាភិបាលណាមួយឱ្យជួយផ្តល់ពតិមាន ឬ ឯកសារ ។ តុលាការអាចស្នើសុំកិច្ចសហប្រតិបត្តិការ និងការជួយជ្រោមជ្រែងដែលមានទ្រង់ទ្រាយផ្សេងៗទៀត តាមការដែលអាចព្រមព្រៀងជាមួយអង្គការនេះ និង ស្របតាមសមត្ថកិច្ច ឬ អាណត្តិនៃអង្គការនោះ ។

៧. នៅពេលដែលរដ្ឋភាគីខកខានមិនបានអនុវត្តតាមសំណើសុំកិច្ចសហប្រតិបត្តិការពីតុលាការ ផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់លក្ខន្តិកៈនេះ ដោយរារាំងតុលាការមិនឱ្យអនុវត្តមុខងារនិងអំណាចរបស់ខ្លួនក្រោមច្បាប់លក្ខន្តិកៈនេះបាន នោះតុលាការអាចធ្វើការសន្និដ្ឋានអំពីឥទ្ធិពលនេះ ហើយបញ្ជូនបញ្ហានេះទៅសន្និបាតនៃរដ្ឋភាគី ឬ ទៅក្រុមប្រឹក្សាសន្តិសុខនៅពេលដែលក្រុមប្រឹក្សាសន្តិសុខបានបញ្ជូនរឿងនេះទៅតុលាការ ។

## មាត្រា ៨៨ : អំពីការមាននីតិវិធីក្រោមច្បាប់ជាតិ

រដ្ឋភាគីទាំងឡាយត្រូវធានាថា ខ្លួនមាននីតិវិធីក្រោមច្បាប់ជាតិរបស់ខ្លួន សំរាប់អនុវត្តកិច្ចសហប្រតិបត្តិការគ្រប់ទ្រង់ទ្រាយដែលមានចែងនៅក្នុងភាគនេះ ។

## មាត្រា ៨៩ : អំពីការប្រគល់មនុស្សទៅឱ្យតុលាការ

១. តុលាការអាចបញ្ជូនសំណើដើម្បីសុំការចាប់ខ្លួន ឬ សុំការប្រគល់ខ្លួនជនណាមួយដោយអមជាមួយនូវឯកសារគាំទ្រសំណើដែលបានបញ្ជាក់ក្នុងមាត្រា៩១ ទៅរដ្ឋណាមួយដែលជននោះអាចត្រូវបានគេរកឃើញនៅលើទឹកដីនៃរដ្ឋនោះ ហើយស្នើសុំឱ្យមានកិច្ចសហប្រតិបត្តិការពីរដ្ឋនោះ ដើម្បីចាប់និងប្រគល់ខ្លួនជននោះ។ ស្របតាមបទប្បញ្ញត្តិនៅក្នុងភាគនេះ និងតាមនីតិវិធីនៃច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីត្រូវអនុវត្តតាមសំណើសុំការចាប់និងប្រគល់ខ្លួន។

២. នៅពេលជនដែលត្រូវបានស្វែងរកការប្រគល់ខ្លួន ធ្វើបណ្តឹងតវ៉ាចំពោះតុលាការជាតិ ដោយឈរលើមូលដ្ឋាននៃគោលការណ៍ការជំនុំជំរះតែមួយលើក (Ne bis in idem)ដូចដែលបានចែងក្នុងមាត្រា២០ នោះរដ្ឋទទួលសំណើត្រូវតែ ពិគ្រោះយោបល់ជាបន្ទាន់ជាមួយតុលាការ ដើម្បីកំណត់ថា តើមានការសំរេចណាមួយដែលពាក់ព័ន្ធលើភាពអាចទទួលយកបាននៃករណីរឿងក្តីនេះ។ បើសិនជា ករណីរឿងក្តីនេះអាច

ទទួលយកបាន នោះរដ្ឋទទួលសំណើត្រូវតែបន្តអនុវត្តតាមសំណើ។ បើសិនជា ការសំរេចអំពីភាពអាចទទួលយកបានមិនទាន់បានសំរេចនៅឡើយ រដ្ឋទទួលសំណើអាចផ្អាកការអនុវត្តសំណើសុំការប្រគល់ខ្លួនជននោះរហូតដល់តុលាការ បានកំណត់អំពីភាពអាចទទួលយកបាននៃករណីរឿងក្តីសិន។

៣. (ក) ស្របតាមច្បាប់ស្តីពីនីតិវិធីរបស់ប្រទេសខ្លួន រដ្ឋជាភាគីត្រូវអនុញ្ញាតឱ្យបញ្ជូនឆ្លងកាត់ទឹកដីរបស់ខ្លួននូវជនដែលត្រូវរដ្ឋផ្សេងប្រគល់ឱ្យទៅតុលាការ លើកលែងតែ ក្នុងករណីដែលការបញ្ជូនឆ្លងកាត់រដ្ឋនោះនឹងបង្អាក់ ឬ ពន្យាពេលការបញ្ជូនខ្លួន ។

(ខ) សំណើដែលតុលាការសុំបញ្ជូនឆ្លងកាត់ត្រូវផ្ញើរជូន ស្របតាមមាត្រា ៨៧ ។ សំណើសុំបញ្ជូនឆ្លងកាត់ត្រូវមាន :

(i) ការពណ៌នាអំពីជនដែលត្រូវបញ្ជូន

(ii) សេចក្តីថ្លែងការណ៍ជាសង្ខេបអំពីអង្គហេតុនៃករណីរឿងក្តី និងអំពីចរិកលក្ខណៈនីត្យានុកូលនៃអង្គហេតុ, និង

(iii) ដីកាសុំការចាប់និងប្រគល់ខ្លួន

(គ) ជនដែលត្រូវបញ្ជូន នឹងត្រូវបានឃុំខ្លួន ក្នុងកំឡុងពេលត្រូវបញ្ជូនឆ្លងកាត់

(ឃ) ពុំចាំបាច់សុំការអនុញ្ញាតឡើយ បើសិនជា ជននោះត្រូវបានគេបញ្ជូនតាមផ្លូវអាកាស ហើយការចុះចតពុំត្រូវបានគ្រោងទុកជាមុននៅលើទឹកដីនៃរដ្ឋត្រូវឆ្លងកាត់

(ង) បើសិនជាការចុះចតដែលពុំបានគ្រោងទុកកើតឡើងនៅលើទឹកដីនៃរដ្ឋត្រូវឆ្លងកាត់ រដ្ឋនោះអាចតម្រូវឱ្យមានសំណើសុំឆ្លងកាត់ដែលចេញពីតុលាការនេះ ដូចដែលមានចែងក្នុងអនុកថាខ័ណ្ឌ(ខ) ។ រដ្ឋដែលត្រូវឆ្លងកាត់ត្រូវឃុំឃាំងជនដែលត្រូវគេបញ្ជូនខ្លួន រហូតទាល់តែបានទទួលសំណើសុំឆ្លងកាត់ ហើយការឆ្លងកាត់បានប្រព្រឹត្តទៅ ដោយលក្ខខ័ណ្ឌថាការឃុំខ្លួនសំរាប់គោលបំណងនៃអនុកថាខ័ណ្ឌនេះមិនលើសពី៩៦ម៉ោងចាប់ពីពេលចុះចតដែលពុំបានគ្រោងទុក លើកលែងតែសំណើសុំឆ្លងកាត់ ត្រូវបានទទួលក្នុងកំឡុងពេលនោះ ។

៤. បើសិនជាជនដែលត្រូវគេស្វែងរកនោះ កំពុងត្រូវបានគេប្តឹង ឬ ជាប់ពន្ធនាគារក្នុងរដ្ឋទទួលសំណើ ពីបទល្មើសព្រហ្មទណ្ឌមួយផ្សេងពីបទល្មើសព្រហ្មទណ្ឌដែលតុលាការនេះស្វែងរកការប្រគល់ខ្លួន នោះរដ្ឋទទួលសំណើត្រូវតែពិគ្រោះយោបល់ជាមួយតុលាការនេះ បន្ទាប់ពីខ្លួនបានសំរេចចិត្តផ្តល់ឱ្យតាមសំណើ ។

## មាត្រា ៩០ : អំពីសំណើប្រជែងគ្នា

១. រដ្ឋភាគីដែលបានទទួលសំណើពីតុលាការសុំការប្រគល់ខ្លួនមនុស្សក្រោមមាត្រា៨៩ បើសិនរដ្ឋភាគីបានទទួលសំណើពីរដ្ឋផ្សេងទៀតដែលសុំការធ្វើបត្យាប័នជនតែមួយដូចគ្នា សំរាប់ការប្រព្រឹត្តតែមួយដូចគ្នាដែលបង្កើតជាមូលដ្ឋាននៃបទល្មើសព្រហ្មទណ្ឌដែលតុលាការស្វែងរកការប្រគល់ខ្លួនជននោះ រដ្ឋនោះត្រូវជូនដំណឹងទៅតុលាការ និង ទៅរដ្ឋធ្វើសំណើអំពីអង្គហេតុនោះ។

២. នៅពេលរដ្ឋដែលធ្វើសំណើជារដ្ឋភាគីមួយ នោះរដ្ឋទទួលសំណើត្រូវតែផ្តល់អាទិភាពចំពោះសំណើរបស់តុលាការ បើសិនជា :

(ក) អនុលោមតាមមាត្រា ១៨ និង១៩ តុលាការបានកំណត់ថា ករណីដែលការប្រគល់ខ្លួនត្រូវបានស្វែងរកគឺអាចទទួលយកបាន ហើយការកំណត់នោះយកចិត្តទុកដាក់លើការស៊ើបអង្កេត ឬការនាំយកមកជំនុំជំរះ ដែលធ្វើឡើងដោយរដ្ឋធ្វើសំណើ យោងតាមការស្នើសុំការធ្វើបត្យាប័នរបស់រដ្ឋនេះ, ឬ

(ខ) តុលាការបានធ្វើការកំណត់ ដូចមានចែងក្នុងអនុកថាខ័ណ្ឌ(ក) ស្របតាមការជូនដំណឹងពីរដ្ឋទទួលសំណើ ក្រោមបទបញ្ញត្តិ កថាខ័ណ្ឌទី១ ។

៣. នៅពេលដែលការកំណត់ក្រោមបទប្បញ្ញត្តិកថាខ័ណ្ឌទី២(ក) មិនទាន់ត្រូវបានធ្វើឡើង នោះរដ្ឋទទួលសំណើ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន រង់ចាំការកំណត់របស់តុលាការក្រោមបទប្បញ្ញត្តិកថាខ័ណ្ឌទី២(ខ) អាចបន្តដោះស្រាយសំណើសុំការធ្វើបត្យាប័នពីរដ្ឋធ្វើសំណើ ប៉ុន្តែមិនត្រូវធ្វើបត្យាប័នជននោះឡើយ រហូតទាល់តែតុលាការបានកំណត់ថាករណីរឿងក្តីនេះមិនអាចទទួលយកបាន។ ការកំណត់របស់តុលាការនឹងត្រូវធ្វើឡើងផ្អែកលើមូលដ្ឋានលឿនរហ័ស។

៤. បើសិនជារដ្ឋធ្វើសំណើ មិនមែនជារដ្ឋភាគីនៃច្បាប់លក្ខន្តិកៈនេះទេ ហើយមិនស្ថិតនៅក្រោមកាតព្វកិច្ចអន្តរជាតិក្នុងការធ្វើបត្យាប័នជននោះទៅរដ្ឋធ្វើសំណើ នោះរដ្ឋទទួលសំណើត្រូវតែផ្តល់អាទិភាពចំពោះសំណើសុំការប្រគល់ខ្លួនពីតុលាការ បើសិនជា តុលាការបានកំណត់ថា រឿងក្តីនេះអាចទទួលយកបាន ។

៥ នៅពេលករណីរឿងក្តីមួយ ក្រោមបទប្បញ្ញត្តិ កថាខ័ណ្ឌទី៤ មិនទាន់ត្រូវបានតុលាការកំណត់ថាអាចទទួលយកបានឬអត់ទេ រដ្ឋទទួលសំណើ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន អាចបន្តដោះស្រាយសំណើសុំការធ្វើបត្យាប័នពីរដ្ឋធ្វើសំណើបាន ។

៦. នៅក្នុងករណីដែលគ្របដណ្តប់ដោយកថាខ័ណ្ឌទី៤ លើកលែងតែ រដ្ឋទទួលសំណើកំពុងឋិតនៅក្រោមកាតព្វកិច្ចអន្តរជាតិក្នុងការប្រគល់ជននោះទៅរដ្ឋធ្វើសំណើដែលមិនមែនជាភាគីនៃច្បាប់លក្ខន្តិកៈនេះ រដ្ឋទទួលសំណើត្រូវតែសំរេចថា ត្រូវប្រគល់ជននោះទៅតុលាការ ឬ ធ្វើបត្យាប័នជននោះទៅរដ្ឋធ្វើសំណើ។ ក្នុងការធ្វើសេចក្តីសំរេច រដ្ឋទទួលសំណើ ត្រូវពិចារណាវាល់កត្តាពាក់ព័ន្ធទាំងអស់ ដែលរួមមានប៉ុន្តែមិនកំរិតដែនកំណត់ត្រឹមនេះទេ :

(ក) កាលបរិច្ឆេទទាំងឡាយនៃបណ្តាសំណើ

(ខ) ប្រយោជន៍នៃរដ្ឋធ្វើសំណើ រួមទាំង បើសិនជាទាក់ទង ថាតើបទល្មើសព្រហ្មទណ្ឌនោះត្រូវបានប្រព្រឹត្តនៅក្នុងទឹកដីរបស់រដ្ឋធ្វើសំណើ ហើយជាប្រទេសផ្តល់សញ្ជាតិឱ្យជនរងគ្រោះនិងជនដែលត្រូវស្វែងរក. និង

(គ) លទ្ធភាពនៃការប្រគល់ខ្លួននាពេលបន្តបន្ទាប់ រវាងតុលាការ និងរដ្ឋធ្វើសំណើ ។

៧. នៅពេលរដ្ឋភាគីមួយ ដែលបានទទួលសំណើពីតុលាការសុំការប្រគល់ខ្លួនជនណាម្នាក់ ក៏បានទទួលសំណើពីរដ្ឋណាមួយ ដែលសុំការធ្វើបត្យាប័ននៃជនដដែលចំពោះអំពើផ្សេងពីអំពើដែលបង្កើតបទល្មើសព្រហ្មទណ្ឌដែលតុលាការស្វែងរកការប្រគល់ខ្លួនជននោះ :

(ក) រដ្ឋទទួលសំណើ ត្រូវតែផ្តល់អាទិភាពចំពោះសំណើរបស់តុលាការ បើសិនជាខ្លួនមិនកំពុងស្ថិតនៅក្រោមកាតព្វកិច្ចអន្តរជាតិក្នុងការធ្វើបត្យាប័នជននោះទៅរដ្ឋធ្វើសំណើទេ

(ខ) បើសិនជា រដ្ឋទទួលសំណើកំពុងស្ថិតនៅក្រោមកាតព្វកិច្ចអន្តរជាតិ ក្នុងការធ្វើបត្យាប័នជននោះទៅរដ្ឋធ្វើសំណើ រដ្ឋទទួលសំណើត្រូវតែសំរេចថាតើត្រូវប្រគល់ជននោះទៅតុលាការ ឬ ត្រូវធ្វើបត្យាប័នជននោះទៅរដ្ឋធ្វើសំណើ។ ក្នុងការសំរេចនោះ រដ្ឋទទួលសំណើត្រូវតែពិចារណាលើរាល់កត្តាពាក់ព័ន្ធទាំងអស់ ដែលរួមមាន ប៉ុន្តែមិនកំរិតដែនកំណត់ចំពោះកត្តាទាំងឡាយណាដែលមានចែងក្នុងកថាខ័ណ្ឌទី៦ ទេ តែត្រូវផ្តល់ការពិចារណាជាពិសេសទៅលើប្រភេទនិងសភាពធ្ងន់ធ្ងរដែលទាក់ទងនៃអំពើដែលឋិតក្នុងចំណោទបញ្ហានោះ ។

៨. ដោយអនុលោមតាមការជូនដំណឹង ក្រោមមាត្រានេះ តុលាការបានកំណត់ថាករណីរឿងក្តីណាមួយមិនអាចទទួលយកបាន ហើយក្រោយមករដ្ឋទទួលសំណើបដិសេធការធ្វើបត្យាប័នឱ្យទៅរដ្ឋធ្វើសំណើ ក្នុងករណីនេះរដ្ឋទទួលសំណើត្រូវជូនដំណឹង ទៅតុលាការអំពីការបដិសេធនេះ ។

## មាត្រា ៩១ : អំពីមាតិកានៃសំណើសុំការចាប់និងប្រគល់ខ្លួន

១. សំណើសុំការចាប់និងប្រគល់ខ្លួន ត្រូវតែធ្វើឡើងជាលាយល័ក្ខអក្សរ ។ នៅក្នុងករណីបន្ទាន់ សំណើអាចធ្វើឡើងតាមមធ្យោបាយណាមួយដែលអាចបញ្ជូនឯកសារជាលាយល័ក្ខអក្សរបាន ដោយមានលក្ខខ័ណ្ឌថាសំណើនោះត្រូវបានបញ្ជាក់តាមរយៈបណ្តាញ ដែលមានចែងក្នុង កថាខ័ណ្ឌ១(ក) នៃមាត្រា៨៧។

២. នៅក្នុងករណី សំណើសុំការចាប់ខ្លួន ឬ ប្រគល់ខ្លួនជនណាម្នាក់ដែលត្រូវបាន សភាមុនការជំនុំជំរះ ចេញដីកាចាប់ខ្លួន ក្រោមបទប្បញ្ញត្តិមាត្រា ៥៨ សំណើនោះត្រូវតែមាននិងគាំទ្រដោយ :

(ក) ពត៌មានដែលពណ៌នាអំពីជនដែលត្រូវស្វែងនោះ ដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីកំណត់អត្តសញ្ញាណជននោះ និងពត៌មានស្តីអំពីទីកន្លែងដែលជននោះអាចស្នាក់នៅ

(ខ) ដីកាចាប់ខ្លួនមួយច្បាប់, និង

(គ) ឯកសារ សេចក្តីថ្លែងការណ៍ ឬ ពត៌មានទាំងឡាយ ដែលអាចមានសារៈសំខាន់ចាំបាច់ដើម្បីបំពេញតាមលក្ខខ័ណ្ឌតម្រូវផ្សេងៗសំរាប់ដំណើរការប្រគល់ខ្លួននៅក្នុងរដ្ឋទទួលសំណើ លើកលែងតែលក្ខខ័ណ្ឌតម្រូវទាំងអស់នោះមិនដាក់បន្ទុកកាន់តែធ្ងន់លើសពីលក្ខខ័ណ្ឌតម្រូវទាំងឡាយ ដែលត្រូវអនុវត្តលើសំណើសុំការធ្វើបត្យាប័ន ដោយស្របតាមសន្ធិសញ្ញាឬការចាត់ចែងឡើងរវាងរដ្ឋទទួលសំណើនិងរដ្ឋដទៃផ្សេង

ទៀត និង បើសិនអាចធ្វើទៅបានលក្ខខ័ណ្ឌតម្រូវត្រូវតែមានបន្ទុកស្រាលជាង ដោយពិចារណាលើប្រភេទដោយឡែកនៃតុលាការ ។

៣. នៅក្នុងករណី សំណើសុំការចាប់និងប្រគល់ខ្លួនជនណាមួយដែលត្រូវបានតុលាការសំរេចថាមានពិរុទ្ធភាពរួចទៅហើយ សំណើនោះត្រូវតែមាននិងគាំទ្រដោយ :

(ក) ដីកាដែលសុំការចាប់ខ្លួនជននោះ ចំនួនមួយច្បាប់

(ខ) សាលក្រមសំរេចថាមានពិរុទ្ធភាព ចំនួនមួយច្បាប់

(គ) ពត៌មានដែលបញ្ជាក់ថាជនដែលត្រូវស្វែងរកនោះ គឺជាជនដែលសាលក្រមសំរេចថាមានពិរុទ្ធភាពនោះសំដៅលើ. និង

(ឃ) សាលក្រមប្រកាសទោស ចំនួនមួយច្បាប់ បើសិនជនដែលត្រូវស្វែងរកនោះ បាននិងកំពុងជាប់ទោស ហើយក្នុងករណីជាប់ទោសពន្ធនាគារ លិខិតបញ្ជាក់អំពីរយៈពេលបានជាប់ឃុំរួចហើយ និងរយៈពេលជាប់ឃុំដែលនៅសល់ ។

៤. ក្រោយពីមានការស្នើសុំដោយតុលាការ រដ្ឋភាគីត្រូវតែពិគ្រោះយោបល់ជាមួយតុលាការ អំពីបញ្ហាទូទៅ ឬ បញ្ហាពិសេស ដែលទាក់ទងនឹងលក្ខខ័ណ្ឌតម្រូវណាមួយក្រោមបទប្បញ្ញត្តិនៃច្បាប់ប្រទេសខ្លួនដែលអាចអនុវត្តបានក្រោមបទប្បញ្ញត្តិកថាខ័ណ្ឌទី២(គ)។ ក្នុងកំឡុងពេលពិគ្រោះយោបល់ រដ្ឋភាគីត្រូវតែផ្តល់យោបល់ដល់តុលាការ អំពីលក្ខខ័ណ្ឌតម្រូវណាមួយដោយច្បាប់ប្រទេសខ្លួន ។

## មាត្រា ៩២ : អំពីការចាប់ខ្លួនបណ្តោះអាសន្ន

១. នៅក្នុងករណីបន្ទាន់ តុលាការអាចស្នើសុំឱ្យមានការចាប់ខ្លួនជាបណ្តោះអាសន្ននៃជនដែលត្រូវស្វែងរកនោះក្នុងរយៈពេលរងចាំការបង្ហាញសំណើសុំប្រគល់ខ្លួន និងឯកសារគាំទ្រសំណើ ដូចបានចែងក្នុងមាត្រា ៩១ ។

២. សំណើសុំចាប់ខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងតាមមធ្យោបាយណាមួយដែលអាចបញ្ជូនឯកសារជាលាយល័ក្ខអក្សរបាន ហើយត្រូវមាន :

(ក) ពត៌មាន ដែលពណ៌នាអំពីជនដែលត្រូវស្វែងរកនោះ និង ដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីកំណត់អត្តសញ្ញាណជន នោះ និងពត៌មានស្តីអំពីទីកន្លែងដែលជននោះអាចស្នាក់នៅ ។

(ខ) សេចក្តីថ្លែងការណ៍សង្ខេបអំពីបទល្មើសព្រហ្មទណ្ឌសំរាប់ស្វែងរកចាប់ខ្លួនជននោះ និង សេចក្តីថ្លែងការណ៍អំពីអង្គហេតុដែលចោទឡើងដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌនោះ បើសិនជាអាចធ្វើទៅបាន រួមទាំងកាលបរិច្ឆេទនិងទីកន្លែងនៃបទល្មើសព្រហ្មទណ្ឌនោះផង ។

(គ) សេចក្តីថ្លែងការណ៍អំពីការមានដីកាចាប់ខ្លួន ឬ ការមានសាលក្រមសំរេចថាមានពិរុទ្ធភាពប្រឆាំងនឹងជនដែលត្រូវស្វែងរក. និង

(ឃ) សេចក្តីថ្លែងការណ៍ថា សំណើសុំប្រគល់ខ្លួនជនដែលត្រូវស្វែងរក នឹងធ្វើតាមក្រោយ ។

៣. ជនដែលត្រូវចាប់ខ្លួនបណ្តោះអាសន្ន អាចត្រូវគេដោះលែងឱ្យរួចឃុំបាន បើសិនរដ្ឋទទួលសំណើមិនបានទទួលសំណើសុំប្រគល់ខ្លួន និងឯកសាគាំទ្រសំណើ ដូចមានចែងក្នុងមាត្រា៩១ ក្នុងកំឡុងពេលកំណត់ដូចមានចែងក្នុងវិធាននៃនីតិវិធីនិងភស្តុតាង។ ទោះបីជាយ៉ាងណាក្តី ជននោះអាចយល់ព្រមប្រគល់ខ្លួនមុនពេលផុតរយៈពេលកំណត់នេះ បើសិនជា ច្បាប់នៃរដ្ឋទទួលសំណើអនុញ្ញាតឱ្យធ្វើបាន ។ ក្នុងករណីនោះ រដ្ឋទទួលសំណើ ត្រូវបន្តដំណើរការប្រគល់ខ្លួនជននោះទៅតុលាការឱ្យបានឆាប់ជាទីបំផុត ។

៤. អង្គហេតុដែលជនត្រូវស្វែងរកនោះត្រូវបានគេដោះលែងពីការឃុំខ្លួនស្របតាមកថាខ័ណ្ឌទី៣ មិនមានអគតិចម៉ចំពោះការចាប់ខ្លួនឬប្រគល់ខ្លួនជននោះនាពេលក្រោយឡើយ បើសិនជាសំណើសុំ ប្រគល់ខ្លួន និង ឯកសារគាំទ្រសំណើ ត្រូវបានគេបញ្ជូននាថ្ងៃក្រោយមកទៀត ។

## មាត្រា ៩៣ : អំពីកិច្ចសហប្រតិបត្តិក្រោមទម្រង់ផ្សេងទៀត

១. ស្របតាមបទបញ្ញត្តិក្នុងភាគនេះ និងក្រោមនីតិវិធីនៃច្បាប់ប្រទេសនីមួយៗរបស់ខ្លួន រដ្ឋភាគីទាំងឡាយត្រូវអនុវត្តតាមសំណើពីតុលាការ ក្នុងការផ្តល់នូវការជួយជ្រោមជ្រែងដែលទាក់ទងនឹងការស៊ើបអង្កេតនិងការនាំយកមកជំនុំជំរះ ដូចខាងក្រោម :

(ក) ការធ្វើអត្តសញ្ញាណកម្ម និងប្រាប់ពីទីកន្លែងនៃជននោះ ឬ ពីទីតាំងនៃវត្ថុនោះ

(ខ) ការប្រមូលភស្តុតាង រួមទាំងសក្ខីកម្មដែលឆ្លើយក្រោមពាក្យសម្បថ និងការផលិតភស្តុតាង រួមទាំងយោបល់អ្នកឯកទេស និងរបាយការណ៍ផ្សេងៗដែលមានសារៈសំខាន់ចាំបាច់សំរាប់តុលាការ

(គ) ការសួរចំលើយជនទាំងឡាយណាដែលកំពុងត្រូវបានស៊ើបអង្កេត ឬ កំពុងត្រូវបាននាំខ្លួនយកមកជំនុំជំរះ

(ឃ) ការបំរើផ្ញើកឯកសារ រួមទាំងឯកសារតុលាការ

(ង) ការជួយសម្រួលដល់អ្នកទាំងឡាយណាដែលមកបង្ហាញខ្លួនដោយស្ម័គ្រចិត្ត ធ្វើជាសាក្សី ឬ ជាអ្នកឯកទេស នៅចំពោះមុខតុលាការ

(ច) ការបញ្ជូនជាបណ្តោះអាសន្ននៃជនជាប់ឃុំ ដូចមានចែងក្នុងកថាខ័ណ្ឌទី៧

(ឆ) ការត្រួតពិនិត្យដល់ទីកន្លែងឬទីលាន រួមទាំងការគាស់លើកសពពីក្នុងដីនិងការត្រួតពិនិត្យទីលានផ្នូរ

(ជ) ការប្រតិបត្តិនៃការឆែកឆេរ ឬរឹបអូស

(ឈ) ការផ្តល់នូវកំណត់ហេតុ ឬ ឯកសារផ្សេងៗ រួមទាំងកំណត់ហេតុនិងឯកសារផ្លូវការ

(ញ) ការការពារជនរងគ្រោះនិងសាក្សី និងការរក្សាទុកនូវភស្តុតាង

(ដ) ការធ្វើអត្តសញ្ញាណកម្ម តាមដាន បញ្ឈប់ ឬរឹបអូសផលដែលបានមកពីការលក់ទ្រព្យ ទ្រព្យសម្បត្តិ ទ្រព្យធន និងឧបករណ៍ប្រើសំរាប់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ សំរាប់គោលបំណងនៃការរឹបអូសជាយថាហេតុ ដោយមិនមានអគតិធមិចំពោះសិទ្ធិនៃតតិយជនសុច្ចរិតឡើយ ។ និង

(ឋ) ការជួយជ្រោមជ្រែងផ្សេងៗទៀត ដែលច្បាប់នៃរដ្ឋទទួលសំណើមិនបានហាមឃាត់ ក្នុងគោលបំណងដើម្បីជួយសម្រួលការស៊ើបអង្កេតនិងការនាំយកបទល្មើសព្រហ្មទណ្ឌមកជំនុំជំរះ ក្នុងក្របខ័ណ្ឌយុត្តាធិការនៃតុលាការ ។

២. តុលាការ មានអំណាចផ្តល់ការធានាចំពោះសាក្សី ឬៈអ្នកឯកទេសដែលមកបង្ហាញខ្លួនក្នុងតុលាការថា ខ្លួនគេមិនត្រូវបានតុលាការជំនុំជំរះ ឃុំខ្លួន ឬ ត្រូវដកហូតសិទ្ធិសេរីភាពផ្ទាល់ខ្លួន ដោយសារអំពើ ឬ ការខកខានណាមួយ ដែលកើតឡើងមុនពេលដែលជននោះបានចេញដំណើរពីរដ្ឋទទួលសំណើ ។

៣. នៅពេលដែលការប្រតិបត្តិវិធានការជួយជ្រោមជ្រែងពិសេសណាមួយ ដែលបានចែងយ៉ាងពិស្តារនៅក្នុងសំណើសុំដែលបានលើកឡើងក្រោមបទប្បញ្ញត្តិ កថាខ័ណ្ឌទី១ ត្រូវបានគេហាមឃាត់នៅក្នុងរដ្ឋទទួលសំណើ ដោយផ្អែកលើគោលការណ៍ច្បាប់ទូទៅជាមូលដ្ឋានគ្រឹះដែលមានស្រាប់ នោះរដ្ឋទទួលសំណើត្រូវតែពិគ្រោះយោបល់ជាបន្ទាន់ជាមួយតុលាការ ដើម្បីព្យាយាមដោះស្រាយបញ្ហានោះ។ ក្នុងការពិគ្រោះយោបល់នោះ ការពិចារណាគួរតែផ្តោតទៅលើថាតើការជួយជ្រោមជ្រែងនោះ អាចធ្វើទៅបានក្រោមរូបភាពដទៃទៀត ឬ ដោយមានលក្ខខ័ណ្ឌ។ បើសិនក្រោយការពិគ្រោះយោបល់បញ្ហានោះមិនអាចដោះស្រាយបានទេ តុលាការត្រូវធ្វើការកែប្រែសំណើតាមភាពចាំបាច់ ។

៤. ស្របតាមមាត្រា៧២ រដ្ឋភាគីអាចបដិសេធសំណើសុំជួយជ្រោមជ្រែង មួយផ្នែក ឬទាំងស្រុងបានចំពោះសំណើដែលទាក់ទងនឹងការផលិតឯកសារ ឬ ការលើកបង្ហាញភស្តុតាងដែលទាក់ទងនឹងសន្តិសុខជាតិរបស់ខ្លួនតែប៉ុណ្ណោះ ។

៥. មុនពេលបដិសេធសំណើជួយជ្រោមជ្រែងក្រោមបទប្បញ្ញត្តិកថាខ័ណ្ឌទី១(ឋ) រដ្ឋទទួលសំណើត្រូវពិចារណាថាតើការជួយជ្រោមជ្រែងនោះ អាចផ្តល់ឱ្យបានក្រោមលក្ខខ័ណ្ឌពិសេសណាមួយ ឬ ថាតើការជួយជ្រោមជ្រែងនោះអាចផ្តល់ឱ្យបាន នៅថ្ងៃក្រោយ ឬតាមរូបភាពដទៃ ឬទេ លើកលែងតែតុលាការ ឬព្រះរាជអាជ្ញាយល់ព្រមទទួលយកការជួយជ្រោមជ្រែងដែលជាប់លក្ខខ័ណ្ឌនោះ តុលាការឬព្រះរាជអាជ្ញាត្រូវតែគោរពតាមលក្ខខ័ណ្ឌអស់ទាំងនោះ ។

៦. ប្រសិនបើសំណើនោះត្រូវបានបដិសេធ រដ្ឋទទួលសំណើត្រូវតែជូនដំណឹងជាបន្ទាន់មកតុលាការ ឬ ព្រះរាជអាជ្ញាអំពីមូលហេតុនៃការបដិសេធនេះ ។

៧. (ក) តុលាការអាចស្នើសុំឱ្យបញ្ជូនជាបណ្តោះអាសន្ននូវជនជាប់ឃុំ ក្នុងគោលបំណងដើម្បីធ្វើការកំណត់អត្តសញ្ញាណកម្ម ឬ ដើម្បីទទួលសក្ខីកម្ម ឬការជួយជ្រោមជ្រែងផ្សេងៗទៀត។ ជននោះអាចត្រូវបញ្ជូនខ្លួនជាបណ្តោះអាសន្ន បើសិនជាលក្ខខ័ណ្ឌខាងក្រោម ត្រូវបានបំពេញ :

(i) ជននោះបានយល់ព្រមដោយស្ម័គ្រចិត្តលើការបញ្ជូនខ្លួនជាបណ្តោះអាសន្ននេះ តាមរយៈការជូនដំណឹង

(ii) រដ្ឋទទួលសំណើយល់ព្រមធ្វើការបញ្ជូន ក្រោមលក្ខខ័ណ្ឌដូចដែលរដ្ឋនោះនិងតុលាការ អាចយល់ព្រម ។

(ខ) ជនដែលត្រូវបញ្ជូនខ្លួនជាបណ្តោះអាសន្ននោះ ត្រូវនៅជាប់ឃុំដដែល ។ នៅពេលគោលបំណងនៃការបញ្ជូនខ្លួនជាបណ្តោះអាសន្ន ត្រូវបានបំពេញអស់ហើយ តុលាការត្រូវតែបញ្ជូនជននោះត្រលប់ទៅរដ្ឋទទួលសំណើវិញដោយគ្មានការបង្អង់ឡើយ ។

៨ (ក) តុលាការត្រូវតែធានាអំពីអាថិកំបាំងនៃឯកសារនិងពត៌មានទាំងឡាយ លើកលែងតែមានការតម្រូវសំរាប់ការស៊ើបអង្កេត និង សំរាប់ដំណើរការជំរះរឿងក្តីដូចដែលបានរៀបរាប់នៅក្នុងសំណើ ។

(ខ) នៅពេលចាំបាច់ រដ្ឋទទួលសំណើអាចបញ្ជូនឯកសារនិងពត៌មានទាំងឡាយទៅព្រះរាជអាជ្ញា ដោយឈរលើគោលការណ៍រក្សាអាថិកំបាំង។ ពេលនោះព្រះរាជអាជ្ញាអាចប្រើប្រាស់ឯកសារនិងពត៌មានទាំងនេះ ក្នុងគោលបំណងដើម្បីរកបានភស្តុតាងថ្មីតែប៉ុណ្ណោះ ។

(គ) តាមពាក្យសុំរបស់រដ្ឋទទួលសំណើខ្លួនឯង ឬ តាមសំណើរបស់ព្រះរាជអាជ្ញា រដ្ឋទទួលសំណើអាចយល់ព្រមលើកបង្ហាញនូវឯកសារឬពត៌មានទាំងនោះបាននៅពេលក្រោយ។ ពេលនោះឯកសារនិងពត៌មានអស់ទាំងនេះ អាចត្រូវបានប្រើប្រាស់ជាភស្តុតាង ដោយអនុលោមតាមបទប្បញ្ញត្តិនៃភាគទី៥និងទី៦ និង ស្របតាមវិធាននៃនីតិវិធីនិងភស្តុតាង ។

៩. (ក) (i) ប្រសិនជារដ្ឋភាគីមួយបានទទួលសំណើប្រជែង ក្រៅអំពីសំណើសុំបញ្ជូនខ្លួនឬសំណើសុំការធ្វើបត្យាប័ន ពីតុលាការឬពីរដ្ឋដទៃ ស្របតាមកាតព្វកិច្ចអន្តរជាតិ រដ្ឋភាគីនេះត្រូវតែខ្នះខ្នែងឆ្លើយតបសំណើទាំងពីរ ដោយពិគ្រោះយោបល់ជាមួយតុលាការនិងរដ្ឋដទៃនោះ ប្រសិនចាំបាច់ដោយពន្យាពេល ឬភ្ជាប់លក្ខខ័ណ្ឌលើសំណើមួយឬមួយផ្សេងទៀត ។

(ii) បើសិនជាមិនបានធ្វើដូចនេះ សំណើប្រជែងទាំងឡាយ នឹងត្រូវដោះស្រាយយោងតាមគោលការណ៍ដែលមានចែងក្នុងមាត្រា៩០ ។

(ខ) នៅពេលដែលសំណើពីតុលាការទាក់ទងនឹង ពត៌មាន ទ្រព្យសម្បត្តិ ឬ ជនដែលឋិតនៅក្រោមការគ្រប់គ្រងនៃតតីយរដ្ឋឬអង្គការអន្តរជាតិ តាមរយៈកិច្ចព្រមព្រៀងអន្តរជាតិ រដ្ឋទទួលសំណើត្រូវជូនដំណឹងនេះទៅតុលាការ ហើយ តុលាការត្រូវដាក់សំណើរបស់ខ្លួនទៅតតីយរដ្ឋឬអង្គការអន្តរជាតិនោះ ។

១០. (ក) តាមការស្នើសុំ តុលាការអាចសហការជាមួយ និង ផ្តល់ការជួយជ្រោមជ្រែងដល់រដ្ឋភាគីក្នុងការធ្វើការស៊ើបអង្កេត ឬ ចាត់ចែងការជំនុំជំរះការប្រព្រឹត្តដែលបង្កើតជាបទល្មើសព្រហ្មទណ្ឌឋិតនៅក្រោមយុត្តាធិការនៃតុលាការ ឬ ដែលជាបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរឋិតនៅក្រោមច្បាប់របស់រដ្ឋធ្វើសំណើ ។

(ខ) (i) ការជួយជ្រោមជ្រែងដែលមានចែងក្នុងកថាខ័ណ្ឌ (ក) នឹងរួមមាន ដូចជា :

(1) ការបញ្ជូននូវសេចក្តីថ្លែងការណ៍ ឯកសារ ឬភស្តុតាងប្រភេទផ្សេងទៀតដែលបានទទួលនៅពេលស៊ើបអង្កេត ឬ នៅពេលជំនុំជំរះដែលធ្វើឡើងដោយតុលាការ, និង

(2) ការសួរចំលើយជនណាម្នាក់ដែលជាប់ឃុំដោយដីកាតុលាការ ។

(ii) នៅក្នុងករណីជួយជ្រោមជ្រែងក្រោមបទប្បញ្ញត្តិអនុកថាខ័ណ្ឌ (ខ)(i)(1) :

(1) បើសិនឯកសារឬភស្តុតាងប្រភេទផ្សេងទៀត ត្រូវបានទទួលដោយសារមានការជួយជ្រោមជ្រែងពីរដ្ឋមួយ ការបញ្ជូនឯកសារ ឬ ភស្តុតាងនោះ ត្រូវតែមានការយល់ព្រមពីរដ្ឋនោះ ។

(2) ប្រសិនបើសេចក្តីថ្លែងការណ៍ ឯកសារ ឬភស្តុតាងប្រភេទផ្សេងទៀត ត្រូវបានផ្តល់ឱ្យដោយ សាក្សី ឬអ្នកជំនាញ ការបញ្ជូនសេចក្តីថ្លែងការណ៍ ឯកសារ ឬភស្តុតាងប្រភេទផ្សេងទៀតនេះ ត្រូវធ្វើឡើងតាមបទប្បញ្ញត្តិនៃមាត្រា៦៨ ។

(គ) ក្រោមលក្ខខ័ណ្ឌដែលមានចែងក្នុងកថាខ័ណ្ឌនេះ តុលាការអាចយល់ព្រមទទួលសំណើសុំជួយជ្រោមជ្រែង ក្រោមកថាខ័ណ្ឌនេះ ពីរដ្ឋមួយដែលមិនមែនជារដ្ឋភាគីនៃច្បាប់លក្ខន្តិកៈនេះ ។

## មាត្រា ៩៤ : អំពីការពន្យាពេលអនុវត្តនូសំណើទាក់ទងលើដំណើរការស៊ើបអង្កេត ឬ ការនាំយកមកជំនុំជំរះ ដែលកំពុងតែប្រព្រឹត្តទៅ

១. បើសិនការអនុវត្តន៍សំណើបន្ទាន់មួយ អាចបង្អាក់ដល់ដំណើរការស៊ើបអង្កេតឬការនាំយកមកជំនុំជំរះ ដែលកំពុងតែប្រព្រឹត្តទៅលើរឿងក្តីមួយផ្សេងអំពីរឿងក្តីនៅក្នុងសំណើបន្ទាន់ នោះរដ្ឋទទួលសំណើអាច ពន្យាពេលអនុវត្តសំណើបន្ទាន់នោះ មួយរយៈតាមការយល់ព្រមពីតុលាការ ។ ទោះបីជាយ៉ាងណាក្តី រយៈពេលពន្យាមិនត្រូវលើសរយៈពេលដែលចាំបាច់ដើម្បីបំពេញនូវការស៊ើបអង្កេត ឬ ការនាំយកជំនុំជំរះដែលពាក់ព័ន្ធនៅក្នុងរដ្ឋទទួលសំណើឡើយ ។ មុនពេលធ្វើការសំរេចពន្យាពេល រដ្ឋទទួលសំណើត្រូវតែពិចារណាថាតើ ការជួយជ្រោមជ្រែង អាចត្រូវផ្តល់ជូនភ្លាម១ ក្រោមលក្ខខ័ណ្ឌមួយចំនួន ឬអត់ ។

២. ប្រសិនបើការសំរេចពន្យាពេលត្រូវបានធ្វើឡើងស្របតាមកថាខ័ណ្ឌទី១ ព្រះរាជអាជ្ញានៅតែអាចស្វែងរកវិធានការដើម្បីរក្សាភស្តុតាង ស្របតាម កថាខ័ណ្ឌទី១(ញ) នៃមាត្រា៩៣ ។

## មាត្រា ៩៥ : អំពីការពន្យាពេលអនុវត្តន៍សំណើ ដោយសារមានការប្រជែងតវ៉ាលើភាពអាចទទួលយកបាន

ដោយមិនមានអគតិជមិចំពោះ កថាខ័ណ្ឌទី២នៃមាត្រា៥៣ នៅពេលមានការប្រជែងតវ៉ាលើភាពអាចទទួលយកបានដែលតុលាការកំពុងតែពិចារណា ស្របតាមមាត្រា១៨ឬ១៩ រដ្ឋទទួលសំណើអាចពន្យាពេលអនុវត្តសំណើ ក្រោមភាគនេះ ដើម្បីរងចាំតុលាការសំរេចបាន បើសិនជាតុលាការមិនទាន់បានបញ្ជាដោយជាក់លាក់ថា ព្រះរាជអាជ្ញាអាចបន្តការប្រមូលភស្តុតាងនោះ អនុលោមទៅតាមមាត្រា១៨និង១៩ ។

## មាត្រា ៩៦:

## អំពីមាតិកានៃសំណើសុំជំនួយជ្រោមជ្រែងដែលមានទ្រង់ទ្រាយផ្សេងទៀត ក្រោមមាត្រា៩៣

១. សំណើសុំជំនួយជ្រោមជ្រែងដែលមានទ្រង់ទ្រាយផ្សេងទៀត ដែលបានលើកឡើងក្នុងមាត្រា៩៣ នឹងត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ ។ នៅក្នុងករណីបន្ទាន់ សំណើអាចធ្វើឡើងតាមមធ្យោបាយណាមួយដែល

អាចបញ្ជូនឯកសារជាលាយល័ក្ខអក្សរបាន តាមលក្ខខ័ណ្ឌថាសំណើនោះត្រូវបានបញ្ជាក់តាមរយ
បណ្ដាញដែលមានចែងក្នុង កថាខ័ណ្ឌ១(ក) នៃមាត្រា៨៧។

២. តាមដែលអាចអនុវត្តបាន សំណើនោះត្រូវមាន ឬគាំទ្រដោយ :

(ក) សេចក្ដីថ្លែងការណ៍សង្ខេបអំពីគោលបំណងនៃសំណើ និងអំពីជំនួយជ្រោមជ្រែងដែលត្រូវបានស្វែ
រក រួមទាំងមូលដ្ឋានច្បាប់ និងហេតុផលនៃសំណើ ។

(ខ) ពត៌មានលំអិតដូចដែលអាចធ្វើទៅបាន អំពីទីកន្លែងឬអត្តសញ្ញាណនៃជនណាម្នាក់ ឬកន្លែងណ
មួយដែលត្រូវតែរក ឬ ត្រូវតែកំណត់អត្តសញ្ញាណ ដើម្បីទទួលបានជំនួយដែលត្រូវស្វែងរកនោះ ។

(គ) សេចក្ដីថ្លែងការណ៍សង្ខេបអំពីអង្គហេតុសំខាន់ៗ ដែលជាមូលដ្ឋាននៃសំណើ ។

(ឃ) ហេតុផលនិងពត៌មានលំអិតស្ដីអំពីនីតិវិធី ឬ លក្ខខ័ណ្ឌតម្រូវដែលត្រូវអនុវត្តតាម ។

(ង) ពត៌មានទាំងឡាយដែលអាចតម្រូវដោយច្បាប់នៃរដ្ឋទទួលសំណើ ដើម្បីអនុវត្តសំណើ។ និង

(ច) ពត៌មានផ្សេងទៀត ដែលពាក់ព័ន្ធ ដើម្បីទទួលបានជំនួយដែលត្រូវស្វែងរកនោះ ។

៣. ដោយមានសំណើពីតុលាការ រដ្ឋភាគីត្រូវតែពិគ្រោះយោបល់ជាមួយតុលាការ ទោះបីជាលើបញ្ហាទូទៅ
បញ្ហាពិសេសទាក់ទងនឹងលក្ខខ័ណ្ឌតម្រូវណាមួយក្រោមច្បាប់ជាតិរបស់ខ្លួន ដែលអាចអនុវត្តលើក
ខ័ណ្ឌទី២(ង)។ ក្នុងកំឡុងពេលពិភាក្សា រដ្ឋដែលជាភាគីនោះ ត្រូវតែផ្ដល់យោបល់ដល់តុលាការអំពីល
ខ័ណ្ឌតម្រូវពិសេសដោយច្បាប់ជាតិរបស់ខ្លួន ។

៤. បើសិនជាអាចអនុវត្តទៅបាន រាល់បទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះ ត្រូវតែអនុវត្តផងដែរទៅ
សំណើសុំជំនួយដែលស្នើដល់តុលាការ ។

## មាត្រា ៩៧ : អំពីការពិគ្រោះយោបល់

ទៅពេលរដ្ឋភាគីមួយទទួលសំណើ នៅក្រោមបទប្បញ្ញត្តិនៃភាគនេះ ដែលទាក់ទងនឹងការធ្វើកំណ
សំគាល់លើបញ្ហាទាំងឡាយដែលអាចបង្អាក់ ឬ បង្ការដល់ការអនុវត្តន៍នូវសំណើនោះ រដ្ឋនោះត្រូវតែពិគ្រ
យោបល់ជាមួយតុលាការដោយគ្មានការបង្អង់ ដើម្បីដោះស្រាយបញ្ហានោះ។ បញ្ហាទាំងនោះ រួមមានដូចជា

(ក) ពត៌មានមិនគ្រប់គ្រាន់ដើម្បីអនុវត្តសំណើ

(ខ) នៅក្នុងករណីនៃសំណើសុំបញ្ជូនខ្លួន ទោះបីជាមានការខិតខំប្រឹងប្រែងជាក់ស្តែងក៏ដោយជនដែលត្រូវស្វែងរកនោះ ក៏នៅតែមិនអាចរកឃើញនៅឡើយ ឬ ការស៊ើបអង្កេតដែលធ្វើឡើងនោះបានកំណត់ថាជនដែលនៅក្នុងរដ្ឋឃុំខ្លួននោះ គឺប្រាកដជាមិនមែនជនដែលមានឈ្មោះនៅក្នុងដីកាឡើយ។

(គ) ការអនុវត្តន៍នូវសំណើតាមទំរង់ជាក់ស្តែងរបស់វា គួរ. ចតម្រូវឱ្យរដ្ឋទទួលសំណើនោះបំពានកាតព្វកិច្ចក្នុងសន្ធិសញ្ញាដែលមានស្រាប់ ដែលបានធ្វើជាមួយរដ្ឋ. រផ្សេងទៀត។

## មាត្រា ៩៨ : អំពីកិច្ចសហប្រតិបត្តិការទាក់ទងនឹងការបោះ ង់អភ័យឯកសិទ្ធិ និង ការយល់ព្រមបញ្ជូនខ្លួន

១. តុលាការមិនអាចបន្តធ្វើសំណើសុំបញ្ជូនខ្លួន ឬ សំណើសុំជំនួយជ្រោមជ្រែង រ. រគួរអាចតម្រូវឱ្យរដ្ឋទទួលសំណើអនុវត្តផ្ទុយពី កាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិដែលពាក់ព័ន្ធនឹង. យឯកសិទ្ធិរដ្ឋ ឬ អភ័យឯកសិទ្ធិការទូតនៃជន ឬ នៃទ្រព្យសម្បត្តិរបស់តតីយរដ្ឋមួយ លុះត្រាណាតែតុលាការបានទទួលជាមុននូវកិច្ចសហប្រតិបត្តិការពីតតីយរដ្ឋនោះលើការបោះបង់អភ័យឯកសិទ្ធិរបស់ខ្លួន។

២. តុលាការមិនអាចបន្តធ្វើសំណើសុំបញ្ជូនខ្លួន ដែលគួរអាចតម្រូវឱ្យរដ្ឋទទួលសំណើអនុវត្តផ្ទុយពីកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងអន្តរជាតិ អនុលោមតាមកិច្ចព្រមព្រៀងនេះ ការយល់ព្រមពីរដ្ឋបញ្ជូនត្រូវតម្រូវឱ្យបញ្ជូនខ្លួនមនុស្សណាម្នាក់របស់រដ្ឋនោះទៅតុលាការ លុះត្រាណាតែតុលាការ អាចទទួលជាមុននូវកិច្ចសហប្រតិបត្តិការពីរដ្ឋបញ្ជូន លើការព្រមព្រៀងបញ្ជូនខ្លួន។

## មាត្រា ៩៩ : អំពីការអនុវត្តន៍សំណើ ក្រោមបទប្បញ្ញត្តិមាត្រា ៩៣ និង ៩៦

១. សំណើសុំជំនួយជ្រោមជ្រែង ត្រូវអនុវត្តឡើងស្របតាមនីតិវិធីពាក់ព័ន្ធ ក្រោមបទប្បញ្ញត្តិច្បាប់របស់រដ្ឋទទួលសំណើ ហើយបើសិន ជាមិនមានការហាមប្រាមដោយច្បាប់រដ្ឋនេះទេ នោះសំណើសុំជំនួយជ្រោមជ្រែងត្រូវអនុវត្តឡើងស្របតាមបទប្បញ្ញត្តិដែល មានចែងក្នុងសំណើនោះ ស្របតាមនីតិវិធីណាមួយដែល

បានបញ្ជាក់ក្នុងសំណើ ឬ អនុញ្ញាតឱ្យជនទាំងឡាយដែលមានឈ្មោះបញ្ជាក់នៅក្នុងសំណើនោះ ឱ្យមានវត្តមាន និង ជួយជ្រោមជ្រែង ក្នុងដំណើរការអនុវត្តសំណើ ។

២. ក្នុងករណីសំណើមួយជាសំណើបន្ទាន់ ឯកសារនិងភស្តុតាងដែលបានបង្កើតឡើងដើម្បីឆ្លើយតបនឹងសំណើនឹងត្រូវផ្ញើរជាបន្ទាន់ តាមការស្នើសុំពីតុលាការ ។

៣. ចំលើយឆ្លើយតបពីរដ្ឋទទួលសំណើនឹងត្រូវបញ្ជូនជាភាសាដើមនិងទ្រង់ទ្រាយដើមរបស់រដ្ឋទទួលសំណើ ។

៤. ដោយមិនមានអគតិចមិដល់មាត្រាដទៃក្នុងភាគនេះ នៅពេលចាំបាច់ក្នុងការអនុវត្តប្រកបដោយជោគជ័យនូវសំណើមួយ ដែលអាចអនុវត្តដោយគ្មានវិធានការចាប់បង្ខំ រួមទាំង ជាពិសេស ការសំភាសន៍ ឬការយកភស្តុតាងពីជនណាម្នាក់ ដោយផ្អែកលើមូលដ្ឋានស្ម័គ្រចិត្ត រួមទាំងការធ្វើបែបនេះដោយគ្មានវត្តមាននៃអាជ្ញាធររបស់រដ្ឋទទួលសំណើ បើសិនជាវាមានសារៈសំខាន់ ដើម្បីឱ្យសំណើនោះអាចអនុវត្តទៅបាន ហើយការត្រួតពិនិត្យមិនបានផ្លាស់ប្តូរទីតាំងសាធារណៈឬទីកន្លែងសាធារណៈដទៃទៀតនោះព្រះរាជអាជ្ញាអាចអនុវត្តសំណើនេះដោយផ្ទាល់នៅលើទឹកដីនៃរដ្ឋមួយ ដូចខាងក្រោម :

(ក) នៅពេលរដ្ឋភាគីទទួលសំណើ គឺជារដ្ឋមួយ ដែលបទល្មើសព្រហ្មទណ្ឌត្រូវបានគេចោទប្រកាន់ថាបានកើតឡើងនៅលើទឹកដីរបស់ខ្លួន ហើយមានការសំរេចអំពីភាពអាចទទួលបាន ស្របតាមមាត្រា ១៨ ឬ ១៩ នោះព្រះរាជអាជ្ញា អាចអនុវត្តសំណើនេះដោយផ្ទាល់ បន្ទាប់ពីបានពិគ្រោះយោបល់ទាំងអស់ដែលអាចធ្វើទៅបានជាមួយរដ្ឋភាគីទទួលសំណើ ។

(ខ) នៅក្នុងករណីផ្សេងពីនេះ ព្រះរាជអាជ្ញាអាចអនុវត្តសំណើនេះ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយរដ្ឋភាគីទទួលសំណើ ហើយដោយគោរពតាមលក្ខខ័ណ្ឌនិងការព្រួយបារម្ភសមហេតុផលដែលលើកឡើងដោយរដ្ឋភាគីនោះ ។ នៅពេលរដ្ឋភាគីទទួលសំណើ បានធ្វើការកត់សំគាល់ឃើញនូវបញ្ហាក្នុងការអនុវត្តសំណើមួយ ស្របតាមអនុកថាខ័ណ្ឌនេះ រដ្ឋនោះត្រូវតែពិគ្រោះយោបល់ជាមួយតុលាការដោយមិនបង្អង់ ដើម្បីដោះស្រាយបញ្ហាខាងលើ ។

៥. រាល់បទប្បញ្ញត្តិដែលអនុញ្ញាតឱ្យជនណាម្នាក់ដែលត្រូវតុលាការសួរចំលើយឬពិនិត្យ ក្រោមបទប្បញ្ញត្តិមាត្រា៧២ ដើម្បីលើកអំពីលក្ខខ័ណ្ឌដើម្បីបង្ការការលើកបង្ហាញពត៌មានអាថិកំបាំងដែលទាក់ទងនឹងកិច្ចការពារ ឬសន្តិសុខជាតិ នឹងត្រូវអនុវត្តសំណើសុំជំនួយជ្រោមជ្រែង ក្រោមបទប្បញ្ញត្តិមាត្រានេះផងដែរ ។

## មាត្រា ១០០ : អំពីសោហ៊ុយចំណាយ

១. សោហ៊ុយចំណាយធម្មតាសំរាប់ការអនុវត្តសំណើនៅក្នុងទឹកដីនៃរដ្ឋទទួលសំណើ ត្រូវជាបន្ទុករបស់រដ្ឋនោះ លើកលែងតែសោហ៊ុយចំណាយ ដែលជាបន្ទុករបស់តុលាការ ដូចមានចែងខាងក្រោម :

(ក) សោហ៊ុយចំណាយ លើការធ្វើដំណើរ និង លើសន្តិសុខសំរាប់សាក្សីនិងអ្នកជាប់ចោទ ឬ លើការបញ្ជូនជនជាប់ឃុំក្រោមបទប្បញ្ញត្តិមាត្រា៩៣ ។

(ខ) សោហ៊ុយចំណាយលើការបកប្រែឯកសារ ការបកប្រែផ្ទាល់មាត់ និងការកត់ត្រាជាលាយល័ក្ខអក្សរ ។

(គ) សោហ៊ុយចំណាយ សំរាប់ការធ្វើដំណើរនិងការចិញ្ចឹមជីវិតនៃចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី ក្រឡាបញ្ជីរង និងបុគ្គលិកនៃអង្គតុលាការណាមួយ ។

(ឃ) សោហ៊ុយចំណាយទៅលើយោបល់អ្នកជាប់ចោទ ឬ លើរបាយការណ៍ដែលស្នើឡើងដោយតុលាការ ។

(ង) សោហ៊ុយចំណាយ លើការដឹកជញ្ជូនជនដែលត្រូវបញ្ជូនខ្លួនទៅតុលាការ ដោយរដ្ឋឃុំខ្លួនជននោះ ។

(ច) បន្ទាប់ពីមានការពិគ្រោះយោបល់ រាល់សោហ៊ុយចំណាយមិនប្រក្រតី ដែលអាចបណ្តាលមកពីការអនុវត្តសំណើ ។

២. តាមការសមស្រប បទប្បញ្ញត្តិនៃកថាខ័ណ្ឌទី១ នឹងត្រូវអនុវត្តលើសំណើចេញអំពីរដ្ឋភាគីទៅតុលាការ ។ នៅក្នុងករណីនេះ តុលាការត្រូវទទួលបន្ទុកលើសោហ៊ុយចំណាយធម្មតាសំរាប់ការអនុវត្តសំណើ ។

## មាត្រា ១០១ : អំពីវិធានពិសេស

១. ជនដែលត្រូវបញ្ជូនខ្លួនមកតុលាការ ក្រោមបទប្បញ្ញត្តិច្បាប់លក្ខន្តិកៈនេះ នឹងមិនត្រូវបានគេប្តឹងប្រឆាំង ដាក់ទណ្ឌកម្ម ឬ ត្រូវបានឃុំខ្លួន ដោយសារអំពើណាមួយដែលបានប្រព្រឹត្តមុនការបញ្ជូនខ្លួន លើកលែងតែ

អំពើឬលំនាំនៃអំពើដែលបង្កើតជាមូលដ្ឋាននៃអំពើបទល្មើសព្រហ្មទណ្ឌ ដែលជាមូលហេតុនាំអោយមានការបញ្ជូនខ្លួនជននោះ ។

២. តុលាការអាចស្នើសុំឱ្យបោះបង់នូវលក្ខខ័ណ្ឌតម្រូវផ្សេងៗនៅក្នុងកថាខ័ណ្ឌទី១ ពីរដ្ឋដែលបញ្ជូនខ្លួនជននោះទៅតុលាការ ហើយបើសិនជាមានការចាំបាច់ តុលាការត្រូវផ្តល់ពត៌មានបន្ថែមស្របតាមមាត្រាទី៩១។ រដ្ឋភាគីទាំងឡាយ នឹងមានអំណាចក្នុងការផ្តល់ឱ្យតុលាការនូវការបោះបង់លក្ខខ័ណ្ឌតម្រូវនេះ ហើយខ្លួនគួរតែខ្នះខ្នែងធ្វើបែបនេះ។

## មាត្រា ១០២ : អំពីការប្រើប្រាស់ពាក្យ

សំរាប់គោលបំណងនៃច្បាប់លក្ខន្តិកៈនេះ :

(ក) ពាក្យ "ប្រគល់ខ្លួន" មានន័យថា នាំយកជនណាម្នាក់មកឱ្យតុលាការដោយរដ្ឋណាមួយ អនុលោមតាមច្បាប់លក្ខន្តិកៈនេះ ។

(ខ) ពាក្យ "ការធ្វើបត្យាប័ន" មានន័យថា នាំយកជនណាម្នាក់មកឱ្យរដ្ឋមួយផ្សេងទៀត ដោយរដ្ឋណាមួយ ដូចមានចែងដោយសន្ធិសញ្ញា អនុសញ្ញា ឬ ដោយច្បាប់ជាតិ ។

# ភាគទី ១០ : ការអនុវត្តន៍

## មាត្រា ១០៣ : អំពីតួនាទីរបស់រដ្ឋក្នុងការអនុវត្តន៍ការដាក់ទោសពន្ធនាគារ

១. (ក) ការដាក់ទោសពន្ធនាគារ នឹងត្រូវធ្វើឡើងនៅក្នុងរដ្ឋមួយដែលចាត់តាំងដោយតុលាការចេញពីបញ្ជីនៃរដ្ឋទាំងឡាយដែលបានបង្ហាញប្រាប់ដល់តុលាការអំពីឆន្ទៈរបស់ខ្លួន ក្នុងការទទួលពិរុទ្ធជន ។

(ខ) នៅពេលប្រកាសអំពីឆន្ទៈរបស់ខ្លួនក្នុងការទទួលពិរុទ្ធជន រដ្ឋមួយអាចដាក់លក្ខខ័ណ្ឌលើការទទួលយករបស់ខ្លួន ដូចដែលបានយល់ព្រមដោយតុលាការ និងអនុលោមតាមភាគនេះ ។

(គ) រដ្ឋដែលត្រូវបានចាត់តាំងនៅក្នុងករណីពិសេស ត្រូវតែជូនដំណឹងមកតុលាការជាបន្ទាន់ ថាតើខ្លួនទទួលយល់ព្រមតាមការចាត់តាំងរបស់តុលាការ ឬអត់។

២. (ក) រដ្ឋដែលដាក់ឱ្យអនុវត្ត ត្រូវតែជូនដំណឹងមកតុលាការអំពីកាលៈទេសៈពិសេសណាមួយ រួមទាំងការអនុវត្តនីនូវលក្ខខ័ណ្ឌណាមួយ ដែលបានយល់ព្រមក្រោមកថាខ័ណ្ឌទី១ ដែលអាចប៉ះពាល់យ៉ាងជាក់ស្តែងលើលក្ខខ័ណ្ឌ និង កំរិតនៃការដាក់ទោស។ តុលាការ ត្រូវមានរយៈពេលយ៉ាងហោចណាស់៤៥ថ្ងៃ ដើម្បីទទួលការជូនដំណឹងអំពីកាលៈទេសៈបែបនេះ ដែលបានដឹងរួចមកហើយឬដែលបានគ្រោងទុកមុន។ ក្នុងរយៈពេលនេះ រដ្ឋដែលដាក់ឱ្យអនុវត្ត មិនត្រូវធ្វើសកម្មភាពទាំងឡាយណាដែលអាចមានអគតិធមិដល់កាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រា១១០ឡើយ ។

(ខ) នៅពេលដែលតុលាការមិនអាចឯកភាពលើកាលៈទេសៈដែលបានលើកឡើងក្នុងអនុកថាខ័ណ្ឌ(ក) នោះតុលាការត្រូវតែជូនដំណឹង រដ្ឋដែលដាក់ឱ្យអនុវត្តនោះ ហើយត្រូវបន្តអនុវត្តតាម កថាខ័ណ្ឌទី១ នៃមាត្រា១០៤។

៣. ក្នុងពេលអនុវត្តតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីចាត់តាំងរដ្ឋណាមួយ ក្រោមកថាខ័ណ្ឌទី១ តុលាការត្រូវតែធ្វើការពិចារណា លើកត្តាដូចជា :

(ក) គោលការណ៍ដែលថារដ្ឋភាគីទាំងអស់ គួរតែចូលរួមចំណែកទទួលខុសត្រូវលើការអនុវត្តនីការដាក់ទោសពន្ធនាគារ ដោយអនុលោមទៅតាមគោលការណ៍នៃការបែងចែកសមភាព ដូចដែលមានចែងក្នុងវិធាននៃនីតិវិធីនិងភស្តុតាង ។

(ខ) ការអនុវត្តនីតាមស្តង់ដារសន្ធិសញ្ញាអន្តរជាតិដែលត្រូវបានគេទទួលយកជាទូទៅ ស្តីអំពីការប្រព្រឹត្តលើពិរុទ្ធជន ។

(គ) ទស្សនៈរបស់ពិរុទ្ធជន

(ឃ) សញ្ជាតិរបស់ពិរុទ្ធជន

(ង) កត្តាផ្សេង១ទៀត ដែលទាក់ទងនឹងកាលៈទេសៈនៃអំពើល្មើសព្រហ្មទណ្ឌ ឬ នៃពិរុទ្ធជន ឬ ដែលទាក់ទងនឹងការអនុវត្តនី ប្រកបដោយប្រសិទ្ធភាពនៃការដាក់ទោស ដែលអាចសមស្របក្នុងការចាត់តាំងរដ្ឋដាក់ឱ្យអនុវត្តនោះ ។

៤. បើសិនជាមិនទាន់មានរដ្ឋណាមួយត្រូវបានចាត់តាំងឡើងក្រោមកថាខ័ណ្ឌទី១ ការដាក់ទោសពន្ធនាគារនឹងត្រូវធ្វើឡើងនៅក្នុងពន្ធនាគារដែលបានផ្តល់ឱ្យដោយរដ្ឋម្ចាស់ផ្ទះ ស្របតាមលក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងទីបញ្ជាការ ដែលបានលើកឡើងក្នុងកថាខ័ណ្ឌទី២នៃមាត្រា៣។ នៅក្នុងករណីនេះ សោហ៊ុយចំណាយក្នុងការអនុវត្តការដាក់ទោសពន្ធនាគារ ត្រូវជាបន្ទុករបស់តុលាការ ។

## មាត្រា១០៤ : អំពីការប្តូរការកំណត់ទីតាំងរដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រម

១- តុលាការអាចសំរេចឱ្យមានការផ្ទេរទណ្ឌិតទៅពន្ធនាគារនៃរដ្ឋមួយផ្សេងទៀតនៅពេលណាក៏បាន។

២- ទណ្ឌិតអាចស្នើសុំទៅតុលាការឱ្យផ្ទេរខ្លួនចេញពីរដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រមនោះនៅពេលណាក៏បាន។

## មាត្រា១០៥ : អំពីការដាក់ឱ្យអនុវត្តទោស

១- តាមលក្ខខ័ណ្ឌដែលរដ្ឋមួយអាចបានកំណត់ ដោយអនុលោមតាមកថាខ័ណ្ឌទី១(២)នៃមាត្រា១០៣ ទោសពន្ធនាគារ នឹងដាក់កាតព្វកិច្ចលើរដ្ឋភាគីទាំងអស់ ដោយគ្មានការកែប្រែ។

២- មានតែតុលាការមួយគត់ដែលមានសិទ្ធិសំរេចលើពាក្យបណ្តឹងឧទ្ធរណ៍ និង បណ្តឹងសើរើ។ រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រមមិនអាចជំទាស់រាំងបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសើរើដែលធ្វើឡើងដោយទណ្ឌិតនោះបានទេ។

## មាត្រា១០៦ :

## អំពីការត្រួតពិនិត្យការដាក់ឱ្យអនុវត្តទោសពន្ធនាគា និង លក្ខខ័ណ្ឌនៃការដាក់ពន្ធនាគារ

១- ការអនុវត្តទោសពន្ធនាគាត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ និង ស្របតាមបទដ្ឋានគំរូនៃសន្ធិសញ្ញាអន្តរជាតិដែលត្រូវបានគេទទួលយកយ៉ាងទូលំទូលាយក្នុងការគ្រប់គ្រងថែទាំអ្នកទោស។

២- លក្ខខ័ណ្ឌនៃការដាក់ពន្ធនាគារត្រូវគ្រប់គ្រងដោយច្បាប់របស់រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រមនោះ និង ស្របតាមបទដ្ឋានគំរូនៃសន្ធិសញ្ញាអន្តរជាតិ ដែលត្រូវបានគេទទួលយកយ៉ាងទូលំទូលាយក្នុងការគ្រប់គ្រងថែទាំអ្នកទោស ហើយគ្មានករណីណាដែលលក្ខខ័ណ្ឌទាំងនោះមានកំរិតធ្ងន់ជាង ឬ ស្រាលជាងកំរិត

ដែលកំណត់ចំពោះជនដែលត្រូវសំរេចថាមានពិរុទ្ធភាពលើបទល្មើសស្រដៀងគ្នានៅក្នុង រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រមនោះទេ។

៣- រាល់ការប្រាស្រ័យទាក់ទងរវាងទណ្ឌិត និងតុលាការមិនត្រូវបានរាំង និងត្រូវទុកជាការសំងាត់។

## មាត្រា១០៧ : អំពីការផ្ទេរជននោះនៅពេលបញ្ចប់ការដាក់ទោស

១- នៅពេលបញ្ចប់ការដាក់ទោស ជនដែលមិនមែនជាពលរដ្ឋរបស់រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រម ដោយយោងតាមច្បាប់របស់រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រម ជននោះអាចត្រូវបញ្ជូនទៅកាន់រដ្ឋដែលមានកាតព្វកិច្ចត្រូវទទួលខ្លួន ឬ ក៏រដ្ឋដទៃផ្សេងទៀតដែលយល់ព្រមទទួលខ្លួន ដោយពិចារណាលើការប្រាថ្នារបស់ជនដែលត្រូវផ្ទេរទៅកាន់រដ្ឋនោះ លើកលែងតែរដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រមនោះ អនុញ្ញាតឱ្យជននោះឋិតនៅលើទឹកដីរបស់ខ្លួន។

២- ប្រសិនបើ គ្មានរដ្ឋណាមួយទទួលបន្ទុកសោហ៊ុយចំណាយសំរាប់ការផ្ទេរជននោះទៅរដ្ឋផ្សេងទៀតទេ ដោយអនុលោមទៅតាមកថាខ័ណ្ឌទី១ សោហ៊ុយចំណាយនោះជាបន្ទុករបស់តុលាការ។

៣- តាមបទប្បញ្ញត្តិនៃមាត្រា១០៨ រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រម ដោយយោងតាមច្បាប់របស់ជាតិខ្លួន អាចធ្វើបត្យាប័ន ឬ អាចប្រគល់ជននោះទៅឱ្យរដ្ឋដែលស្នើសុំធ្វើបត្យាប័ន ឬ សុំឱ្យមានការប្រគល់ខ្លួនជននោះ ដើម្បីវិនិច្ឆ័យទោស ឬ ដាក់ឱ្យអនុវត្តទោស។

## មាត្រា១០៨ :

## អំពីការកំរិតដែនកំណត់ការនាំយកទៅជំនុំជំរះ ឬ ការដាក់ទោសចំពោះបទល្មើសផ្សេងៗ

១- ទណ្ឌិតដែលស្ថិតក្រោមការគ្រប់គ្រងថែទាំរបស់រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រមមិនត្រូវរងនូវការនាំខ្លួនយកទៅជំនុំជំរះ ឬ ការដាក់ទោស ឬ ការធ្វើបត្យាប័នឱ្យទៅរដ្ឋទីបីសំរាប់ការប្រព្រឹត្ត ដែលពាក់ព័ន្ធមុនពេលបញ្ជូនជននេះទៅកាន់រដ្ឋដែលត្រូវដាក់ឱ្យអនុវត្តសាលក្រមនោះទេ លើកលែងតែការនាំខ្លួនយកមកជំនុំជំរះ ការដាក់ទោស ឬការធ្វើបត្យាប័ននេះ ត្រូវបានយល់ព្រមដោយតុលាការតាមការស្នើសុំរបស់រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រមនោះ។

២- តុលាការត្រូវសំរេចរឿងនេះ បន្ទាប់ពីបានស្តាប់ទស្សនៈរបស់ទណ្ឌិតនោះ។

៣- បទប្បញ្ញត្តិក្នុងកថាខ័ណ្ឌទី១ នឹងលែងយកមកអនុវត្ត ប្រសិនបើទណ្ឌិតនោះឋិតនៅដោយស្ម័គ្រចិត្ត លើសពី៣០ថ្ងៃលើទឹកដីរបស់រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រម បន្ទាប់ពីបានទទួលទោសទាំងស្រុងដែលបានដាក់បង្គំដោយតុលាការ ឬ ជននោះត្រឡប់ទៅដែនដីនៃរដ្ឋនោះវិញបន្ទាប់ពីខ្លួនបានចាកចេញ។

## មាត្រា ១០៩ : អំពីការដាក់ឱ្យអនុវត្តការផាកពិន័យ និង វិធានការរឹបអូស

១- គ្រប់រដ្ឋភាគីទាំងឡាយត្រូវធ្វើឱ្យមានប្រសិទ្ធភាពក្នុងការផាកពិន័យ ឬ ការរឹបអូសតាមបញ្ជាតុលាការដែលមានចែងក្នុងភាគទី៧ ដោយគ្មានអគតិចមិចំពោះសិទ្ធិរបស់តតិយជនសុច្ចរិត និង អនុលោមតាមនីតិវិធីនៃច្បាប់ជាតិ របស់ខ្លួន។

២- ប្រសិនបើរដ្ឋភាគីមួយ គ្មានលទ្ធភាពធ្វើឱ្យមានប្រសិទ្ធភាពនូវបញ្ជាក្នុងការរឹបអូស រដ្ឋនោះត្រូវចាត់វិធានស្តារឡើងវិញនូវតម្លៃនៃទ្រព្យសម្បត្តិ ឬទ្រព្យធនផ្សេងៗ ដែលត្រូវតុលាការបញ្ជាឱ្យរឹបអូស ដោយគ្មានអគតិចមិចំពោះសិទ្ធិរបស់តតិយជនសុច្ចរិត។

៣- ទ្រព្យ ឬ ចំណូលផ្សេងៗដែលបានមកពីការលក់អចលនទ្រព្យ ឬ ក្នុងករណីសមស្របចំណូលដែលបានពីការលក់ទ្រព្យផ្សេងៗដែលទទួលដោយរដ្ឋភាគីមួយ ដោយសារលទ្ធផលនៃការដាក់ឱ្យអនុវត្តរបស់ខ្លួនលើសាលក្រមរបស់តុលាការ ត្រូវផ្ទេរឱ្យតុលាការវិញ។

## មាត្រា១១០ : អំពីការត្រួតពិនិត្យដោយតុលាការលើការបន្ធូរបន្ថយទោស

១- រដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រម មិនត្រូវដោះលែងទណ្ឌិតមុនកាលផុតកំណត់នៃទោសដែលបានប្រកាសដោយតុលាការឡើយ។

២- មានតែតុលាការមួយគត់ដែលមានសិទ្ធិសំរេចក្នុងការបន្ធូរបន្ថយទោស និងត្រូវសំរេចរឿង បន្ទាប់ពីបានស្តាប់ជននោះ។

៣- នៅពេលដែលទណ្ឌិតទទួលទោសបាន ២/៣ នៃទោសទាំងមូល ឬ បាន២៥ឆ្នាំករណីទោសពន្ធនាគារមួយជីវិត តុលាការនឹងពិនិត្យឡើងវិញនូវទោស ដើម្បីកំណត់ថា តើវាគួរត្រូវបន្ធូរបន្ថយឬអត់។ ការត្រួតពិនិត្យនេះមិនត្រូវធ្វើឡើងមុនពេលនោះទេ។

៤- ក្នុងការពិនិត្យឡើងវិញតាមកថាខ័ណ្ឌទី៣ តុលាការអាចបន្ធូរបន្ថយទោស កាលណាបើតុលាការរកឃើញថា មានកត្តាមួយ ឬច្រើនក្នុងចំណោមកត្តាទាំងឡាយ ដូចមានរាយខាងក្រោមនេះ :

(ក) ការស្ម័គ្រចិត្តតាំងពីដើម និង បន្តជាប់ជានិច្ចរបស់ជននោះ ដើម្បីរួមសហការជាមួយតុលាការក្នុងការស៊ើបអង្កេត និង ការនាំខ្លួនយកទៅជំនុំជំរះរបស់តុលាការ ។

(ខ) ជំនួយដោយស្ម័គ្រចិត្តរបស់ជននោះក្នុងការផ្តល់លទ្ធភាពដល់ការដាក់ឱ្យអនុវត្តសាលក្រម និង ដីកា របស់តុលាការក្នុងករណីផ្សេងៗទៀត ជាពិសេសផ្តល់ជំនួយក្នុងការស្វែងរកទ្រព្យធនទាំងឡាយតាមដីកាជាកពិន័យ ដីការឹបអូស ឬ ដីកាឱ្យជូសជុលការខូចខាតដែលអាចប្រើជាប្រយោជន៍សំរាប់ជនរងគ្រោះ ឬ

(គ) កត្តាផ្សេងៗទៀតដែលបង្កើតឱ្យមានការផ្លាស់ប្តូរដ៏សំខាន់និងច្បាស់លាស់នូវកាលៈទេសៈដែលសមល្មមដើម្បីធ្វើយុត្តិកម្មក្នុងការបន្ធូរបន្ថយទោស ដូចមានចែងក្នុងវិធាននៃនីតិវិធីនិងភស្តុតាង ។

៥- ប្រសិនបើតុលាការកំណត់ក្នុងការពិនិត្យឡើងជាដំបូងរបស់ខ្លួន តាមកថាខ័ណ្ឌទី៣ ថាវាមិនសមស្របនឹងបន្ធូរបន្ថយទោសទេនោះ ក្រោយមក តុលាការត្រូវពិនិត្យឡើងវិញលើចំណោទបញ្ហានៃការបន្ធូរបន្ថយទោស នៅចន្លោះពេលនោះដែលត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាននៃនីតិវិធីនិងភស្តុតាង ។

## មាត្រា១១១ : អំពីការគេចខ្លួន

ប្រសិនបើពិរុទ្ធជន រត់គេចខ្លួនពីមន្ទីរឃុំឃាំង និងភៀសខ្លួនចេញពីរដ្ឋដែលដាក់ឱ្យអនុវត្តសាលក្រម នោះបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយតុលាការ រដ្ឋនោះអាចស្នើសុំឱ្យមានការប្រគល់ខ្លួនជននោះពីរដ្ឋដែលជននោះស្ថិតនៅ ដោយយោងតាមកិច្ចព្រមព្រៀងទ្វេរភាគី ឬ ពហុភាគីដែលមានជាធរមាន ឬក៏ ស្នើទៅតុលាការឱ្យស្វែងរកការប្រគល់ខ្លួនជននោះ ។ តុលាការអាចបញ្ជាឱ្យបញ្ជូនខ្លួនជននោះទៅកាន់រដ្ឋដែលជននោះបានកំពុងទទួលទោស ឬ ក៏រដ្ឋផ្សេងទៀតដែលកំណត់ដោយតុលាការ ។

## ភាគទី ១១ : សន្និបាតនៃរដ្ឋជាភាគីទាំងឡាយ

### មាត្រា១១២ : អំពីសន្និបាតនៃរដ្ឋភាគី

១- តាមរយៈច្បាប់លក្ខន្តិកៈនេះ សន្និបាតមួយនៃរដ្ឋភាគី ត្រូវបានបង្កើតឡើង។ រដ្ឋភាគីនីមួយៗត្រូវមានតំណាងមួយរូបដែលអាចអមដោយអ្នកចាំជំនួស និង ទីប្រឹក្សាច្រើននាក់បាន។ រដ្ឋផ្សេងទៀតដែលបានចុះហត្ថលេខាលើច្បាប់លក្ខន្តិកៈនេះ ឬ ច្បាប់ស្ថាពរ អាចធ្វើជាអ្នកសង្កេតការណ៍នៅក្នុងសន្និបាតបាន។

២- សន្និបាតត្រូវ :

(ក) ពិចារណា និង អនុម័តតាមសមស្របនូវអនុសាសន៍របស់គណកម្មាការរៀបចំ

(ខ) ប្រាប់ពីភាពខ្វះចន្លោះ(ការមើលរំលង)ក្នុងការរៀបចំចាត់ចែងដល់ ធិបតីប្រធាន ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី ទាក់ទងនឹងការងាររដ្ឋបាលរបស់តុលាការ

(គ) ពិចារណារបាយការណ៍ និង សកម្មភាពរបស់ការិយាល័យដែលបង្កើតឡើងតាមកថាខ័ណ្ឌទី៣ និង ចាត់វិធានការសមស្រប

(ឃ) ពិចារណា និង សំរេចពីថវិការបស់តុលាការ

(ង) សំរេច ថាតើត្រូវកែប្រែចំនួនចៅក្រម ឬអត់ ដោយយោងតាមមាត្រា៣៦

(ច) តាមកថាខ័ណ្ឌទី៥ និងទី៧ នៃមាត្រា៨៧ ពិចារណាចំណោទបញ្ហាផ្សេងៗដែលទាក់ទងនឹងការមិនសហប្រតិបត្តិការគ្នា

(ឆ) បំពេញតួនាទីផ្សេងៗទៀតដែលកំណត់ក្នុងច្បាប់លក្ខន្តិកៈ និង វិធាននៃនីតិវិធីនិងភស្តុតាង

៣- (ក) សន្និបាតត្រូវមានការិយាល័យមួយដែលមានសមាសភាព ប្រធានមួយរូប អនុប្រធានពីររូប និង សមាជិក១៨រូប ដែលត្រូវបោះឆ្នោតជ្រើសរើសឡើងដោយសន្និបាតសំរាប់អាណត្តិ៣ឆ្នាំ។

(ខ) ការិយាល័យនេះត្រូវមានចរិកលក្ខណៈជាតំណាងដែលពិចារណាជាពិសេសលើការបែងចែកតាមភូមិភាគស្មើៗគ្នា និង ការតំណាងគ្រប់គ្រាន់ឱ្យប្រព័ន្ធច្បាប់ជាគោលរបស់ពិភពលោក។

(គ) ការិយាល័យនេះត្រូវអាចប្រជុំជាញឹកញាប់បានតាមការចាំបាច់ តែយ៉ាងតិចមួយម្តងក្នុងមួយឆ្នាំ។ ការិយាល័យនេះត្រូវជួយសន្និបាតនៅក្នុងបំពេញកិច្ចការនៃការទទួលខុសត្រូវរបស់ខ្លួន។

៤- សន្និបាតអាចបង្កើតអង្គភាពបុត្រសម្ព័ន្ធ តាមការចាំបាច់ រួមទាំងយន្តការត្រួតពិនិត្យឯករាជ្យមួយសំរាប់ធ្វើអធិការកិច្ច ការវាយតំលៃ និង ការស៊ើបអង្កេតរបស់តុលាការ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និង សេដ្ឋកិច្ចរបស់ខ្លួន។

៥- ប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ឬ អ្នកតំណាងរបស់ពួកគេ តាមការសមស្រប អាចចូលរួមកិច្ចប្រជុំនានារបស់សន្និបាត និង របស់ការិយាល័យបាន។

៦- សន្និបាតត្រូវប្រជុំនៅឯអាសនៈរបស់តុលាការ ឬទីបញ្ជាការរបស់អង្គការសហប្រជាជាតិម្តងក្នុងមួយឆ្នាំ ហើយពេលមានកាលៈទេសៈតម្រូវ ត្រូវបើកសម័យប្រជុំពិសេស។ លើកលែងតែមានការចែងផ្សេងពីនេះ នៅក្នុងច្បាប់លក្ខន្តិកៈនេះ សម័យប្រជុំពិសេសត្រូវកោះប្រជុំដោយការិយាល័យ តាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬ តាមការស្នើសុំរបស់រដ្ឋភាគីចំនួន ១/៣ នៃរដ្ឋភាគីទាំងអស់។

៧- រដ្ឋភាគីនីមួយៗត្រូវមានមួយសំលេង។ រាល់ការខំប្រឹងប្រែងត្រូវធ្វើឡើងដើម្បីឈានទៅដល់ការសំរេចបាននូវសេចក្តីសំរេចមួយដោយមតិឯកច្ឆន្ទនៅក្នុងសន្និបាត និង ការិយាល័យ។ ប្រសិនបើគ្មានមតិឯកច្ឆន្ទ លើកលែងតែ មានការចែងផ្សេងពីនេះនៅក្នុងច្បាប់លក្ខន្តិកៈនេះ:

(ក) សេចក្តីសំរេចលើបញ្ហាជាសារវន្ត ត្រូវមានការយល់ព្រមដោយមតិភាគច្រើន ២/៣ នៃអ្នកមានវត្តមាន និង បោះឆ្នោត នៅក្នុងលក្ខខ័ណ្ឌដែលចំនួនមតិភាគច្រើនដាច់ខាតនៃរដ្ឋភាគីទាំងឡាយបង្កើតកូរ៉ុមសំរាប់ការបោះឆ្នោតនេះ។

(ខ) សេចក្តីសំរេចលើបញ្ហាជានីតិវិធីត្រូវធ្វើឡើងដោយមតិភាគច្រើនសាមញ្ញនៃរដ្ឋភាគីទាំងឡាយដែលមានវត្តមាន និង បោះឆ្នោត។

៨- រដ្ឋភាគីមួយដែលខកខានមិនបានបង់ប្រាក់ភាគទានហិរញ្ញវត្ថុសំរាប់សោហ៊ុយចំណាយរបស់តុលាការទាន់ពេលកំណត់ គ្មានសំលេងឆ្នោតនៅក្នុងសន្និបាតនិងការិយាល័យទេ ប្រសិនបើចំនួនទឹកប្រាក់ដែលខកខានមិនបានបង់នោះ ស្មើឬលើស ចំនួនទឹកប្រាក់ភាគទានដែលរដ្ឋនោះត្រូវបង់ក្នុងរយៈពេល២ឆ្នាំពេញមុន

នេះ។ ទោះបីជាយ៉ាងណាក៏ដោយ សន្និបាតអាចអនុញ្ញាតឱ្យរដ្ឋភាគីនោះបោះឆ្នោតនៅក្នុងសន្និបាតនិងការិយាល័យ ប្រសិនបើ សន្និបាត ពេញចិត្តថាការខកខានក្នុងការបង់ភាគទានដោយសារកត្តាដែលហួសពីលទ្ធភាពគ្រប់គ្រងរបស់រដ្ឋភាគីនោះ ។

៩- សន្និបាតអនុម័តវិធាននៃនីតិវិធីផ្ទាល់របស់ខ្លួន ។

១០- ភាសាប្រើប្រាស់ និងភាសាផ្លូវការរបស់សន្និបាត គឺភាសាដែលប្រើប្រាស់នៅក្នុងមហាសន្និបាតនៃអង្គការសហប្រជាជាតិ ។

## ភាគទី ១២ : អំពីហិរញ្ញកិច្ច

### មាត្រា១១៣ : អំពីបទបញ្ញាហិរញ្ញវត្ថុ

លើកលែងតែមានការចែងជាពិសេសផ្សេងពីនេះ រាល់បញ្ហាហិរញ្ញវត្ថុដែលទាក់ទងនឹងតុលាការនិងកិច្ចប្រជុំរបស់សន្និបាតនៃរដ្ឋភាគីទាំងឡាយ រួមទាំងការិយាល័យ និង អង្គភាពបុត្រសម្ព័ន្ធរបស់វាផងត្រូវគ្រប់គ្រងដោយច្បាប់លក្ខន្តិកៈនេះ និងបទបញ្ញាហិរញ្ញវត្ថុ និង វិធានដែលអនុម័តដោយសន្និបាតនៃរដ្ឋភាគីទាំងឡាយ ។

### មាត្រា១១៤ : អំពីការបង់ថ្លៃចំណាយ

ថ្លៃចំណាយទាំងអស់របស់តុលាការ និងរបស់សន្និបាតនៃរដ្ឋភាគីទាំងឡាយ រួមទាំងរបស់អង្គភាពបុត្រសម្ព័ន្ធ ត្រូវបង់ដោយមូលនិធិរបស់តុលាការ ។

### មាត្រា១១៥ : អំពីមូលនិធិរបស់តុលាការ និងរបស់សន្និបាតនៃរដ្ឋភាគីទាំងឡាយ

ថ្លៃចំណាយទាំងអស់របស់តុលាការនិងរបស់សន្និបាតនៃរដ្ឋភាគីទាំងឡាយ រួមទាំងរបស់អង្គភាពបុត្រសម្ព័ន្ធ ដូចមាននៅក្នុងថវិកាដែលសំរេចដោយសន្និបាតនៃរដ្ឋភាគីទាំងឡាយនោះ បានមកពីប្រភពផ្សេង១ដូចខាង ក្រោម :

(ក) ភាគទានចាំន់ស្មានដែលបង់ដោយរដ្ឋភាគីទាំងឡាយ

(ខ) មូលនិធិបានមកពីអង្គការសហប្រជាជាតិ ក្រោមការអនុម័តយល់ព្រមរបស់មហាសន្និបាត ជាពិសេសទាក់ទងនឹងថ្លៃចំណាយដែលកើតមានឡើងដោយការដាក់ករណីជូនតុលាការរបស់ក្រុមប្រឹក្សាសន្តិសុខ។

### មាត្រា១១៦ : អំពីភាគទានស្ម័គ្រចិត្ត

ដោយគ្មានអគតិចំពោះមាត្រា១១៥ តុលាការអាចទទួល និង ប្រើប្រាស់ជាមូលនិធិបន្ថែមនូវភាគទានស្ម័គ្រចិត្តដែលបានពីរដ្ឋាភិបាលនានា អង្គការអន្តរជាតិ រូបវន្តបុគ្គល សាជីវកម្ម និងអង្គភាពនានា ដោយស្របតាម លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធដែលត្រូវបានអនុម័តដោយសន្និបាតនៃរដ្ឋភាគីទាំងឡាយ។

### មាត្រា១១៧ : អំពីការប៉ាន់ស្មានប្រាក់ភាគទាន

ភាគទានរបស់រដ្ឋភាគីទាំងឡាយ ត្រូវប៉ាន់ស្មានដោយអនុលោមទៅតាមមាត្រដ្ឋាននៃការប៉ាន់ប្រមាណដែលបានព្រមព្រៀង ផ្អែកតាមមាត្រដ្ឋានដែលអនុម័តដោយអង្គការសហប្រជាជាតិសំរាប់ថវិកាទៀងទាត់របស់ខ្លួន និងកែសំរួល ដោយអនុលោមទៅតាមគោលការណ៍ដែលមាត្រដ្ឋានបានផ្អែកលើ។

### មាត្រា១១៨ : អំពីសវនកម្មប្រចាំឆ្នាំ

បញ្ជី សៀវភៅ និងគណនេយ្យទាំងអស់របស់តុលាការ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនផងត្រូវធ្វើសវនកម្មជាទៀងរាល់ឆ្នាំ ដោយសវនករឯករាជ្យម្នាក់។

## ភាគទី ១៣ : អវសានបញ្ញត្តិ

### មាត្រា១១៩ : អំពីដំណោះស្រាយវិវាទ

១- វិវាទទាំងឡាយណាដែលទាក់ទងនឹងតួនាទីយុត្តិធម៌នៃតុលាការ ត្រូវដោះស្រាយដោយសេចក្តីសំរេចរបស់តុលាការ។

២- វិវាទផ្សេងទៀតរវាងរដ្ឋភាគីពីរ ឬ ច្រើនដែលទាក់ទងនឹងការបកស្រាយឬការអនុវត្តន៍ច្បាប់លក្ខន្តិកៈនេះ មិនអាចដោះស្រាយតាមការចរចារបានក្នុងរយៈពេលបីខែនៃការចាប់ផ្តើមកើតវិវាទនោះ ត្រូវដាក់ជូនសន្និបាតនៃរដ្ឋភាគី។ សន្និបាតអាចស្វែងរកដំណោះវិវាទដោយខ្លួនឯង ឬ ធ្វើអនុសាសន៍លើមធ្យោបាយ

បន្តសំរាប់ការដោះស្រាយវិវាទនោះ រួមទាំងការដាក់ជូនទៅតុលាការយុត្តិធម៌អន្តរជាតិ(ICJ) ដោយអនុលោមតាមច្បាប់លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ។

## មាត្រា១២០ : អំពីការបំរុងទុក (Reservation)

គ្មានការបំរុងទុកណាមួយអាចធ្វើឡើងចំពោះច្បាប់លក្ខន្តិកៈនេះបានទេ ។

## មាត្រា១២១ : អំពីវិសោធនកម្ម

១- រដ្ឋភាគីទាំងឡាយអាចស្នើសុំធ្វើវិសោធនកម្មច្បាប់លក្ខន្តិកៈនេះបាន បន្ទាប់ពីផុតកំណត់៧ឆ្នាំក្រោយពីការចូលជាធរមាននៃច្បាប់លក្ខន្តិកៈនេះ ។ អត្ថបទស្នើសុំធ្វើវិសោធនកម្មត្រូវដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិដែលជាអ្នកត្រូវបញ្ជូនចែកចាយអត្ថបទនោះទៅគ្រប់រដ្ឋភាគីទាំងអស់យ៉ាងរួសរាន់ ។

២- ក្នុងរយៈមិនតិចជាង៣ខែចាប់ពីថ្ងៃជូនដំណឹង សន្និបាតនៃរដ្ឋភាគីលើកក្រោយត្រូវសំរេចថា តើទទួលយកសំណើសុំធ្វើវិសោធនកម្មនោះឬអត់ តាមមតិភាគច្រើននៃអ្នកមានវត្តមាននិងបោះឆ្នោត ។ សន្និបាតអាចចាត់ការលើសំណើដោយផ្ទាល់ ឬ អាចកោះប្រជុំសន្និសិទត្រួតពិនិត្យមួយ ប្រសិនបើបញ្ហាដែលពាក់ព័ន្ធនោះតម្រូវឱ្យធ្វើ ។

៣- ការអនុម័តលើសំណើសុំធ្វើវិសោធនកម្ម នៅឯសម័យប្រជុំសន្និបាតនៃរដ្ឋភាគី ឬ នៅក្នុងសន្និសិទត្រួតពិនិត្យ ដែលគ្មានមតិឯកឆន្ទទេនោះត្រូវសំរេចតាមមតិភាគច្រើន ២/៣ នៃរដ្ឋភាគីទាំងអស់ ។

៤- លើកលែងករណីដូចមានចែងក្នុងកថាខ័ណ្ឌទី៥ វិសោធនកម្មនឹងចូលជាធរមានចំពោះគ្រប់រដ្ឋភាគីទាំងអស់ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីឧបករណ៍នៃការផ្តល់សច្ចាប័ន ឬ នៃការទទួលយក បានតំកល់ទុកជាមួយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិដោយរដ្ឋភាគី ៧/៨ នៃរដ្ឋភាគីទាំងអស់ ។

៥- វិសោធនកម្មលើមាត្រា៥នៃច្បាប់លក្ខន្តិកៈនេះនឹងចូលជាធរមានសំរាប់រដ្ឋភាគីទាំងឡាយណាដែលបានទទួលយកវិសោធនកម្មនេះមួយឆ្នាំបន្ទាប់ពីបានតំកល់ទុកនូវឧបករណ៍នៃការផ្តល់សច្ចាប័នឬនៃការទទួលយក ។ សំរាប់រដ្ឋ ដែលមិនទទួលយកវិសោធនកម្មនេះ តុលាការមិនអនុវត្តយុត្តាធិការរបស់ខ្លួនលើបទល្មើសព្រហ្មទណ្ឌ ដែលគ្របដណ្តប់ដោយមាត្រាដែលធ្វើវិសោធនកម្មនោះទេ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្តដោយពលរដ្ឋនៃរដ្ឋភាគីនោះ ឬ នៅលើដែនដីនៃរដ្ឋនោះ ។

៦- ប្រសិនបើវិសោធនកម្មនោះទទួលយកដោយរដ្ឋចំនួន ៧/៨នៃរដ្ឋភាគីទាំងអស់នោះ ដោយអនុលោមទៅតាមកថាខ័ណ្ឌទី៤ រដ្ឋជាភាគីណាដែលមិនទទួលយកវិសោធនកម្មនេះអាចដកខ្លួនចេញពីច្បាប់លក្ខន្តិកៈនេះភ្លាម ទោះជាមានកថាខ័ណ្ឌទី១នៃមាត្រា១២៧ក៏ដោយ តែជាកម្មវត្ថុនៃកថាខ័ណ្ឌទី២នៃមាត្រា១២៧ ដោយការផ្តល់នូវការជូនដំណឹងមិនយឺតជាងមួយឆ្នាំបន្ទាប់ពីការចូលជាធរមាននៃវិសោធនកម្មនោះ។

៧- អគ្គលេខាធិការនៃអង្គការសហប្រជាជាតិបញ្ជូនចែកចាយទៅគ្រប់រដ្ឋភាគីទាំងអស់ នូវវិសោធនកម្មដែលត្រូវបានអនុម័ត នៅក្នុងសន្និបាតនៃរដ្ឋភាគី ឬ នៅក្នុងសន្និសិទត្រួតពិនិត្យមួយ។

## មាត្រា១២២ : អំពីការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិដែលមានលក្ខណៈជាស្ថាប័ន

១- ការធ្វើវិសោធនកម្ម បទបញ្ញតិនៃច្បាប់លក្ខន្តិកៈនេះដែលមានលក្ខណៈជាស្ថាប័នសុទ្ធសាធ ដូចជា. មាត្រា៣៥. កថាខ័ណ្ឌទី៨និងទី៩នៃមាត្រា៣៦. មាត្រា៣៧. មាត្រា៣៨. មាត្រា៣៩. កថាខ័ណទី១ (២ឃ្លាដំបូង) ទី២ និងទី៤ នៃមាត្រា៤២. កថាខ័ណ្ឌទី៤ដល់ទី៩នៃមាត្រា៤៣. កថាខ័ណ្ឌទី២ និងទី៣ នៃមាត្រា៤៤. មាត្រា ៤៦. ៤៧ និង៤៩ អាចត្រូវបានស្នើគ្រប់ពេលដោយ រដ្ឋភាគីណាមួយ ថ្វីបើមានកថាខ័ណ្ឌទី១នៃមាត្រា១២១ ក៏ដោយ។ អត្ថបទស្នើសុំធ្វើវិសោធនកម្មត្រូវដាក់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ឬ បុគ្គលផ្សេងទៀតដែលកំណត់ដោយសន្និបាតនៃរដ្ឋភាគីដែលជាអ្នកបញ្ជូនចែកចាយអត្ថបទនោះទៅកាន់គ្រប់រដ្ឋភាគីទាំងអស់ និងអ្នកចូលរួមផ្សេងទៀតនៅក្នុងសន្និបាតយ៉ាងរួសរាន់។

២- វិសោធនកម្មតាមមាត្រានេះ បើគ្មានមតិឯកច្ឆន្ទទាំងអស់ទេ នោះត្រូវអនុម័តដោយសន្និបាតនៃរដ្ឋភាគីទាំងអស់ ឬ ដោយសន្និសិទត្រួតពិនិត្យមួយ សំរេចតាមមតិភាគច្រើន ២/៣ នៃរដ្ឋភាគីទាំងអស់។ វិសោធនកម្មទាំងឡាយ នោះនឹងចូលជាធរមានសំរាប់គ្រប់រដ្ឋទាំងអស់ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ការអនុម័តដោយសន្និបាត ឬ តាមករណីជាក់ស្តែងដោយសន្និសិទត្រួតពិនិត្យមួយ។

## មាត្រា១២៣ : អំពីការត្រួតពិនិត្យច្បាប់លក្ខន្តិកៈឡើងវិញ

១- ក្នុងរយៈពេលប្រាំពីរឆ្នាំបន្ទាប់ពីការចូលជាធរមាននៃច្បាប់លក្ខន្តិកៈនេះ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវកោះប្រជុំសន្និសិទត្រួតពិនិត្យមួយ ដើម្បីពិចារណាលើការធ្វើវិសោធនកម្មណាមួយលើ

ច្បាប់លក្ខន្តិកៈនេះ។ ការត្រួតពិនិត្យឡើងវិញនេះ អាចរួមបញ្ចូលទាំងបញ្ជីរាយឈ្មោះបទល្មើសព្រហ្មទណ្ឌដែលមានក្នុងមាត្រា៥ តែមិនកំរិតដែនកំណត់ត្រឹមនេះទេ។ សន្និសិទនេះត្រូវបើកឱ្យមានការចូលរួមដោយអ្នកដែលចូលរួមនៅក្នុងសន្និបាតនៃរដ្ឋជាភាគីទាំងអស់ ហើយក្នុងលក្ខខ័ណ្ឌដូចគ្នា។

២- ក្រោយមក នៅពេលណាក៏ដោយ តាមសំណើរបស់រដ្ឋភាគីមួយ និង សំរាប់គោលបំណងដែលកំណត់ក្នុងកថាខ័ណ្ឌទី១ អគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ តាមការអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីទាំងអស់ ត្រូវកោះប្រជុំសន្និសិទត្រួតពិនិត្យមួយ។

៣- បទប្បញ្ញត្តិ កថាខ័ណ្ឌទី៣ដល់ទី៧នៃមាត្រា១២១ ត្រូវអនុវត្តចំពោះការអនុម័ត និង ការចូលជាធរមាននៃវិសោធនកម្មទាំងឡាយលើច្បាប់លក្ខន្តិកៈនេះដែលត្រូវបានពិចារណានៅឯសន្និសិទត្រួតពិនិត្យមួយ។

## មាត្រា១២៤ : អំពីអន្តរប្បញ្ញត្តិ

ថ្វីបើមានកថាខ័ណ្ឌទី១នៃមាត្រា១២ រដ្ឋមួយនៅពេលក្លាយជាភាគីមួយនៅក្នុងច្បាប់លក្ខន្តិកៈនេះ ក្នុងរយៈពេល៧ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃច្បាប់លក្ខន្តិកៈនេះចំពោះរដ្ឋនោះ អាចប្រកាសថាខ្លួនមិនទទួលយកយុត្តាធិការរបស់តុលាការចំពោះប្រភេទនៃបទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា៨ នៅពេលបទល្មើសព្រហ្មទណ្ឌមួយត្រូវបានចោទថាត្រូវបានប្រព្រឹត្តិដោយពលរដ្ឋរបស់ខ្លួន ឬ នៅលើទឹកដីរបស់ខ្លួននោះ។ ការប្រកាសតាមមាត្រានេះ អាចដកចេញវិញនៅពេលណាក៏បាន។ បទប្បញ្ញត្តិនៃមាត្រានេះត្រូវត្រួតពិនិត្យឡើងវិញនៅក្នុងសន្និសិទត្រួតពិនិត្យមួយដែលកោះប្រជុំតាម កថាខ័ណ្ឌទី១ នៃមាត្រា១២៣។

## មាត្រា១២៥ : អំពីការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការយល់ព្រមចូលជាសមាជិក

១- ច្បាប់លក្ខន្តិកៈនេះនឹងត្រូវបើកចំហរទុកឱ្យគ្រប់រដ្ឋទាំងអស់ចុះហត្ថលេខានៅទីក្រុងរ៉ូម នៅឯទីបញ្ជាការដ្ឋាននៃអង្គការម្ហូបអាហារនិងកសិកម្ម នៃអង្គការសហប្រជាជាតិ នៅថ្ងៃទី១៧ កក្កដា ១៩៩៨។ បន្ទាប់ពីពេលនោះមក ច្បាប់លក្ខន្តិកៈនេះនៅតែបើកចំហរសំរាប់ការចុះហត្ថលេខានៅទីក្រុងរ៉ូម នាក្រសួងការបរទេសរបស់អ៊ីតាលីរហូតដល់ថ្ងៃ១៧ តុលា ១៩៩៨។ បន្ទាប់ពីកាលបរិច្ឆេទនោះ ច្បាប់លក្ខន្តិកៈ

នេះនៅតែបើកចំហរសំរាប់ការចុះហត្ថលេខានៅទីក្រុងញ៉ូយ៉ក នាទីបញ្ជាការរបស់អង្គការសហប្រជាជាតិ រហូតដល់ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០០០។

២- ច្បាប់លក្ខន្តិកៈនេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តពីរដ្ឋហត្ថលេខីទាំងអស់។ ឧបករណ៍នៃការផ្តល់សច្ចាប័ន នៃការទទួលយក ឬ នៃការអនុម័ត ត្រូវតំកល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៣- ច្បាប់លក្ខន្តិកៈនេះបើកចំហរទទួលការយល់ព្រមចូលជាសមាជិកពីគ្រប់រដ្ឋទាំងអស់។ ឧបករណ៍នៃការយល់ព្រមចូលជាសមាជិកត្រូវតំកល់ទុកនៅជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា១២៦ : អំពីការចូលជាធរមាន

១- ច្បាប់លក្ខន្តិកៈនេះ ត្រូវចូលជាធរមាននៅថ្ងៃទី១នៃខែបន្ទាប់ពីថ្ងៃទី៦០ក្រោយកាលបរិច្ឆេទនៃថ្ងៃតំកល់ទុកឧបករណ៍នៃការផ្តល់សច្ចាប័ន នៃការទទួលយក នៃការអនុម័ត ឬនៃការយល់ព្រមចូលជាសមាជិក នៅជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២- រដ្ឋនីមួយៗដែលបានផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬយល់ព្រមចូលជាសមាជិកនៃច្បាប់លក្ខន្តិកៈនេះ បន្ទាប់ពីតំកល់ទុក៦០ថ្ងៃនូវឧបករណ៍នៃការផ្តល់សច្ចាប័ន នៃការទទួលយក នៃការអនុម័ត ឬនៃការយល់ព្រមចូលជាសមាជិក ច្បាប់លក្ខន្តិកៈនេះនឹងចូលជាធរមាននៅថ្ងៃទី១នៃខែ បន្ទាប់ពីថ្ងៃទី៦០ក្រោយកាលបរិច្ឆេទនៃថ្ងៃតំកល់ទុកឧបករណ៍នៃការផ្តល់សច្ចាប័ន នៃការទទួលស្គាល់ នៃការអនុម័ត ឬ នៃការយល់ព្រមចូលជាសមាជិក។

## មាត្រា១២៧ : អំពីការដកខ្លួនចេញ

១- រដ្ឋភាគីមួយដោយជូនដំណឹងជាលាយលក្ខ័អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ អាចដកខ្លួនចេញពីច្បាប់លក្ខន្តិកៈនេះបាន។ ការដកខ្លួនចេញនេះមានប្រសិទ្ធភាពក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីថ្ងៃទទួលបានការជូនដំណឹងនោះ លើកលែងតែការជូនដំណឹងនោះមានបញ្ជាក់កាលបរិច្ឆេទដែលយូរជាងរយៈពេលមួយឆ្នាំ។

២. រដ្ឋភាគីមួយនឹងមិនរួចបន្ទុកដោយសារមូលហេតុនៃការដកខ្លួន ចំពោះកាតព្វកិច្ចដែលកើតចេញពីច្បាប់លក្ខន្តិកៈនេះ នៅក្នុងកំឡុងពេលដែលខ្លួនជាភាគីនៃច្បាប់លក្ខន្តិកៈ នោះទេ រួមទាំងកាតព្វកិច្ចខាងហិរញ្ញ

វត្ថុដែលអាចមាននៅជំពាក់។ ការដកខ្លួនរបស់រដ្ឋនោះគ្មានឥទ្ធិពលលើសហប្រតិបត្តិការនានាជាមួយនឹងតុលាការក្នុងទំនាក់ទំនងរឿងស៊ើបអង្កេតព្រហ្មទណ្ឌ និង ដំណើរការជំរះរឿងក្តីនានាទាក់ទងនឹងរដ្ឋដែលដកខ្លួនមានកាតព្វកិច្ចត្រូវសហប្រតិបត្តិការ និង ដែលបានចាប់ផ្តើមឡើងនៅមុនកាលបរិច្ឆេទនៃការដកខ្លួននោះមានប្រសិទ្ធភាព ឬ វាមិនមានអគតិធមិតាមបែបណាមួយចំពោះការពិចារណាជាបន្តលើបញ្ហាណាមួយដែលឋិតក្រោមការពិចារណាដោយតុលាការរួចជាស្រេច នៅមុនកាលបរិច្ឆេទនៃការដកខ្លួនមានប្រសិទ្ធភាព។

## មាត្រា១២៨ : អំពីអត្ថបទយថាភូត

ច្បាប់ដើមនៃច្បាប់លក្ខន្តិកៈនេះដែលមានជាភាសាអារ៉ាប់, ភាសាចិន, ភាសាអង់គ្លេស, ភាសាបារាំង, ភាសារុស្ស៊ី និង ភាសាអេស្ប៉ាញដែលមានតំលៃស្មើគ្នាជាយថាភូត ត្រូវតំកល់ទុកនៅជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលជាអ្នកត្រូវបញ្ជូនចែកចាយច្បាប់ថតចំលងដែលមានបញ្ជាក់ថាថតចំលងតាមច្បាប់ដើមទៅគ្រប់រដ្ឋភាគីទាំងអស់។

ដោយមានវត្តមានសាក្សី អ្នកដែលចុះហត្ថលេខាខាងក្រោមនេះដែលបានទទួលការអនុញ្ញាតយ៉ាងពេញលេញដោយរដ្ឋាភិបាលរបស់ពួកគេ បានចុះហត្ថលេខាលើច្បាប់លក្ខន្តិកៈនេះ។

ធ្វើនៅទីក្រុងរ៉ូម ថ្ងៃទី១៧ កក្កដា ១៩៩៨